ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍
- សម្ភាសការពីរនាក់ប្រជាជនកម្ពុជា

[illegible]

លេខ១ ខែមករា ឆ្នាំ២០០០

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១ ខែមករា ឆ្នាំ២០០០



## មាតិកា

- សំបុត្រៈ ដើម្បីស្វែងរកការពិត.............................. ១
- អំពីទស្សនាវដ្ដីស្វែងរកការពិត.............................. ៥

**ផ្នែកឯកសារ**

- ឯកសារខ្មែរក្រហម.............................................. ៦
- ការថែរក្សាភស្តុតាងជាក់ស្តែងមានសារៈសំខាន់ជាចាំបាច់.... ៧
- ចម្លើយសារភាពរបស់ សាន់ ប៊ូ.............................. ១២
- វត្តបារាយណ៍ជាន់ដែកក្រោមរបបកម្ពុជាប្រជាធិបតេយ្យ..... ១៤
- ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ.............................. ១៧
- ជនជាតិចាមនៅគុកទួលស្លែង.................................. ១៨
- ចម្លើយសារភាពរបស់ ធូ ហៃ.................................២០
- តើ ទីវ ម៉ី ចូលបំរើចលនាតស៊ូ.............................២៣
- ការស្រាវជ្រាវ និងធ្វើផែនទីរណ្ដៅខ្មោចក្រិដ្ឋកម្ម................២៩

**ផ្នែកប្រវត្តិសាស្ត្រ**

- សម្លេងពីមន្ទីរ ស-២១........................................ ៣១
- គ្រោះថ្នាក់នៃអព្យាក្រិត........................................ ៣២
- គំរូមួយនៃភស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់............ ៣៤

**ផ្នែកច្បាប់**

- ការស្វែងយល់អំពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍.... ៤០
- «សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ».............................. ៤៤
- គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា................ ៤៧

**វេទិកាពិភាក្សាជាសាធារណៈ**

- អ្វីទៅជាការពិត? ................................................ ៥០
- មរតកខ្មែរក្រហម................................................ ៥៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- បងស្រីខ្ញុំ និងផ្ញើមកពូរបស់ខ្ញុំ.................................. ៦៦

**ទស្សនៈ និងសិល្បៈខ្មែរក្រហមៈ** ចម្រៀងខ្មែរក្រហម

- ឆ្នាំថ្មីស្រែថ្មី.......................................................
- រូបភាព..................................................ក្របក្រោយ

រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាន

នៃរាជរដ្ឋាភិបាលកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី

ក្រសួងព័ត៌មាន លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩





**វាគ្មិនលេខនេះ** បណ្ឌិត គ្រេក អ៊ិចដេសាន់, សាស្ត្រាចារ្យ ដេវីត ឆេនដល័រ, មេធាវី រ៉េម៉ិន ចូរហាន់សាន់, មេធាវី ចន ឆីឆរអាវី, សាស្ត្រាចារ្យ ស៊ីវ ហេឌ័រ, សាស្ត្រាចារ្យ យៃនតុន ក្លែម័រ, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ, **ជំនួយការនិពន្ធនាយកៈ** អែម សុឃឹម, **និពន្ធនាយករងទី១ៈ** ដាត កុសល, **និពន្ធនាយករងទី២ៈ** ស៊ឹម សុរិយ៉ា, **អ្នកបកប្រែៈ** ឡាយ ពុទ្ធារ៉ា, **និពន្ធនាយកទូទៅៈ** ឆាំង យុ, **ក្រាហ្វិកកុំព្យូទ័រ និង គ្រប់គ្រងការចែកផ្សាយៈ** ស៊ឹម សុភ័ក្ត្រ, **អ្នកថតរូបៈ** ច័ន្ទ គ្រីស្នា

# សំបុត្រៈ ដើម្បីស្វែងរកការពិត





មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នស្រាវជ្រាវកម្ពុជាឯករាជ្យមួយដែលប្តូរផ្តាច់ក្នុងការចងក្រងឯកសារស្តីអំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍ប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ។ របបកម្ពុជាប្រជាធិបតេយ្យនេះត្រូវបានស្គាល់ជាទូទៅថាជារបបប្រល័យពូជសាសន៍ ឬរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់បដិសន្ធិឡើងជាផ្លូវការនៅក្នុងខែមករា ឆ្នាំ១៩៩៥ ។ មជ្ឈមណ្ឌលឯកសារកម្ពុជារហូតមកទល់បច្ចុប្បន្ននេះបានទទួលការគាំទ្រពីសំណាក់អង្គការមូលនិធិអន្តរជាតិ និងបណ្តាប្រទេសនានាចំនួន៣៩ នៃទ្វីបចំនួន៤ គឺអាមេរិក, អឺរ៉ុប, អាស៊ី និងអូសេអានី ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ការស្វែងរកយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមរយៈតុលាការឯករាជ្យមួយ គឺទាមទារឲ្យមានការចូលរួមត្រួតពិនិត្យឲ្យបានដិតដល់ពីសំណាក់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ ជាពិសេសបំផុតនោះ គឺជនរងគ្រោះដោយរបបខ្មែរក្រហម ។ ជនរងគ្រោះទាំងអស់ ត្រូវសមនឹងទទួលបាននូវតុលាការស្របច្បាប់មួយដែលអាចស្វែងរកយុត្តិធម៌បានដោយត្រឹមត្រូវ និងមិនលម្អៀង ។ ហេតុដូច្នេះ ជនរងគ្រោះទាំងអស់ត្រូវការចាំបាច់ឲ្យមានការផ្តល់ព័ត៌មានជាលម្អិតស្តីអំពីដំណើរការតុលាការ និងរឿងក្តីនានា ដោយរាប់បញ្ចូលទាំងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមទៀតផងដើម្បីផ្សារខ្លួនភ្ជាប់ទៅនឹងដំណើរការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងដើរតួនាទីជា «និរសា» ឲ្យជនរងគ្រោះពីរបបខ្មែរក្រហមលើបញ្ហាទាំងអស់ខាងលើ ។ ដើម្បីសម្រេចភារកិច្ចនេះ បានមជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅបើកយុទ្ធនាការអប់រំមួយតាមរយៈការផ្សព្វផ្សាយចំណេះដឹងអំពីនីតិវិធីតុលាការកាត់ទោសរបបខ្មែរក្រហម និងរឿងរ៉ាវប្រវត្តិសាស្ត្រនានាដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ ឯកសារទាំងអស់នោះមានតម្កល់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រមទាំងប្រភពផ្សេងៗទៀត រួមមានមហាវិទ្យាល័យច្បាប់ធំៗនៅសហរដ្ឋអាមេរិក និងអឺរ៉ុប, អង្គការក្រៅរដ្ឋាភិបាលនានា, អ្នកជំនាញការច្បាប់ និងអ្នកប្រវត្តិវិទូអំពីប្រទេសកម្ពុជាក្នុងនោះរួមមានទាំងក្រុមប្រឹក្សា និងទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងធ្វើការផ្សព្វផ្សាយជូនដល់ជនរងគ្រោះពីរបបខ្មែរក្រហមតាមរយៈទស្សនាវដ្តីមួយដែលចេញផ្សាយរៀងរាល់ខែ ។ ទស្សនាវដ្តីនេះមានឈ្មោះថា «ស្វែងរកការពិត» ដែលអស់លោកអ្នកកំពុងអាន ។ នៅក្នុងប្រទេសកម្ពុជា មានប្រភពព័ត៌មានឯករាជ្យតិចតួចស្តួចស្តើងណាស់ ។ សារព័ត៌មាន វិទ្យុ ទូរទស្សន៍ ភាគច្រើន បានសម្រេចចិត្តឈរនៅលើបញ្ហានយោបាយម្ខាងៗ ។ សូម្បីតែវិទ្យុផ្សាយសម្លេងរបស់សហរដ្ឋអាមេរិក ដែលផ្សាយជាភាសាខ្មែរក៏ត្រូវបានមជ្ឈដ្ឋានមួយចំនួនចាត់ទុកថា មាននិន្នាការនយោបាយទៅរកបក្សសម្ព័ន្ធណាមួយដែរ ។ ទស្សនាវដ្តី «ស្វែងរកការពិត» នឹងបំពេញនូវតម្រូវការដ៏សំខាន់ចាំបាច់នេះក្នុងការបង្កើតឲ្យមាននូវប្រភពផ្សព្វផ្សាយចំណេះដឹងជាភាសាខ្មែរ និង ឯករាជ្យមួយស្តីអំពីបញ្ហាតុលាការ និងប្រវត្តិសាស្ត្រខ្មែរក្រហម ។ ដើម្បីធានាឲ្យមានយុត្តិធម៌មួយត្រូវបានកើតចេញពីអង្គតុលាការឯករាជ្យ ហើយថែមទាំងត្រូវបានសាធារណជន ជាពិសេសប្រជាជនកម្ពុជាដែលរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហមបានឃើញដោយផ្ទាល់នឹងភ្នែកថា «យុត្តិធម៌» ពិតជាត្រូវបានធ្វើឡើងមែននោះ

ចាំបាច់គឺត្រូវឲ្យមានការលើកកម្ពស់នូវការយល់ដឹងជាទូទៅជាសាធារណៈអំពីនីតិវិធីច្បាប់ថាតើ នីតិវិធីនៅក្នុងតុលាការខ្មែរក្រហមត្រូវបានឆ្លើយតបពេញលេញដែរឬទេ? ។ ទស្សនាវដ្ដីស្វែងរកការពិតនឹងបំពេញតួនាទីបន្ថែមទៀតជា «អ្នកឃ្លាំមើល និងការពារ» ក្នុងដំណើរការកាត់ទោស ហើយនឹងធ្វើការកំណត់នូវកម្រិតនៃការជ្រៀតជ្រែកផ្នែកនយោបាយឲ្យបានប្រហាក់ប្រហែលនឹងសារពត៌មានខ្មែរដែលមានលក្ខណៈសេរី និងឯករាជ្យ ខ្មែរក្រហមរាប់ពាន់នាក់ ជនរងគ្រោះស្ទើរតែគ្រប់គ្នាទាំងអស់នោះបានរៀបរាប់ និងចោទសួរនូវចម្ងល់ដូចគ្នាថាតើ រឿងរ៉ាវខ្មែរក្រហមនេះបានកើតឡើងយ៉ាងដូចម្ដេច? ជាពិសេសចង់ដឹងថានរណាជាអ្នកបញ្ជាឲ្យសម្លាប់មនុស្ស និងដោយសារមូលហេតុអ្វី? ។ ការបោះពុម្ពផ្សាយដោយសច្ចភាពនូវរឿងហេតុដែលកើតឡើងនៅចំពេលដែលតុលាការខ្មែរក្រហមហៀបនឹងចាប់ដំណើរការ នឹងផ្ដល់នូវយន្ដការប្រាប់ការពិតមួយ ។ នេះគឺជាផ្នែកមួយដ៏សំខាន់



អាចធ្វើទៅបាន ។ ទោះជាក្នុងស្ថានភាពណាក៏ដោយ ការផ្ដល់ជូនពត៌មានថ្មីៗ និងការពន្យល់ជាទូទៅអំពីដំណើរការទាំងឡាយដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់តុលាការនឹងមានតម្លៃធំធេងណាស់ដល់ជនរងគ្រោះដោយរបបខ្មែរក្រហម និងសាធារណជនកម្ពុជាទាំងមូល ។ ជាការពិតណាស់មានការរែកញែកតាមផ្លូវសីលធម៌ និងផ្លូវច្បាប់ដ៏គួរឲ្យជឿជាក់មួយថា ប្រជាជនខ្មែរដែលសេសសល់ពីសេចក្ដីស្លាប់ក្នុងរបបខ្មែរក្រហម ហើយដែលធ្លាប់បានទទួលរងនូវការរំលោភសិទ្ធិយ៉ាងកម្រោល គឺមានសិទ្ធិក្នុងការយល់ដឹងនូវការពិតនៃព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើង ។ ជាក់ស្ដែង គ្រប់ពេលដែលខ្ញុំសាកសួរទៅដល់ជនរងគ្រោះពីរបប នៃការបង្រួបបង្រួមជាតិ ។ ដូចជានៅប្រទេសអាហ្វ្រិកខាងត្បូងមានធ្វើការចាក់ផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ នូវដំណើរការសវនាការមួយភាគធំរបស់គណៈកម្មាធិការបង្រួបបង្រួម និងការពិត ។ កម្ពុជាពុំមានការផ្សព្វផ្សាយពត៌មាន តាមវិទ្យុ ទូរទស្សន៍ ដែលមានលក្ខណៈឯករាជ្យពិតប្រាកដនៅឡើយទេ ម្ល៉ោះហើយដោយមូលហេតុថា មាននិន្នាការនយោបាយ សារពត៌មានទាំងនោះនឹងមិនទំនងជារៀបរាប់បកស្រាយនូវការពិតទាំងសងខាងអំពីរឿងរ៉ាវនានាដូចដែលបានកើតឡើងនោះទេ ។ ដូច្នេះហើយទើបទស្សនាវដ្ដីមួយដែលរួមចំណែកដល់ទីបញ្ចប់ អំពីដំណើរការកាត់ទោសរបបខ្មែរក្រហម គឺមិនគ្រាន់តែជួយបំពេញចន្លោះខ្វះខាត

ផ្នែកផ្សព្វផ្សាយពត៌មានតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំពេញតួនាទីពិសេសមួយទៀត គឺការព្យាបាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះទៀតផង តាមរយៈការផ្សព្វផ្សាយនូវអ្វីដែលជាការពិត ។ ភាពឯករាជ្យទាំងស្រុង និងភាពស្វ័យគ្រប់គ្រងខ្លួនឯងដោយពេញលេញព្រមទាំងលទ្ធភាពផ្សព្វផ្សាយ ចែកចាយពត៌មានជាភាសាខ្មែររបស់ទស្សនាវដ្តីស្វែងរកការពិត ទូទាំងប្រទេសកម្ពុជា គឺមានសារៈសំខាន់ធំធេងណាស់ ។ ទស្សនាវដ្តីស្វែងរកការពិតនឹងក្លាយទៅជាប្រភពពត៌មានតែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យទាំងអស់នោះ ។ មិនតែប៉ុណ្ណោះទៀតសោត ទស្សនាវដ្តីស្វែងរកការពិត ក៏អាចចុះផ្សាយនូវប្រធានបទ និងបញ្ហានានាដទៃទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រភពពត៌មានដ៏ច្រើនលើសលប់លើប្រធានបទនិងបញ្ហាទាំងអស់នោះ ប៉ុន្តែប្រហែលជាមិនឈានផ្តោះទៅរកការពាក់ព័ន្ធនឹងការកាត់ទោសរបបខ្មែរក្រហមទេ ។ ឧទាហរណ៍ ដូចជាប្រធានបទស្តីអំពីអំពើហិង្សាលើស្ត្រីភេទនៅក្រោមរបបខ្មែរក្រហម និងអំពើហិង្សាទៅលើ ជនជាតិភាគតិច និងព្រះសង្ឃជាដើម ។ល ។ ទស្សនាវដ្តីស្វែងរកការពិតនឹងអាចក្លាយទៅជាប្រភពពត៌មានមួយនៅក្នុងចំណោមប្រភពពត៌មាននានានៅក្នុងពិភពលោក ស្តីអំពីបញ្ហាអ្វីដែលសាធារណជនតែងតែមើលរំលង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមបញ្ជាក់ឲ្យអស់កង្វល់ថា ទស្សនាវដ្តីស្វែងរកការពិត នឹងក្លាយទៅជាទស្សនាវដ្តីតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលផ្សព្វផ្សាយអំពីបញ្ហានេះជាភាសាខ្មែរ ។ បណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាប្រភពឯកសារដ៏ពិសិដ្ឋនៅក្នុងប្រទេសកម្ពុជាដែលស្ថិតនៅក្នុងភាពឯករាជ្យ ។ ពត៌មានដែលចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺមានលក្ខណៈឯករាជ្យលើផ្លូវនយោបាយ ហើយមិនផ្សព្វផ្សាយដើម្បីបម្រើឲ្យផលប្រយោជន៍ ឬគោលបំណងផ្នែកនយោបាយណាមួយឡើយ ។ លើសពីនេះទៅទៀតទស្សនាវដ្តីស្វែងរកការពិតផ្ទាល់ខ្លួនឯងអាចប្រើប្រាស់ធ្វើជាឯកសារប្រវត្តិសាស្ត្រទូទៅសម្រាប់កត់ត្រាដំណើរការរបស់ប្រទេសជាតិមួយ ដែលកំពុងត្រួតពិនិត្យអតីតកាលរបស់ខ្លួនឡើងវិញ ហើយនឹងកំពុងតែបោះជំហានទៅមុខជាមួយនឹងដំណើរការ បង្រួបបង្រួមជាតិជាពិសេស គឺប្រតិកម្មដែលកំពុងលេចឡើងជាបន្តបន្ទាប់ ជុំវិញបញ្ហាកាត់ទោសរបបខ្មែរក្រហម ដែលកំពុងត្រូវបានបញ្ចូលនៅក្នុងដំណើររឿងទាំងអស់នោះ ។ ប្រជាជនកម្ពុជាគឺជាចំណាប់ខ្មាំងចំពោះអតីតកាលរបស់ខ្លួន ។ ប្រជាជនកម្ពុជាទាំងអស់មិនអាចអស់បញ្ហា និងចម្ងល់នៃភាពហ្មងសៅពីក្នុងខ្លួន ឬមានសេរីភាពពេញលេញបានទេ ដរាបណាមិនទាន់មានយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍ ។ កម្ពុជាអាចបោះជំហានទៅមុខ និងប្រែក្លាយខ្លួនទៅជាសង្គមប្រជាធិបតេយ្យរឹងមាំមួយបាន លុះត្រាណាតែប្រជាជនរបស់ខ្លួនត្រូវបានអនុញ្ញាតឲ្យយល់ដឹងការពិតអំពីអតីតកាលដ៏ភ័យរន្ធត់របស់ប្រទេសជាតិខ្លួន ។ សិស្សានុសិស្សនាបច្ចុប្បន្ននេះពុំមានការចងចាំអំពីព្រឹត្តិការណ៍សំខាន់ៗក្នុងទសវត្សរ៍ ឆ្នាំ៧០ រីឯកម្មវិធីសិក្សាផ្នែកប្រវត្តិវិជ្ជា ក្នុងទសវត្សរ៍ ឆ្នាំ៨០ទៀតសោតត្រូវបានទទួលរងនូវការរិះគន់យ៉ាងខ្លាំងដោយសារការបកស្រាយអំពីរបបខ្មែរក្រហមជាលក្ខណៈនយោបាយតែប៉ុណ្ណោះ ។ ប្រជាជនកម្ពុជាភាគច្រើនត្រូវការចម្លើយចំពោះជោគវាសនារបស់ក្រុមគ្រួសារដែលបានបាត់ខ្លួន ឬបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដើម្បីឲ្យខ្លួនបានស្ងប់នៅក្នុងចិត្ត ។ យុវវ័យកម្ពុជាជំនាន់ក្រោយ ត្រូវការយល់ដឹងអំពីអតីតកាលដែលញាំញីទៅដោយបញ្ហាស្មុគស្មាញនានារបស់ជាតិខ្លួន ប្រសិនបើយុវវ័យជំនាន់ឥឡូវ ត្រូវជំនះបានលើកេរមរតកដ៏ល្វីងជូរចត់នេះហើយកសាងអនាគតមួយប្រកបដោយសន្តិភាព តាមគន្លងលទ្ធិប្រជាធិបតេយ្យ ។ ទស្សនាវដ្តីស្វែងរកការពិតនឹងជួយនាំខ្លួនជនទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋនានានៅក្នុងរបបខ្មែរក្រហមទៅឲ្យតុលាការវិនិច្ឆ័យទោស ។ ការដាក់ទណ្ឌកម្មចំពោះជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋនានា គឺជាអំពើមួយដ៏មានអត្ថន័យ និងមហិទ្ធិឫទ្ធិខ្លាំងក្លាបំផុតដែលអាចផ្ញើជូន និងជម្រាបប្រាប់ដល់ប្រជាជាតិខ្មែរទាំងអស់ថា ខ្លួនមានសិទ្ធិសេរីភាពស្មើៗគ្នាចំពោះមុខច្បាប់នៅក្នុងសង្គមប្រជាធិបតេយ្យ ។ លទ្ធផលដ៏មានសារៈសំខាន់បំផុតនៃតុលាការខ្មែរក្រហម គឺឥទ្ធិពលរបស់តុលាការនេះទៅលើ «វប្បធម៌នៃភាពគ្មានទោស» នៅកម្ពុជា ។ បច្ចុប្បន្ននេះ

ស៊ើរតែជាទូទៅមន្ត្រីរាជការកម្ពុជាជាច្រើន ក្នុងនោះមានអ្នកនយោបាយ ប៉ូលីស និង ទាហាន ហើយសូម្បីតែប្រជាជនសាមញ្ញបានសុខចិត្តទទួលយកដោយចាត់ទុកថា វប្បធម៌នៃ «ភាពនិរទោស ឬភាពគ្មានទោស» នេះជាប្រការមួយដែលមិនអាចជៀសផុតបាន ហើយថែមទាំងបានសុខចិត្ត ទទួលយកថា «អ្នកខ្លាំងយកអ្វីៗគ្រប់យ៉ាងដែលអាចយកបាន ឯអ្នកខ្សោយទទួលរងនូវអ្វីៗគ្រប់យ៉ាងដែលត្រូវទទួលរង ហើយគ្មាននរណាម្នាក់សង្ឃឹមថា បទដ្ឋានច្បាប់នឹងចូលមកធ្វើអន្តរាគមន៍កែប្រែទម្លាប់នេះឡើយ» ។ ប៉ុន្តែការធ្វើយ៉ាងណាដើម្បីដាក់ទណ្ឌកម្មឲ្យបានលើឧក្រិដ្ឋជនសាហាវយង់ឃ្នងបំផុត នាសតវត្សរ៍ទី២០ កន្លងមកថ្មីៗនេះ ដូចជាមេដឹកនាំខ្មែរក្រហមជាដើមគឺជាមធ្យោ-បាយដ៏មានប្រសិទ្ធិភាពបំផុត ដែលតាមរយៈសកម្មភាពនេះកម្ពុជាអាចជម្រះចោលនូវវប្បធម៌នៃភាពគ្មានទោស ហើយពង្រឹងមូលដ្ឋានគ្រឹះមួយដែលមិនងាយបាក់បែកសម្រាប់សង្គមកម្ពុជាថ្មីមួយដែលកសាងឡើងផ្អែកលើបទដ្ឋានច្បាប់ ។ នេះគឺជាគន្លឹះដ៏វិសេសវិសាលក្នុងការជួយប្រទេសកម្ពុជា ឲ្យប្រែក្លាយខ្លួនទៅជានីតិរដ្ឋដ៏ពិតប្រាកដមួយ ។ គោលបំណងសំខាន់ៗរបស់ទស្សនាវដ្តីស្វែងរកការពិតមានជាអាទិ៍គឺ ទី១៖ គាំទ្រតុលាការឯករាជ្យមួយដើម្បីធ្វើការវិនិច្ឆ័យលើបទឧក្រិដ្ឋនានា ដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥-១៩៧៩ និងលើសពីនេះទៀតគឺដើម្បីអប់រំ និងរួមចំណែកដល់ការស្តាបនាមូលដ្ឋានច្បាប់នៅក្នុងប្រទេសកម្ពុជា ។ ទី២៖ ជំរុញឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីៈ ក-នីតិវិធីនៃដំណើរការរបស់តុលាការខ្មែរក្រហមនិង ខ-ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមដោយផ្អែកលើឯកសារដើមដែលមានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាប័ននានា ។ ទី៣៖ បំពេញនាទីជាវេទិកាមួយសម្រាប់ការជជែកវែកញែកស្តីអំពីដំណើរការរបស់តុលាការ និងប្រវត្តិសាស្ត្រខ្មែរក្រហម និង ទី៤៖ បំពេញនាទីជាប្រភពផ្តល់ព័ត៌មានសម្រាប់ប្រជាជាតិកម្ពុជាដើម្បីឲ្យបានយល់ដឹង និងបានជជែកវែកញែកនូវអ្វីដែលកំពុងកើតឡើង ឬមិនបានកើតឡើងជាលក្ខណៈអន្តរជាតិឧទាហរណ៍ៈ លក្ខន្តិកៈទីក្រុងរ៉ូម រឿងក្តីពីណូជេ អតីតមេដឹកនាំនៅប្រទេសឈីលី ឬ ក៏រឿងក្តីមីឡូសូវិក បច្ចុប្បន្នមេដឹកនាំនៅប្រទេសយូហ្គោស្លាវីជាដើម ។ ព្រឹត្តិការណ៍ដែលកំពុងបាននិងមិនបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺជះឥទ្ធិពលពីបទដ្ឋានអន្តរជាតិនេះ ហើយខ្ញុំជឿថា អ្នកអាននឹងចង់ដឹងរឿងរ៉ាវពីខាងក្រៅ ក៏ដូចគ្នាពីខាងក្នុងប្រទេសដែរ ។ ក្រុមអ្នកជំនាញការច្បាប់ អ្នកប្រាជ្ញ និងប្រវត្តិវិទូអំពីបញ្ហាកម្ពុជា និងអ្នកយកព័ត៌មានឯករាជ្យដែលមានបទពិសោធន៍ខ្ពស់ នឹងធ្វើការវាយតម្លៃលើអត្ថបទនៃទស្សនាវដ្តីស្វែងរកការពិត ។ ជាបន្ថែមទៀតនឹងមានក្រុមប្រឹក្សានិពន្ធដែលចំណុះដោយអ្នកជំនាញផ្នែកច្បាប់ និងប្រវត្តិសាស្ត្រត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យអត្ថបទរបស់ទស្សនាវដ្តីស្វែងរកការពិតមុនពេលចេញផ្សាយ ។ ទស្សនាវដ្តីស្វែងរកការពិតស្វាគមន៍ និងលើកទឹកចិត្តដល់ការចូលរួមផ្តល់មតិយោបល់ពីសាធារណជនទូទៅចំពោះដំណើរការកាត់ទោសរបបខ្មែរក្រហម និងចំពោះការអានជាទូទៅនៃប្រវត្តិសាស្ត្រដ៏គួរឲ្យតក់ស្លុតមួយ ។ ខ្ញុំសង្ឃឹមថាទស្សនាវដ្តីស្វែងរកការពិត អាចជួយធ្វើជាមិត្តដ៏ល្អដ៏កម្រកបានដល់អ្នកអានគ្រប់ៗរូប ។ ទស្សនាវដ្តីស្វែងរកការពិតគឺអាចជាមិត្តដ៏ពិតម្នាក់ដែលតាមរយៈមិត្តម្នាក់នេះ អ្នកអានអាចសិក្សា និងពិភាក្សាជាមួយ នៅពេលណាដែលអ្នកអានមានការចង់ដឹងចង់យល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមឲ្យកាន់តែច្បាស់ថែមទៀត ។ ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណដល់បងប្អូនខ្មែរគ្រប់រូប ជាពិសេសបងប្អូននៅតាមភូមិជនបទដាច់ស្រយាល ដែលតែងតែបានជួយជ្រោមជ្រែងរូបខ្ញុំក្នុងការស្រាវជ្រាវនានា និងបានជួយធ្វើឲ្យរូបខ្ញុំបានមកដល់គោលដៅដ៏ប្រពៃសព្វថ្ងៃនេះ ។ ថ្វីបើខ្ញុំមិនអាចចងចាំឈ្មោះទាំងអស់គ្នាឲ្យបានគ្រប់ៗរូបយ៉ាងណាក៏ដោយ ខ្ញុំសូមបញ្ជាក់ប្រាប់ឲ្យបានដឹងថា ពូ អ៊ំ មា មីង បងប្អូនទាំងអស់គ្នាស្ថិតនៅក្នុងបេះដូងរបស់ខ្ញុំរៀងរាល់ថ្ងៃ យ៉ាងកក់ក្តៅជាទីបំផុត ។ សូមបន្តការចូលរួមចំណែកដើម្បីស្វែងរកការពិត និងយុត្តិធម៌ជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ដោយសេចក្តីគោរពនិងរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ឆាំង យុ**

**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

# អំពីទស្សនាវដ្ដីស្វែងរកការពិត

ទស្សនាវដ្ដីស្វែងរកការពិតចែកចេញជា៥ផ្នែក គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ អត្ថបទសម្រាប់ផ្នែកទី១នឹងរៀបរៀងឡើងដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ និយាយឲ្យស្រួលស្ដាប់ គឺការសង្ខេបឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះគឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ផ្នែកទី២ គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រិតឡើងទៀត ។ ផ្នែកនេះជាចំណុចមួយនៃការវិភាគទិន្នន័យដើម្បីបម្រើឲ្យការរៀបចំសៀវភៅប្រវត្តិសាស្ត្រស្ដីអំពីរបបខ្មែរក្រហមដែលបំណងនឹងដាក់ចូលជាកម្មវិធីសិក្សារបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងថ្ងៃអនាគត ។ ផ្នែកទី៣ គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគ




ដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណាដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤គឺជាវេទិកាពិភាក្សា និងផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះគឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានាសមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិតជាដើម ។ល។ និយាយរួម គឺជាវេទិកាពិភាក្សាសម្រាប់សាធារណជនទូទៅ ។ ថ្វីត្បិតតែផ្នែកនេះ មានលក្ខណៈបើកទូលាយជាទូទៅយ៉ាងណាក៏ដោយ ក៏អត្ថបទវិភាគទាន តម្រូវឲ្យមានលក្ខណៈវែកញែកប្រកបដោយសីលធម៌ គុណធម៌ និងសេចក្ដីថ្លៃថ្នូរដ៏ខ្ពស់បំផុតដែលអាចធ្វើទៅបាន ។ វាគឺជាទំព័រ «ចូលរួម» ដើម្បី «ដោះស្រាយបញ្ហា» ក្នុងការស្វែងរកយុត្តិធម៌ និងក្នុងការជួយបំភ្លឺប្រវត្តិសាស្ត្រមួយ សម្រាប់ជាការផ្សះផ្សារបួសផ្លូវចិត្ត និងការអប់រំទៅថ្ងៃអនាគត ។ ផ្នែកទី៥ គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកពត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ទៅដោយដៃពួកខ្មែរក្រហម ។ ជាទំព័រឈឺចាប់អាណោចអធម ប៉ុន្តែក៏ជាទំព័រទម្លាប់ការមន្ទិលសង្ស័យ ដើម្បីសេចក្ដីសុខ

ក្នុងខ្លួនជាអមតៈមួយ ។ ទំព័រនេះនឹងជួយផ្សព្វផ្សាយរកព័ត៌មានជូនដល់សាធារណជនដោយសុទ្ធចិត្ត ហើយជាទំព័រដែលរៀបរាប់អំពីការរកឃើញឡើងវិញ នូវជីវិតថ្មីក្រោយរបបខ្មែរក្រហម ។ ទំព័រនេះនឹងស្វាគមន៍គ្រប់សំណើ ស្តីពីការស្វែងរកក្រុមគ្រួសារមកពីសាធារណជនទូទៅ ។ សរុបសេចក្តីទៅផ្នែកទាំង៥ខាងលើ នៃទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជានឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ ទស្សនាវដ្តីស្វែងរកការពិត គឺជាទស្សនាវដ្តីរបស់ប្រជាជនកម្ពុជាគ្រប់រូប ដែលបង្កើតឡើងដោយស្នាដៃប្រជាជនកម្ពុជាសម្រាប់បម្រើដល់ប្រជាជនកម្ពុជា និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជា ។ គ្រប់លិខិត ឬអត្ថបទដែលផ្ញើមកកាន់ទស្សនាវដ្តីស្វែងរកការពិត សូមដាក់ឈ្មោះមុខងារ អាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ធ្វើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។ ទស្សនាវដ្តីស្វែងរកការពិត សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែទស្សនាវដ្តីស្វែងរកការពិត នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។ ទស្សនាវដ្តីស្វែងរកការពិតគោរព និងលើកកម្ពស់ច្បាប់សារព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជាជាពិសេសនៅលើមាត្រាទី៥ ។

សូមផ្ញើលិខិត ឬ អត្ថបទមកកាន់ៈ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ ១១១០
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬផ្ញើតាមទូរសារលេខ
(៨៥៥) (២៣) ២១០ ៣៥៨

# ឯកសារខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា មានតម្កល់ឯកសារស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ជាង៤សែនសន្លឹក ។ ឯកសារទាំងនេះ មិនបានរាប់បញ្ចូលឯកសារប្រភេទរូបថត កាសែតសំលេង វីដេអូ ឬទស្សនាវដ្តី ជាដើមឡើយ ។ ឯកសារខ្មែរក្រហមនីមួយៗ មានលក្ខណៈពិបាកយល់ផ្នែកឃ្លោងឃ្លា ពាក្យពេចន៍ ហើយមានលក្ខណៈឯកោ ប៉ុន្តែប្រទាក់ក្រឡាជាមួយឯកសារផ្សេងទៀត ពិបាករកមូលហេតុបានដោយជាក់លាក់ ។ ឯកសារទាំងអស់មានចរិតខុសដាច់ពីគ្នា ។ ឯកសារខ្លះមានចរិត ជាប្រវត្តិរូប របាយការណ៍ កំណត់ហេតុអង្គប្រជុំ ទូរសារ ឬចម្លើយសារភាព ។ នៅក្នុងចំណោមឯកសារទាំងអស់នេះទស្សនាវដ្តីស្វែងរកការពិតបានជម្រើសយកឯកសារចំនួន ៦១៨៥សន្លឹក មកចាប់ផ្តើមធ្វើការសរសេរជាមុន ។ មូលហេតុចាំបាច់តែមួយគត់នៃការជ្រើសយកឯកសារ ៦១៨៥សន្លឹក គឺឯកសារនោះមានចំណាររបស់មេដឹកនាំខ្មែរក្រហមស្ទើរតែនៅលើគ្រប់ឯកសារទាំងអស់ ។ ឯកសារនេះមានសារៈសំខាន់ពីរគឺទាំងផ្នែកប្រវត្តិសាស្ត្រ និងផ្នែកច្បាប់ ។ ស្នេហរបស់ទស្សនាវដ្តីស្វែងរកការពិតនឹងព្យាយាមសង្ខេបឯកសារដើមទាំងស្រុងឲ្យទៅជាអត្ថបទសមរម្យមួយដែលងាយយល់ និងតាមដាន ។ ឯកសារ ៦១៨៥សន្លឹកនេះ ត្រូវបានអ្នកសិក្សាជាន់ខ្ពស់ និងប្រវត្តិវិទូវាយតម្លៃខុសៗគ្នា ។ អ្នកខ្លះបានចាត់ទុកថាឯកសារនេះជាកម្មសិទ្ធិរបស់ សុន សេន អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបខ្មែរក្រហម ។ អ្នកខ្លះយល់ថា ឯកសារនេះជាឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជា ។ ខ្លះទៀតយល់ថា ឯកសារនេះជាឯកសាររបស់ក្រុមសន្តិសុខ ឬសន្តិបាលនៃរបបខ្មែរក្រហម ហើយខ្លះទៀតយល់ថាជាប្រភេទឯកសារលាក់ការណ៍ខ្ពស់ដែលបានរាយការណ៍ផ្ទាល់ដល់ ប៉ុល ពត ទៀតផង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានតួនាទីត្រឹមតែបង្ហាញឲ្យឃើញពីចរិតដើមទាំងស្រុងនៃឯកសារស្តីអំពីរបបខ្មែរក្រហម ហើយផ្តល់ជូននូវទិន្នន័យដើមទៅដល់សាធារណជន ។ ការវិភាគថាតើឯកសារនេះជាឯកសារប្រភេទណា ហើយមានតម្លៃដូចម្តេចនោះ គឺជាតួនាទីរបស់អ្នកអាន ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការថែរក្សាភស្តុតាងជាក់ស្តែងមានសារៈសំខាន់ជាចាំបាច់



រណ្តៅសាកសពរួមរាប់ពាន់ ស្លាកស្នាមអគារជាគុករបស់របបខ្មែរក្រហម និងអដ្ឋិធាតុរបស់ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អាចជាភស្តុតាងជាក់ស្តែងដ៏សំខាន់ចំពោះឧក្រិដ្ឋកម្មដែលរបបនេះបានប្រព្រឹត្ត ។ ភស្តុតាងទាំងនេះមានសារៈសំខាន់សម្រាប់ទាំងប្រវត្តិសាស្ត្រ និងផ្នែកច្បាប់ ។

ជាការចាំបាច់បំផុតដែលប្រជាជនកម្ពុជាត្រូវយល់ដឹងនូវការពិតទាំងស្រុងអំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមដើម្បីទុកជាមេរៀន និងទប់ស្កាត់ប្រវត្តិសាស្ត្រពោរពេញទៅដោយសោកនាដកម្មបែបនេះ កុំឲ្យកើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមកម្ពុជានាពេលអនាគត ។ របបប្រល័យពូជសាសន៍បែបនេះអាចកើតឡើងនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាទាំងអស់ ។ គ្មាននរណាម្នាក់ដឹងច្បាស់ថា អំពើបែបនេះនឹងពុំអាចកើតឡើងនៅក្នុងប្រទេសកម្ពុជាម្តងទៀតនោះឡើយ ។ ក្រៅអំពីច្បាប់ដ៏រឹងមាំមួយ, ការធានាដ៏ល្អបំផុតដើម្បីទប់ស្កាត់ជាមុនកុំឲ្យអំពើបែបនេះអាចកើតឡើងបាន គឺថាភស្តុតាងដ៏សំខាន់ ដូចជាអដ្ឋិធាតុជនរងគ្រោះក្រោមរបបខ្មែរក្រហម ចាំបាច់ត្រូវរក្សាឲ្យបានត្រឹមត្រូវ និងឲ្យមានសុវត្ថិភាព ហើយប្រជាជនកម្ពុជាជាពិសេសពលរដ្ឋកម្ពុជាដែលកើតពុំទាន់របបនេះ ត្រូវដឹងឲ្យបានច្បាស់អំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ដោយរបបខ្មែរក្រហម ។

ក្នុងខណៈដែលអង្គជំនុំជម្រះមេដឹកនាំខ្មែរក្រហមកំពុងហៀបនឹងកើតឡើង អដ្ឋិធាតុរបស់ជនរងគ្រោះដោយរបបខ្មែរក្រហម គុក និងរណ្តៅសាកសពទាំងឡាយដែលមាននៅស្ទើរតែគ្រប់ស្រុកទាំង១៧០ក្នុងទូទាំងប្រទេសកម្ពុជា នឹងជាភស្តុតាងជាក់ស្តែងដ៏សំខាន់បំផុតសម្រាប់ការស៊ើបអង្កេតរបស់តុលាការ ។

ជាអាទិ៍ក្រោមចំណុច «ខ» ស្តីអំពីភស្តុតាងជាក់ស្តែងនៃជំពូក៤ ស្តីអំពីការវាយតម្លៃភស្តុតាងក្នុងរបាយការណ៍ក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជាកាលពីដើមឆ្នាំ១៩៩៩ កន្លងមកនេះ បានសរសេរថា «ភស្តុតាងជាក់ស្តែងដែលមានការទាក់ទងបំផុតសម្រាប់ដំណើរការជំនុំជម្រះក្តីណាមួយអាចចែកជា៣ប្រភេទៈ អដ្ឋិធាតុជនរងគ្រោះ សំណង់ អគារ ឧបករណ៍ច្រវ៉ាក់ខ្នោះឃ្នាង និងឯកសារផ្សេងៗ» ។

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានខិតខំរក្សានូវអដ្ឋិធាតុ និងភស្តុតាងដទៃទៀតដើម្បីសបញ្ជាក់ពីឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យក្នុងទសវត្សរ៍ឆ្នាំ៨០ ប៉ុន្តែការថែរក្សានេះត្រូវបានបាត់បង់សកម្មភាពជាផ្លូវការ នៅក្រោយពេលបោះឆ្នោត ឆ្នាំ១៩៩៣ ។ រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននេះគួរ ឬប្រហែលជាមានកាតព្វកិច្ចចំពោះតុលាការក្នុងការចាត់វិធានការឲ្យទាន់ពេលវេលាដើម្បីធានាឲ្យប្រាកដថា ភស្តុតាងទាំងនេះនឹងមិនត្រូវបានបាត់បង់ ឬ ខូចតម្លៃតាមផ្លូវច្បាប់ឡើយ ។ អាជ្ញាធរមូលដ្ឋានគួរតែត្រូវបានពន្យល់ឲ្យដឹងច្បាស់អំពីភាពចាំបាច់នៃការរក្សាភស្តុតាងទាំងនេះសម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមក្នុងពេលខាងមុខ ។ អដ្ឋិធាតុជនរងគ្រោះត្រូវតែរក្សាឲ្យមានសុវត្ថិភាព ហើយរាល់ការប៉ុនប៉ងណាមួយក្នុងការឈូសចោលដើម្បីអភិវឌ្ឍន៍ ឬ មូលហេតុនយោបាយណាមួយលើកន្លែងរណ្តៅរាលពិឃាដ និងគុកខ្មែរក្រហមចាំបាច់ត្រូវផ្អាកមួយអន្លើ ឬទប់ស្កាត់យ៉ាងហោចណាស់រហូតដល់ដំណើរការស៊ើបអង្កេតដ៏ត្រឹមត្រូវមួយសម្រាប់បម្រើឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបញ្ចប់សព្វគ្រប់ ។

នៅពេលថ្មីៗនេះ ខ្ញុំបានទៅពិនិត្យមើលមជ្ឈមណ្ឌលឧក្រិដ្ឋកម្មដ៏ធំ និងដែលត្រូវបានស្គាល់ជាសាធារណៈគឺ គុកសង់ ក្នុងភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ កន្លែងនេះក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិធ្លាប់បានចុះមកពិនិត្យ ក្នុងអំឡុងបេសកកម្មរបស់ខ្លួនក្នុងប្រទេសកម្ពុជា កាលពីខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ ខ្ញុំបានជួបប្រទះនឹងការផ្លាស់ប្តូររូបភាពចំពោះអដ្ឋិធាតុជនរងគ្រោះនៃរបបខ្មែរក្រហម និងព័ត៌មានជុំវិញមជ្ឈមណ្ឌលឧក្រិដ្ឋកម្មនេះ តាមរយៈបទសម្ភាសន៍ជាមួយចៅអធិការវត្តក្រូចសើច គឺព្រះតេជគុណ ពេញ សាម៉ន ដូចខាងក្រោមនេះ ៖

**សួរ (ស):** ពួកខ្ញុំករុណាទាំងអស់គ្នាមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា មកមើលអដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅគុកសង់នេះ ។ ពេលមកដល់ឃើញមានចេតិយថ្មីដាក់តម្កល់អដ្ឋិធាតុត្រឹមត្រូវ ។ អ្នកស្រុកបានប្រាប់ថា ព្រះតេជគុណជាអ្នកផ្តួចផ្តើមកសាងចេតិយនេះឡើង ។ ដូច្នេះខ្ញុំព្រះករុណាសូមក្រាបទូលសួរថាតើមានហេតុផលអ្វីបានជាព្រះតេជគុណកសាងចេតិយសម្រាប់តម្កល់អដ្ឋិធាតុទាំងអស់នោះ?



**ឆ្លើយ (ឆ):** មូលហេតុដែលអាត្មាមានគំនិតកសាងចេតិយនេះឡើងដោយសារអាត្មាមានញោមប្រុសម្នាក់បានស្លាប់នៅកន្លែងហ្នឹងដែរ ម្យ៉ាងទៀតឃើញឆ្អឹងទាំងអស់ហ្នឹងនៅរាយប៉ាយត្រូវភ្លៀង ត្រូវខ្យល់ ត្រូវថ្ងៃ ពុកផុយ ណាមួយគោស៊ីផង ក៏គិតថា បើចេះតែទុកអ៊ីចឹងតទៅច្បាស់ជារលាយបាត់អស់ហើយ អត់មានសល់ ភស្តុតាងសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានឃើញទេ ហើយម្យ៉ាងទៀតនោះបើទុកអ៊ីចឹងបងប្អូនពុទ្ធបរិស័ទគាត់ចង់មកអុជធូប គោរពវិញ្ញាណក្ខន្ធក៏គ្មានកន្លែងត្រឹមត្រូវ ក៏មានគំនិតកសាងចេតិយមួយដើម្បីតម្កល់អដ្ឋិធាតុទាំងអស់ហ្នឹង ដល់មានគំនិតអ៊ីចឹងក៏បានចាប់ផ្តើមធ្វើតែម្តងទៅ រួមទាំងពុទ្ធបរិស័ទមកពីគ្រប់ទិសទីព្រមទាំងចៅហ្វាយស្រុក ចៅហ្វាយខេត្ត ចូលរួមផងក៏នាំគ្នាធ្វើចេតិយហ្នឹង ហើយបានដាក់អដ្ឋិធាតុទៅក៏ចេះតែមានសទ្ធាជ្រះថ្លាតទៅទៀតថាឥឡូវធ្វើចេតិយហើយ អ៊ីចឹងពុទ្ធបរិស័ទដែលគាត់មកចង់ធ្វើបុណ្យធ្វើទានហ្នឹងតើបានអីជ្រក? ព្រោះថាពេលបង្សុកូលម្តងៗខែភ្ជុំបិណ្ឌ ភ្លៀងមកទទឹកអស់ ប៉ុន្តែដោយសារសេចក្តីជ្រះថ្លានៅនឹកនាដល់អ្នកដែលស្លាប់ទៅទាំងព្រះសង្ឃ ទាំងអីក៏ឆាន់កណ្តាលភ្លៀងដល់ពេលធ្វើបុណ្យឆ្លង ចេតិយក៏បានចៅហ្វាយខេត្តកណ្តាលគាត់អញ្ជើញមកដែរ..។

**(ស):** ចៅហ្វាយខេត្តកណ្តាលហ្នឹង?

**(ឆ):** ពរ! ឯកឧត្តម ឃឹម បូ ក៏បានអញ្ជើញមកទៀតអាត្មាក៏សុំគាត់ទៀតទៅគាត់ក៏ឯកភាពបានកសាងជាសាលាឆាន់ទៅហើយកសាងសាលាហ្នឹងអាត្មាថា គ្មានលទ្ធភាពដែរទេបានជាចាក់បានតែជើងតែអីទេ តែថាចេះតែធ្វើបន្តមួយឆ្នាំបន្តិចៗ ឥឡូវចៅហ្វាយខេត្តគាត់ថា ចេះតែធ្វើទៅចាំគាត់ជួយ ។

**(ស):** អ៊ីចឹងព្រះតេជគុណផ្ទាល់ ជាអ្នកផ្តួចផ្តើមគំនិតនេះមុនគេ?

**(ឆ):** ពរ! គឺអាត្មា ។

**(ស):** ហើយខាងអាជ្ញាធរស្រុក គេគាំទ្រ?

**(ឆ):** ពរ! គាត់គាំទ្រ ។ អាត្មាគ្រាន់តែផ្តើម ប៉ុន្តែដូចថាកសាងហ្នឹងវាព្រមគ្នាទាំងអស់ណា៎ អាត្មាផង ឃុំផង ហើយស្រុក ខេត្តវាព្រមគ្នាទាំងអស់បានអាចដំណើរការហ្នឹងកើត ។

**(ស):** អ៊ីចឹងហេតុផលចម្បងៗដែលតេជគុណមានគឺដោយសារថាមានឪពុកតេជគុណ...។

**(ឆ):** ញោមប្រុស! ឪពុកអាត្មាហ្នឹងគាត់ស្លាប់នៅជំនាន់ ប៉ុល ពត ហើយជាពិសេសអាណិតដល់ពុទ្ធបរិស័ទទាំងអស់ដែលគាត់ គ្មានលទ្ធភាពនឹងសាងសង់ចេតិយម្នាក់ឯងណា៎ មានតែកម្លាំងព្រះសង្ឃដែលយើងផ្តួចផ្តើមទៅពុទ្ធបរិស័ទ គាត់ជ្រះថ្លាលើយើងបានអាចធ្វើចេតិយណឹងហើយ ។

**(ស):** មូលហេតុអ្វីបានជាមិនយកឆ្អឹងខ្មោចទៅកន្លែងផ្សេងហើយធ្វើចេតិយនៅកន្លែងដដែល?

**(ឆ):** កាលពីមុន គេចង់យកឆ្អឹងខ្មោចហ្នឹងទៅដាក់នៅវត្តកោះសុក្រំ ប៉ុន្តែចេះតែមួយឆ្នាំៗ អត់ដែលឃើញយកទៅដល់អ៊ីចឹងទៅអាត្មាសុំចៅហ្វាយស្រុកថា បើយើងយកចេញពីហ្នឹងទៅដូចជាបាត់ស្លាកស្នាមកាលពីសម័យ ប៉ុល ពត សម្លាប់នៅត្រង់ហ្នឹងណា៎ បើអ៊ីចឹងវាបាត់ថាកន្លែងហ្នឹងកន្លែងវាលពិឃាត កន្លែងសម្លាប់ ហើយវាអត់មានអីជាភស្តុតាង អ៊ីចឹងបានអាត្មាសុំគេធ្វើចេតិយ ។ អាដីទៅខាងឆ្វេងគេទុកឲ្យរដ្ឋ ហើយអាដីមកខាងស្តាំផ្លូវចូលទៅកាន់កន្លែងឆ្អឹងខ្មោចខាងរដ្ឋគេប្រគេនអាត្មាមកដាច់ ។

**(ស):** ចុះកន្លែងចាស់ធ្លាប់ដាក់ឆ្អឹងខ្មោចហ្នឹង?

**(ឆ):** កន្លែងចាស់ហ្នឹងគេថា រដ្ឋទុកធ្វើជាសាលាភូមិនូរដ្ឋបាល ហើយមិនដឹងគេដំណើរការពេលណាក៏អត់ដឹងដែរ ។

**(ស):** គម្រោងរំលោល ឬក៏គម្រោងធ្វើយ៉ាងម៉េចទៅវិញព្រោះកន្លែងហ្នឹងជាគុកខ្មែរក្រហម?

**(ឆ):** គម្រោងរបស់គេ គេរំលោលហើយគេសាងសង់សារថ្មី ។ ពរ! កន្លែងហ្នឹងជាគុក ជាគុកធំហើយហ្នឹង ។ ហើយកន្លែងដែលអាត្មាសាងសង់ជាកន្លែងមេអាពតគេនៅណា៎ កន្លែងផ្ទះរបស់គេជំនាន់ហ្នឹង ។

**(ស):** តើព្រះតេជគុណចាប់អារម្មណ៍យ៉ាងណាដែរ ព្រោះថាគេជគុណចាប់អារម្មណ៍រឿងរក្សាភស្តុតាង រក្សាស្លាកស្នាមនៃរបបប្រល័យពូជសាសន៍ទុកឲ្យកូនចៅជំនាន់ក្រោយបានដឹង ដល់ឥឡូវខាងអាជ្ញាធរបម្រុងរំលោល ហើយសាងសង់ជាកន្លែងថ្មី?

**(ឆ):** បើយើងថា ទុកនៅហ្នឹងដើម្បីទុកជាកេរតំណែលវាល្អហើយ តែបើស្រុកគេត្រូវការហើយយើងក៏មិនអាចហាមឃាត់គេបាន ព្រោះអីគេថាបើទុកចោលអ៊ីចឹងក៏វាអត់បានប្រយោជន៍អីដែរដល់អ៊ីចឹងគេកសាងជាថ្មីទៅវាល្អដែរ ។

**(ស):** គេជគុណផ្តួចផ្តើមសាងសង់ចេតិយពីឆ្នាំណាមក?

**(ឆ):** សាងសង់ទើបតែចុង៩៩ ហ្នឹង ។

**(ស):** ចុះហេតុអ្វីក៏ពីដំបូងព្រះតេជគុណមិនគិតថា រក្សាឆ្អឹងហ្នឹងទុកនៅកន្លែងដដែល ហើយធ្វើដំបូលប្រក់ពីលើគុកហ្នឹងវិញកុំឲ្យត្រូវភ្លៀង?

**(ស):** អាណឹងចង់អ៊ីចឹងដែរ ប៉ុន្តែដំណាក់កាលថាបើយើងទុកនៅត្រង់ណឹងក៏គេមិនអាចទុកដែរ ដួនកាលគេយកទៅវត្តទៅអីឯណាឆ្ងាយទៅវារឹតតែដាច់ពីទីនោះទៅទៀត ហើយអាត្មាក៏គ្មានលទ្ធភាពថាសុំដាក់នៅត្រង់ណឹងដែរណា៎ គឺអត់បានដែរ ហើយជាពិសេសបើអាត្មាមិនធ្វើគឺឆ្អឹងហ្នឹងមួយឆ្នាំវាតិចម្តងៗ វាបាត់អស់ហើយ ។

**(ស):** ចុះឯកឧត្តមទាំងប៉ុន្មាន ដែលលោកបានចូលបច្ច័យថវិកាសម្រាប់កសាងចេតិយហ្នឹង សុទ្ធតែមានសាច់ញាតិស្លាប់នៅកន្លែងហ្នឹងដែរឬអត់ទេ?

**(ឆ):** ឯកឧត្តមខ្លះក៏មាន ឯកឧត្តមខ្លះក៏អត់ ព្រោះអីគាត់ជាអ្នកដែលនៅឆ្ងាយៗណា៎ អ្នកដែលស្លាប់នេះតែនៅខាងស្រុកកណ្តាលស៊ឹងទេ ។

**(ស):** មានប្រជាជននៅជុំវិញទីនោះទៅអុជធូបអុជអី មានបងប្អូនគេស្លាប់ច្រើនដែរទេ?

**(ឆ):** ពរ!មានច្រើន ជាពិសេសនៅខាងយើងនេះ (កណ្តាលស៊ឹង) ស្លាប់ច្រើន បើនៅខាងទីនោះដូចជាមិនសូវដែរព្រោះអីខាងទីនោះដូចជាភូមិត្រពាំងស្វា អ្នកត្រពាំងស្វាជំនាន់អាពត គឺអ្នកកាន់កាប់សម្លាប់នៅហ្នឹងណា៎ បើយើងធ្វើអ៊ីចឹងក៏គេមិនសូវជ្រះថ្លាប៉ុន្មានដែរ ព្រោះអីគេចង់បិទភស្តុតាងកុំឲ្យយើងទៅឃើញគេអ៊ីចឹងទៅចេះតែមានកំហឹងណា៎ ប៉ុន្តែយើងគ្មានកំហឹងអីទេ ប៉ុន្តែគំនិតរបស់គេគឺមិនចង់ឲ្យយើងផ្តួចផ្តើមទេ ។

**(ស):** អ៊ីចឹងមានគេជំទាស់ដែរ?

**(ឆ):** គេអត់សូវហ៊ានជំទាស់អីដែរ ព្រោះថាមិនមែនតែអាត្មាឯណារដ្ឋអំណាចគាត់នៅពីក្រោយយើងដែរ អ៊ីចឹងគាត់អត់សូវហ៊ានទេ បើម៉េចៗយើងទៅអាងរដ្ឋអំណាចគេជួយ ។

**(ស):** អ៊ីចឹងដោយសារថាមានបងប្អូនប្រជាជនគេនៅហ្នឹងស្លាប់នៅជំនាន់ប៉ុលពតហ្នឹង?

**(ឆ):** ពរ! ជំនាន់ប៉ុលពតច្រើន ហើយនេះដឹងតែជិតៗហ្នឹងដែរ អ្នកដែលកសាង ព្រោះអីសម័យហ្នឹងស្លាប់ច្រើនណាស់ ប៉ុន្តែយើងគ្មានលទ្ធភាពថា យកលុយទៅផ្សាយទៅអីឲ្យគេមកជួយកសាងអី វាអត់ណា៎ វាអត់មានលទ្ធភាពនឹងដកលុយទៅផ្សាយយើងធ្វើបានតិចៗគេចេះតែដឹង ចេះតែពុមក គេចេះតែជួយ ។

**(ស):** តេជគុណមានទឹកចិត្តធ្វើកន្លែងហ្នឹង អ៊ីចឹងដោយសារថាឪពុកបានស្លាប់នៅកន្លែងហ្នឹង ។ តើតេជគុណជ្រាបថា គាត់ស្លាប់យ៉ាងម៉េចទេ?

**(ឆ):** អត់ផង កាលណឹងអាត្មាក៏នៅតូចដែរ ប៉ុន្តែញោមស្រីគាត់ប្រាប់ថាគាត់មានស្នឹងណា គាត់ធ្វើជាងណា៎ សិប្បកម្ម រំពោតរំអី ប៉ុន្តែគេចេះតែថាគាត់ហ្នឹងជំនាន់នេះធ្វើសក្តិនេះ សក្តិ

នោះអ៊ីចឹងទៅ គេក៏ហៅគាត់ចេញពីកន្លែងគុកសង់ឆ្នាំ១៩៧៨ ជិតបែកទៅហើយ ។

**(ស):** ធ្វើយ៉ាងម៉េចបានជាដឹងថាគាត់ស្លាប់នៅកន្លែងហ្នឹង?

**(ឆ):** មានគេឃើញ ហើយអ្នកដែលនាំទៅក៏នៅរស់ដែរ ។

**(ស):** ឈ្មោះអីដែរអ្នកនាំណឹង?

**(ឆ):** ឈ្មោះរឿង, ម៉ៅ ហ្នឹងហើយ ឈ្មោះទាំងនេះជាអ្នកគ្រប់គ្រងនៅហ្នឹង ។ អ្នកសម្លាប់នៅត្រពាំងស្វាច្រើន ហើយនៅរស់ទាំងអស់សព្វថ្ងៃ ។

**(ស):** អម្បាញ់មិញ ខ្ញុំករុណាឮបងម្នាក់និយាយពីរឿងលួចក្បាលអដ្ឋិ ធាតុ តើមានពិតទេ?

**(ឆ):** លួចក្បាលអត់ទេ! ប៉ុន្តែបើខ្មោះមានបាត់ខ្លះពីមុនខ្មោះច្រើនណាស់ ពួកអាក្មេងៗវាលួចយកទៅដូរអេតចាយ ព្រោះអីខ្មោះកាលអាត្មាទៅលើកមុនច្រើន ឥឡូវប្រមូលបានមិនប៉ុន្មានទេ ហ្នឹងរឿងខ្មោះ បើថាក្បាលមិនដឹងគេលួចយកទៅធ្វើអីទេ ។ មានតែគោ គោចេះតែស៊ីរាយពេញវាល ចេះតែប្រមូលយកមកទុកទៅ គោវាស៊ីមែន ។ ពីមុនកាលពីមិនទាន់បោះឆ្នោះ៩៣ គឺគេថែទាំប្រក់អី ឃុំទ្រា គេប្រក់ថែទាំមែនទែន ដល់ពេលបោះឆ្នោតហើយ ដូចជាចេះតែរយាលៗទៅ ។

**(ស):** អ៊ីចឹងឆ្អឹងដែលតេជគុណប្រមូលទុកហ្នឹង គឺយកមកទាំងអស់ហើយអត់មានអ្នកណាធ្លាប់ដុតធ្លាប់អីខ្លះទេឬអី?

**(ឆ):** អត់ទេ ប្រមូលមកទាំងអស់ ។

**(ស):** ហើយតេជគុណជឿជាក់ទេថា ដែលតេជគុណប្រមូលមកទុកអ៊ីចឹងវាអាចរក្សាបានក្នុងរយៈពេលយូរទៅទៀត?

**(ឆ):** អត់សូវដឹងដែរ តែវាអាចព្រោះអីវាហប់អ៊ីចឹងទៅ វាពុកផុយដែរប៉ុន្តែគ្រាន់តែយូរ វាមិនដូចត្រូវភ្លៀង ត្រូវភ្លៀងត្រូវខ្យល់វាចេះតែពុកៗទៅជាដី ។

**(ស):** ចុះថ្ងៃ២០ ឧសភា ខាងស្រុកមកធ្វើពិធីបុណ្យ ថ្ងៃចងកំហឹងនៅកន្លែងហ្នឹងដែរ?

**(ឆ):** ពរ! គេធ្វើនៅហ្នឹងច្រើន មួយស្រុកកណ្តាលស្ទឹងយើងទៅរួបរួមគ្នានៅគុកសង់ទាំងអស់ ។

**(ស):** អ៊ីចឹងតទៅតេជគុណគិតថា កន្លែងហ្នឹងគេធ្វើសម្រាប់ថ្ងៃ ២០ ឧសភា ចងកំហឹងគេមកគុកសង់រៀងរាល់ឆ្នាំអ៊ីចឹងទៅ?

**(ឆ):** ពរ! ជារៀងរាល់ឆ្នាំអ៊ីចឹង កាលថ្ងៃរាប់បាត្រមុននេះ ចៅហ្វាយខេត្តគាត់មកធ្វើឯណឹងដែរ ។

**(ស):** ក្នុងចំណោមហេតុផលមួយចំនួនដែលតេជគុណលើកឡើង ទី១ ដោយសារថា ឪពុកតេជគុណស្លាប់នៅគុកសង់ហើយ ទី២ ការបារម្ភថា បើទុកបណ្តោយអ៊ីចឹងទៅវាអាចបាត់ហើយ ហេតុផលមួយទៀតគឺថា ធ្វើអ៊ីចឹងទៅដើម្បីមានកន្លែងទៅអុជធូបគោរពវិញ្ញាណក្ខន្ធ ។ ក្នុងចំណោមហេតុផលទាំង៣ហ្នឹង តើហេតុផលណាសំខាន់ចំពោះព្រះតេជគុណផ្ទាល់?

**(ឆ):** ហេតុផលទី២ គឺហេតុផលដែលថាយើងខ្លាចវាបាត់ វាបាត់អដ្ឋិធាតុហ្នឹងណា៎ ញោមដែលស្លាប់ទៅ គាត់ទៅបាត់ហើយ ប៉ុន្តែវាខ្លាចបាត់ភស្តុតាងហ្នឹងតែម្តងដើម្បីកុំឲ្យគេថា យី!ថាស្លាប់ៗដល់ពេលទៅអត់ឃើញ អាហ្នឹងសំខាន់ជាងគេតែម្តង មិនមែនថាដើម្បីតែញោមមួយអត្តទត្តបុគ្គល លុយបច្ច័យគេគរគោកមិនមែនយើងកសាងតែយើងឯណា អានេះដើម្បីកុំឲ្យបាត់ភស្តុតាងហ្នឹងតែម្តង ដើម្បីឲ្យពុទ្ធបរិស័ទមកពីគ្រប់ទិសទីមកគោរពបូជា ហើយអនាគតទៅអាត្មាក៏សុំចៅហ្វាយស្រុកថា កន្លែងហ្នឹងមួយក៏មិនឲ្យ រសាត់អ៊ីចឹងដែរ ចង់ទុកឲ្យព្រះសង្ឃគង់នៅដើម្បីឲ្យពុទ្ធបរិស័ទមកពីគ្រប់ទិសទីធ្វើបុណ្យធ្វើទានឧទ្ទិសកុសលផលបុណ្យទេ ព្រោះថាក៏មានអ្នកខ្លះទៅពន្យល់សប្តិដល់ឪពុកម្តាយ កូនចៅថាមិនទាន់បានទៅចាប់ជាតិទេនៅវិលវល់កន្លែងណឹង អ៊ីចឹងឲ្យធ្វើបុណ្យទៅ មានគេចេះតែទៅសង្ឃទានឧទ្ទិសឲ្យអ៊ីចឹងដែរ ។ ប្រុងធ្វើជាក់ជាកន្លែងសមាធិតែម្តងណា៎ សមាធិធ្វើធម៌ទៅដើម្បីឲ្យអារម្មណ៍អ្នកដែលស្លាប់ហ្នឹងបានស្ងប់ ទ្រឹស្តីនៃព្រះពុទ្ធសាសនាការដែលយើងស្លាប់ទៅហើយ មានសុវណ្ណចិត្តមួយដែលមិនដាច់លះអំពីមនុស្សលោកអារម្មណ៍តែងតែវិលវល់ ។ ឆ្អឹងទាំងនេះយើងមិនអាចដុតចោលទេ ព្រោះថានេះជាកេរតំណែលដើម្បីទុកឲ្យក្មេងស្រករក្រោយដឹងថាជំនាន់មុនពួកខ្មែរក្រហមវាឃោរឃៅយ៉ាងណា ព្រោះអីក្មេងៗ... អាត្មាណឹងក៏ទាន់ខ្លះដែរ ជំនាន់ប៉ុល ពត ការពិបាកយ៉ាងណាៗ ហើយក្មេងឥឡូវក៏វាមិនទាន់ណឹងភស្តុតាងមានផង ហើយអ្នកខ្លះនៅតែមិនជឿ ចុះទម្រាំតែអត់ទៅយើងបានអីជាគោលអាង?

**(ស):** ចុះបើគេចង់កម្ទេចគុកចាស់ហ្នឹង តើតេជគុណជំទាស់ទេ?

**(ឆ):** អត់ហ៊ានជំទាស់ទេ បើគេកម្ទេចក៏អាត្មាអត់ហ៊ានដែរ ។

**(ស):** ចុះបើតាមតេជគុណជ្រាប កន្លែងកប់សាកសពមានរណ្តៅច្រើនណាស់ខាងហ្នឹងគេប្រុងអភិវឌ្ឍន៍ឬប្រុងធ្វើអីគេទៅ? ព្រោះខ្ញុំព្រះករុណាគិតថាបើគេសាងសង់អ្វីថ្មីប្រហែលជាគេឈូសឆាយ

ដីកន្លែងកប់ខ្មោចហ្នឹងចោល?

**(ឆ):** ពរ! ហ្នឹងហើយ បើគេសង់ថ្មីគេនឹងឈូសឆាយខ្ទេចអស់ហើយ ។ ធ្វើទាំងមូលតែម្តង ហើយខ្មោចកប់គឺទៅខាងណោះច្រើន មកខាងអាត្មានេះអត់ទេ ហើយខ្មោចដែលគាស់បានមកហ្នឹងពីមុនច្រើនមែនទែនឆ្អឹង មិនមែនតែ៥-៦គូបប៉ុណ្ណឹងទេ ប៉ុន្តែគាស់ប៉ុណ្ណឹងក៏មិនទាន់អស់ដែរ ទើបតែបានប៉ុន្មានរណ្តៅប្រហែល ៣០-៦០នាក់ក្នុងមួយរណ្តៅទេ នៅរណ្តៅច្រើនទៀត អាខ្លះ២នាក់ អាខ្លះ៥នាក់ អាខ្លះ៦នាក់ ខ្លះម្នាក់អីចឹងទៅ ច្រើនណាស់កាប់កន្លែងណាក៏ចំដែរខ្មោច ។ លោកមេឃុំមានប្រសាសន៍បន្ថែមថាមិនទាន់អស់ទេកន្លែងហ្នឹងវានៅច្រើនណា៎ ។

**(ស):** ចុះបើឧបមាថាគេឈូសឆាយកន្លែងរណ្តៅសពហ្នឹង តេជគុណយល់យ៉ាងម៉េចដែរ?

**(ឆ):** គឺចង់ទុកអីចឹងតែម្តង ចង់ទុកជាភស្តុតាង ប៉ុន្តែគេថាបើទុកតែចោលអីចឹងទៅអត់កសាងអី ក៏អត់មានផលប្រយោជន៍អី គំនិតរបស់គេអីចឹងបានគេចង់ធ្វើ បើគេមានគំនិតដូចយើងថា ចង់ទុកដើម្បីជាកេរតំណែល ដូចជានៅប្រទេសជប៉ុន (ស្លាកស្នាមនៅហ៊ីរ៉ូស៊ីម៉ា) សាងសង់របងទុកឲ្យក្មេងស្រុកក្រោយមើលអីចឹងទៅមានអី ។






**(ស):** អីចឹងបើឧបមាថា ថ្ងៃក្រោយមានថ្នាក់លើណាម្នាក់គេមកបញ្ជាថា ឆ្អឹងហ្នឹងដុតទៅទុកអត់ប្រយោជន៍ទេ តេជគុណនឹងគិតយ៉ាងម៉េច?

**(ស):** អាត្មាអត់ហ៊ានជំទាស់ជាមួយគេទេ មិនមែនថាមិនហ៊ានសុទ្ធទេ យើងគ្រាន់តែសំណូមពរគេថា ឥឡូវយើងដុតធ្វើអីអានេះ គឺទុកឲ្យអាត្មាចុះ ព្រោះអីអាត្មាធ្វើចេតិយធ្វើអីហើយ យើងមកប៉ះពាល់អីទៀត បើថាអ្នកឯងមិនឲ្យខ្ញុំសាងសង់នៅត្រង់ណឹង ខ្ញុំលើកឆ្អឹងហ្នឹងខ្ញុំហែមកដាក់វត្តខ្ញុំវិញ អាហ្នឹងគ្រាន់តែជាសំណូមពររបស់យើង ប៉ុន្តែបើគេថា អត់បានទេមិនឲ្យហែទៅឯណាគឺដុតចោលក៏អត់ហ៊ានទេ ។ ប៉ុន្តែតាមចិត្តអាត្មាបើគេមិនឲ្យដាក់កន្លែងហ្នឹង អាត្មាសុំគេហែមកដាក់វត្តអាត្មា ហើយចេះតែផ្សព្វផ្សាយពុទ្ធបរិស័ទថា អដ្ឋិធាតុដែលនៅឯណោះ បើចង់បង្សុកូលជូនដល់មាតាបិតាអីឲ្យមកដល់វត្តអាត្មាមក ។

**(ស):** ពេលតេជគុណធ្វើចេតិយហ្នឹង តើមាននឹកឃើញដល់ញោមជាឪពុកដែរឬទេ?

**(ឆ):** ចេះតែនឹកឃើញដែរ ហើយចេះតែនឹកទៅថា កូនកាលពីមុននៅតូច មិនទាន់បានសងគុណកតញ្ញូកតវេទិតាចិញ្ចឹមញោមទេ ឥឡូវញោមបានស្លាប់ទៅហើយ មានតែលទ្ធភាពសាងសង់ចេតិយឧទ្ទិសជូនញោមតែប៉ុណ្ណឹង មានតែអុជធូបតែប៉ុណ្ណឹង ហើយបង្សុកូលអីចឹងទៅ ។

**(ស):** ចុះស្រុកកំណើតព្រះតេជគុណ នៅស្រុកនេះតែម្តងឬ?

**(ឆ):** ពរ! ស្រុកកំណើតអាត្មានៅហ្នឹងតែម្តង អាត្មាបួសនៅវត្តហ្នឹងបាន១ឆ្នាំ ទើបទៅរៀននៅវត្តមហាមន្ត្រី ។ ពេលចៅអធិការវត្តនេះលោកចាស់ លោកក៏សុំត្រឡប់ទៅស្រុកវិញ ពុទ្ធបរិស័ទចំណុះជើង វត្តក៏ទៅនិមន្តអាត្មាមកធ្វើជាចៅអធិការវត្តនេះបាន៦វស្សាហើយ ។ អាត្មាគិតថាសាលាឆាន់ណឹងពេលធ្វើដំបូលហើយ អាត្មានឹងឲ្យគេគូរគំនូរកាលជំនាន់ប៉ុលពត នៅតាមជញ្ជាំងគឺគូររូបគេធ្វើទារុណកម្មអ្នកទោស រូបអីផ្សេងៗទៀតទុកឲ្យក្មេងជំនាន់ក្រោយបានមើលឃើញថា វាឃោរឃៅយ៉ាងណា ។

**ផាត កុសល**

# ចម្លើយសារភាពរបស់សាន់ ប៉ូ





*នេះជាសេចក្តីសង្ខេបពីឯកសារលេខ ៤៥១(J) ដែលជាចម្លើយសារភាពរបស់ឈ្មោះ សាន់ ប៉ូ អ្នកទោសគុកទួលស្លែង ក្នុងរបបខ្មែរក្រហម ។*

សាន់ ប៉ូ មានអាយុ ២៤ឆ្នាំ ស្រុកកំណើតនៅស្រុកជីក្រែង ខេត្តសៀមរាប ត្រូវបាន «អង្គការ» ចាប់ខ្លួនបញ្ជូនមកគុកទួលស្លែង នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៨ ដោយចោទថា ក្បត់អង្គការ ។ មុនពេលត្រូវចាប់ខ្លួន សាន់ ប៉ូ ជាយុទ្ធជននៅផ្សាររដ្ឋ (ផ្សារថ្មី) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស ។

ឯកសារលេខ៤៥១(J) នេះមានចំណងជើងថា «ចម្លើយរបស់ សាន់ ប៉ូ យុទ្ធជនផ្សាររដ្ឋ, អំពីប្រវត្តិសកម្មភាពក្បត់បក្សផ្ទាល់» ដែលអត្ថបទមានលក្ខណៈជាអក្សរអង្គុលីលេខកម្រាស់ ១២សន្លឹក បញ្ជាក់ដោយហត្ថលេខារបស់ សាន់ ប៉ូ ចុះកាលបរិច្ឆេទ ថ្ងៃទី ២ ខែ ៨ ឆ្នាំ១៩៧៨ និងមានឈ្មោះ ថន ជាអ្នកសួរចម្លើយ ។ នៅលើផ្នែកខាងមុខនៃឯកសារចម្លើយរបស់ សាន់ ប៉ូ នេះមានចំណារ ជាអក្សរដៃពណ៌ក្រហមចារថា «ស.មវ៉ាន់»[1] ។ ផ្នែកខាងក្រោយមានតារាងឈ្មោះកម្លាំងក្បត់ ដែលដកស្រង់ចេញពីចម្លើយសារភាពរបស់ សាន់ ប៉ូ ទាំងអស់ចំនួន៣៤ នាក់ ក្នុងនោះឈ្មោះ២នាក់ គឺ ចំរើន និងភី មានបញ្ជាក់ថា «អង្គការបានចាប់ខ្លួនហើយ» ។

ក្នុងចម្លើយសារភាព សាន់ ប៉ូ បានរៀបរាប់អំពីសកម្មភាពក្បត់អង្គការរួមជាមួយនឹងបក្សពួករបស់គាត់ ។

### តើ សាន់ ប៉ូ បានធ្វើអ្វីក្បត់នឹងអង្គការខ្លះតាមចម្លើយសារភាពនេះ?

នៅខែធ្នូ ឆ្នាំ១៩៧៣ សាន់ ប៉ូ បានចូលធ្វើបដិវត្តន៍តាមរយៈឈ្មោះ សាន ប្រធាន មន្ទីរពេទ្យស្រុកជីក្រែង ដែល សាន់ ប៉ូ បានស្គាល់នៅពេលដែលខ្លួនឈឺសម្រាកព្យាបាលនៅមន្ទីរពេទ្យស្រុកជីក្រែង ។

នៅខែមករា ឆ្នាំ១៩៧៤ សាន បានអប់រំ សាន់ ប៉ូ ឲ្យធ្វើសកម្មភាពក្បត់នឹងបដិវត្តន៍ជាមួយឈ្មោះឡាំ,ផែន,នារីខ្មៅ នារីវ៉ន, នារីនន់ ដែលសុទ្ធតែជាបុគ្គលិកពេទ្យស្រុកជីក្រែង ។ សាន បានដាក់ផែនការឲ្យស្អប់ប្រជាជនណាដែលស្មោះត្រង់នឹងបដិវត្តន៍ខ្មែរក្រហម ហើយនៅពេលមានជំងឺបានហាមកុំចាក់ថ្នាំឲ្យ បានបញ្ចុះបញ្ចូលកុំខំប្រឹងធ្វើការច្រើនពេក ប្រយ័ត្នខូចសុខភាព ឲ្យកាប់មាន់ទាដែលចិញ្ចឹមហូបទៅ ឲ្យបំផ្លិចបំផ្លាញថ្នាំពេទ្យដោយលាក់ទុកឲ្យខូចចោលប្រើការលែងកើត ហើយនិងកុំឲ្យអ្នកជំងឺហូបឆ្អែត។ ទាំង សាន់ ប៉ូ និងអ្នកដទៃទៀតព្រមធ្វើតាម សាន ទាំងមិនយល់ និងដោយសារខ្លាច សាន ចាប់ចងធ្វើបាបទៀតផង ព្រោះធ្លាប់ឃើញគំរូអ្នកមុនៗ ២-៣នាក់ ដែលត្រូវ សាន ចាប់ចងដាក់មន្ទីរសន្តិសុខ ដោយសារតែមិនព្រម

ធ្វើតាមបញ្ជា ។

ខែមេសាឆ្នាំ ១៩៧៤ សាន់ ប៉ូ ដែន និង ទ្រី ត្រូវបានដកទៅនៅអង្គភាពយោធាតំបន់សៀមរាប-ឧត្តរមានជ័យ ឬតំបន់១០៦ ជាតំបន់ពិសេសស្ថិតនៅក្នុងខេត្តសៀមរាប នៅចន្លោះតំបន់ព្រះវិហារ (១០៣) និងភូមិភាគពាយ័ព្យ (៥៦០)[២] ។ មុនពេលចេញទៅតំបន់សៀមរាប-ឧត្តរមានជ័យ សាន បានប្រាប់ សាន់ ប៉ូ ឲ្យទាក់ទងជាមួយឈ្មោះ ណូ ប្រធានអង្គភាពយោធាតំបន់សៀមរាប-ឧត្តរមានជ័យ ។ នៅអង្គភាពយោធាខេត្តសៀមរាបនេះ សាន់ ប៉ូ និងមនុស្ស១៣នាក់ទៀត បានធ្វើសកម្មភាពលាក់អាវុធ ចំនួន២ឡាន តាមបញ្ជារបស់ ណូ ។ ក្រៅពីនេះនៅលាក់ជ័យភ័ណ្ឌមានអាវុធ គ្រាប់រំសេវ និងអង្ករជាច្រើនពាន់តោនទៀតផង ។

ខែ៧ ឆ្នាំ១៩៧៤ អង្គការបានដក ណូ ចេញពីអង្គភាព ហើយដាក់អ្នកគ្រប់គ្រងថ្មី ឈ្មោះ គ្រឿន ។ គ្រឿន ក៏ដឹកនាំ សាន់ ប៉ូ និងបក្ខពួកធ្វើសកម្មភាពលាក់អាវុធយុទ្ធភណ្ឌ ស្បៀងអាហារ សម្ភារៈប្រើប្រាស់ និងទុកឲ្យខ្មាំងចូលមកកៀរប្រជាជនយកទៅអស់ជាច្រើនគ្រួសារ ។

ក្រោយឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ សាន់ ប៉ូ ត្រូវដកមកនៅខាងផ្សាររដ្ឋផ្សារថ្មីវិញ នៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ស៊ិន ជាប្រធានអង្គភាពផ្សាររដ្ឋ។ ស៊ិន ដាក់បញ្ជាឲ្យ សាន់ ប៉ូ និងមនុស្សមួយចំនួនទៀតលាក់សម្ភារៈមានក្រណាត់៣០គី ស្រា១៥កេស សាច់ជ្រូកគំប៉ុង១៥កេស ។

មួយសប្តាហ៍ក្រោយអង្គការ ដក ស៊ិន ចេញ ហើយដាក់អ្នកគ្រប់គ្រងថ្មីឈ្មោះ លុំ ។ ឆ្នាំ១៩៧៦ លុំ ត្រូវអង្គការដកចេញទៀតហើយដាក់ ភី ជំនួស ។ ភី ដឹកនាំ សាន់ ប៉ូ និងកម្លាំងមួយចំនួនទៀតឲ្យលាក់ម្ហូបអាហារមាន ត្រីងៀត ប្រហុក ផ្អក ស្ករ លាក់ទាល់តែខូចអស់ទើបបើកឲ្យកម្មករទទួលទាន។ កន្លះខែក្រោយមក ភី ត្រូវដកចេញដាក់ជំនួសដោយមនុស្សថ្មីម្នាក់ទៀត ឈ្មោះ ដូន ។

ខែធ្នូ ឆ្នាំ១៩៧៧ ដូន ត្រូវដកចេញពីអង្គភាពផ្សាររដ្ឋទៀត។ ខែមករា ឆ្នាំ១៩៧៨ ឈ្មោះ វ៉ុយ មកទទួលខុសត្រូវផ្សាររដ្ឋវិញ។ ក្រោមបញ្ជារបស់ វ៉ុយ, សាន់ ប៉ូ បានរួមធ្វើសកម្មភាពលាក់អង្ករ ម៉ាស៊ីនអង្គុលីលេខ ក្រម៉ា និងខោអាវជាមួយបក្ខពួកមួយចំនួនទៀត ។

ខែកុម្ភៈ ឆ្នាំ១៩៧៨ អង្គការដក វ៉ុយ ចេញបាត់ទៀត ហើយដាក់ឈ្មោះ មឿន ឲ្យមកទទួលខុសត្រូវវិញ។ មឿន ក៏ដក សាន់ ប៉ូ ឲ្យទៅនៅខាងចំការនៅព្រែកព្នៅវិញ ។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ សាន់ ប៉ូ ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកគុកទួលស្លែង ។ មកទល់នឹងសព្វថ្ងៃនេះគ្មានឯកសារណាមួយ ឬ សាក្សីណាមួយបញ្ជាក់ថា សាន់ ប៉ូ នៅមានជីវិតនៅឡើយទេ។

**កល្យាណ**



---

១ សម វ៉ាន់ គឺជាឈ្មោះហៅក្រៅរបស់ អៀង សារី ដែលជាអតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អៀង សារី មានឈ្មោះកំណើតថា គីម ត្រាង។

២ យោងតាមផែនទីភូមិសាស្ត្រ បោះពុម្ពផ្សាយដោយក្រសួងអប់រំនៃរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ ។

# វត្តបារាយណ៍ជាន់ដែកក្រោម របបកម្ពុជាប្រជាធិបតេយ្យ




វត្តបារាយណ៍ជាន់ដែកបច្ចុប្បន្ន ស្ថិតនៅក្នុងភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ស្ថិតនៅចម្ងាយប្រមាណ៣គីឡូម៉ែត្រ ពីផ្លូវបំបែកខាងឆ្វេងពីផ្លូវជាតិលេខ៦ ត្រង់ចំណុចផ្សារស្គន់ ។ យោងតាមផែនទីរដ្ឋបាលបោះពុម្ពដោយក្រសួងអប់រំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៦ គុកវត្តបារាយណ៍ជាន់ដែក ស្ថិតនៅភូមិភាគឧត្តរ(៣០៣) ។ ជាង២០ឆ្នាំមុន ក្នុងអំឡុងរបបខ្មែរក្រហមចន្លោះឆ្នាំ១៩៧៥-៧៩ វត្តបារាយណ៍ជាន់ដែកទាំងមូល ត្រូវបានពួកខ្មែរក្រហមប្រែក្លាយទៅជាមន្ទីរសន្តិសុខ និងជាទីកន្លែងសម្លាប់រង្គាលប្រជាជនស្លូតត្រង់ និងព្រះសង្ឃរាប់ពាន់នាក់ យ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ដែលហាក់បីដូចជាព្រឹត្តិការណ៍គួរឲ្យរន្ធត់ ទើបនឹងកើតឡើងថ្មីៗ ចំពោះអ្នកទោសដែលធ្លាប់ជាប់ក្នុងវត្តបារាយណ៍ជាន់ដែក ហើយដែលនៅរស់នាពេលបច្ចុប្បន្ននេះ ។

លោកតាឡេ អាយុ ៧០ឆ្នាំ នៅភូមិដូង បានប្រាប់ឲ្យដឹងថា គាត់ធ្លាប់បានជាប់គុកក្នុងវត្តបារាយណ៍ជាន់ដែកអស់រយៈពេល៣ឆ្នាំ (ពីឆ្នាំ១៩៧៦-៧៨) ។ មុននឹងបញ្ជូនមកគុកវត្តបារាយណ៍ជាន់ដែក ពួកខ្មែរក្រហមបានចាប់រូបគាត់តាំងពីឆ្នាំ ១៩៧៤ មកម៉្លេះ ដោយប្រធានភូមិ ឈ្មោះសមមិត្ត ញ៉ែម ដែលស្លាប់បាត់ទៅហើយនោះជាអ្នករាយការណ៍ថា គាត់ជាជំទប់លេខ១ ពីរបបសីហនុ និងលន់ ណុល ។ ពួកខ្មែរក្រហមបញ្ជូនគាត់ទៅដាក់គុកក្នុងភូមិត្រដែតឲ្យទៅកាប់ព្រៃទាំងយប់ទាំងថ្ងៃ ។

ពួកខ្មែរក្រហមបានបញ្ជូនលោកតា ឡេ មកដាក់នៅក្នុងគុកវត្តបារាយណ៍ជាន់ដែកនេះ ដោយដាក់កម្រិតឲ្យក្រុមគាត់ដែលមានគ្នា៤នាក់ ធ្វើរទេះគោឲ្យបាន៤ ក្នុងមួយខែ ។ លោកតាបានប្រាប់ថា ដោយរោងជាងធ្វើរទេះគោនៅមិនឆ្ងាយពីក្លោងទ្វារចូលវត្ត គាត់បានឃើញផ្ទាល់នឹងភ្នែក ក្នុងមួយខែៗប្រជាជនប្រហែល៥ឡានជាមធ្យមត្រូវបានពួកខ្មែរក្រហមដឹកចូល ហើយពេលខ្លះហូរហៀរ ដោយគ្មានកន្លែងដាក់ ក៏ដឹកចេញទៅវិញខ្លះ ។ ក្នុងដើមឆ្នាំ១៩៨០ លោកតាឡេ មាននាទីជាប្រធានភូមិហើយបាននាំប្រជាជនក្នុងភូមិឲ្យចូលរួមក្នុងការគាស់សាកសព និងអដ្ឋិធាតុដើម្បីតម្កល់ទុកធ្វើបុណ្យ ។ លោកតាបានប៉ាន់ស្មានថា ពួកខ្មែរក្រហមសម្លាប់អ្នកទោសប្រហែលជា ១០០០ ទៅ២០០០ នាក់ ក្នុងវត្តបារាយណ៍ជាន់ដែក ។

លោកតា យឹង អាយុ ៦៥ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិដូងជាមួយគ្នានេះដែរបានរៀបរាប់ឲ្យដឹងថា លោកតាធ្លាប់ជាប់គុកនៅក្នុងវត្តបារាយណ៍ជាន់ដែកនេះដែរ ពីឆ្នាំ១៩៧៦-

៧៨ ដោយមូលហេតុថាក្នុងរបប លន់ ណុល គាត់ធ្វើចលនាព្រះពុទ្ធសាសនា ជាអាចារ្យវត្ត ។ ដោយមូលហេតុនេះហើយ បានជាពួកខ្មែរក្រហមចាប់គាត់មកដាក់គុកនៅទីនេះ ។ គាត់ចង្អុលបង្ហាញថាសាលាឆាន់ធំៗ និងវិហារធំៗនៅក្នុងវត្តសព្វថ្ងៃនេះ ត្រូវបានពួកខ្មែរក្រហមប្រើប្រាស់ជាគុក ។ គាត់បានឡើងទៅលើសាលាឆាន់មួយបង្ហាញពីកន្លែងដែលគាត់ត្រូវបានដាក់ខ្នោះជើងជាមួយអ្នកទោសរាប់សិបនាក់ទៀតដេករណ្ដូករណែល បញ្ច្រាសទិសគ្នា ដោយជើងជាប់ខ្នោះទៅនឹងរបារដែកដ៏វែង ជាជួរៗលើរនាបក្ដារ ។ អ្នកទោសទាំងអស់ព្រមទាំងរូបគាត់ផ្ទាល់ត្រូវបានធ្វើទារុណកម្ម ដោយបង្អត់អាហារ ដាក់ឲ្យរស់នៅក្នុងស្ថានភាពមានសង្អើចខាំ មូសខាំ ស្មោគគ្រោក ដេក អាចម៍នោម និងស៊ីចុកនៅកន្លែងតែមួយមិនតែប៉ុណ្ណោះ១៥ថ្ងៃ ទើបឲ្យងូតទឹកម្ដង ។

គាត់បន្តទៀតថា ថ្ងៃខ្លះមានអ្នកទោសស្លាប់ពី ៥ ទៅ ១០នាក់ ដោយអត់អាហារ និងជំងឺគ្មានថ្នាំព្យាបាល ហើយត្រូវបានអូសចេញតាមទ្វារចំហៀង ឆ្ពោះទៅខាងក្រោយវត្ត ។ លោកតា យឹង ប្រាប់ថា ឲ្យតែនឹកដល់រឿងនេះ គាត់នឹកឃើញអារម្មណ៍ព្រឺព្រួចតក់ស្លុត ។ មានពេលមួយនោះ អ្នកទោសនៅក្បែរគាត់ ត្រូវបានពួកខ្មែរក្រហមហៅឈ្មោះ ហើយដោះខ្នោះបណ្ដើរចេញទៅដោយកាណុងកាំភ្លើង ជាភ័ព្វសំណាងលោកតា យឹង ត្រូវបានដោះលែងឲ្យមកធ្វើរទេះជាមួយក្រុមតា ឡេ នៅខាងក្រៅឃុំវិញ រហូតដល់ឆ្នាំ១៩៧៩ ។

តាហៃ អាយុ ៦៧ឆ្នាំ រស់នៅភូមិត្រស់ ឃុំបល្ល័ង្កបានប្រាប់ថា ព្រះវិហារក៏ជាគុកដែរ ក៏ប៉ុន្តែអ្នកទោសទាំងនោះពុំដាក់ខ្នោះជើង ខ្នោះដៃទេ ។ អ្នកទោសទាំងនោះក៏ពុំតម្រូវឲ្យធ្វើការអ្វីដែរ ។ ពួកខ្មែរក្រហមយកវិហារនេះគ្រាន់តែសម្រាប់ដាក់អ្នកទោសរយៈពេលខ្លី រង់ចាំបញ្ជូនទៅសម្លាប់នៅរណ្ដៅខាងក្រោយវត្ត ។ លោកតា ហៃ រស់នៅក្បែរវត្តនេះក៏ធ្លាប់បានជាប់គុកក្នុងវត្តបារាយណ៍ដាន់ដែកនេះដែរ ហើយត្រូវបានពួកខ្មែរក្រហមដោះលែង នៅចុងឆ្នាំ១៩៧៧ ។ នៅចុងបំផុតឆ្នាំ ១៩៧៨ មានសន្តិសុខខ្មែរក្រហមនៅវត្តបារាយណ៍ដាន់ដែកម្នាក់បានរត់គេចខ្លួន នៅពេលដែលកងទ័ពវៀតណាមវាយចូល ហើយមកស្នាក់នៅផ្ទះគាត់ ២យប់ ។ ដោយការធ្វេសប្រហែសរបស់កងសន្តិសុខនោះ លោកតាហៃ បានលួចមើលឃើញក្នុងឯកសារដែលនៅជាប់ខ្លួនកងសន្តិសុខនោះ ។ តាមឯកសារដែលគាត់បានឃើញនោះថា អ្នកស្លាប់នៅវត្តបារាយណ៍ដាន់ដែកមានចំនួន ២៥១៤នាក់ ។ លោកតាហៃ បានបញ្ជាក់ថាតួលេខនេះគឺគាត់បានឃើញផ្ទាល់នឹងភ្នែក ។

លោកតា ហៃ បានចង្អុលបង្ហាញចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះដែលស្ថិតនៅខាងក្រោយវត្ត ក្បែរទីលានសម្លាប់ ។ លោកតា ឡេ និងលោកតា ហៃ បញ្ជាក់ប្រាប់ថារណ្ដៅធំៗចំនួនពី៣០ទៅ ៤០ ហើយរណ្ដៅនីមួយៗមានជំរៅ ២,៥០ម៉ែត្រ ទំហំ៣ម៉ែត្រ បួនជ្រុង និងរណ្ដៅតូចៗ សំរាប់ដាក់សាកសព ៣ ទៅ ៤នាក់ មានរាប់រយរណ្ដៅ ជុំវិញព្រះវិហារដូចរន្ធបាយខុមតម្រៀបជាជួរតៗគ្នា ។ លោកតាទាំងបីបានប្រាប់ថា ជនរងគ្រោះទាំងអស់ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ ដោយវាយនឹងពូថៅ ប្តុញញួរ ហើយធាក់ទម្លាក់ចូលទៅក្នុងរណ្ដៅរួមដែលជីកហើយស្រាប់ ។ លោកតា ហៃ បានរើសយកលលាដ៍ក្បាលជាច្រើន ហើយចង្អុលបង្ហាញស្នាមប្រេះស្រាំ និងស្នាមប្រហោងលើលលាដ៍ក្បាលផ្នែកខាងក្រោយ និងចំហៀង ដែលបង្ហាញថាជនរងគ្រោះត្រូវបានពួកខ្មែរក្រហមសម្លាប់ តាមរបៀបតែមួយដូចដែលគាត់បានប្រាប់មែន ។ តាមសំដីអះអាង របស់តា ហៃ គាត់បានដឹងតាមរយៈសន្តិសុខដែលស្នាក់នៅផ្ទះគាត់ដែលបានប្រាប់គាត់ថា ជនរងគ្រោះមានគ្រប់ប្រភេទដូចជា មន្ត្រីរបប លន់ ណុល ដែលមាននិន្នាការជាប៉ូលីស ទាហាន គ្រូ អ្នកទីក្រុងដែលជម្លៀសមកពីគ្រប់ទិសទី រួមទាំងព្រះរាជវង្សានុវង្សរបស់នរោត្តម ឧត្តមវង្ស និងមហេសី ព្រមទាំងបុត្រី ២ព្រះអង្គទៀតផង ។

លោកតាទាំង៣បានប្រាប់ពីការព្រួយបារម្ភរបស់ពួកគាត់ថា គំនរឆ្អឹងលលាដ៍ក្បាលនៃសាកសពជនរងគ្រោះមួយចំនួនធំត្រូវបានជ្រូក និង គោស៊ីអស់ ខ្លះទៀតបាត់បង់ដោយការរើ



កន្លែងតម្កល់ចុះឡើង ដោយកន្ទុះកន្លែងតម្កល់ត្រឹមត្រូវ ម្យ៉ាង ទៀតអដ្ឋិធាតុទាំងនេះរងការបាត់បង់ ដោយសារការទុកចោល ហាលវាល ហាលខ្យល់ ។ ប៉ុន្តែឥឡូវនៅខាងក្រោយវត្ត ឃើញ មានបូជនីយដ្ឋាន តម្កល់អដ្ឋិធាតុជនរងគ្រោះដែលដាក់គរលើគ្នា និងមានកំប៉ុងដើងធូបមួយនៅពីមុខ និងទង់ព្រលឹងមួយដោតជាប់ នឹងជញ្ជាំង ។ ព្រះសង្ឃនៅក្នុងវត្តនេះមានពុទ្ធដីកាថា មានឧបាសក ឧបាសិកា មកពីគ្រប់ទិសទីក្នុងខេត្ត និងខេត្តផ្សេងៗទៀតមកធ្វើ បុណ្យបញ្ជូនកុសលឲ្យជនរងគ្រោះ ដោយសារបានជឿថា ជាបង ប្អូនរបស់ខ្លួន ហើយដែលសង្ស័យថាពួកខ្មែរក្រហមបានយកមក សម្លាប់នៅទីនេះ ។ ជារៀងរាល់ឆ្នាំ ថ្ងៃទី២០ ខែឧសភា មន្ត្រី តំណាងមកពីគ្រប់ឃុំទាំងអស់ក្នុងស្រុក មកប្រារព្ធពិធីចងកំហឹង ចំពោះរបបប្រល័យពូជសាសន៍ ។

លោកតា ហៃ បានប្រាប់ ឲ្យដឹងអំពីប្រធានសន្តិសុខ នៅគុកវត្តបារាយណ៍ជាន់ដែក និង ឈ្មោះកងសន្តិសុខជាច្រើន ទៀតដែលទទួលខុសត្រូវនៅទីនោះ ។

លោកតាទាំង៣ បានបញ្ជាក់ថា ពួកគាត់ចង់បានតុលា ការមួយដែលអាចរកយុត្តិធម៌ពិតប្រាកដចំពោះរូបគាត់ និងឲ្យ ជនរងគ្រោះនៅទីនេះ គាត់សុំខ្លួនចូលតុលាការធ្វើជាសាក្សី ប្រសិនបើតុលាការ ត្រូវការរូបគាត់ ។ **ផាត កុសល**



## ខេត្ត ភូមិភាគ តំបន់ និងស្រុក

ប្រទេសកម្ពុជាយើងមាន១៩ខេត្ត គឺខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ចាម ស្វាយរៀង ព្រៃវែង កណ្ដាល តាកែវ កំពត កោះកុង កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ សៀមរាប ពោធិសាត់ និងខេត្តបាត់ដំបង ។ ក្នុងខេត្តទាំង១៩នេះ បើតាមការបែងចែកចាស់គឺមានស្រុក១១២ ឃុំ១.១៦០ និងភូមិជាច្រើនទៀត ។ ក្នុងសម័យតស៊ូនយោបាយសម្ងាត់ ក្នុងសម័យសង្គ្រាមផ្ទៃក្នុង និងក្នុងសម័យសង្គ្រាមបដិវត្តន៍ជាង៥ឆ្នាំកន្លងមកដើម្បីសម្រួលដល់ការទាក់ទង ការគ្រប់គ្រង និងកិច្ចដំណើរការសម្រេចភារកិច្ចបដិវត្តន៍គ្រប់ផ្នែកឲ្យបានល្អ អង្គការបដិវត្តន៍យើងបានបែងចែកប្រទេសកម្ពុជា ជាភូមិភាគ និងតំបន់ពីលើខេត្ត-ស្រុក-ឃុំ និងភូមិចាស់ថែមទៀត ។ ទន្ទឹមនេះយើងក៏បានចាត់តាំងសហករណ៍តាំងពីសម័យសង្គ្រាមបដិវត្តន៍មកដែរ ។ (បញ្ហាល្អិតអំពីសហករណ៍ និងមានរៀបរាប់ក្នុងមេរៀនទី១២) ។ ក្រោយមហាជ័យជំនះ១៧ មេសា ១៩៧៥ ដោយឃើញថាការបែងចែកបែបនេះសមស្របនឹងសភាពជាក់ស្ដែងទាំងខាងផ្នែកភូមិសាស្ត្រ ទាំងខាងផ្នែកនយោបាយ និងសេដ្ឋកិច្ច អង្គការបដិវត្តន៍យើង ក៏បានរក្សាទុកភូមិភាគ និងតំបន់តមកទៀតដើម្បីងាយស្រួលដល់កិច្ចការរដ្ឋបាលផ្សេងៗ ។



អត្តបទភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផ្នែកនយោបាយ បោះពុម្ពដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ លើកទី១ ឆ្នាំ១៩៧៧ សម្រាប់ថ្នាក់ទី២ (ផែនទីបោះពុម្ពផ្សាយ ឆ្នាំ១៩៧៦)

បច្ចុប្បន្ននេះកម្ពុជាប្រជាធិបតេយ្យយើងចែកជា៦ភូមិភាគ និងតំបន់ខ្លះទៀតដែលចាត់តាំងដោយឡែក មិននៅក្នុងភូមិភាគណា ។ ឯក្រុងកំពង់សោមក៏ជាទីក្រុងដែលចាត់តាំងដោយឡែកដូចតំបន់មួយចំនួនទៀតដែរ ។ តំបន់ ឬទីក្រុង ដែលចាត់តាំងដោយឡែកនេះទាក់ទងការងារជាមួយអង្គការរដ្ឋតែម្ដងមិនតាមរយៈអង្គការភូមិភាគណាមួយទេ ។ ទន្ទឹមនេះយើងក៏បានចាត់តាំងស្រុកថ្មីមួយចំនួនទៀតដែរដូចជាស្រុកកោះជ័យ (ពីមុនហៅព្រះស្ដេច) ស្រុកក្រសាំងក្នុងភូមិភាគបូព៌ា ស្រុកតាំងគោក-ស្រុកបារាយណ៍ ក្នុងភូមិភាគឧត្តរ ស្រុកដាំសង្កែ... ក្នុងភូមិភាគនិរតី ស្រុកថ្មសរ ក្នុងភូមិភាគបស្ចិម ស្រុកកណ្ដៀង ស្រុកក្លាត ស្រុកផ្លាម្អម ស្រុកសំឡូត...ក្នុងភូមិភាគពាយ័ព្យជាដើម ។

ភូមិភាគទាំង៦របស់យើងគឺ ភូមិភាគឥសាន ភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ ។ ភូមិភាគទាំងអស់នេះ យើងមិនមែនចាត់តាំងឲ្យនៅក្នុងអង្គភាពខេត្តមួយៗតែម្ដងទេ គឺយើងកាត់ចេញពីខេត្តនេះខ្លះ ខេត្តនោះខ្លះមកបញ្ចូលគ្នា ឬយកខេត្ត២ ឬច្រើនមកបញ្ចូលធ្វើតែមួយភូមិភាគ ។ ឧទាហរណ៍ ភូមិភាគបូព៌ា យើងយកខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល ហើយកាត់យកពីខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយឆ្វេងទន្លេមេគង្គទាំងអស់ ហើយនិងកាត់យកខេត្តក្រចេះមួយស្រុក គឺស្រុកឆ្លូងព្រមទាំងកាត់យកពីខេត្តកណ្ដាលមួយផ្នែកទៀត ។ ឧទាហរណ៍ ភូមិភាគនិរតីយើង យកខេត្តកំពតនិង ខេត្តតាកែវ ទាំងមូល ហើយកាត់យកពីខេត្តកំពង់ស្ពឺ ២ស្រុក គឺស្រុកសំរោងទង និងស្រុកគងពិសី ហើយនិងកាត់យកពីខេត្តកណ្ដាល ៥ស្រុក គឺស្រុកកណ្ដាលស្ទឹង ស្អាង កោះធំ កៀនស្វាយ និងស្រុកលើកដែក ។ ឧទាហរណ៍ ភូមិភាគពាយ័ព្យ យើងយកខេត្តពោធិសាត់ និងខេត្តបាត់ដំបង ទាំងមូល ។ល ។

ភូមិភាគនីមួយៗ ចែកជាច្រើនតំបន់ ។ ហើយតំបន់នីមួយៗក៏ចែកជាច្រើនស្រុកទៅទៀតដែរ ។ មកដល់ដើមឆ្នាំ១៩៧៧ ក្នុងកម្ពុជាប្រជាធិបតេយ្យយើងទាំងមូល ស្រុកនីមួយៗបានចាត់តាំងជាសហករណ៍ឃុំ ដែលមានសមាជិកមួយពាន់គ្រួសារជាទូទៅហើយ ។ តែតាមសភាពជាក់ស្ដែង និងសេចក្ដីត្រូវការចាំបាច់ខាងកិច្ចការពារ និងកសាងប្រទេសស្រុកមួយចំនួននៅមានចែកជាឃុំ និងសហករណ៍រួមភូមិ «២ ឬ៣ភូមិដែរ» ។ ជាទូទៅសហករណ៍រួមភូមិ មានសមាជិកតិចជាងមួយពាន់គ្រួសារ ។

ភូមិភាគ តំបន់ ស្រុក ឬឃុំនីមួយៗ សុទ្ធតែមានអង្គការទទួលខុសត្រូវហៅថា «គណៈកម្មាធិការបម្រើប្រជាជន» ។ សហករណ៍នីមួយៗរបស់ប្រជាជនកសិករសមូហភាពយើង ក៏មានគណៈកម្មការទទួលខុសត្រូវដែរហើយហៅថា «គណៈកម្មការសហករណ៍» ។

# ជនជាតិចាមនៅគុកទួលស្លែង

ជនជាតិចាម ក៏ដូចជាជនជាតិភាគតិចផ្សេងៗទៀតដែរ ត្រូវបានពួកខ្មែរក្រហមចាប់យកទៅដាក់គុកទួលស្លែង ហើយក្រោយឆ្នាំ១៩៧៩ បានបន្សល់ទុកនូវឯកសារពាក់ព័ន្ធជាច្រើនសន្ធឹកសន្ធាប់ដូចជាប្រវត្តិរូប បញ្ជីអ្នកទោស ឯកសារចម្លើយសារភាពជាដើម ។ អ្នកប្រវត្តិសាស្ត្រល្បីៗពុំបានចាប់អារម្មណ៍លើផ្នែកជនជាតិភាគតិចឡើយដោយបដិសេធថា ព័ត៌មានទាំងស្រុងក្នុងឯកសារនេះមិនមែនជាការពិត ហើយថាអ្នកទោសឆ្លើយក្រោមការបង្ខិតបង្ខំ ។ ផ្ទុយទៅវិញ តាមរយៈឯកសារទាំងនេះ ខ្ញុំបានរកឃើញការពិតជាច្រើន ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញរបស់ខ្មែរក្រហមមកលើក្រុមជនជាតិភាគតិចជាច្រើន ដែលក្នុងលេខនេះ ខ្ញុំសូមលើកយកករណីជនជាតិចាម ឈ្មោះ ហាជី សាឡេះ យ៉ាស់យ៉ា ហៅកុងរីម៉ាត់ ឬហៅ សារាយ ក្នុងរបបខ្មែរក្រហម ។

យ៉ាស់យ៉ា បានឆ្លើយសារភាពដល់ទៅ៥៨ទំព័រ តាមសំណួររបស់ «មិត្តឡេង» ដែលស្ថិតនៅក្នុងក្រុមសួរចម្លើយ «ក្រុមបងម៉ុនតូច» នៃគុកទួលស្លែង ។ ទំព័រទាំងអស់នេះបានរៀបរាប់យ៉ាងពិស្តារពីប្រវត្តិរូបផ្ទាល់ខ្លួន ការសិក្សា ប្រវត្តិការងារ ប្រវត្តិក្បត់នឹងខ្មែរក្រហម ។ តាមខ្លឹមសារសម្ភាសន៍របស់ខ្ញុំ ចំណុចតែមួយដែលមិនអាចបញ្ជាក់ថាពិតនោះ គឺអំពើយ៉ាស់យ៉ាក្បត់ខ្មែរក្រហម ។ មកដល់ថ្ងៃនេះយើងមិនទាន់រកឃើញអ្នកនៅរស់ណាដឹងពី «ប្រវត្តិក្បត់» នោះឡើយ ។ ឬមួយយ៉ាស់យ៉ាមិនបាន «ក្បត់» ហើយសរសេរតាមការបង្ខំរបស់ពួកអ្នកសួរឈ្មោះ «ឡេង» នោះ? ចំណុចសំខាន់ដែលយើងរកឃើញនោះគឺ យ៉ាស់យ៉ា ពិតជាសមាជិកព្រឹទ្ធសភាក្នុងរបបសាធារណរដ្ឋខ្មែរ ជាមន្ត្រីផ្នែកកិច្ចការខ្មែរអ៊ីស្លាមនៅក្រសួងធម្មការក្នុងរបបសង្គមរាស្ត្រនិយម ហើយពិតជាត្រូវបានពួកខ្មែរក្រហមចាប់ខ្លួន និងយកមកគុកទួលស្លែងមែន ។ ចំណែកឯប្រវត្តិផ្ទាល់ខ្លួនការសិក្សា ការងារផ្សេងៗទៀត ក៏យើងខ្ញុំបានធ្វើការផ្ទៀងផ្ទាត់ឃើញថាពិតដែរ ពោលគឺឯកសារចម្លើយសារភាពដូចគ្នានឹងសំដីអ្នកដែលយើងខ្ញុំបានសម្ភាសន៍ជាច្រើននាក់ ដែលជាអ្នកស្គាល់ និងជាសាច់ញាតិផ្ទាល់ផង ។

បន្ទាប់ពីសារភាពថា ខ្លួនបានបំផុសមេដឹកនាំចាម ឈ្មោះ ហ៊ីម ម៉ាន និងលីមូហាំម៉ាត់ ព្រម ទាំងប្រជាជននៅភូមិគោហេ ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ឲ្យងើបឡើងប្រឆាំងនឹងខ្មែរក្រហមរួចមក យ៉ាស់យ៉ា បន្ថែមថា «យប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៥ ពេលម៉ោង១០យប់ អង្គការបានចាប់ខ្លួនខ្ញុំពីផ្ទះ នៅភូមិគោហេ យកទៅវត្តដំរីសរកាកោង» ។ ក្មួយរបស់ យ៉ាស់យ៉ា ជាប់គុកនៅវត្តនេះដូចគ្នា ហើយបានរស់នៅដល់សព្វថ្ងៃបានប្រាប់ខ្ញុំថា គាត់បានជួបពូ យ៉ាស់យ៉ា ក្នុងគុកវត្តដំរីសនោះ ។ «ប្រហែលជាម៉ោង៥ល្ងាច គាត់ចូលមកឃើញខ្ញុំនៅក្នុងនោះ គាត់ឃើញខ្ញុំគាត់ដួលមួយសន្ទុះហើយវារមក ។ នៅក្នុងនោះមានគ្នាប្រហែល៣០នាក់ ។ គាត់ចេះតែខិតបន្តិចម្តងៗមកដល់ខ្ញុំហើយគាត់ផ្តេកក្បាលមកលើភ្លៅខ្ញុំនេះហើយ គាត់យកដៃខ្ញុំស្ទាបក្បាលគាត់ ហើយគាត់និយាយថា ក្មួយមកដល់ទីនេះប៉ុន្មានថ្ងៃហើយ ហើយខ្ញុំប្រាប់គាត់ថា ខ្ញុំមកនៅទីនេះប្រហែលកន្លះខែហើយ ហើយគាត់និយាយថាអត់ឃើញក្មួយឯងមកដែរ អញនៅជាប់បន្ទប់នេះ ។ គេយកអញទៅសួរចម្លើយ ។ ឥឡូវវាបញ្ជូនឲ្យជួបឯង ។ អញ្ចឹងបើអញស្លាប់នៅពេលនេះ ក្មួយឯងតស៊ូណាក្មួយ សុំវាទៅ «សំយ៉ាងម៉ាយិត» ថ្វាយបង្គំក្នុងពីធីបញ្ចុះសាកសពឲ្យអញផង ។ គាត់យកដៃខ្ញុំទៅស្ទាបក្បាលគាត់ ឃើញថាទន់ណាស់ទៅហើយ ។ ខ្ញុំសួរគាត់ថាវាវ៉ៃអីហ្នឹងមា គាត់ថានឹងពីស្តូឡេ ។ ដល់ម៉ោង៦កន្លះ ពួកវាក៏បានបើកទ្វារមកនិយាយថា រកឃើញហើយតើ សាឡេះ យ៉ាស់យ៉ា រកមុខយូរហើយ ឥឡូវមកក្រោមកដឹងគ្នាហើយថ្ងៃនេះ ។ នៅពេលខ្មែរក្រហមទាញ យ៉ាស់យ៉ា ទៅបន្តិច ក្មួយរបស់

យ៉ាស់យ៉ា បានត្រឹម «ពុស្ដូរគាត់ស្រែកខាងក្រៅពុស្ដូរអ៊ុះៗៗ» ។ អ្នកជាប់គុកដែលនៅក្បែរជញ្ជាំងលួចគោងមើលតាមជញ្ជាំង មិនដឹងជា ឃើញអ្វីខ្លះស្រាប់តែស្ងុតពេកដួលធ្លាក់មកក្រោយ ។ តាមខ្ទឹមសារសម្ភាសន៍ចាប់ពីពេលនោះមក យ៉ាស់យ៉ា បាត់ដំណឹងរហូត ។ តែតាមបញ្ជីស្បែកខ្មៅគុកទួលស្លែង យ៉ាស់យ៉ា បន្តទទួលទារុណកម្មក្នុងគុកទួលស្លែង រហូតដល់ស្លាប់ នៅថ្ងៃទី២ ខែឧសភា ១៩៧៦ ។ រឿងចាប់ខ្លួន យ៉ាស់យ៉ា នេះ ធ្វើឡើងក្រោយពីមានការបះបោរកាលពីថ្ងៃទី២២ វិច្ឆិកា ឆ្នាំ១៩៧៥ ។ ការ បះបោរត្រូវបានខ្មែរក្រហមបង្ក្រាប ហើយអ្នកបះបោររាប់រយនាក់ ត្រូវបានចាប់ដាក់គុកវត្តដំរីស ។ មានអ្នកជាប់នៅវត្តនេះ ហើយនៅរស់ចំនួនពីរនាក់ ដែលយើងបានជួបសម្ភាសន៍ ។ ប្រជាជនភាគច្រើនស្គាល់វត្តនេះថា ជាវត្ត ដំរីស រីឯប្រជាជនមួយចំនួនទៀត ហៅវត្តនេះថាជាវត្តសេរីមង្គលតាមផ្លាកនៅក្លោងទ្វារសព្វថ្ងៃនេះ ។

សរុបមកវិញ យើងបានដឹងពីពេលវេលាចាប់ខ្លួន ទីកន្លែងឃាត់ខ្លួន អ្នកបានជួប និងជាប់គុកជាមួយ យ៉ាស់យ៉ា ចម្លើយសារភាពឈ្មោះ យ៉ាស់យ៉ា ស្លាប់ដោយ «ស្ពឹក និងគ្រាំខ្លួន» ក្នុងបញ្ជីអ្នកទោសគុកទួលស្លែង រូបថត យ៉ាស់យ៉ា កាលពីនៅជាសមាជិកព្រឹទ្ធសភា ព្រមទាំងមានអ្នកធ្លាប់ឃើញរូបថត យ៉ាស់យ៉ា ក្នុងគុកទួលស្លែងរហូតដល់សព្វថ្ងៃនេះទៀតផង ។

យ៉ាស់យ៉ា ជាសមាជិកព្រឹទ្ធសភាម្នាក់ ក្នុងចំណោមសមាជិក៤០នាក់ ដែលមានប្រធានឈ្មោះ សូ ខាំខូយ ក្នុងរបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខលន់ណុល ។ ក្នុងសម័យសង្គមរាស្ត្រនិយមនាទសវត្សរ៍ឆ្នាំ៦០ យ៉ាស់យ៉ា ជាមន្ត្រីម្នាក់ក្នុងក្រសួងធម្មការ ធ្លាប់កាន់មុខតំណែងជានាយការិយាល័យរដ្ឋបាល របៀបការិយាល័យបុគ្គលិក និង គណនេយ្យ ព្រមទាំងផ្នែកកិច្ចការខ្មែរអ៊ីស្លាម ។ គាត់ធ្លាប់ឈរឈ្មោះបោះឆ្នោតឲ្យគណបក្សសង្គមរាស្ត្រនិយមនៅមណ្ឌលក្រែក ក្នុងខេត្តកំពង់ចាម ។ គាត់ធ្លាប់ចូលរួមសន្និសីទអ៊ីស្លាម អាស៊ី-អាព្រិច ឥណ្ឌូនេស៊ី ឆ្នាំ១៩៦៥ ។ គាត់បានទៅធ្វើបុណ្យ ហាជី នៅទីក្រុងមេកា ប្រទេសអារ៉ាប់ ។ យ៉ាស់យ៉ា កើតនៅឆ្នាំ១៩២២ រៀនខាងសាសនាអ៊ីស្លាម និងវប្បធម៌ទូទៅនៅជ្រោយចង្វារ ភ្នំពេញ មានភរិយាឈ្មោះ អាមីណាស់ មានម្ដាយឈ្មោះ ខទីចះ និងឪពុកឈ្មោះ សាឡេះ ។ **ស៊ឹម សុរិយ៉ា**



# ចម្លើយសារភាពរបស់ ធូ ហៃ

ឯកសារចម្លើយសារភាពអ្នកទោសគុកទួលស្លែងលេខ ៨៣(J) បាននិយាយអំពីមូលហេតុ ធូ ហៃ ក្លាយទៅជាខ្មាំងរបស់អង្គការ ។ ឯកសារនេះមាន ៣៨ទំព័រ ហើយនៅទំព័រទី៣ មានចំណារមួយនៅខាងលើបានសរសេរថា «ទុកជូនសមមិត្ត ម៉ុក ទំនាក់ទំនងតំបន់២៥ និង៣៣ និរតី» ផ្នែកខាងក្រោមមានចំណារថា «ទំនាក់ទំនង ២៨-៣-៧៨ និង ១១-២-៧៨» ។ អ្នកសរុបចម្លើយរបស់ ធូ ហៃ គឺសមមិត្ត «ភាព» ។ នៅផ្នែកខាងក្រោយទំព័រ៣៥-៣៧ មានភ្ជាប់មកនូវបញ្ជីឈ្មោះ រួមមានទាំងមុខងារនៅលាយឡំគ្នា ក្នុងចំណោមអ្នកដែលជាប់ពាក់ព័ន្ធក្នុងប្រវត្តិ ធូ ហៃ ក្នុងនោះមានឈ្មោះ៤នាក់ បានចាប់ខ្លួនហើយ និងឈ្មោះ១៨នាក់ទៀត មានសញ្ញាខ្វែងជើងក្អែក ។



**ធូ ហៃ ជានរណា?**

ធូ ហៃ ជាកម្មករ ។ មុនពេលចាប់ខ្លួន ធូ ហៃ គឺជាកម្មករនៅរោងចក្រអារឈើ អ៥ មានស្រុកកំណើតនៅភូមិតាឡៃ ឃុំព្រែកអំបិល ស្រុក ២០(ស្អាង) តំបន់២៥ ខេត្តកណ្តាល ប្រពន្ធឈ្មោះ ហម គ្រាវ និងមានកូនប្រាំពីរនាក់ ។ ក្នុងរយៈពេលធ្វើការនៅរោងចក្រអារឈើ អ៥ គាត់មានទំនាក់ទំនងជាមួយប្អូនថ្លៃថៅកែ ឈុន ទា ឈ្មោះ មុច ។ មុច នេះ បានបបួលគាត់ចូលធ្វើជា ទាហាន ប៉ុន្តែដោយមិនចេះអក្សរ ក៏ធ្វើជាអ្នកស៊ើបការណ៍ (ស៊ី.អាយ.អេ) វិញ។ ធូ ហៃ ធ្វើជាកម្មករអារឈើផង ធ្វើសកម្មភាពស៊ើបការណ៍ផងគឺចាប់តាំងពីឆ្នាំ១៩៦០ ដល់ ឆ្នាំ១៩៧៧ ។ នៅឆ្នាំ១៩៦០ គាត់បានក្លាយជាសកម្មជន ស៊ី.អាយ.អេ ពេញសិទ្ធិក្រោមការតែងតាំងរបស់លោកសក្តិ៤ កុម្ម៉ង់ដង់សៅ និង សែម តាមរយៈ មុច ។ ក្រោយមកនៅថ្ងៃទី ២៦ ខែ១២ ឆ្នាំ១៩៧៧ ត្រូវពួកខ្មែរក្រហមចាប់ខ្លួនដាក់ក្នុង គុកទួលស្លែង ឬ មន្ទីរស-២១ ។ ក្រោមការសួរចម្លើយពី ប្រាក់ ខន, ធូ ហៃ រៀបរាប់ពី សកម្មភាពខ្លួនដូចតទៅ៖

**សកម្មភាពក្នុងជួរ ស៊ី.អាយ.អេ**

ក្រោយពីបានតែងតាំងរួច ធូ ហៃ ទទួលភារកិច្ចជាអ្នកឃោសនាបំផុសប្រជាជនកុំឲ្យជឿលើខ្មែរក្រហម តាមដានខ្មែរក្រហម និងមើលប្រជាជនណា ត្រូវដៃជើងយកស្បៀងឲ្យខ្មែរក្រហម ។ នៅឆ្នាំ១៩៦១ ធូ ហៃ ត្រឡប់មកធ្វើជាកម្មករអារឈើវិញ កសាងបានកម្លាំង ៣នាក់ ឈ្មោះ ស្រេង, ថ្វាង, ស្រឿន ដែលជាកម្មករអារឈើ នៅភូមិសំប៉ាន ស្រុកកោះធំ ខេត្តកណ្តាល ។ ឆ្នាំ១៩៦២ ធូ ហៃ រាយការណ៍ឲ្យសៅ និងសែម ពីកម្លាំងដែលបានកសាង ។ សៅ-សែម បានណែនាំ ធូ ហៃ ឲ្យខិតខំប្រឹងបន្ថែមទៀតនូវចំណុចខាងលើ ដោយប្រគល់រង្វាន់លើកទឹកចិត្តចំនួន១៥០០រៀលផង ។ ក្នុងឆ្នាំដដែល ធូ ហៃ កសាងបានកម្លាំង២នាក់ទៀត ។ កម្លាំងទាំង៥នាក់របស់ ធូ ហៃ នេះ ត្រូវសែម-សៅ បញ្ចូលជាក្រុមស៊ី.អាយ.អេ នៅផ្សារព្រែកល្ពៅ ទាំង៥នាក់នោះឈ្មោះ ស្រេង ថ្វា, ស្រឿន, ប្រាយ និងចាម សុទ្ធតែជាកម្មករអារឈើដូចគ្នា ។

ឆ្នាំ១៩៦៣ ធូ ហៃ បានរៀបការជាមួយកូនស្រីថៅកែរោងចក្រអារឈើម្នាក់ឈ្មោះ ឈុន ទា ក្រោយមកកម្មករបានធ្វើការបះបោរដេញវ៉ៃថៅកែនោះរត់បាត់ទៅ ។ ធូ ហៃ នាំប្រពន្ធទៅធ្វើការរោងចក្រព្រែកល្ពៅឲ្យថៅកែឡេងវិញ រួចភ្ជាប់ខ្សែ ស៊ី.អាយ.អេ ជាមួយថៅកែឡេង ដែលជាខ្សែរបស់កុម្ម៉ង់ដង់សៅ ។ ថៅកែឡេង បានអប់រំឲ្យខំកសាងកម្លាំងស៊ី.អាយ.អេ

តាមដានចំពោះជនណាដែលបម្រើសកម្មភាពឲ្យខ្មែរក្រហម បើមានសកម្មភាពត្រូវរាយការណ៍ រួចហើយត្រូវបំផុសប្រជាជនកុំឲ្យជឿខ្មែរក្រហម ផាកជឿលើអាមេរិកវិញ ។ ក្រោមការណែនាំរបស់ថៅកែឡេង ឌូ ហៃ បានធ្វើការសក្តិស្មើជាមួយថៅកែសាមគន និងថៅកែបៅ ។ ក្រោយមកបានជួបសែម ។ សែមដឹងថា ឌូ ហៃ ត្រឡប់មកវិញ ក៏ឲ្យភ្ជាប់ទំនាក់ទំនងកម្លាំងរបស់គាត់បីនាក់ទៀតគឺ ស៊ិន ស៊ុង ហេង ។ អ្នកទាំងបីនេះក៏កសាងបានកម្លាំងបីនាក់ដែរ ទាំងអស់នេះរួមគ្នាកសាងបានកម្លាំង៣នាក់ទៀតធ្វើការបំផុសប្រជាជនក្នុងភូមិថា បើមានខ្មែរក្រហមត្រូវរាយការណ៍ឲ្យគាត់ ។ ដល់ពាក់កណ្តាលឆ្នាំ១៩៦៣ ឌូ ហៃ ទទួលបញ្ជាពី សៅ ស៊ុំ សែម ទៅស៊ើបការណ៍នៅខេត្តកំពត ទៅទំនាក់ទំនងជាមួយទាហានចាស់ជាខ្សែរបស់សែម រួចក៏នាំគ្នាទៅពិនិត្យមើលសកម្មភាពខ្មែរក្រហម បំផុសឲ្យប្រជាជនស្អប់ខ្មែរក្រហម កុំឲ្យជឿលើខ្មែរក្រហម ព្រោះតែកាលណាមានខ្មែរក្រហមនៅកន្លែងណារកស៊ីអីក៏មិនបានដែរ ។ ដល់ចុងឆ្នាំ១៩៦៣ ឌូ ហៃ នាំគ្រួសារមកនៅព្រែកអំបិល ខេត្តកណ្តាល ។ បន្ទាប់មកធាក់ស៊ីក្លូនៅភ្នំពេញជាមួយ ហេង ។ ហេង ធាក់ស៊ីក្លូពេលយប់ ហៃ ធាក់ស៊ីក្លូពេលថ្ងៃ ។ ឆ្នាំ១៩៦៤ ឌូ ហៃ បានមកទាក់ទងជាមួយប៉ូលីសខេត្តក្រចេះ ឈ្មោះ សៀន និងម្នាក់ទៀតឈ្មោះ លី ដែលជាខ្សែសែមដែរ តាមរយៈ ហេង រួចក៏ធ្វើការនៅរោងអារឈើ ខេត្តក្រចេះនេះរហូតដល់ឆ្នាំ១៩៦៦ ។ ក្នុងរយៈពេលនោះ ឌូ ហៃ កសាងបានកម្លាំងបីនាក់ ដោយលើកខ្លឹមសារអប់រំអ្នកទាំងបីឲ្យយល់ពីសិទ្ធិនៅអាមេរិកដែលសម្បូរសប្បាយ រកស៊ីដោយសេរីតាមចិត្ត និងធ្វើជា ស៊ី.អាយ.អេ មានមុខមាត់ មានប្រាក់ចាយ ។ ពេលកសាងបានកម្លាំងទាំងបីហើយទើប ឌូ ហៃ ត្រឡប់មកស្រុកកំណើតវិញនៅចុងឆ្នាំ១៩៦៦ ហើយទៅរកស៊ីអារឈើនៅឃុំឈើខ្មៅ ស្រុកកោះធំ តំបន់២៥ ខេត្តកណ្តាល វិញបានមួយខែ ក្រោយមកក៏ធ្វើការជាមួយមនុស្សបីនាក់នៅឈើខ្មៅគឺ ផាត, ឆាង, ស៊ែង ជាខ្សែរបស់សៅ ដែរ ។

ឆ្នាំ១៩៦៧ ឌូ ហៃ ទទួលផែនការពី ផាត ឲ្យបំផុសប្រជាជនប្រឆាំងនឹងខ្មែរក្រហម តាមដានប្រជាជនក្រែងយកស្បៀងឲ្យខ្មែរក្រហម និង កសាងកម្លាំងស៊ី.អាយ.អេ ។ ឆ្នាំ១៩៦៧-៦៨ ឌូ ហៃ ចាប់បានខ្មែរក្រហមពីរនាក់តាមរយៈ ស៊ិន និងស៊ុង ឲ្យការណ៍មកពីព្រៃល្វាថា ទាំងពីរនាក់នេះនៅជាមួយខ្មែរក្រហម ខេត្តកំពត ។ រួចរាយការណ៍ ឲ្យឈ្មោះ នាង ចាប់យកទៅ ។

ឆ្នាំ១៩៦៩ ឌូ ហៃ ត្រឡប់មកស្រុកកំណើតវិញ នាំប្អូនធ្វើការជាមួយ យុត ក្រោយពេលដឹងថា យុត ជាខ្សែរបស់ ផាត ។ ឌូ ហៃ បានណែនាំ ចក់-ដាវ ឲ្យ យុត បានស្គាល់ ដើម្បីធ្វើការជាមួយគ្នា ។ សកម្មភាព ហៃ ក្នុងឆ្នាំ១៩៦៩នេះ ចាប់ប្រជាជនពីរនាក់ដែលទទួលដំណឹងថា ជាខ្មែរក្រហមមកពីតំបន់៣៣ ភូមិភាគនិរតី តែត្រូវលែងវិញ ។

ឆ្នាំ១៩៧០ ឌូ ហៃ ចាប់ផ្តើមធ្វើការជាមួយ យុត (អតីតមេឃុំ) និងកម្លាំងគាត់បីនាក់ ។ យុត បានលើកពីសភាពការណ៍ ឆ្នាំ១៩៧០នេះ មានយួនចូលស្រុកច្រើន ហើយដូច្នេះត្រូវបំផុសប្រជាជនកុំឲ្យគាំទ្រយួន និងជួយលាក់កម្លាំងវដ្ឋការចាស់ៗ បើកាលណាគេសួរកុំប្រាប់ ដើម្បីលាក់កម្លាំងទុកធ្វើការបន្តទៀត ។

ឆ្នាំ១៩៧១ យុត បានឲ្យ ហៃ ចក់ ដាវ ធ្វើការជាមួយគាត់ ព្រោះបានភ្ជាប់ខ្សែយួនខាងជើង ឬយួនវៀកកុង តែរូបភាពបដិវត្តន៍មានខ្លឹមសារដណ្តើមយករដ្ឋអំណាចពីបដិវត្តន៍ដូចស៊ី.អាយ.អេ ដែរ ។ តែទាំងបីនាក់មិនយល់ស្របតាម ព្រោះគាត់មានកូនច្រើនពេក ។ យុត យល់ព្រមតែត្រូវបន្តធ្វើសកម្មភាពខាងក្រោយ បំផុសបំផុលប្រជាជនកុំឲ្យគាំទ្រកម្លាំងបដិវត្តន៍ ឲ្យតាមដានមន្ទីរបដិវត្តន៍ ជួបនៅកន្លែងណា ត្រូវបំផ្លាញចោល ពេលចប់ត្រូវត្រឡប់មកវិញ ។ យុត បានឲ្យ ហៃ អប់រំប្រពន្ធខ្លួនដើម្បីធ្វើការរួមគ្នា ព្រោះបើប្តីធ្វើការហើយ ប្រពន្ធមិនធ្វើវាមិនកើត ។ ក្រោយមក ហៃ បានអប់រំប្រពន្ធឲ្យធ្វើការជាមួយ ដោយប្រគល់ភារកិច្ចឲ្យអនុវត្តសកម្មភាពផ្ទុះផ្ទៀលខាងផ្នែកស្ត្រី ដែលនៅក្នុងភូមិឲ្យមានទំនាស់និងគ្នា ។

ឆ្នាំ១៩៧២ ហៃ បាននាំ ហេង មកភ្ជាប់ខ្សែជាមួយ

យុតៗក៏យល់ព្រមប្រាំថ្ងៃក្រោយ យុត ក៏ប្រកាសឲ្យ ហេ ហៃ និងប្រពន្ធចូលក្នុងខ្សែបក្សពលករវៀតណាមខាងជើង ក្នុងពេលនោះមានម្នាក់ឈ្មោះ សុង ហេង បង្ហាញយុថ្កា ដែលដាក់ហោប៉ៅថា នេះជារូបសញ្ញា របស់បក្សពលករ ។ ក្នុងឆ្នាំនេះដដែល ហៃ ចក់ និងដាវ បានចុះទៅបំផុសប្រជាជនឲ្យទំនាស់ទាមទារពីគណៈសង្កាត់ឲ្យបើកផ្លូវចេញធ្វើសំបុត្រស្នាមឲ្យប្រជាជនចេញចូលទៅដីតំបន់៣៣ ដើម្បីយកស្រូវអង្ករទៅដោះដូរ រួចមកបានចុះទៅបំផ្លាញរហាត់ទឹកចោលទៀត ។

ឆ្នាំ១៩៧៣ ទាំងបីនាក់ដដែលអនុវត្តផែនការបំផុសរវាងសហករណ៍មួយ ទៅសហករណ៍មួយ ឲ្យទំនាស់គ្នា បំផ្លាញសម្ភារៈក្នុងសហករណ៍ ។ បន្ទាប់មក ហៃ បានធ្វើទំនាក់ទំនងឈ្មោះ សុន ណែនាំក្រុមខ្លួនឲ្យស្គាល់ដើម្បីសហការគ្នា ក្រោយពីឯកភាពគ្នាហើយ ក៏រួមគ្នាទៅបំផ្លាញទង្គិល រហាត់ទឹកនៅសហករណ៍ភូមិសំប៉ាន់ក្រោម ឃុំព្រែកអំបិល ខេត្តកណ្តាលទៀត ។

ឆ្នាំ១៩៧៤ សុង ហេង គ្រូចក់ បុន ហៃ និងមេឃុំយុត ប្រមូលកម្លាំងមកប្រជុំគ្នានៅចុងភូមិព្រែកអំបិល ដើម្បីពង្រឹងការអនុវត្តន៍ភារកិច្ចពិសេសក្នុងសហករណ៍ឲ្យរេចរិលមិនបាច់តែជួរបដិវត្តន៍ទេ ។ ខ្លួននិងបក្សពួកចុះធ្វើសកម្មភាពបន្ត ដូចជាបំផ្លាញសម្ភារៈសហករណ៍នៅសំប៉ាន់លើ ដោយទម្លាក់ឧបករណ៍នោះទៅក្នុងទឹកអស់ ។ ដល់ខែ៥ ទៅបំផ្លាញស្រូវសហករណ៍ បោះពន្លិចកណ្តាប់ស្រូវអស់មួយដួន និង កាប់ជើងគោរបស់សហករណ៍ព្រែកតាឡៅ ។ នៅខែ១០ ទៅដាន់ពោតដែលទើបនឹងដុះខ្ទេចអស់ រួចក៏បន្តសកម្មភាពទៅបំផ្លាញទង្គិល រនាស់រហាត់ទឹក នៅភូមិត្រើយត្រឹង្ស ឃុំព្រែកអំបិល ខេត្តកណ្តាល ។

ឆ្នាំ១៩៧៥ ក្រោយថ្ងៃរំដោះ ហៃ ត្រូវអង្គការដកឲ្យមកធ្វើជាកម្មករអារឈើនៅភ្នំពេញវិញ ។ ហៃបានមកជួបមនុស្សម្នាក់ឈ្មោះ អាន បន្ទាប់ពីរាក់ទាក់គ្នាមកទើបដឹងថា អានមានទំនាក់ទំនងជាមួយ ចក់ ហើយចាប់ផ្តើមធ្វើការជាមួយក្រុមរបស់ អាន ពីរនាក់ធ្វើសកម្មភាពឲ្យឆេះអំប្រ៊ីយ៉ាម៉ាស៊ីនអារឈើខូចអស់ បន្តមកទៀតយកម៉ាស៊ីនបូមទឹកចំនួន៤ ទៅទម្លាក់ទឹកទន្លេ ។ ខែ១១ ឆ្នាំ១៩៧៥ មានមនុស្សម្នាក់ឈ្មោះ ភេមជាសមាជិករោងចក្រគីឡូម៉ែត្រលេខ៦សុំជួប ហៃ តែពីរនាក់ចង់ឲ្យធ្វើការជាមួយគាត់ ព្រោះយល់ថា ជាមនុស្សស្លូតហើយនៅកន្លែងគាត់មានរបស់ហូបតាមចិត្ត ។ ភេម បានណែនាំ ហៃឲ្យ ស្គាល់ ម៉ុម ប្រមាណជាបីថ្ងៃក្រោយ ម៉ុម បបួលទៅបង់សំណាញ់ ដោយនិយាយទៀតថា ចង់ឲ្យ ហៃ ធ្វើការជាមួយពេលនោះ ហៃ ក៏យល់ស្របតាម ។

ឆ្នាំ១៩៧៦ ទទួលការណែនាំឲ្យទៅពង្រេចពង្រិលសម្ភារៈម៉ាស៊ីនអារឈើ ដោយយកដែកគ្រីបទៅបញ្ចូលម៉ាស៊ីនឲ្យបាក់ស្ពីបង្វិរប្រេងម៉ាស៊ីនចោល ។ ក្នុងចន្លោះឆ្នាំនេះ ហៃ បានធ្វើការជាមួយមនុស្សជាច្រើន ដោយធ្វើសកម្មភាពពង្រេចពង្រិលដដែលៗ ។

ឆ្នាំ១៩៧៧ ក្រុមខ្លួនក៏នៅតែបន្តសកម្មភាពឲ្យខូចសម្ភារៈអារឈើ ធ្វើឲ្យដាច់ធ្មេញរណាអារឲ្យខូចក្តា ២៥បន្ទះ ក្រោយមកនៅពេលអារឈើ នាំគ្នារុញម៉ាស៊ីនឲ្យធ្លាក់ផុតពីផ្លូវដួលវៀចតួម៉ាស៊ីនមួយគ្រឿង ។ ដល់ខែ១០ អង្គការបានចាត់ឲ្យទៅរៀបម៉ាស៊ីនអារឈើមួយនៅខេត្តព្រះវិហារ ។ នៅខេត្តព្រះវិហារ ហៃជួបកម្មករម្នាក់ឈ្មោះ ឆាន នៅជិតខាងខ្លួន ។ ហៃ សុំឲ្យមកធ្វើការជាមួយក្រុមខ្លួន ។ ឆាន បានយល់ព្រមតាមសំណូមពរ ព្រោះគាត់មានការលំបាកណាស់ តាំងពីចូលធ្វើបដិវត្តន៍កាលណាមកហូបមិនដែលបានឆ្អែត ចង្អៀតចង្អល់ ធុញថប់ទៅណាមកណាក៏ពិបាកដែរ ។ ឆាន បានធ្វើការជាមួយ ហៃ ។ សកម្មភាពនៅទីនោះនៅរោងអារឈើមួយដោយមិនចាក់ប្រេង ធ្វើឲ្យម៉ាស៊ីនមួយគ្រឿង ឡោកខូច និងម៉ាស៊ីនម៉ាស៊ូតអូសភ្លើងមួយគ្រឿងក៏ខូច ។ រហូតមកដល់ថ្ងៃទី២០.១១.៧៧ ហៃ ទទួលបញ្ជាពីអង្គការឲ្យត្រឡប់មកកន្លែងដដែលវិញ ។ ជារួមមកក្នុងរយៈពេលប្រមាណជាងដប់ឆ្នាំ ហៃបានធ្វើសកម្មភាពស្ទើរតែគ្រប់ទីកន្លែងផ្សារភ្ជាប់ខ្សែមួយទៅខ្សែមួយ និងកសាងបានកម្លាំងយ៉ាងច្រើនមកប្រឆាំងនឹងរបបខ្មែរក្រហមដើម្បីរាំងស្ទះមិនឲ្យបដិវត្តន៍កុម្មុយនិស្តនេះមានដំណើរឈានទៅមុខបាន ។ ប៉ុន្តែជាអកុសល ក្រោយពីបញ្ចប់កិច្ចការរួច ហៃ ប្រពន្ធ និងកូនប្រាំពីរនាក់ត្រូវអង្គការចាប់ខ្លួនទាំងអស់ ។

**សុផល**

# តើ ទីវ មុី ចូលបំរើចលនាតស៊ូស៊ី.អាយ.អេ នៅភូមិភាគឧត្ដរ ធ្វើសកម្មភាពអ្វីខ្លះប្រឆាំងនឹងរបបខ្មែរក្រហម?

ឯកសារលេខ ៦៨៧ (J) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៩៧ ជាប្រភេទឯកសារចម្លើយសារភាព របស់ឈ្មោះ ទីវ មុី ហៅសន្តិភាព ដែលជាប្រជាជនថ្មីរស់នៅក្នុងសហករណ៍ភូមិតាកែវ សង្កាត់គរ ស្រុកព្រៃឈរ ភូមិភាគឧត្ដរ និងជាអ្នកទោសដែលខ្មែរក្រហមចាប់ឃុំឃាំងបានបង្ហាញឲ្យដឹងថា ចាប់តាំងពីឆ្នាំ១៩៦៥ ឈ្មោះ ទីវ មុី បានចូលធ្វើជាកម្មករនៅក្នុងរោងចក្រស្ករស នៅកំពង់ត្រាំ ក្នុងខេត្តកំពង់ស្ពឺ រហូតមក ។ មូលហេតុដែលឈ្មោះ ទីវ មុី ហៅសន្តិភាព បានចូលបម្រើក្នុងចលនា ស៊ី.អាយ.អេ នៅភូមិភាគឧត្ដរ គឺដោយសារនៅឆ្នាំ ១៩៧១ មានឈ្មោះ សូ បូមែន អតីតកម្មករនៅរោងចក្រស្ករសដែរ ក្រោយមកជាភ្នាក់ងារនៅក្រសួងនគរបាលជាតិ និងឈ្មោះ ញ៉ែម អតីតជាភ្នាក់ងារនៅក្រសួងនគរបាលជាតិដែរ បានណែនាំឈ្មោះ ទីវ មុី ឲ្យចូលធ្វើជាភ្នាក់ងារ ស៊ី.អាយ.អេ ជាមួយពួកគេ ។

តាមចម្លើយសារភាពរបស់ឈ្មោះ ទីវ មុី បានឲ្យដឹងថា ខ្ទឹមសារណែនាំឲ្យចូលធ្វើជាភ្នាក់ងារ ស៊ី.អាយ.អេ ដែលទាំងពីរនាក់នោះបានលើកឡើងក្នុងការអូសទាញខ្លួន គឺថា «កាលណាឯងបានចូលធ្វើការជាមួយយើង ជីវភាពរបស់ឯងនឹងធូរធារជាងនេះដោយគេ (ស៊ី.អាយ.អេ) ឲ្យប្រាក់ខែច្រើន ។ នៅរោងចក្របានតែបីពាន់រៀល បើទៅឯណោះបានដល់មួយម៉ឺនរៀល ជីវភាពខ្ញុំពីមុនក៏តឹងតែងដែរ ដល់ចូលធ្វើការខាងនោះ ក៏បានធូរធារគ្រាន់បើ ឯងមើលចុះសព្វថ្ងៃនេះមហាអំណាចធំៗមានតែពីរទេ បើយើងច្បាំងឈ្នះពួកកុម្មុយនិស្ដ ប្រទេសយើងគ្មានការប្រែប្រួលឡើយ និងរឹតតែសម្បូរសប្បាយជាងនេះ ដោយសារប្រទេសលោកសេរីជាច្រើននឹងជួយគាំទ្រយើង ។ ខាងនយោបាយក្ដី ខាងសេដ្ឋកិច្ចក្ដី រោងចក្រក្ដី ម៉ាស៊ីន និងសំណង់ផ្សេងៗក្ដី របស់ប្រើប្រាស់ក្ដី រោងចក្រក្ដី គឺសុទ្ធតែទំនើបដើរទាន់សម័យនិយមទាំងអស់ ។ គោលដៅនយោបាយរបស់ ស៊ី.អាយ.អេ មានតែមួយគឺប្រឆាំងដាច់ខាតជាមួយនឹងប្រទេសកុម្មុយនិស្ដ ។ បើយើងចាញ់ពួកកុម្មុយនិស្ដ ប្រទេសយើងនឹងមានការប្រែប្រួលរបៀបរស់នៅ ដូចយើងបានឃើញស្រាប់ហើយ ជំនួយរបស់ពួកកុម្មុយនិស្ដពីមុនមក ម៉ាស៊ីនក្ដី រោងចក្រក្ដី របស់ប្រើប្រាស់ក្ដី ខាងកុម្មុយនិស្ដធ្វើមិនដែលបានល្អប៉ុន្មានទេ» ។

## តើបែបបទនៃការចូលជាសមាជិក ស៊ី.អាយ.អេ នេះប្រព្រឹត្ដទៅដោយរបៀបណា?

ចម្លើយសារភាពនេះបានឆ្លើយបញ្ជាក់ អំពីកម្មវិធីបញ្ចូលជាសមាជិកក្រុម សេ.អ៊ី.អា គឺគោរពទង់ជាតិ ដែលដាក់នៅលើតុ ដែលមានទង់ជាតិរបស់សាធារណរដ្ឋខ្មែរ និងទង់ជាតិរបស់សហរដ្ឋអាមេរិក ។ បន្ទាប់មកចូលដល់ពិធីធ្វើសច្ចាប្រណិធាន ដោយសន្យានឹងគោរពតាមបទបញ្ញាវិន័យរបស់ក្រសួងយ៉ាងស្មោះត្រង់ និងបំរើមាគ៌ារបស់ក្រសួងឲ្យបានត្រឹមត្រូវដាក់លាក់ដាច់ខាត ។

ខ្សែទាក់ទងរបស់ក្រុមស៊ី.អាយ.អេ នេះគឺមាន ឈ្មោះ សូ បូមែន ជាអ្នកដឹកនាំធ្វើការដែលមានភារកិច្ចស៊ើបយកការណ៍នៅស្រុកអង្គស្នួល ខេត្តកណ្ដាល ។ ឈ្មោះ កែវ ឆន (អតីតជាភ្នាក់ងារនគរបាលជាតិ) ជាអ្នកស៊ើបយកពត៌មាននៅខាងស្រង់ ។ ឈ្មោះ ទីវ មុី ជាអ្នកស៊ើបការណ៍យកពត៌មាននៅខាងកំពង់ត្រាំ ។ ឈ្មោះ ប្រាក់ សុផាត (អតីតជាភ្នាក់ងារនគរបាលជាតិ) ជាអ្នកយកពត៌មាននៅខាងត្នោតពង ។ ឈ្មោះ ញ៉ែម ជាអ្នកស៊ើបយកពត៌មាននៅខាងបែកចាន និងឈ្មោះ សាវ៉ាង ជាអ្នកយកពត៌មានខាងកំបូល ។ ក្រុមនេះត្រូវធ្វើការទាក់ទងគ្នា បើមានហេតុការណ៍យ៉ាងណាត្រូវឲ្យពត៌មានគ្នាជាបន្ទាន់ ។ គោលដៅធំបំផុតរបស់ ស៊ី.អាយ.អេ គឺប្រឆាំងយ៉ាងដាច់ខាតនឹងអំពើជ្រៀតជ្រែករបស់បក្សកុម្មុយនិស្ដ ។

## សកម្មភាពរបស់ក្រុមស៊ី.អាយ.អេ ប្រឆាំងនឹងបដិវត្តន៍ ខ្មែរក្រហម មុនថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥

នៅឆ្នាំ១៩៧១ ឈ្មោះ សូ បូមែន បានលើកឡើងអំពីបញ្ហាប្រាក់ខែ និង ធ្វើការប្រៀបធៀបអំពីរបៀបរស់នៅតាមរបៀបសេរីនិយមនឹងរបបកុម្មុយនិស្តនិយម ។ ហើយបានអប់រំបន្ថែមទៀតអំពីភារកិច្ចរបស់ភ្នាក់ងារស៊ី.អាយ.អេ និងអំពីការងារ ដែលប្រតិបត្តិធូរស្រាលខុសប្លែកអំពីកម្មករ ។

នៅឆ្នាំ១៩៧២ ឈ្មោះ ទីវ មុី បានទទួលដំណឹងថា នៅខាងជ្រៃអូញ៉ោ (ខេត្តតាកែវ) មានពួកខ្មែរក្រហមចេញចូលញឹកញាប់ណាស់ ហើយឈ្មោះនេះក៏បានស៊ើបការណ៍ដល់ទីកន្លែងឃើញថា ពួកខ្មែរក្រហមបានបង្កកម្លាំងនៅទីនោះមែន ។ បន្ទាប់បានមករាយការណ៍បញ្ជូនពត៌មាននេះឲ្យទៅឈ្មោះ សូ បូមែន ហើយឈ្មោះ សូ បូមែន ក៏បានបញ្ជូនពត៌មានទៅក្រសួងនគរបាលជាតិជាបន្ទាន់ ។ ពេលនោះក្រុមស៊ី.អាយ.អេ បានធ្វើការប្រជុំមួយដើម្បីរកវិធីដោះស្រាយ ដោយធ្វើយ៉ាងណាដើម្បីឲ្យមានប្រសិទ្ធិភាព ។ នៅពេលជួបប្រជុំគ្នាសមាជិកម្នាក់ៗនៃក្រុមស៊ី.អាយ.អេ បានរាយការណ៍អំពីស្ថានការណ៍នៅជុំវិញកន្លែងរបស់ខ្លួនធ្វើការ ។ ជាចុងក្រោយប្រធានអង្គប្រជុំបានណែនាំថា «យើងត្រូវចេះបង្កប់ខ្លួនយកពត៌មានឲ្យបានច្បាស់លាស់ ហើយធ្វើសេចក្តីរាយការណ៍មកខ្ញុំជាបន្ទាន់ ដើម្បីខ្ញុំនឹងបញ្ជូនទៅក្រសួងឲ្យទាន់ពេលវេលា ។ យើងត្រូវប្រឹងប្រែងធ្វើការឲ្យមែនទែន ព្រោះក្រសួងបានប្រគល់ភារកិច្ចមកលើយើងម្នាក់ៗនេះគឺសង្ឃឹមលើយើងហើយ» ។

ចំណែកឯនៅភូមិប៉ារីស ខាងកើតកំពង់ត្រាំ មានពួកខ្មែរក្រហមចេញចូលជាញឹកញាប់ដើម្បីបញ្ចុះបញ្ចូលអ្នកស្រុក ។ ទីវ មុី បានរាយកាណ៍ទៅឈ្មោះ សូ បូមែន ឲ្យបញ្ជូនមកក្រសួងដែរ ។ ពេលនោះពួកខ្មែរក្រហមបានចេញចូលឃោសនាប្រជាជនជាញឹកញាប់ណាស់ ។

នៅឆ្នាំ១៩៧៣ ពេលនោះពួកខ្មែរក្រហមធ្វើសកម្មភាពកាន់តែខ្លាំង ពោលគឺបានវាយបិទផ្លូវនៅត្រង់វត្តបាក់កទៅភ្នំស្រង់ក្នុងខេត្តកំពង់ស្ពឺ ។ ចរាចរណ៍ពីកំពង់ត្រាំទៅភ្នំស្រង់ និងពីកំពង់ស្ពឺទៅភ្នំស្រង់ ត្រូវកាត់ផ្តាច់ ដោយកាលនោះមានទាហានសញ្ញាក្បាលខ្វារបស់ លន់ ណុល បានទៅធ្វើការបើកផ្លូវនោះផង ។

ក្រោយមកពួកខ្មែរក្រហម បានបិទផ្លូវទៅភ្នំស្រង់ មុំអនុវិទ្យាល័យអង្គមេត្រី ពេលនោះឈ្មោះ កែវ ឆន និងឈ្មោះ ទីវ មុី បានដាច់ការទាក់ទងគ្នា ហើយឈ្មោះ ទីវ មុី ក៏បានធ្វើសេចក្តីរាយការណ៍ទៅឲ្យឈ្មោះ សូ បូមែន ដើម្បីឲ្យឈ្មោះនេះរាយការណ៍បន្តទៅក្រសួង ។ ប្រហែលជាមួយសប្តាហ៍ ទើបបើកផ្លូវទៅភ្នំស្រង់បាន បន្ទាប់មកឈ្មោះ សូ បូមែន បានហៅក្រុមស៊ី.អាយ.អេ ប្រជុំដាក់ផែនការយ៉ាងសម្ងាត់មួយដែលមានគ្នាចំនួន ៨នាក់ រួមទាំងឈ្មោះ ទីវ មុី ម្នាក់ផង ។ បន្ទាប់ពីបានជួបជុំគ្នាហើយឈ្មោះ សូ បូមែន បាននិយាយថា «សព្វថ្ងៃនេះស្ទើរតែនៅគ្រប់ទីកន្លែង គឺមានការវាយប្រហាររបស់ពួកខ្មែរក្រហម ហើយច្រើនតែមានការបិទចរាចរណ៍លែងទៅមកបានផង ដូច្នេះទាំងអស់គ្នាត្រូវប្រយ័ត្នខ្លួនក្រែងធ្លាក់ក្នុងកណ្តាប់ដៃរបស់ពួកនេះ ។ ត្រូវខិតខំធ្វើការយកពត៌មានឲ្យបានច្បាស់លាស់ ហើយបញ្ជូនមកឲ្យខ្ញុំឲ្យបានរហ័សមិនត្រូវបណ្តែតបណ្តោយនៅក្នុងការងាររបស់យើងឡើយ ព្រោះសព្វថ្ងៃនេះពួកខ្មែរក្រហមកំពុងធ្វើចលនាខ្លាំងណាស់អ្នកណាមានពត៌មានប្លែកចូរឲ្យមកខ្ញុំ ហើយធ្វើការវិញចុះ» ។

នៅកំពង់ត្រាំពួកខ្មែរក្រហមបានលបធ្វើសកម្មភាពយ៉ាងស្ងាត់មួយ ដោយបានចូលមកកៀរពួកកុម្ម៉ង់ដូដែលនៅយាមតាមស្ពានអស់ប្រហែលជាចំនួន៤០នាក់ ហើយថែមទាំងបានយកអាវុធទៅជាមួយផង ។ តាមពត៌មានបានឲ្យដឹងទៀតថា ពួកខ្មែរក្រហមបានចូលមកកាន់កាប់ផ្សារកំពង់ត្រាំ ហើយប្រុងវាយប្រហារទៅលើរោងចក្រស្ករស និងបិទផ្លូវទៅកាន់ស្រង់ផង ។ ក្នុងពេលនោះ ឈ្មោះ ទីវ មុី បានរាយការណ៍ទៅឲ្យឈ្មោះ សូ បូមែន ដើម្បីបញ្ជូនទៅក្រសួង ។ នៅយប់មួយទៀតពួកខ្មែរក្រហមបានចូលទៅដាក់មីនធ្វើឲ្យដាច់ផ្លូវ និងស្ពានមួយដុំធំនាំឲ្យចរាចរណ៍ត្រូវអាក់ដំណើរនៅស្ពានអូក្រាំងអំបិលខាងលិចព្រៃផ្តៅ ។ ពេលជាមួយគ្នានោះឈ្មោះ ទីវ មុី បានទាក់ទងយ៉ាងសម្ងាត់ជាមួយជនជាតិចិនម្នាក់ឈ្មោះ ហោ ស្រៀង អតីត



សមាជិកស៊ី.អាយ.អេ ធ្វើការ នៅកុងស៊ី ធ្វើស្រានៅកំពង់ត្រាំ ហើយ ក្រោយមកគាត់ត្រូវពួកខ្មែរក្រហមកៀរយកទៅដោយសារតែគាត់មិនព្រមភៀសខ្លួនឲ្យទាន់មុនពេលដែលមានការវាយប្រហាររបស់ខ្មែរក្រហមមកលើកំពង់ត្រាំ និងរោងចក្រស្ករស ។ ឈ្មោះ ទីវ មុី បានឲ្យឈ្មោះ ហោ ស្រៀង ជួយទាក់ទងយកព័ត៌មានពីតំបន់ដែលខ្មែរក្រហមកាន់កាប់ និងជួយធ្វើការឃោសនាពន្យល់ពួកកម្មករដែលធ្វើការនៅកុងស៊ី ស្រា និងពួកអ្នកស្រុកនៅកំពង់ត្រាំ ឲ្យធ្វើការតស៊ូប្រឆាំងនឹងខ្មែរក្រហម ។ ដោយឈ្មោះ ហោ ស្រៀង នឹកអាណិតដល់ពួកកុម្ម៉ង់ដូគ្នាគាត់ ដែលខ្មែរក្រហមបានកៀរយកទៅ គាត់ក៏សុខចិត្តធ្វើការងារនេះឲ្យឈ្មោះ ទីវ មុី ។

ថ្ងៃមួយឈ្មោះ ទីវ មុី បានព័ត៌មានថាពួកខ្មែរក្រហមប្រុងវាយបិទផ្លូវពីស្រុកអង្គស្នួលទៅកំពង់ស្ពឺ និងខាងកំពង់ត្រាំ ហើយឈ្មោះ ទីវ មុី បានផ្តល់ព័ត៌មានទៅឲ្យឈ្មោះ សូ បូមែន ដើម្បីបញ្ជូនទៅក្រសួង ។ មួយស្របក់ក្រោយមកក៏ឃើញឈ្មោះ គង់ យ៉េន មកដល់ ហើយបានរាយការណ៍មកថាពួកខ្មែរក្រហមវាយបិទផ្លូវអង្គស្នួលទៅកំពង់ស្ពឺ និងកំពង់ត្រាំ ។ ហើយទាំងបីនាក់ (សូ បូមែន, ទីវ មុី និងគង់ យ៉េន) ក៏បាននាំគ្នាត្រឡប់ថយទៅកន្លែងរបស់ឈ្មោះ ញ៉ឹម នៅបែកចាន ស្រុកភ្នំពេញ ខេត្តកណ្តាល ។ បន្ទាប់មក ឈ្មោះ កែវ ឆន ក៏បានមកដល់ដែរដោយបានទទួលដំណឹងថា ពួកខ្មែរក្រហមប្រុងវាយបិទផ្លូវកំពង់ត្រាំ និងផ្លូវភ្នំស្រង់ទៀត ។ តាមព័ត៌មានមកថាម្តងនេះពួកខ្មែរក្រហមប្រុងវាយខ្លាំងមែនទែន ព្រោះកំពុងតែរៀបចំកម្លាំងច្រើន ហើយក៏បានរាយការណ៍ឲ្យទៅឈ្មោះ សូ បូមែន ។ ស្របពេលជាមួយគ្នានេះនៅត្មាតពង ពួកខ្មែរក្រហមក៏កំពុងតែរៀបចំកម្លាំងប្រុងវាយរោងចក្រស្ករស និងបិទផ្លូវពីកំពង់ត្រាំទៅត្មាតពង និងពីអង្គស្នួលទៅកំពង់ស្ពឺ ។ ឈ្មោះនេះបានផ្តល់ព័ត៌មានទៅឲ្យឈ្មោះ សូ បូមែន ហើយ សូ បូមែន ក៏បញ្ជូនព័ត៌មាន នោះទៅក្រសួងជាបន្ទាន់ ។

យោងតាមចម្លើយសារភាពរបស់ឈ្មោះ ទីវ មុី បានឲ្យដឹងថា ពួកខ្មែរក្រហមបានវាយ នៅបន្ទាយអង្គស្នួល រោងចក្រ ស្ករស សាលាស្រុកព្រៃផ្តៅ ហើយបិទផ្លូវដាច់ ។ ចរាចរណ៍ភ្នំពេញទៅកំពង់ស្ពឺ ត្រូវបានកាត់ផ្តាច់អស់រយៈពេលជាង២០ថ្ងៃ ទើបបានបើកឡើងវិញ ។ នៅកំពង់ត្រាំ ប្រជាជនធ្វើដំណើរបានដោយ

លំបាកគឺដើរបានត្រឹមតែរោងចក្រមកផ្ទល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល តែប៉ុណ្ណោះ ។ ផ្ទះសម្បែងត្រូវខូចខាតអស់តាំងពីនៅព្រៃផ្តៅ កំពង់ត្រាំ ផ្ទល់ទទឹង និងអង្គស្នួល ប្រជាជនត្រូវភៀសខ្លួនទៅនៅកន្លែងផ្សេងទៀតប្រជាជនខ្លះត្រូវខ្មែរក្រហមកៀរយកទៅ ។ ពេលដែលក្រុមស៊ី.អាយ.អេ បានមកជួបជុំគ្នាឈ្មោះ សូ បូមែន បាននិយាយថា «នៅគ្រប់ទីកន្លែងដែលពួកយើងធ្វើការ ប្រជាជនភៀសខ្លួនអស់ ហើយយើងមិនដឹងទៅនៅជាមួយអ្នកណាទៀតទេ ទាំងអស់គ្នានៅកន្លែង ញ៉ែម សិនចុះចាំខ្ញុំទៅជួបជាមួយឈ្មោះ នូវ សំអៀច ហៅ សំបូរ សិន» ។

ក្រោយពេលឈ្មោះ សូ បូមែន បានជួបឈ្មោះ នូវ សំអៀច ហើយបានត្រឡប់មកវិញឈ្មោះ សូ បូមែន បាននិយាយថា «ឈ្មោះ នូវ សំអៀច ហៅ សំបូរ បានដកពួកយើង ដែលមានខ្ញុំ ឈ្មោះ ទីវ ម៉ី ហៅសន្តិភាព, ឈ្មោះ ប្រាក់ សូផាត, ឈ្មោះ កែវ ឆន និងឈ្មោះ គង់ យ៉េន ឲ្យចូលទៅធ្វើការនៅភ្នំពេញវិញ រីឯឈ្មោះ ញ៉ែម និងឈ្មោះ សាវ៉ាង នៅដដែល ព្រោះកន្លែងរបស់គេពុំទាន់មានការវាយលុកពីខ្មែរក្រហម» ។ ទាំងប្រាំនាក់ត្រូវបានឈ្មោះ នូវ សំអៀច ហៅទៅធ្វើការនៅការិយាល័យស៊ើបអង្កេតពិសេសក្រោមការដឹកនាំរបស់ឈ្មោះ ស្នួង សុទ្ធី អតីតនាយការិយាល័យស៊ើបអង្កេតពិសេស នៅក្រសួងនគរបាលជាតិ និងស៊ី.អាយ.អេ ។ ចំណែកឯឈ្មោះ សូ បូមែន និង ឈ្មោះ គង់ យ៉េន ត្រូវបានចាត់ឲ្យទៅធ្វើការនៅច្បារអំពៅជាមួយ ឈ្មោះ ប្រាក់ សុខុម (អតីតនាយការិយាល័យស៊ើបអង្កេតពិសេស នៅក្រសួងនគរបាលជាតិ និង ស៊ី.អាយ.អេ) ។

នៅឆ្នាំ១៩៧៤ ឈ្មោះ នូវ សំអៀច ហៅ សំបូរ បានបង្គាប់ទៅឈ្មោះ ស្នួង សុទ្ធី ឲ្យធ្វើការណែនាំអ្នកទាំងបីនាក់ ដែលនៅជាមួយឈ្មោះនេះ ឲ្យស្គាល់សមាជិកក្នុងការិយាល័យ ដើម្បីរួបរួមគ្នាធ្វើសកម្មភាពស៊ី.អាយ.អេ បន្តទៀត ។ បន្ទាប់មក ឈ្មោះ ស្នួង សុទ្ធី បានហៅសមាជិកក្នុងការិយាល័យទាំងអស់ មកប្រជុំដែលមានសរុបទាំងអស់ចំនួន២០នាក់ ។ បន្ទាប់ពីបាន ជួបជុំគ្នាហើយ ឈ្មោះ ស្នួង សុទ្ធី បានណែនាំសមាជិកស៊ី.អាយ.អេ របស់ខ្លួនឲ្យស្គាល់គ្នាទៅវិញទៅមកដើម្បីសហការគ្នាធ្វើសកម្មភាពប្រឆាំងនឹងខ្មែរក្រហមទៅមុខទៀត ដោយបានលើកឡើងថា «ទាំងអស់គ្នា ត្រូវខិតខំធ្វើការឲ្យខ្លាំងក្លាជាងសព្វថ្ងៃនេះទៀត ព្រោះសព្វថ្ងៃនេះ ខ្មែរក្រហមវាយសម្រុកកាន់តែខ្លាំងក្លាហើយ» ។ តមកទៀតឈ្មោះ ស្នួង សុទ្ធី បានចាត់តាំងឲ្យឈ្មោះ ទីវ ម៉ី ទៅបង្កប់ខ្លួនធ្វើការដើម្បីយកពត៌មាននៅគីឡូម៉ែតលេខ៦ ស្រុកឬស្សីកែវ រាជធានីភ្នំពេញ ឈ្មោះ កែវ ឆន ទៅធ្វើការបង្កប់ខ្លួននៅស្ទឹងមានជ័យ រីឯឈ្មោះ ប្រាក់ សុផាត ត្រូវទៅបង្កប់ខ្លួននៅខាងចាក់អង្រែ ដើម្បីយកពត៌មាននៅកន្លែងនោះ ។

ដោយឡែកនៅព្រែកព្នៅវិញចម្លើយរបស់ឈ្មោះ ទីវ ម៉ី បានឲ្យដឹងពីពត៌មានពីអ្នកស្រុកថា នៅត្រើយម្ខាងមានពួកខ្មែរក្រហមនៅច្រើន ប្រជាជនមិនអាចឆ្លងកាត់ទៅរកស៊ីនៅខាងនោះបានទៀតឡើយ ហើយពួកនេះបានចូលទៅក្តាប់ដល់ភូមិដំណាក់តាសេក ក្បែររោងចក្រធ្វើស្រាផង ។ ក្រោយពីបានពត៌មាននេះឈ្មោះ ទីវ ម៉ី បានយកទៅរាយការណ៍ទៅការិយាល័យជាបន្ទាន់ ។

នៅពេលនោះ ក្រសួងបានធ្វើការផ្លាស់ប្តូរនាយការិយាល័យ ហើយក៏បានហៅនាយផ្នែក និងសមាជិកទាំងអស់មកប្រជុំ ។ នៅពេលប្រជុំគ្នាឈ្មោះ វ៉ាន់ ស និងឈ្មោះ នូវ សំអៀច ហៅ សំបូរ ព្រមទាំងឈ្មោះ សុខ សំអាត (អតីតនាយការិយាល័យស៊ើបអង្កេតពិសេសនៅក្រសួងនគរបាលជាតិ និងស៊ី.អាយ.អេ) ក៏បានចូលរួមដែរ ។ ឈ្មោះ វ៉ាន់ ស បាននិយាយថា «យើងសូមធ្វើការផ្លាស់ប្តូរនាយការិយាល័យចេញ ដោយដកឈ្មោះ ស្នួង សុទ្ធី ជានាយការិយាល័យចេញដើម្បីឲ្យទៅបំពេញភារកិច្ចថ្មី និងដាក់ឈ្មោះ សុខ សំអោក នេះជានាយការិយាល័យចូលវិញ» ។ បន្ទាប់មកទៀតក្រុមស៊ី.អាយ.អេ នេះតែងតែដើរបំផុសអប់រំប្រជាជនឲ្យចូលរួមក្នុងចលនាស៊ី.អាយ.អេ របស់ខ្លួន ដោយបានលើកឡើងអំពីជីវភាពរស់នៅ អំពីការចម្រើនលូតលាស់រវាងប្រទេសលោកសេរី ដោយធ្វើការប្រៀបធៀបជាមួយពួកកុម្មុយនិស្តអំពីបញ្ហាការងារធូរស្រាល អំពីប្រាក់ខែ និងភារកិច្ចភ្នាក់ងាររបស់ស៊ី.អាយ.អេ ។ ក្រោយពីបានធ្វើការបំផុសអប់រំច្រើនលើកច្រើនសារ ក៏មានអ្នកចូលរួមក្នុងចលនានេះជាបន្ត

បន្ទាប់ ហើយក៏បានបើកកម្មវិធីបញ្ចូលជាសមាជិកស៊ី.អាយ.អេ ថ្មីជាហូរហែ ដើម្បីរួមគ្នាធ្វើការជាបន្តទៀតប្រឆាំងនឹងបដិវត្តន៍របស់ខ្មែរក្រហម ។

## សកម្មភាពរបស់ក្រុម ស៊ី.អាយ.អេ ប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហមក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥

នៅឆ្នាំ១៩៧៥ ឈ្មោះ ទីវ មី បានធ្វើដំណើរទៅខាងតាខ្មៅ ខេត្តកណ្តាល ដើម្បីដឹងពត៌មានអំពីសកម្មភាពខ្មែរក្រហមនៅទីនោះ ។ បើតាមពត៌មានពីអ្នកស្រុកនៅទីនោះបានឲ្យដឹងថា នៅត្រើយម្ខាងទល់មុខតាខ្មៅ នៅពេលនោះមានពួកខ្មែរក្រហមចេញចូលជាញឹកញាប់ណាស់ នៅពេលយប់ប្រជាជនខស្សរាហ៍ឃើញពួកខ្មែរក្រហមដើរចុះដើរឡើងពុំសូវខានទេ ។ ប្រជាជនបារម្ភខ្លាចតែពួកនេះវាយសម្រុកចូលមកទេ ហើយនៅឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ក៏អ៊ីចឹងដែរ ។

និយាយរួម សកម្មភាពរបស់ខ្មែរក្រហមនៅពេលនោះមានសភាពខ្លាំងក្លាស្ទើរតែគ្រប់ទិកន្លែង ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហម បានបើកការវាយលុកយ៉ាងខ្លាំងក្លាជាបន្តបន្ទាប់ ហើយមួយកន្លែងៗសុទ្ធតែទទួលបានជោគជ័យទៀតផងជាពិសេសរោងចក្រស្ករស ថ្នល់ទទឹង អន្លង់ស្នួល បែកចានសុទ្ធតែត្រូវទទួលរងនូវការវាយប្រហារពីពួកខ្មែរក្រហមទាំងអស់ ។

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពេលលោកសេនាប្រមុខ លន់ ណុល ភៀសខ្លួនចេញពីប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាមេរិកទៅ នាយការិយាល័យក៏បានហៅសមាជិកទាំងអស់ធ្វើការប្រជុំមួយ ។ ប្រធានអង្គប្រជុំបានលើកឡើងថា «ក្រសួងបានដាក់ផែនការ ឲ្យធ្វើការប្រជុំនេះដោយឲ្យយើងខំពង្រឹងនូវគោលជំហរក្នុងការងារតទៅទៀត ។ ពិតមែនតែលោកសេនាប្រមុខ លន់ ណុល បានចាកចេញទៅមែន យើងមិនត្រូវអស់សង្ឃឹមឡើយ យើងនៅមានអ្នកដឹកនាំតទៅទៀតដែរ ត្រូវខិតខំពុះពារបន្ថែម មិនត្រូវបន្ថយល្បឿនឡើយក្នុងកិច្ចការរបស់យើង ។ ក្រសួងគ្រាន់តែបានផ្តាំថា បើយើងធ្លាក់ខ្លួនចាញ់ដៃពួកកុម្មុយនិស្ត ត្រូវចេះលាក់ខ្លួនគ្រប់រូបភាពទាំងអស់រកវិធីទាក់ទងគ្នា ឆ្លៀតឱកាសកសាងកម្លាំងស៊ី.អាយ.អេ តទៅទៀត ។ ក្រសួងគ្រាន់តែផ្តាំផ្ញើប៉ុណ្ណោះ ពុំឃើញមានដាក់ផែនការអ្វីថ្មីទៀតឡើយ ។ ទីវ មី ក៏គ្មានវិធានការណ៍អ្វីថ្មីទៀតដែរ តែទាំងអស់គ្នា ត្រូវខិតខំយកពត៌មានឲ្យបានច្បាស់លាស់ ព្រោះពួកខ្មែរក្រហមកាន់តែខិតមកជិតយើងហើយ នាំគ្នាធ្វើការតាមកន្លែងចុះ» ។ រហូតមកដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ ស្ថានការណ៍នៅទីក្រុងភ្នំពេញ នៅមានសភាពស្ងប់ស្ងាត់នៅឡើយ តែនៅប៉ែកខាងជើងពោធិចិនតុង ពួកខ្មែរក្រហមបានវាយសន្ធាប់កាន់តែខ្លាំងឡើងៗ ។ ដោយឡែកនៅខាងត្បូងតាខ្មៅ ពួកខ្មែរក្រហមបានធ្វើការវាយលុកខ្លាំង ហើយផ្នែកខាងកើតច្បារអំពៅ ក៏ពួកខ្មែរក្រហមវាយសម្រុកខ្លាំងដែរ ប្រជាជនបានភៀសខ្លួនយ៉ាងច្រើនចូលមកនៅក្នុងក្រុងភ្នំពេញ ។

ពេលនោះឈ្មោះ ទីវ មី បានធ្វើសេចក្តីរាយការណ៍ទៅឲ្យនាយការិយាល័យជាបន្ទាន់ ។ នៅវេលាយប់ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ នៅច្បារអំពៅ ត្រូវបានពួកខ្មែរក្រហមវាយខ្លាំងណាស់ ភ្លើងឆេះផ្ទះ យ៉ាងសន្ធោរសន្ធៅ ហើយមានការបាញ់ផ្លោងចូលមកខាង ក្បាលថ្នល់ជាច្រើនផង ។ ឈ្មោះ ទីវ មី បានថយមកនៅក្នុងក្រុងភ្នំពេញវិញ ។ កាលនោះបម្រាមគោចរក្នុងក្រុងភ្នំពេញធ្លាប់តែបិទនៅម៉ោង៧យប់ យប់នោះក៏ឃាត់លែងឈ្នះហើយ ព្រោះថាប្រជាជនបានភៀសខ្លួនចូលមកនៅក្រុងភ្នំពេញទាំងយប់ដោយដើរពាសពេញតែផ្លូវ ។ គ្មាននរណាម្នាក់ដឹងថា ទីក្រុងភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះទេ ហើយក្រសួងក៏ពុំមានវិធានការណ៍អ្វីថ្មីទៀតដែរ ។ លុះព្រឹកឡើងមានលេចឮនូវពត៌មានជាបន្តបន្ទាប់ថា កងទ័ពលែងប្រយុទ្ធគ្នាទៀតហើយ ព្រោះបានចរចាត្រូវរ៉ូវគ្នាដោយលើកទង់ជ័យសជាសញ្ញាឈប់បាញ់គ្នានៅគ្រប់កន្លែងទាំងអស់ ក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នេះ ។ នៅវេលាប្រហែលជាម៉ោង១១ ស្រាប់តែសមមិត្តខាងយោធាខ្មែរក្រហមបានដើរប្រាប់ប្រជាជន ឲ្យរៀបចំឥវ៉ាន់ចេញពីផ្ទះយ៉ាងរហ័សក្នុងរយៈពេលបីថ្ងៃសិន ដើម្បីអង្គការរៀបចំទីក្រុង ។ ប្រជាជនម្នាក់ៗធ្វើភ្នែកមូល ដោយគ្មានអ្នកណាម្នាក់ដឹងដល់ «ផែនការជម្លៀស» របស់អង្គការនេះឡើយ ។ ប៉ុន្តែប្រជាជននឹកសង្ឃឹម

ថា នឹងបានចូលមករស់នៅទីក្រុងវិញ ព្រោះការរៀបចំឥវ៉ាន់ស្បៀងអាហារសម្រាប់តែបីថ្ងៃប៉ុណ្ណោះ ដោយសមមិត្តខាងយោធាខ្មែរក្រហមបានប្រាប់ថា អង្គការឲ្យចេញតែបីថ្ងៃសិនទេ។ ម្នាក់ៗខ្លះភ័យ ខ្លះអរ ដោយពុទ្ធនិយាយគ្នាថា យើងចាំមើលរបៀបរៀបចំថ្មីរបស់អង្គការបដិវត្តន៍ ចាំមើលការបោសសម្អាតពួកពុករលួយ ព្រោះអ្នកទាំងនេះ (អង្គការ) សុទ្ធតែជាអ្នកស្អាតស្អំ ហើយតាំងតែពីដើមមក ពួកនេះមិនដែលត្រូវនឹងមន្ត្រីណាដែលពុករលួយទេ។

ក្រោយពីបានជម្លៀសទៅប្រជាជននៅស្រុកភូមិរបស់ ទីវ មុី បានទៅរស់នៅជាមួយឪពុកម្តាយក្នុងសហករណ៍ ភូមិតាកែវ សង្កាត់គរ ក្នុងភូមិភាគឧត្តរ។

បន្ទាប់មកមិត្តតំណាងភូមិក៏បានមកសាកសួរ និងកត់ត្រាទីកន្លែងធ្វើការ កាលពីនៅភ្នំពេញ។ ដោយឈ្មោះ ទីវ មុី ធ្លាប់ធ្វើការនៅរោងចក្រស្ករសពីដើមមក សម័យមុនរំដោះ ហើយអ្នកស្រុកក៏បានដឹងពុទ្ធគ្រប់ៗគ្នាផងនោះ ឈ្មោះ ទីវ មុី ក៏បានប្រាប់ទៅមិត្តតំណាងភូមិវិញថា «ខ្ញុំធ្វើការនៅរោងចក្រស្ករសដដែលទេ» ។ «កុំអីខ្ញុំក៏មិនអាចរស់នៅដល់សព្វថ្ងៃនេះដែរ ព្រោះនៅស្រុក ភូមិ អង្គការបានបោសសម្អាតអស់ហើយ តាំងពីកូនទាហាន ប៉ូលិសតូចតាច ប៉េអឹម គឺគ្មានសល់ម្នាក់ទេ» ។ តាមចម្លើយសារភាពរបស់ឈ្មោះ ទីវ មុី បានឲ្យដឹងទៀតថាដោយការងារបដិវត្តន៍សព្វថ្ងៃមមាញឹកខ្លាំង ការក្តាប់ប្រជាជនថ្មីរបស់មិត្តតំណាងភូមិ និងការបោសសម្អាតខ្លាំងរបស់អង្គការមានសកម្មភាពខ្លាំងក្លា ហើយនៅពេលប្រជុំម្តងៗ តំណាងភូមិតែងតែបានលើកឡើងអំពីការកម្ចាត់ខ្មាំង តទៅទៀតពុំដែលឈប់នោះធ្វើឲ្យ ទីវ មុី ខ្លាចរអារពុំហ៊ានកម្រើកឡើយ។ ដោយគ្រាន់តែឃើញមន្ទីរសន្តិសុខតំបន់នៅភូមិតាកែវ ដែលមួយថ្ងៃៗមានដឹកជនក្បត់ចូលពុំដាច់នោះដែលធ្វើឲ្យ ទីវ មុី ព្រឺខ្លួនមិនហ៊ានបញ្ចេញសកម្មភាព ឬធ្វើចលនាអ្វីឡើយ គឺខំសម្ងំយកសុខធ្វើយ៉ាងណាឲ្យតែបានរស់។

ម្យ៉ាងទៀត ផែនការជម្លៀសរបស់អង្គការជាថ្នាំមួយមានប្រសិទ្ធិភាពខ្លាំងណាស់ ធ្វើឲ្យផ្តាច់ការទាក់ទងខ្សែរយៈ ស៊ី.អាយ.អេ អស់រលីង ដូច្នេះ ទីវ មុី ដែលតាំងពីជម្លៀសមករហូតដល់ថ្ងៃដែលអង្គការចាប់ មិនដែលបានជួបអ្នកដែលធ្វើការជាមួយគ្នាណាម្នាក់ឡើយ។ នៅក្នុងសហករណ៍ ទីវ មុី បានខិតខំធ្វើការងារគ្រប់ផ្នែក តាមការចាត់តាំងរបស់ប្រធានសហករណ៍ គឺជាខិតខំយកចិត្តទុកដាក់ក្នុងការងារមិនដែលឲ្យទាស់ចិត្តបងប្អូនជាម្ចាស់ស្រុកឡើយ។ ឈ្មោះ ទីវ មុី ត្រូវបានប្រធានសហករណ៍ និងកម្លាំងពីរបីនាក់ទៀត ចាប់ខ្លួននៅល្ងាចថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៧ នៅពេលដែលខ្លួនកំពុងរៀបចំស្ទូកដាក់រទេះដើម្បីយកទៅប្រក់ផ្ទះ។

ជារួមចម្លើយសារភាពរបស់ឈ្មោះ ទីវ មុី បានសារភាពអំពីសកម្មភាពក្បត់នឹងបដិវត្តខ្មែរក្រហមក្នុងចលនាស៊ី.អាយ.អេ ក្នុងភូមិភាគឧត្តរ។ តាមចម្លើយសារភាពនេះ ឈ្មោះ ទីវ មុី បានរៀបរាប់អំពីបក្ខពួកក្បត់របស់ខ្លួន និងបដិវត្តន៍ខ្មែរក្រហមមានចំនួន៣១នាក់។ ហើយក្នុងកំណត់ហេតុចម្លើយសារភាពនេះមានស្នាមផ្តិតមេដៃរបស់ឈ្មោះ ទីវ មុី ផង កំណត់ហេតុសួរចម្លើយនេះធ្វើឡើងនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ ស្ថិតនៅក្រោមការសួរចម្លើយរបស់ឈ្មោះ អឿន ដែលជាអ្នកសួរចម្លើយនៅមន្ទីរស-២១ (គុកទួលស្លែង) ក្នុងរបបខ្មែរក្រហម។ នៅក្នុងឯកសារនេះ មានចំណារលើកំណត់ហេតុសួរចម្លើយអំពីឈ្មោះ ទីវ មុី ផង។

បន្ទាប់ពីទទួលបានឯកសារនេះហើយឈ្មោះ ឌុច ដែលត្រូវបានស្គាល់ថាជាប្រធានមន្ទីរស-២១ (គុកទួលស្លែង) បានធ្វើរបាយការណ៍ទៅថ្នាក់លើដោយសរសេរផ្តើមថា «បងជាទីគោរព» ហើយបញ្ចប់ថា «ដោយគោរព, ឌុច ចុះថ្ងៃទី១១ ខែ១១ ឆ្នាំ៧៧» ។ របាយការណ៍នេះទំនងជាផ្ញើទៅ សុន សេន ឬ នួន ជា ទើបឃើញមានចំណារសរសេរថា «ភ.ក1/2 (ភូមិភាគកណ្តាល),ប្អូន ទីវ អុល, មិនទាន់អាន, ជូនបង នួន ១ច្បាប់, ១១-១១-៧៧» ។ ទាក់ទិននឹងចំណាររបស់ សុន សេន ដែលសរសេរថា «ប្អូន ទីវ អុល» គឺមានន័យថា ទីវ មុី ជាប្អូនរបស់ឈ្មោះ ទីវ អុល ដែលអង្គការចាប់ខ្លួនហើយ។ ភ្ជាប់មកជាមួយឯកសារនេះមានបញ្ជីឈ្មោះដែល ទីវ មុី រាយ

ឈ្មោះ ចំនួន៣១នាក់ ដែលត្រូវបានចោទថាជនក្បត់ ហើយចំនួន៣១នាក់ ប្រហែលត្រូវបាន សុន សេន គូសចំណាំជាសញ្ញា «គូសបញ្ជាក់» ទាំងអស់ ។ **សុភារិទ្ធ**

---

# ការស្រាវជ្រាវ និងធ្វើផែនទីរណ្តៅឧក្រិដ្ឋកម្ម នៃរបបកម្ពុជាប្រជាធិបតេយ្យ

បេសកកម្មចុះស្រាវជ្រាវ និងធ្វើផែនទីរណ្តៅឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការចងក្រងប្រវត្តិសាស្ត្រ ឯកសារ និងភស្តុតាងជាក់ស្តែងនៃឧក្រិដ្ឋកម្ម ដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ មិនតែប៉ុណ្ណោះ គោលដៅនៃបេសកកម្មនេះ គឺសំដៅកំណត់ទីតាំងដែនទីរណ្តៅឧក្រិដ្ឋកម្មទូទាំងប្រទេសកម្ពុជា និងប្រមូលចងក្រងពត៌មានស្រាវជ្រាវរកបានពីកន្លែងកើតហេតុដើម្បីបម្រើគោលដៅច្បាប់ និងជាពិសេសបំផុតបម្រើឲ្យប្រវត្តិសាស្ត្រ និង ការអប់រំអំពីប្រព័ន្ធសន្តិសុខនៃប្រល័យពូជសាសន៍នៅកម្ពុជា ។

អ្វីដែលបានស្រាវជ្រាវរកឃើញមកទល់ពេលនេះ គឺការបំបាត់ភាពអាថ៌កំបាំងអំពីយន្តការ ដែលរបបកម្ពុជាប្រជាធិបតេយ្យបានបង្កើតឡើង ដើម្បីសម្លាប់មនុស្សអស់ជាច្រើន ។ របបកម្ពុជាប្រជាធិបតេយ្យ បានបង្កើតបណ្តាញមជ្ឈមណ្ឌលសម្លាប់មនុស្សនៅស្ទើរគ្រប់ស្រុកទូទាំងប្រទេស ហើយនៅទីនោះពួកខ្មែរក្រហមសម្លាប់ «សត្រូវរបស់បក្សកុម្មុយនិស្ត» ទាំងសត្រូវមែនទែន និង សត្រូវតាមការស្រមើស្រមៃរបស់ខ្លួនជាមធ្យមចំនួន ៥២០០នាក់ ក្នុងមួយសប្តាហ៍ ហើយសម្លាប់ជារៀងរាល់សប្តាហ៍ ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។ ជនរងគ្រោះ១លាននាក់ទៀត ស្លាប់ដោយកង្វះការយកចិត្តទុកដាក់ដ៏ធ្ងន់ធ្ងររបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្អត់អាហារ ជំងឺគ្មានថ្នាំព្យាបាល និងការបង្ខំឲ្យធ្វើការបាក់កម្ទាំង ។

បេសកកម្មចុះស្រាវជ្រាវ និងធ្វើដែនទីរណ្តៅឧក្រិដ្ឋកម្មបច្ចុប្បន្នដំណើរការ និងគ្រប់គ្រងដោយជនជាតិកម្ពុជាមួយក្រុមហៅថា «ក្រុមដែនទី» ដែលបានទទួលការបណ្តុះបណ្តាលយ៉ាងល្អិតល្អន់ និងមានបទពិសោធន៍ ដោយមានការឧបត្ថម្ភពីសកលវិទ្យាល័យនៅសហរដ្ឋអាមេរិក និងអូស្ត្រាលី ។ ចាប់តាំងពីឆ្នាំ ១៩៩៥ មកទល់ពេលនេះក្រុមដែនទីបានចុះទៅស្រុកចំនួន១៨៤ ក្នុងចំណោមស្រុកទាំងអស់១៧០ ក្នុងទូទាំងប្រទេសកម្ពុជាដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងការសហការពីអាជ្ញាធរខេត្ត-ស្រុកក្នុងព្រះរាជាណាចក្រកម្ពុជា ។ មកទល់ពេលនេះ ក្រុមដែនទីបានចុះស្រាវជ្រាវ និង ធ្វើដែនទីទីតាំងឧក្រិដ្ឋកម្មចំនួន៤១៥ ហើយទីតាំងឧក្រិដ្ឋកម្មនីមួយៗ រួមមានរណ្តៅកប់សាកសព (រួមចំនួនប្រហែលពី១០ ទៅ ២០០រណ្តៅ) គុក ឬមន្ទីរសន្តិសុខខ្មែរក្រហម និងបូជនីយដ្ឋាន ដែលសាងសង់ឡើងនៅទសវត្សរ៍ឆ្នាំ ៨០ ដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ក្រុមដែនទីប្រើប្រាស់ឧបករណ៍ ដែលភ្ជាប់ទៅនឹងផ្កាយរណបដ៏ទំនើបហៅថា ប្រព័ន្ធកំណត់ទីតាំងពិភពលោក (Global Positioning System-GPS) ដើម្បីកត់ត្រារយៈទទឹង និងរយៈបណ្តោយដើម្បីកំណត់ទីតាំងរណ្តៅឧក្រិដ្ឋកម្មនីមួយៗ ។ ទិន្នន័យដែលចាប់បានដោយប្រព័ន្ធនេះ ត្រូវបានបញ្ជូនពីឧបករណ៍ចាប់យកទីតាំងពីផ្កាយរណប បញ្ចូលទៅក្នុងកុំព្យូទ័រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបន្ទាប់មកទិន្នន័យនេះត្រូវបានបញ្ជូនទៅសកលវិទ្យាល័យញូវសៅវែល នៅប្រទេសអូស្ត្រាលី ហើយនៅទីនោះអ្នកជំនាញពីសាលាវិស្វកម្មភូមិសាស្ត្រ ច្នៃទិន្នន័យទាំងនេះ ដោយប្រើប្រាស់ប្រព័ន្ធពត៌មានភូមិសាស្ត្រ «Geographic Information System» និងរួមបញ្ចូលជាមួយទិន្នន័យដែនទីដែលបង្កើតឡើងដោយអ៊ុនតាក់ និងបញ្ជីរាយនាមភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំធ្វើឡើងដោយនាយកដ្ឋានភូមិសាស្ត្រនៃក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីបញ្ជាក់លេខកូដស្រុក-ខេត្ត ដែលទីតាំងឧក្រិដ្ឋកម្មនោះស្ថិតនៅ បន្ទាប់មកធ្វើទិន្នន័យទាំងនេះ

ទៅសកលវិទ្យាល័យយ៉េលនៅសហរដ្ឋអាមេរិក ដើម្បីបោះពុម្ពចេញជាផែនទី ។

ក្រុមផែនទី ផ្អែករបកគំហើញពីការចុះស្រាវជ្រាវនេះ សុទ្ធសាធលើព័ត៌មានជាក់ស្តែងពីកសិណសាក្សីដែលបានឆ្លងកាត់ ឬឃើញព្រឹត្តិការណ៍ផ្ទាល់ភ្នែក ហើយដែលបានរួចរស់មានជីវិតពីរបបដ៏ឃោរឃៅនេះតាមរយៈបទសម្ភាសន៍ ហើយនិងរូបថតរណ្តៅសាកសព គុក បូជនីយដ្ឋានជាដើម ។ល ។ ព័ត៌មានទាំងនេះត្រូវបានរៀបចំចងក្រងទុកជាឯកសារយ៉ាងត្រឹមត្រូវ ។ សាក្សីម្នាក់ឈ្មោះមីង សយ អាយុ ៦២ឆ្នាំ នៅភូមិអញ្ចាញ ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ បានប្រាប់ក្រុមផែនទីថា «កាលពីជំនាន់ខ្មែរក្រហម ខ្ញុំជាប់គុកនៅគុកការដ្ឋានអូរលង ស្រុកក្រចេះ ខេត្តក្រចេះ អស់ជិតពាឆ្នាំ ។ ប្តីខ្ញុំត្រូវពួកខ្មែរក្រហមចាប់យកពីផ្ទះទៅសម្លាប់ មុនពេលពួកវាចាប់ខ្ញុំ ។ ពួកវាចាប់ខ្ញុំ ព្រោះប្តីខ្ញុំធ្លាប់ធ្វើទាហានលន់ណុល ។ នៅគុកការដ្ឋានអូរលងនេះមានអ្នកទោសពី២០០ ទៅ៣០០នាក់ ធ្វើការទាំងយប់ទាំងថ្ងៃ ។ ពួកខ្មែរក្រហមហ៊ុមព័ទ្ធការដ្ឋាននេះ ដោយរបងលួសបន្លាយ៉ាងមាំ សូម្បីតែកូនមាន់ ក៏ចេញមិនរួចផង ។ អាមេឃាដករនៅទីនេះឈ្មោះមិត្តអូ ។ ក្នុងពេលជាប់គុកនៅទីនេះ ខ្ញុំបានឃើញនារីម្នាក់ដែលខ្ញុំស្គាល់ឈ្មោះ ផល មានកូនមួយហើយ ត្រូវបានពួកសន្តិសុខបោកយកទៅរំលោភ ដោយបោកនារីផលថា អង្គការហៅទៅយកសម្លៀកបំពាក់ដែលអង្គការចែកឲ្យ ។ បន្ទាប់មកអូសយកទៅសម្លាប់នៅឯដំបូកមួយក្បែរនោះ» ។

មីងសយ គឺគ្រាន់តែជាកសិណសាក្សីដ៏សំខាន់មួយក្នុងចំណោមសាក្សីជាច្រើននៅទូទាំងប្រទេស ដែលបានជួបប្រទះនិងដឹងឮអំពីព្រឹត្តិការណ៍ និងឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម ប៉ុន្តែអ្វីដែលក្រុមផែនទីមានការព្រួយបារម្ភនោះគឺថា សាក្សីទាំងនេះមានវ័យកាន់តែចាស់ជរាហើយ ព័ត៌មានសំខាន់ៗទាំងនេះរក្សាទុកតែតាមការចងចាំផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ជាងនេះទៅទៀត ភស្តុតាងរណ្តៅសាកសព បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះកំពុងទទួលរងគ្រោះនៃការបាត់បង់រូបរាង និងការខូចខាតដោយឥទ្ធិពលធម្មជាតិ សត្វសុី និងកង្វះការយកចិត្តទុកដាក់ថែរក្សា ជាពិសេសនៅតាមទីជនបទ ។ ដូច្នេះចាំបាច់តម្រូវឲ្យមានការចងក្រងឯកសារទុកជាបន្ទាន់ មុនពេលភស្តុតាងឈានទៅរកការបាត់បង់ ។ លលាដ៍ក្បាលសាកសពជនរងគ្រោះនៅបាទីត្រូវបានទទួលរងភាពហិនហោចស្ទើរតែអស់រលីង ហើយត្រូវជំនួសវិញដោយចេតិយតូចមួយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសំណូមពរឲ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ច្រើនបន្ថែមទៀត ក្នុងការថែរក្សាប្រវត្តិសាស្ត្រនេះ ។

នៅចុងបញ្ចប់នៃបេសកកម្មតាមខេត្តនីមួយៗ ព័ត៌មានទាំងអស់ដែលប្រមូលបានត្រូវបានចងក្រងជារបាយការណ៍លម្អិតជាពីរភាសាខ្មែរ និងអង់គ្លេស រួមមានស្ថិតិចំនួនរណ្តៅសាកសព គុក ឬបូជនីយដ្ឋាន ចំនួនជនរងគ្រោះ និងកសិណសាក្សី ព្រមទាំងព័ត៌មានអំពីទិដ្ឋភាពដទៃទៀត ដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មជនដៃដល់ មេសន្តិសុខខ្មែរក្រហម ស្ថានការណ៍រស់នៅជុំវិញទីតាំងឧក្រិដ្ឋកម្មនីមួយៗ ។ រីឯផែនទីឧក្រិដ្ឋកម្មចង្អុលបង្ហាញទីតាំងជាក់លាក់ និងសុក្រិតនៃទីតាំងឧក្រិដ្ឋកម្មនីមួយៗ ព្រមទាំងស្ថិតិជាក់លាក់អំពីចំនួនរណ្តៅ ចំនួនជនរងគ្រោះ រួចហើយត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យកុំព្យូទ័រ និងប្រព័ន្ធអ៊ិនធ័រណែតសម្រាប់សាធារណជនក្នុងប្រទេស និងអន្តរជាតិ ។ លើសពីនេះក្រុមផែនទីបានធ្វើផែនទីដោយគំនូសដៃ សម្រាប់ជាការងាយស្រួលដល់អ្នកស្រាវជ្រាវក្រោយៗក្នុងការធ្វើដំណើរទៅដល់ទីកន្លែងដដែលនេះ ។

ដោយបេសកកម្មស្រាវជ្រាវចងក្រងឯកសារ និងធ្វើផែនទីបានប្រមូលព័ត៌មានសន្ទឹកសន្ធាប់តាមមធ្យោបាយសុក្រិតក្នុងលក្ខណៈវិទ្យាសាស្ត្រ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងត្រៀមបោះពុម្ពលទ្ធផលនៃការស្រាវជ្រាវ និងផលិតចេញនូវផែនទីរបស់ខ្លួនជាលើកដំបូងក្នុងពេលអនាគតខាងមុខនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្តេជ្ញាបំពេញបេសកកម្មដ៏សំខាន់នេះឲ្យបានជោគជ័យ និងបម្រើជាប្រភពដ៏សំខាន់តែមួយគត់ដល់សាធារណជនឲ្យបានដឹងអំពីការពិត អំពីវិសាលភាព និងយន្តការរបស់របបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹងការសម្លាប់រង្គាលចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៩ ។

**ផាត កុសល**




## សម្លេងពីមន្ទីរ ស-២១

### វគ្គទី១: ការរកឃើញមន្ទីរ ស-២១

សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ដែលកំពុងផ្តល់ពន្លឺថ្ងៃដ៏ត្រចះត្រចង់ និងជំនោរត្រសៀកៗក្នុងរដូវរងារនៃប្រទេសកម្ពុជា កងកម្លាំងវៀតណាមប្រដាប់ដោយអាវុធច្រើនស្អេកស្កះ អមដោយសម្ព័ន្ធមិត្តកម្ពុជាដែលប្រដាប់ដោយអាវុធបន្តិចបន្តួចបានបោះពួយមកដល់ជាយក្រុងភ្នំពេញ បន្ទាប់ពីយុទ្ធនាការវាយសម្រុកផ្តាច់ព្រាត់ ដែលចាប់ផ្តើមនៅថ្ងៃបុណ្យណូអែល ។ អស់រយៈពេលជាងមួយឆ្នាំមុនព្រឹត្តិការណ៍នេះ វៀតណាមបានប្រឡូកក្នុងសង្គ្រាមជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ដែលដើរតាមលទ្ធិម៉ៅ ដែលបណ្តាប្រទេសលោកខាងលិចហៅថា ខ្មែរក្រហម ។ កម្លាំងទ័ពលុកលុយរបស់វៀតណាមជាង១សែននាក់ រួមទាំងអង្គភាពរថពាសដែក បានសន្ធាប់ និងវាយគាំទ្រដោយការទម្លាក់គ្រាប់បែកជាប្រចាំពីលើអាកាស[១] ។

ការទទួលបានជោគជ័យដ៏ឆាប់រហ័ស ធ្វើឲ្យមេបញ្ជាការទ័ពវៀតណាមភ្ញាក់ផ្អើលដោយមិននឹកស្មានដល់ ។ មិនដល់២សប្តាហ៍ ក្រោយការប្រយុទ្ធនេះ ប្រទេសកម្ពុជាប្រេះបែកដូចជាពងមាន់ ។ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ពលទាហានភាគច្រើនរបស់របបនេះ និងប្រជាជនដែលរត់តាមរបបនេះរាប់សែននាក់បានរត់ភៀសខ្លួន ឬក៏ត្រូវបានកៀរចេញពីទីក្រុង ។ ទ័ពលុកលុយទទួលការស្វាគមន៍ពីសំណាក់ប្រជាជនស្ទើរគ្រប់រូប ដែលពុំបានរត់ទៅតាមពួកខ្មែរក្រហម ។ ប្រជាជនទាំងនេះ គឺជាប្រជាជនដែលបាក់ស្បាតដោយភាពភ័យរន្ធត់និង អស់កម្លាំងដោយការអត់អាហារបរិភោគគ្រប់គ្រាន់ ការធ្វើការបាក់កម្លាំង និងរូបពីការសម្លាប់រង្គាលអស់រយៈពេលជិត៤ឆ្នាំ ។ ការស្វាគមន៍ស្រដៀងគ្នានេះ ដែលក្រោយមកគបស្នងដោយសោកនាដកម្ម ត្រូវបានសម្តែងទទួលពួកខ្មែរក្រហម នៅពេលដែលពួកខ្មែរក្រហមចូលកាន់កាប់ក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ ហើយបានបញ្ជាឲ្យប្រជាជនទីក្រុងភ្នំពេញទាំងអស់ ចេញទៅទីជនបទឲ្យក្លាយជាកម្មករធ្វើកសិកម្ម ។ ក្នុងករណីស្វាគមន៍ទាំង២លើកនេះ ប្រជាជនសុទ្ធសឹងកំពុងចង់បានសន្តិភាពយ៉ាងខ្លាំង[២] ។

នៅល្ងាចថ្ងៃ៧ មករា ឆ្នាំ១៩៧៩ កងកម្លាំងទ័ពវៀតណាមបានកាន់កាប់ទីក្រុងភ្នំពេញ ។ ក្រៅពីអ្នកទោសសង្គ្រាម ប៉ុន្មាន២ ទៅ៣រយនាក់ និងប្រជាជនដទៃទៀត រួមមានអ្នកធ្វើការមួយចំនួននៅមន្ទីរ ស-២១ ដែលកំពុងលាក់ខ្លួន រង់ចាំគេចខ្លួននោះ ទីក្រុងភ្នំពេញជាទីក្រុងគ្មានមនុស្សរស់នៅដ៏ស្ងាត់ជ្រងំ ។

បន្ទាប់ពីខ្មែរក្រហមបានជម្លៀសមនុស្សអស់ពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ភ្នំពេញនៅតែជារាជធានីនៃប្រទេសកម្ពុជា ក៏ប៉ុន្តែភ្នំពេញពុំដែលទទួលបានឋានៈជាមជ្ឈមណ្ឌលទីក្រុងមួយនោះទេ ។ បុគ្គលិកការិយាល័យ ទាហាន និងកម្មកររោងចក្រ ដែលតាំងនៅក្នុងក្រុងភ្នំពេញ ប្រហែលជាមិនដែលមានចំនួនលើសពី៥ម៉ឺននោះឡើយ ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាពុំមានហាងទំនិញ ផ្សារ សាលារៀន វត្តអារាម ឬបរិក្ខាសាធារណៈ លើកលែងតែឃ្លាំងមួយនៅក្នុងរាជធានីសម្រាប់បម្រើអ្នកការទូតប៉ុណ្ណោះ ។ ក្នុងក្រុងភ្នំពេញ រោងចក្រ បណ្តាគារ បន្ទាយទាហាន និងការិយាល័យរដ្ឋបាល ត្រូវបានហ៊ុំព័ទ្ធ ដោយរបងលួសបន្លាចាក់ស្រេះ ។ ផ្លាកសញ្ញាតាមផ្លូវ ត្រូវបានលាបថ្នាំពីលើ ហើយរនាំងលួសបន្លាត្រូវបានដាក់រាំងខ្ទប់ផ្លូវជាច្រើនពុំអនុញ្ញាតឲ្យធ្វើចរាចរ ។ នៅលើដីទំនេរ ពួកខ្មែរក្រហមដាំសុទ្ធតែដើមចេក ។ យានយន្តដែលបោះបង់ចោលនៅឆ្នាំ ១៩៧៥ ឡើងច្រេះចាប់គរលើគ្នា រួមទាំងម៉ាស៊ីនត្រជាក់ ម៉ាស៊ីន បោកខោអាវ ទូរទស្សន៍ និងម៉ាស៊ីនវាយអង្គុលីលេខ ។ ក្រដាសបោះចោលរាយរប៉ាត់រប៉ាយ រួមទាំងក្រដាសប្រាក់មុនបដិវត្តន៍ ដែលពុំមានតម្លៃអ្វីទាល់តែសោះក្នុងរបបខ្មែរក្រហម ។ នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ពុំមានឃើញប្រជាជន ឬសត្វពាហនៈអ្វីឡើយ ។ ដូចគ្នានឹងថ្ងៃ៧ មករា ឆ្នាំ១៩៧៩ដែរ នៅឆ្នាំ១៩៧៥ រដ្ឋាភិបាលមជ្ឈិមពីមុនបានបាត់អស់រលីង ។ ជាថ្មីម្តងទៀតប្រជាជនកម្ពុជាបានចាប់ពីឆ្នាំសូន្យ ។ (នៅមានត)

[១] និង [២] មានឯកសារយោង ក៏ប៉ុន្តែពុំត្រូវបានបកប្រែ ។

# គ្រោះថ្នាក់នៃអព្យាក្រឹតភាព ការបែកបាក់ទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិកឆ្នាំ ១៩៦៥

កាលពីព្រលឹមស្រាងៗ ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៦៥ ទូរសារដ៏បន្ទាន់មួយ ត្រូវបានបញ្ជូនពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅរាជធានីភ្នំពេញ មកដល់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។ ទន្ទឹមនឹងពេលនោះ បាតុកររាប់រយនាក់កំពុងតែចោមរោមនៅមុខស្ថានទូតអាមេរិកនៅឯភ្នំពេញ ។ ហ្វូងបាតុករបានកើនច្រើនឡើងៗជាលំដាប់ ហើយដុំថ្មជាច្រើនចាប់ផ្តើមហើរចេញពីហ្វូងបាតុករ ។ បុគ្គលិកក្នុងស្រុកទាំងអស់ដែលបម្រើការនៅស្ថានទូតអាមេរិកត្រូវបានបញ្ជូនឲ្យវិលត្រឡប់មកកាន់ផ្ទះរៀងៗខ្លួន ។ យានយន្តរបស់ស្ថានទូតត្រូវបានជម្លៀសចេញពីបរិវេណក្បែរស្ថានទូត ហើយជនជាតិអាមេរិកាំង ដែលស្នាក់អាស្រ័យនៅកម្ពុជាត្រូវបានបញ្ជូនទៅកាន់សណ្ឋាគាររ៉ូយ៉ាល់ ។ ក្នុងរយៈពេលប្រមាណ១ម៉ោងក្រោយប៉ុណ្ណោះ បង្អួចស្ថានទូតទាំងអស់ត្រូវបែកខ្ទេចខ្ទី ហើយទង់ជាតិអាមេរិករបស់ស្ថានទូតត្រូវបានដុតឆេះខ្ទេច ។ បដា២-៣ផ្ទាំងត្រូវបានលើកឲ្យឃើញដោយអំពាវនាវឲ្យទូត និងពលរដ្ឋអាមេរិកទាំងអស់ត្រឡប់ទៅស្រុកវិញ ។ កម្លាំងប៉ូលិសដែលបានមកដល់យឺតហើយនោះបានត្រឹមតែព្យាយាមបំពេញភារកិច្ចក្នុងការទប់ទល់នឹងបាតុករទាំងនោះប៉ុណ្ណោះ ហើយតាមសេចក្តីរាយការណ៍ប៉ូលិសទាំងនោះ «ឈរមើលសកម្មភាពដ៏គគ្រឹកគគ្រេង» នៃហ្វូងបាតុករទៅវិញ ។

មួយម៉ោងបន្ទាប់មកទៀត «ដុំថ្មគ្រប់ប្រភេទ» ធ្លាក់កកកុញលើបរិវេណនៃអគារស្ថានទូត ហើយបន្ទាប់មកប៉ូលិសបំពាក់ដោយឧបករណ៍បង្ក្រាបកុប្បកម្មបានចូលមកធ្វើអន្តរាគមន៍ហើយចាប់ផ្តើមរុញច្រានហ្វូងបាតុករដែលពេលនោះកើនចំនួនរហូតដល់ទៅរាប់ពាន់នាក់ឲ្យថយក្រោយ ។ លោក អាហ្វ ប័រហ្គេសិន Alf Bergesen បានពិពណ៌នាអ្នកចូលរួមក្នុងបាតុកម្មនេះថាលើសលប់ទៅដោយ «មនុស្សវណ្ណៈទាបបំផុតក្នុងសង្គមដែលមានអាកប្បកិរិយាច្រងេងច្រងាង» ។ អ្នកធាក់ស៊ីក្លូគឺល្បីថាជាអ្នកគប់ដុំថ្មដ៏ចម្បងជាងគេ ។ ពេលបាតុកម្មនេះត្រូវបានបញ្ចប់អគារដ៏ធំនេះស្ថិតក្នុងភាពរញ៉េរញ៉ៃគ្មានសណ្តាប់ធ្នាប់ពាសពេញទៅដោយ «ដុំថ្ម ផ្លែប៉េងប៉ោះ និងបំណែកកញ្ចក់នៅគ្រប់បន្ទប់ទាំងអស់» ។ ជញ្ជាំងខាងក្រៅប្រឡាក់ដោយស្នាមអក្សរក្រវេមក្រវាម ។ ក៏ប៉ុន្តែហ្វូងបាតុករពុំបានជ្រៀតចូលទៅក្នុងអគារស្ថានទូតនោះទេហើយការខូចខាតចំពោះអគារនៃស្ថានទូតពុំសូវជាធ្ងន់ធ្ងរប៉ុន្មានទេ គឺខូចខាតគិតជាទឹកប្រាក់អស់៤.៨៧៨,០៦ ដុល្លារអាមេរិកប៉ុណ្ណោះ ។

នេះពុំមែនជាបាតុកម្មហិង្សាលើកដំបូងប្រឆាំងនឹងស្ថានទូតអាមេរិកាំងនោះទេ ។ កាលពីខែមីនា ឆ្នាំ១៩៦៤ ការវាយប្រហារដ៏ធ្ងន់ធ្ងរជាងនេះមួយបានបង្កឲ្យខូចខាតជិត១៦០.០០០ ដុល្លារសហរដ្ឋអាមេរិកឯណោះ ។ នៅក្នុងឱកាសនោះមេដឹកនាំរបស់កម្ពុជា ព្រះអង្គ នរោត្តម សីហនុ ផ្ទាល់អាចជាអ្នកចេញបញ្ជាឲ្យប្រែក្លាយស្ថានទូតទាំងពីរ គឺស្ថានទូតអាមេរិក និងស្ថានទូតចក្រភពអង់គ្លេស ឲ្យប្រៀបដូចជាកន្លែងចាក់សំរាម ។ ក្រោយមកទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសទាំងពីរនេះធ្លាក់ក្នុងសភាពតានតឹង ប៉ុន្តែពុំទាន់មានការកាត់ផ្តាច់ចំណងទាក់ទងនៅឡើយទេ ។ ក៏ប៉ុន្តែ ពេលនេះមើលទៅព្រះអង្គម្ចាស់ សីហនុ ហាក់បីដូចជាតាំងចិត្តកាត់ផ្តាច់ចំណងទាក់ទងជាមួយប្រទេសទាំងពីរនេះ ។ នៅថ្ងៃបន្ទាប់ពីបាតុកម្មនោះ និងតាមដែលគេចងចាំកន្លងមកវាគឺជាលើកដំបូងដែលចលនាបាតុកម្មប្រឆាំងនឹងសហរដ្ឋអាមេរិកបានកើតឡើងនៅតាមបណ្តាទីរួមខេត្តជាច្រើន ដោយបាតុករបានស្រែកទាមទារឲ្យកម្ពុជាកាត់ផ្តាច់ចំណងទាក់ទងជាមួយសហរដ្ឋអាមេរិក ។ ទន្ទឹមនឹងពេលនោះអាជ្ញាធរកម្ពុជាបានបញ្ជាវបេសកជនអាមេរិកាំងចុងក្រោយបំផុតគឺលោក កាល ថមសុន Carl E. Thompson ចេញពីប្រទេសកម្ពុជា ។ អាជ្ញាធរកម្ពុជាបានប្រាប់លោក កាលថមសុនថាជនជាតិអាមេរិកាំងដទៃទៀតទាំងអស់នឹងត្រូវបង្ខំឲ្យចេញពីកម្ពុជាឲ្យអស់ក្នុងពេលឆាប់ៗនេះដែរ រួមទាំងជនជាតិអាមេរិកាំងដែលជាប្តី ឬប្រពន្ធរបស់ពលរដ្ឋកម្ពុជា ។

កាលពីថ្ងៃទី៣ ខែឧសភា ស្ថានទូតសហរដ្ឋអាមេរិកបានរាយការណ៍ថា នៅក្នុងសេចក្តីថ្លែងការណ៍មួយ «ដែលពុំត្រូវបានសង្កេតឲ្យបានសុក្រឹតល្អ» ព្រះអង្គម្ចាស់ សីហនុ ទំនងបានចង្អុលប្រាប់ថា ព្រះអង្គនឹងកាត់ផ្តាច់ចំណងទាក់ទងជាមួយសហរដ្ឋអាមេរិក ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះអង្គសង្ឃឹមថានឹងរក្សាចំណងទាក់ទងកុងស៊ុល ពីព្រោះថាព្រះអង្គទ្រង់ព្រះតម្រិះថាកម្ពុជាត្រូវការរូបិយប័ណ្ណបរទេសដែលអ្នកទេសចរជាតិអាមេរិកផ្តល់ឲ្យ ។ លោក ប៉ៃ បេសិន ភារៈធារី (មន្ត្រីការទូតបណ្តោះ

អាសន្នជិនសមុទ្រឲ្យឯកអគ្គរដ្ឋទូតដែលអវត្តមាន) សហរដ្ឋអាមេរិកបានទទួលពាក្យនេះជាផ្លូវការនៅម៉ោង៦ល្ងាច ថ្ងៃទី៣ ខែឧសភា នោះ ។ ដោយសារថា កម្ពុជាពុំបានផ្តល់ការធានានានាពាក់ព័ន្ធនឹងការបន្តទំនាក់ទំនងកុងស៊ុល សហរដ្ឋអាមេរិកបានសម្រេចចិត្តកាត់ផ្តាច់ទំនាក់ទំនងទាំងស្រុង ។ នៅចុងខែឧសភា ពុំមានជនជាតិអាមេរិកាំងជាផ្លូវការនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

កត្តាដែលទំនងជាមូលហេតុបណ្តាលឲ្យមានការផ្ទុះឡើងនូវបាតុកម្មនេះគឺ ព្រះអង្គម្ចាស់ សីហនុ ទ្រង់មានព្រះទ័យក្រេវក្រោធយ៉ាងខ្លាំងចំពោះអត្ថបទរបស់ ប៊ែណាត គ្រីស័រ Bernard Krisher នៅក្នុងទស្សនាវដ្តី ញូវស៊ីក Newsweek កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៦៤ ដែលបានចោទដោយពុំផ្តល់សំអាងថាព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ (ដែលជាព្រះមាតារបស់ព្រះអង្គម្ចាស់ សីហនុ) គឺ «ឆ្លូតនឹងលុយ» ហើយបានបង្កើតផ្ទះបនស្រីពេស្យាមួយជួរនៅជាយក្រុងភ្នំពេញ ។ ព្រះអង្គម្ចាស់ សីហនុ ទ្រង់ធ្លាប់មានប្រតិកម្មណាស់ចំពោះការរិះគន់មកលើកម្ពុជា ជាពិសេសរាជវង្សានុវង្សរបស់ព្រះអង្គ ហើយអត្ថបទនេះទំនងជា «បានកេះកៃ» ឲ្យផ្ទុះចេញជាការផ្តាច់ទំនាក់ទំនងនេះ ។ ប្រវត្តិវិទូ ដេវីដ ឆែនដល័រ David P. Chandler បានបន្ទរគាំទ្រថា អត្ថបទនេះហើយជាដើមហេតុ ។ លោក ដេវីដ សរសេរថាអត្ថបទនេះគឺជា «អ៊ីចុងក្រោយដែលធ្វើឲ្យព្រះអង្គម្ចាស់ សីហនុ លែងទ្រាំទ្របានតទៅទៀតចំពោះទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក» ។

ទោះបីជាយ៉ាងណាក៏ដោយ នៅពេលនោះមន្ត្រីអាមេរិកាំងអះអាងថា អត្ថបទដែលគួរឲ្យអាក់អន់ចិត្តនេះគ្រាន់តែជាការយកលេសមួយតែប៉ុណ្ណោះ ពីព្រោះថា ទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិក ហៀបនឹងទៅដល់ចំណុចបែកបាក់នៅមុនពេលមានបាតុកម្មនេះទៅទៀត ។ មន្ត្រីមួយចំនួនមាន អារម្មណ៍ថា បាតុកម្មនេះគឺទាក់ទងនឹងយុទ្ធនាការរបស់ព្រះអង្គម្ចាស់ សីហនុ ដើម្បីរាំងស្ទះសន្និសីទក្រុងហ្សឺណែវ ដែលត្រូវបានស្នើឡើងដើម្បីធានាអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា ហើយក៏ជាសន្និសីទមួយដែលព្រះអង្គធ្លាប់ទទូចចង់បានជាយូរមកហើយ ក៏ប៉ុន្តែពេលនេះព្រះអង្គលែងគាំទ្រតទៅទៀតហើយ ។ ប្រវត្តិសាស្ត្រផ្លូវការដែលពុំត្រូវបានបោះពុម្ពផ្សាយនៅឡើយអំពីទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិកបានផ្តល់នូវការបកស្រាយពន្យល់មួយទៀតអំពីបញ្ហានេះថាៈ ការទន្ទ្រានដោយអាវុធមកលើទឹកដីកម្ពុជាចេញពីវៀតណាមខាងត្បូងកាលពីខែមេសា ទើបជាមូលហេតុដែលត្រូវដាក់កំហុសលើ ។

ដូច្នេះពុំអាចកំណត់ថា កត្តាណាមួយតែឯកឯងជាមូលហេតុបណ្តាលឲ្យមានការកាត់ផ្តាច់ចំណងទាក់ទងរវាងកម្ពុជា និងសហរដ្ឋអាមេរិកនោះទេ ។ បញ្ហាជាច្រើនបានមូលផ្តុំគ្នាជះឥទ្ធិពលយ៉ាងខ្លាំង ដែលបណ្តាលឲ្យទំនាក់ទំនងនេះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែល្អក់កករឡើងជាលំដាប់ ។ បាតុកម្មនៅស្ថានទូតចាប់ផ្តើមមិនយូរប៉ុន្មានបន្ទាប់ពីសហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកលើវៀតណាមខាងជើងជាប្រចាំ ហើយនិងបន្ទាប់ពីសហរដ្ឋអាមេរិកបានបញ្ជូនអង្គភាពយោធាប្រយុទ្ធរបស់ខ្លួនជាលើកដំបូងទៅកាន់វៀតណាមខាងត្បូង ។ សង្គ្រាមហៀបតែនឹងរីករាលដាលដល់កម្រិតមួយដែលពុំមាននរណាអាចគ្រប់គ្រងបាន ហើយព្រះអង្គម្ចាស់ សីហនុ ទ្រង់ភ័យខ្លាចថាសង្គ្រាមនេះនឹងលេបត្របាក់មាតុភូមិដ៏តូចរបស់ព្រះអង្គទៅក្នុងអណ្តាតភ្លើងសង្គ្រាមដ៏កាចសាហាវនេះ ។ ដូចដែលភារៈធារីសហរដ្ឋអាមេរិក លោក ប៊ែរចេសិន បានមានប្រសាសន៍នាពេលនោះថា បាតុកម្មនេះបណ្តាលមកពី «ការរិះគន់ដោយប្រើភាសាធន់ជារឿយៗ និងកាន់តែខ្លាំងឡើងចំពោះគោលនយោបាយរបស់សហរដ្ឋអាមេរិក ជាពិសេសនៅវៀតណាម» ។ និយាយទូទៅជាងនេះ សង្គ្រាមត្រជាក់ដ៏អាក្រក់ហួសពីសមត្ថភាពគ្រប់គ្រងព្រមជាមួយនឹងការបង្ហាញគោលជំហរអព្យាក្រឹតផ្នែកយោធារបស់ព្រះអង្គម្ចាស់ សីហនុ គឺជាមូលហេតុចម្បងបណ្តាលឲ្យមានការបែកបាក់ទំនាក់ទំនងរវាងប្រទេសទាំងពីរ ។

នៅទីបញ្ចប់ ការទាមទាររបស់សង្គ្រាមត្រជាក់ជាពិសេសគឺសេចក្តីប៉ងប្រាថ្នាឲ្យប្រទេសចិនចូលរួម ហើយនិងវាយចលនាបះបោរដឹកនាំដោយពួកកុម្មុយនិស្តនៅតាមបណ្តាប្រទេសជិតខាងនឹងវៀតណាមឲ្យបរាជ័យ បានបង្ហាញពីការពិតថាសហរដ្ឋអាមេរិកពិបាកបំផុតនឹងទទួលយកជំហររបស់កម្ពុជាជាប្រទេសអព្យាក្រឹត ។ ទោះបីជាកត្តាផ្ទៃក្នុងនៅកម្ពុជាក៏បានរួមចំណែកនាំឲ្យមានការបែកបាក់ទំនាក់ទំនងរវាងប្រទេសទាំងពីរនេះក៏ដោយ ក៏ការសិក្សាវិភាគចុងក្រោយមួយអំពីអាស៊ី-អគ្នេយ៍បង្ហាញថា សហរដ្ឋអាមេរិកពុំអាចរកវិធីមួយដើម្បីគាំទ្រលទ្ធិប្រឆាំងនឹងកុម្មុយនិស្ត និងលទ្ធិអព្យាក្រឹតក្នុងពេលជាមួយគ្នាបានឡើយ ។ **វ៉ៃយនគុន វ៉ក្លេម័រ**

(នៅមានត)

# គំរូមួយនៃភស្តុតាងឯកសារដែលធ្លាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្ត កម្ពុជាដែលនៅរស់នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

កាលពីខែមីនា ឆ្នាំ១៩៩៩ អគ្គលេខាធិការអង្គការសហប្រជាជាតិ ឯកឧត្តម កូហ្វី អាណាន់ បានផ្សព្វផ្សាយជាសាធារណៈនូវ «របាយការណ៍របស់ក្រុមអ្នកជំនាញជាន់ខ្ពស់របស់អង្គការសហប្រជាជាតិនៅកម្ពុជា» ដែលបានបង្កើតឡើង «ដើម្បីវាយតម្លៃភស្តុតាងដែលមានស្រាប់» អំពី «ការរំលោភបំពានធ្ងន់ធ្ងរទាំងឡាយលើច្បាប់ប្រទេសកម្ពុជា និងច្បាប់អន្តរជាតិ» ដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបគ្រប់គ្រងរបស់បក្សកុម្មុយនិស្តកម្ពុជាដែលនិយមហៅថា «ខ្មែរក្រហម» នៅក្នុងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

អ្នកជំនាញទាំងបីរូបរបស់អង្គការសហប្រជាជាតិ គឺលោក រ៉ាជសូម័រ ឡាឡា, លោក នីនាន ស្ទីហ្វិន និងលោក ស្ទីវ រ៉ាតន័រ បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ ដូចដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ឯកឧត្តម កូហ្វី អាណាន់ បានបញ្ជាក់ក្នុងលិខិតរបស់ឯកឧត្តមប្រគល់របាយការណ៍នេះជូនប្រធានក្រុមប្រឹក្សាសន្តិសុខ និង ប្រធានមហាសន្និបាតអង្គការសហប្រជាជាតិដែរ អ្នកជំនាញទាំងបី បានធ្វើការសន្និដ្ឋានថា «ភស្តុតាងដែលប្រមូលបានមកទល់ពេលនេះ បានផ្តល់សក្ខីភាពច្បាស់ពីការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងររំលោភច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ» រួមមាន «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបង្ខំឲ្យធ្វើពលកម្ម ការធ្វើទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលនានា ដែលត្រូវបានការពារជាអន្តរជាតិ» ។

អ្នកជំនាញទាំង៣ ក៏បានកំណត់ក្រុមជនរងគ្រោះមួយចំនួន «ដែលត្រូវបានដៅ..ដើម្បីបោសសម្អាត ដោយសំអាងថាក្រុមជនរងគ្រោះទាំងនេះមានជំនឿនយោបាយប្រឆាំង ឬមានជាតិពន្ធ ឬវណ្ណៈសង្គមផ្សេង» ។ ទាក់ទងទៅនឹងបញ្ហាខាងលើនេះ អ្នកជំនាញទាំងបីបានអះអាងថា «ដោយពុំមានប្រព័ន្ធច្បាប់ជាផ្លូវការណាមួយ ស្ទើរតែគ្រប់អង្គភាពទាំងអស់នៃរបប (បក្សកុម្មុយនិស្តកម្ពុជា) ទំនងជាមានសិទ្ធិ និងរហូតដល់ទៅមានភារកិច្ចកំណត់អត្តសញ្ញាណកម្ម ចាប់ឃុំឃាំង និងសម្លាប់មនុស្សទាំងឡាយដែលអង្គភាពនីមួយៗជឿថា ជាខ្មាំងសត្រូវ» ។ អ្នកជំនាញទាំងបីបានបញ្ជាក់លម្អិតថា «ចំណាប់ប្រភេទសង្គមដែលត្រូវបានចាត់ទុកជាមុខព្រួញសង្ស័យជាពិសេសទាំងនោះ» រួមមាន «មន្ត្រីនៃរបបមុន» ដូចជា «អតីតមេដឹកនាំរដ្ឋាភិបាលមុន, នាយទាហាន និងបុគ្គលិករាជការនៅតាមបណ្តាការិយាល័យនានានៃរបបសាធារណរដ្ឋ» ដែលបានដួលរលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយប្រភេទមនុស្សទាំងនេះហើយដែល «ត្រូវបានបក្សកុម្មុយនិស្តកម្ពុជា ដាក់គោលដៅបោសសម្អាតភ្លាម» ។ អ្នកជំនាញទាំងបីបានបន្ថែមថា «នៅត្រឹមឆ្នាំ១៩៧៧ ការបោសសម្អាតនេះ បានរាលដាលដល់ពលទាហានបុណ្យសក្តិទាបបំផុតនៃរបបសាធារណរដ្ឋខ្មែរ ក៏ដូចជាដល់សាច់សារលោហិតរបស់ពលទាហានទាំងនោះ» ។ មិនតែប៉ុណ្ណោះ អ្នកជំនាញទាំងបីបានធ្វើការសន្និដ្ឋានថា ជនជាតិភាគតិចដែលត្រូវ «បានដាក់ជាគោលដៅ...បង្ខំឲ្យជនជាតិទាំងនោះទៅរស់នៅឡុកឡំជាមួយសង្គមទូទៅ ឬបង្ខំឲ្យធ្លាក់ក្នុងស្ថានភាពដុនដាបលើសពីនេះទៅទៀត» គឺសហ-គមន៍ជនជាតិចាមជាច្រើនដែលត្រូវបានពួកខ្មែរក្រហម «ប្រើកម្លាំងកម្ចាត់កម្ចាយ ហាមឃាត់មិនឲ្យប្រើប្រាស់ភាសា និងទំនៀមទម្លាប់ និងបង្ខំឲ្យជនជាតិចាមឈរមើលមេដឹកនាំ និងអ្នកដទៃទៀតដែលរើបម្រះប្រឆាំងនឹងនយោបាយរបស់រដ្ឋាភិបាលនៃរបបនេះត្រូវបានយកទៅសម្លាប់» ហើយនឹងសហគមន៍ជនជាតិវៀតណាម ដែលសមាជិកទាំងអស់នៃសហគមន៍នេះត្រូវសម្លាប់ចោលស្ទើរតែទាំងអស់នៅទីបំផុត ។

ជនរងគ្រោះ ២ប្រភេទទៀត ដែលអ្នកជំនាញទាំងបីបញ្ចូលនៅក្នុងបញ្ជីនៃក្រុមដែលជាគោលដៅ គឺ «គ្រូបង្រៀន

និស្សិត និងអ្នកចេះដឹងដទៃទៀត» និង «មេដឹកនាំសាសនា» ជាទូទៅ មិនមែនតែមេដឹកនាំសាសនាអ៊ីស្លាមជាជនជាតិភាគតិច ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងព្រះសង្ឃព្រះពុទ្ធសាសនា ដែលជាសាសនារបស់ក្រុមជនជាតិភាគច្រើន ។

នៅទីបញ្ចប់អ្នកជំនាញទាំងបីនេះ បានចន្លុលបង្ហាញថា «ការបោសសម្អាតផ្ទៃក្នុងបក្សកុម្មុយនិស្តកម្ពុជា» ខ្លួនឯងដែលដៅទៅលើ «ខ្មាំងបង្កប់ក្នុងជួរបក្ស» ទទួលការគាំទ្រពីខាងក្រៅ ដែលត្រូវបានចោទប្រកាន់ «ថាជាភ្នាក់ងារស៊ី.អាយ.អេ កា.ហ្សេ.បេ ឬជាភ្នាក់ងារបម្រើឲ្យវៀតណាម» ។

អ្នកជំនាញទាំង៣ បានធ្វើការសន្និដ្ឋានថា សមាជិកនៃក្រុមទាំងនេះគឺត្រូវបានទទួលរង «ការប្រហារជីវិតដោយផ្ទាល់» ដោយកម្មាភិបាលរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលចាត់ទុកជា «គោលដៅដែលបានកំណត់ជាក់លាក់» ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អ្នកជំនាញទាំងបីបានប្រកាសថា «ការរំលោភបំពានមួយចំនួនទំនងជាបានកើតឡើង ដោយពុំមានទ្រង់ទ្រាយជាសណ្ឋានដូចគ្នាមួយ ដែលអាចកំណត់អត្តសញ្ញាណកម្មបានយ៉ាងច្បាស់លាស់ឡើយ» ។

ទោះបីជាបានប្រកាសអះអាងថា ភស្តុតាងបានបញ្ជាក់សក្ខីភាពចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ហើយថាក្រោមការណែនាំរបស់បក្សកុម្មុយនិស្តកម្ពុជា រដ្ឋាភិបាលបានធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវស្ទើរតែគ្រប់អំពើទាំងអស់ដែលបានចែងនៅក្នុងអនុសញ្ញា «ស្តីអំពីការទប់ស្កាត់ និងការបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ក៏ដោយ ក៏អ្នកជំនាញទាំងបីរូបបានទាញការប្រុងប្រយ័ត្នថា បង្ហាញទោសអំពីបទអំពើប្រល័យពូជសាសន៍អាចជា «ភារកិច្ចមួយដ៏លំបាក» ដើម្បីកំណត់ថា តើបក្សកុម្មុយនិស្តកម្ពុជា «បានអនុវត្តអំពើទាំងនេះដោយមាន «ចេតនា» ដែលជាធាតុផ្សំចាំបាច់ និងប្រព្រឹត្តមកលើក្រុមដែលត្រូវបានទទួលការការពារដោយអនុសញ្ញានេះដែរ



ឬទេ» ។ ហេតុដូច្នេះ អ្នកជំនាញទាំងនោះបានអំពាវនាវសុំឲ្យមានការស៊ើបអង្កេតបន្ថែមលើភស្តុតាងចំពោះ «ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើជនជាតិចាម វៀតណាម និងក្រុមជនជាតិភាគតិចដទៃទៀតហើយនិង សង្ឃព្រះពុទ្ធសាសនា ។»

អ្នកជំនាញទាំងបីទំនងជាកំពុងទាញហេតុផលយ៉ាងច្បាស់ជាងនេះទៀតថា អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ ហើយនិងសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារទំហំនៃការដែលប្រជាជនទាំងនេះត្រូវបានដាក់ឲ្យទទួលរងនូវអំពើមនុស្សឃាត ការសម្លាប់បំផុតពូជ ហើយនិងអំពើទារុណកម្ម និង ថែមទាំងដាក់ជាគោលដៅជាក់លាក់មានលក្ខណៈជាប្រព័ន្ធ និងទាំងហ្វូងៗតាមរយៈអំពើឧក្រិដ្ឋទាំងឡាយដែល «ត្រូវបានប្រព្រឹត្តដោយមានមូលហេតុរើសអើង និងដោយមូលហេតុនយោបាយ» ។



ចំពោះបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលខ្មែរក្រហម អ្នកជំនាញទាំងបីបានសង្កត់បញ្ជាក់ថា «ច្បាប់អន្តរជាតិបានទទួលស្គាល់ជាយូរណាស់មកហើយថា បុគ្គលទាំងឡាយត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើឧក្រិដ្ឋ ទោះបីជាពួកគេពុំបានប្រព្រឹត្តអំពើទាំងនោះដោយផ្ទាល់ក៏ដោយ» ។ ហេតុដូច្នោះ ការទទួលខុសត្រូវព្រហ្មទណ្ឌ គួរតែពន្លាតមិនត្រឹមតែទៅដល់ «មេបញ្ជាការយោធា និង មេដឹកនាំស៊ីវិល» របស់បក្សកុម្មុយនិស្តកម្ពុជា ដែលបានបញ្ជាឲ្យប្រព្រឹត្តអំពើឃោរឃៅទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅដល់បុគ្គលទាំងឡាយដែល «បានដឹងឮ ឬគួរតែបានដឹងថា អំពើឃោរឃៅទាំងនោះកំពុង ឬហៀបនឹងប្រព្រឹត្ត ដោយមន្ត្រីក្រោមបង្គាប់របស់ខ្លួន ហើយខកខានពុំបានទប់ស្កាត់បញ្ឈប់ ឬដាក់ទណ្ឌកម្មមន្ត្រីថ្នាក់ក្រោមទាំងនោះ» ។ អ្នកជំនាញទាំងបីបានទាញហេតុផលបញ្ជាក់ទៀតថា ភស្តុតាងនៃ «ការបានដឹងឮ ឬគួរបានដឹង» នេះបញ្ជាក់ពី «ភាពចាំបាច់តម្រូវឲ្យមានការស៊ើបអង្កេតពី តួនាទីរបស់មន្ត្រីខ្មែរក្រហមទាំងនោះដែលកាន់មុខតំណែងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងអំពើឃោរឃៅទាំងនេះ» ។ នៅក្នុងពេលជាមួយគ្នានេះដែរអ្នកជំនាញទាំងបីបានទាញការប្រុងប្រយ័ត្នថា បញ្ជីមន្ត្រីរដ្ឋាភិបាល និងមន្ត្រីបក្សកុម្មុយនិស្តកម្ពុជាកំពូលៗក្នុងករណីខាងលើពុំអាចដូចគ្នាទាំងអស់ទៅនឹងបញ្ជីបុគ្គលដែលទទួលខុសត្រូវជាងគេបំផុតចំពោះការរំលោភបំពានដ៏ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលនៅក្នុងនោះមេដឹកនាំរដ្ឋាភិបាលកំពូលៗមួយចំនួន អាចត្រូវបានដកចេញពីធាតុផ្សំនៃ «ការបានដឹង និងការធ្វើការសម្រេចចិត្ត» ។ ប៉ុន្តែមេខ្មែរក្រហមដទៃទៀត ដែលមិននៅក្នុងបញ្ជីមេដឹកនាំជាន់ខ្ពស់អាចដើរតួនាទីដ៏សំខាន់មួយនៅក្នុងការប្រព្រឹត្តអំពើឃោរឃៅទាំងនេះ ។

ដូចដែលអ្នកជំនាញមួយរូប ក្នុងចំណោមអ្នកជំនាញទាំងបីបានពន្យល់ក្នុងបរិបទ ដែលមានលក្ខណៈទូលំទូលាយជាងនេះមួយថា:

ការសន្និដ្ឋាននានា ដោយផ្អែកលើឯកសារប្រវត្តិសាស្ត្រពុំដូចគ្នាបេះបិទទៅនឹងភស្តុតាងបំពេញនិយមន័យ ដើម្បីដាក់កំហុសដល់បុគ្គលនោះទេ ។ ការសន្និដ្ឋានទាំងនេះតម្រូវឲ្យធ្វើការត្រួតពិនិត្យភស្តុតាងលម្អិតបន្ថែមទៀត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍

ជាក់លាក់និងតួនាទីរបស់បុគ្គលជាអ្នកប្រព្រឹត្ត នៅក្នុងព្រឹត្តិការណ៍នោះហើយនិងភស្តុតាង ដែលគិតថាអាចទទួលយកបានដោយវេទិកាច្បាប់សមស្របណាមួយ ។

ទោះបីជាយ៉ាងណាក៏ដោយអ្នកជំនាញទាំងបីបានផ្តល់ជាយោបល់ថា «តុលាការណាមួយក៏ដោយ» ដែលបង្កើតឡើងដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មចន្លោះឆ្នាំ១៩៧៥-៧៩ គួរតែ «ផ្តោតទៅលើបុគ្គលទាំងឡាយដែលទទួលខុសត្រូវបំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្ស» នៅក្នុងអំឡុងពេលនៃការដឹកនាំដោយបក្សកុម្មុយនិស្តកម្ពុជា ។ អ្នកជំនាញទាំងបីបានអះអាងថា «នេះរួមមានមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវលើការរំលោភបំពាននានាព្រមទាំងបុគ្គលខ្មែរក្រហមទាំងឡាយ នៅកម្រិតទាបជាងនេះ ដែលមានការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើឃោរឃៅព្រៃផ្សៃបំផុត» ។ អ្នកជំនាញទាំងបីបានជូនយោបល់ថាជាលទ្ធផលប្រហែល «មនុស្សប្រមាណ២០ ទៅ ៣០» នឹងត្រូវនាំយកមកកាត់ទោស ។



អ្នកជំនាញទាំងបីបានពិនិត្យឯកសារសំខាន់ៗរបស់បក្សកុម្មុយនិស្តកម្ពុជាដែលមានស្រាប់ រួមទាំងឯកសារខ្មែរក្រហមដែលតម្កល់ទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ហើយនិងដោយអង្គការដទៃទៀតហើយមានជំនឿថា ឯកសារទាំងនេះរួមមាន «ភស្តុតាងឯកសារ» ដែល «ចង្អុលបង្ហាញអំពីតួនាទីរបស់បុគ្គលខ្មែរក្រហមមួយចំនួននៅក្នុងការប្រព្រឹត្តការរំលោភបំពាន សិទ្ធិមនុស្សធ្ងន់ធ្ងរ» ក្នុងប្រភេទដូចបានរៀបរាប់ខាងលើ ។ ទោះបីជាយ៉ាងណាក៏ដោយអ្នកជំនាញទាំងនោះបាននិយាយ ថាទោះបីជាបណ្ណសារដ្ឋានជាតិ និងឯកសារខ្មែរក្រហម ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកដទៃទៀត «ផ្តល់នូវកាលប្បវត្តិដ៏សំខាន់ និងពត៌មានលម្អិតអំពីព្រឹត្តិការណ៍នានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏ឯកសារទាំងនោះតែឯងពុំគ្រប់គ្រាន់ដើម្បីកសាងសំណុំរឿងប្រឆាំងនឹងបុគ្គលខ្មែរក្រហមណាមួយជាក់លាក់បានឡើយ» ។ អ្នកជំនាញទាំងបីបានធ្វើការកត់សម្គាល់ថាកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ មកទល់ពេលនេះបាន «នាំឆ្ពោះ ទៅរកការស៊ើបអង្កេត ក្នុងការរៀបចំដើម្បីធ្វើការកាត់ទោសបុគ្គលមួយចំនួន» ។ ជាលម្អិតអ្នកជំនាញទាំងបីបានធ្វើការសន្និដ្ឋានថាទោះបីជាកំណត់ត្រាឯកសារដែល «បានចង្អុលបង្ហាញយ៉ាងច្បាស់ពីតួនាទីរបស់បុគ្គលជាក់លាក់ថា ជាអ្នកបានចូលរួមផ្ទាល់ ឬជាមន្ត្រីថ្នាក់លើ» ទំនងជា «មានច្រើនណាស់» ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងយន្តការសួរចម្លើយ និងប្រហារជីវិតរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលហៅថា គុកទួលស្លែង ក៏ដោយ ក៏ «ភស្តុតាងឯកសារ» ដទៃទៀតដែលពាក់ព័ន្ធបុគ្គលខ្មែរក្រហមដោយផ្ទាល់ ទាំងនៅថ្នាក់រដ្ឋាភិបាល ឬតំបន់ ឬកម្រិតមូលដ្ឋាន គឺពុំទាន់មាននៅឡើយទេមកទល់ពេលបច្ចុប្បន្ន ហើយប្រហែលជាពុំអាចរកឃើញទៀតផង ។

ខ្ញុំបានធ្វើការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា កាលពីខែធ្នូ ឆ្នាំ១៩៩៨ ដល់ខែមករា ឆ្នាំ ១៩៩៩ ហើយជាថ្មីម្តងទៀតនៅក្នុងខែកក្កដា ដល់ ខែសីហា ឆ្នាំ១៩៩៩ ដើម្បីពិនិត្យ

មើលឲ្យកាន់តែជិតជាងនេះនូវភស្តុតាងឯកសារ ដោយសារថា អ្នកជំនាញអង្គការសហប្រជាជាតិមានពេលវេលាខ្លី និងឧបសគ្គដទៃទៀត ។ ខ្ញុំបានផ្តោតការសិក្សាទៅលើឯកសារទាំងឡាយដែលតម្កល់ទុក ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំសង្ឃឹមថានឹងអាចបង្កើតបាននូវគំរូឯកសារមួយចេញពីភស្តុតាងឯកសាររាប់រយពាន់ទំព័រនៅមជ្ឈមណ្ឌលឯកសារដែលអាចបន្ថែមទម្ងន់លើការវាយតម្លៃភស្តុតាងលើករណីទាំងនេះ ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់នាភស្តុតាងឯកសារនេះគ្រាន់តែតំណាងឲ្យភស្តុតាងមួយផ្នែកតូចនៃភស្តុតាងទាំងអស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលពាក់ព័ន្ធនឹងមេដឹកនាំខ្មែរក្រហមទាំងនេះ និង បុគ្គលដទៃទៀតប៉ុណ្ណោះ ។ ឯកសារទាំងអស់ដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាតម្រូវឲ្យមានការស្រាវជ្រាវច្រើនបន្ថែមទៀត ។ តាមពិតប្រសិនបើការស្រាវជ្រាវរបស់ខ្ញុំ ពុំបាននិយាយពីភស្តុតាងដទៃទៀតទាក់ទងនឹងបុគ្គលជាក់លាក់ណាមួយនោះ ពុំមែនចាត់ទុកថាពុំមានភស្តុតាងបែបនោះឡើយ ។



ពេលបច្ចុប្បន្ននេះ ដូចជា នួន ជា, តាម៉ុក, អៀង សារី, ខៀវ សំផន និង កែ ពក ដោយបញ្ជាក់ឲ្យច្បាស់ពីទំហំនៃការពាក់ព័ន្ធរបស់មេដឹកនាំខ្មែរក្រហមទាំងនេះ នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬយ៉ាងហោចណាស់ការដឹងឮដែលនាំឲ្យមេខ្មែរក្រហមទាំងនេះមានទោសអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមកលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជាខ្លួនឯង ដែលអ្នកជំនាញអង្គការសហប្រជាជាតិបានចង្អុលបង្ហាញថា ត្រូវបានប្រព្រឹត្តដោយមិនអាចប្រកែកបានក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនិស្តកម្ពុជា ។

ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំសូមសង្កត់បញ្ជាក់ថាគំរូ

## ខ្សែសង្វាក់នៃបទបញ្ជារចនាសម្ព័ន្ធ នៃការសម្រេចចិត្តគោលនយោបាយ និងការអនុវត្តន៍នានា

ការវាយតម្លៃអំពីពិរុទ្ធភាព នៅក្នុងករណីបុគ្គលជាមេដឹកនាំ ខ្មែរក្រហមនីមួយៗតម្រូវឲ្យគូសបញ្ជាក់ឲ្យច្បាស់អំពីទំនាក់ទំនងជាអន្តររវាងខ្សែសង្វាក់នៃបទបញ្ជា និងរចនាសម្ព័ន្ធនៃការធ្វើការសម្រេចចិត្តដែលដឹងឮជាទូទៅ និង សម្ងាត់ពីភ្នែកសាធារណជន និងវិធីផ្សេងៗដែលក្រុមមេដឹកនាំខ្មែរក្រហមប្រើប្រាស់ក្នុងការសម្រេចគោលនយោបាយ និងអនុវត្តគោលនយោបាយទាំងឡាយនោះ ។ ការគូសបញ្ជាក់បែបនេះមានសារៈសំខាន់បំផុត ប៉ុន្តែមានការពិបាកណាស់ នៅក្នុងករណីកម្ពុជា

ពីព្រោះកិច្ចការជាច្រើន ត្រូវបានរបបខ្មែរក្រហមមានចេតនាលាក់ទុកជាការសម្ងាត់ ការចងក្រងឯកសារនៅតែពុំមានលក្ខណៈពេញលេញ ហើយកសិណសាក្សីដែលមានគឺច្រើនតែឆ្លើយផ្ទុយគ្នា ។ អ្វីដែលលើកយកមកនិយាយក្នុងលេខនេះ និងលេខជាបន្តបន្ទាប់របស់ទស្សនាវដ្តីស្វែងរកការពិត គ្រាន់តែជាការប៉ុនប៉ងគូសបញ្ជាក់អំពីទំនាក់ទំនងនៃបទបញ្ជា និងរចនាសម្ព័ន្ធធ្វើការសម្រេចចិត្តមួយជាដំបូងតែប៉ុណ្ណោះ ។

## គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា និង គណៈកម្មាធិការអចិន្ត្រៃយ៍

និយាយជាផ្លូវការ យោងទៅតាមលក្ខន្តិកៈដែលត្រូវបានអនុម័ត នៅឯមហាសន្និបាតបក្សកុម្មុយនិស្តកម្ពុជា ក្នុងខែមករា ឆ្នាំ១៩៧៦ បានបង្ហាញថា «អង្គការដឹកនាំខ្ពស់បំផុត» របស់បក្សគឺគណៈកម្មាធិការមជ្ឈិម ដែលមាន ប៉ុល ពត ជាលេខាចាប់តាំងពីឆ្នាំ១៩៦៣ ហើយ នួន ជា ជាអនុលេខាចាប់តាំងពីឆ្នាំ១៩៦០ មកម្ល៉េះ ។

លក្ខន្តិកៈទាំងនោះបានប្រកាសថា «ភារកិច្ច» ទាំងឡាយរបស់គណៈកម្មាធិការមជ្ឈិមរួមមាន «ការអនុវត្តន៍គោលការណ៍របស់បក្ស...ទូទាំងប្រទេស», «ផ្តល់ការណែនាំនានាទៅគ្រប់ទាំងអស់» ទៅ «អង្គការក្រុង តំបន់ និងភូមិភាគទាំងអស់ និងជាពិសេសទៅឲ្យអង្គការបក្សនានា ដែលទទួលខុសត្រូវចំពោះផ្នែកផ្សេងទៀតទូទាំងប្រទេស» ចាត់ចែង និង ដាក់ពង្រាយសមាជិកបក្ស និងកម្មាភិបាលនៅក្នុងបក្សទាំងមូល...ប៉ុន្តែរក្សាការក្តោបក្តាប់យ៉ាងច្បាស់ និងជាអចិន្ត្រៃយ៍លើប្រវត្តិរូប និងគោលជំហរចាត់តាំងនយោបាយ និងព្រមទាំងអប់រំ និងបំពាក់គោលជំហរកម្មាភិបាលទាំងនោះជាប្រចាំ «អំពីមនោគមន៍វិជ្ជានយោបាយ និងចាត់តាំង» ។

គណៈកម្មាធិការបក្សភូមិភាគត្រូវបានដាក់ភារកិច្ចឲ្យ «ចុះផ្សារភ្ជាប់ខ្លួនយ៉ាងខ្ជាប់ខ្ជួនជាមួយមូលដ្ឋាន សាខា «បក្ស» ស្រុក និងតំបន់ នៅក្រោមការគ្រប់គ្រងរបស់ខ្លួន..... ដើម្បីដឹកនាំអនុវត្តភារកិច្ចក្នុងចំណោមមហាជន» ។ មកទល់ឆ្នាំ១៩៧៦ មានភូមិភាគចំនួន៦គឺ ភូមិភាគបូព៌ា មានសមមិត្ត សោភឹម (ហៅ សូ វណ្ណា ឬបង១៨) ជាលេខា, ភូមិភាគនិរតីមាន តាម៉ុក (ហៅ ឈិត ឈឿន ឬ ង្វួន កង ឬបងទី១៥) ជាលេខា, ភូមិភាគពាយ័ព្យ មានសមមិត្ត រស់ ញឹម (ហៅ ម៉ុល អ៊ុន) ជាលេខា, ភូមិភាគបស្ចិម មានសមមិត្ត ជាង ស៊ី (ហៅ ជូ ជេត) ជាលេខា, ភូមិភាគឧត្តរ មានសមមិត្ត កែ ពក ជាលេខា និងភូមិភាគឦសាន មានសមមិត្ត យ៉ា (ហៅ នៃ សារ៉ន ហៅ ម៉ែន សាន ឬសៀង) ជាលេខា ។ ក្រោយមកបន្ទាប់ពីភូមិភាគឧត្តររបស់ កែ ពក ត្រូវបានរៀបចំឡើងវិញឲ្យទៅជាភូមិភាគមជ្ឈិម ភូមិភាគឧត្តរថ្មីមួយក៏ត្រូវបានបង្កើតឡើង ដោយមាន កង ចាប (ហៅ សែ ឬ ចាន់ សាម) ជាលេខា ។

លក្ខន្តិកៈ ឆ្នាំ១៩៧៦ បាននិយាយអំពីវត្តមាននៃ «គណៈកម្មាការរៀបចំគណៈកម្មាធិការមជ្ឈិម» ហើយនិង «គណៈកម្មាធិការអគ្គសេនាធិការបក្សមួយ» នៃកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ ហើយទាក់ទងនឹងគណៈកម្មាធិការអគ្គសេនាធិការបក្ស លក្ខន្តិកៈនេះបានចែងអំពីការថែរក្សា «កងកម្លាំងយោធាធំមួយដែលជាកម្មសិទ្ធិរបស់មជ្ឈិម» ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខន្តិកៈនេះ ពុំបាននិយាយអំពីអង្គការសំខាន់ដ៏ធំធេងពីរទៀត ដែលប្រភពផ្សេងទៀតបានចង្អុលបង្ហាញនោះគឺ ៖ គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានបញ្ជាក់ដោយឯកសារលក្ខ-ការណ៍ផ្ទៃក្នុងជាច្រើន ចាប់តាំងពីការប្រកាសបើកមហាសន្និបាតបក្ស ខែមករា ឆ្នាំ១៩៧៦ និង តួនាទីរបស់គណៈកម្មាធិការនេះជាអង្គការដឹកនាំកំពូល តាមជាក់ស្តែងត្រូវបានទទួលស្គាល់ជាសាធារណៈក្រោយមក ។ វត្តមាននៃគណៈកម្មាធិការនេះតាំងពីឆ្នាំ១៩៦០មក ត្រូវបានពិពណ៌នានៅក្នុងបទសម្ភាសន៍និងឯកសារនានា ដែលសរសេរដោយអតីតសមាជិកខ្មែរក្រហមដែលនៅរស់រួមមាន នួន ជា តាម៉ុក និង អៀង សារី ប៉ុន្តែមកទល់ពេលនេះពុំមានឃើញឯកសារដើមជាភាសាខ្មែរដែលបានរាយឈ្មោះក្នុងបញ្ជីអំពីសមាជិកភាពនៃគណៈកម្មាធិការនេះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាម នួន ជា គណៈកម្មាធិការអចិន្ត្រៃយ៍មានសមាជិក៣រូប ក្នុងឆ្នាំ១៩៦០ ហើយកើនដល់៤រូបក្នុងឆ្នាំ១៩៦៣ ។ យោងទៅតាម អៀង សារី នៅត្រឹមខែកញ្ញា

ឆ្នាំ១៩៧៥ គណៈកម្មាធិការ នេះរួមមាន ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី (ខ្លួន ឯងផ្ទាល់), សុន សេន, តាម៉ុក និងវ៉ន វេត ។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលរៀបចំឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ បានកត់ត្រាថា គណៈកម្មាធិការអចិន្ត្រៃយ៍នេះបានសម្រេចអំពី «ការបែងចែកភារកិច្ច» និងអំពី «បញ្ហាដំណើរការប្រតិបត្តិកិច្ចការផ្សេងៗទៀត» ដែលដាក់ឲ្យលេខា ប៉ុល ពត ជាអ្នក «ទទួលខុសត្រូវលើផ្នែកយោធា និងសេដ្ឋកិច្ច» អនុលេខាធិការ នួន ជា ទទួលបន្ទុកលើ «កិច្ចការបក្ស កិច្ចការសង្គម វប្បធម៌ ឃោសនាការ និងការអប់រំជាផ្លូវការ» អៀង សារី ហៅ វ៉ាន់ ទទួលបន្ទុកទាំងកិច្ចការបក្ស និងកិច្ចការបរទេស សុន សេន ហៅ ខៀវ ឬ បង៨៧ ទទួលបន្ទុកកងកម្លាំងប្រដាប់អាវុធ «សេនាធិការ និងសន្តិសុខ» ហើយ វ៉ន វេត (ហៅ បង៨៩) ទទួលបន្ទុក «ឧស្សាហកម្ម រថភ្លើង និង នេសាទ» ហើយមិនតែប៉ុណ្ណោះ គណៈកម្មាធិការអចិន្ត្រៃយ៍ បានដាក់ការងារចាត់តាំងផ្សេងៗដល់កម្មាភិបាល ដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មាធិការមជ្ឈិម ។ ទោះបីជាបានសង្កត់បញ្ជាក់ថាគណៈកម្មាធិការអចិន្ត្រៃយ៍ ពុំចង់ឲ្យកិច្ចការទាំងអស់មូលផ្តុំតែនៅក្នុងដៃរបស់ខ្លួនក៏ដោយ កំណត់ហេតុនៃអង្គប្រជុំទាំងឡាយ បានធ្វើការកត់សម្គាល់ថា គណៈអចិន្ត្រៃយ៍នឹង «តាមដាន» ការអនុវត្តន៍មាគ៌ាបក្សរបស់ផ្នែកនីមួយៗ ដែលនៅក្រោមចំណុះគណៈកម្មាធិការនេះ ។ (នៅមានត)

**ស៊ីវ ហេង៉រ**

---

# ការស្វែងយល់អំពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (អត្ថបទសិក្សា)

ពាក្យ «ប្រល័យពូជសាសន៍» ជាដំបូងត្រូវបានបង្កើតឡើងដោយបណ្ឌិត រ៉ាហ្វែល លិមគិន (Dr. Rephael Lemkin) ក្នុងការឆ្លើយតបចំពោះការពិពណ៌នារបស់លោក វិនស្តុន ឆឺរឆីល (Winston Churchill) ដែលអះអាងថា គម្រោងសម្លាប់រង្គាលលើជនជាតិណាហ្ស៊ីជា «ឧក្រិដ្ឋកម្មគ្មានឈ្មោះ» ។ អនុសញ្ញាស្តីពីការបង្ការ និង ការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលក្នុងនេះហៅថា «អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍» គឺជាឧបករណ៍ច្បាប់មួយក្នុងចំណោមឧបករណ៍ច្បាប់សិទ្ធិមនុស្សដ៏ចម្បងៗដទៃទៀត ហើយគឺជាច្បាប់មួយមានសិទ្ធិអំណាចដ៏ចម្បងលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ អនុសញ្ញានេះកំណត់និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ថា ជាអំពើទាំងឡាយណាក្នុងចំណោមអំពើទាំងប៉ុន្មានដែលបានរៀបរាប់ខាងក្រោមនេះ ដែលត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លាញទាំងស្រុង ឬដោយផ្នែកនូវក្រុម ជនជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាមួយដូចជា÷

ក- ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម

ខ- បង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។

គ- បង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែកនៃក្រុម ។

ឃ- ដាក់បង្ខំនូវវិធានការណ៍នានា ដែលបង្ការមិនឲ្យមានកំណើតទារកនៅក្នុងក្រុម ។

ង- យកកូនក្មេងចេញពីសង្គមមួយ ទៅដាក់ក្នុងសង្គមរស់នៅមួយទៀតដោយបង្ខំ ។

ដោយយោងទៅតាមមាត្រា៣ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ សកម្មភាពខាងក្រោមនេះអាចត្រូវបានយកមកផ្តន្ទាទោស÷ ការប្រល័យពូជសាសន៍ ការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការញុះញង់ដោយផ្ទាល់និងជាសាធារណៈ ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការចូលដៃក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍តម្រូវឲ្យភាគីរដ្ឋទាំងឡាយមានកាតព្វកិច្ចចាត់វិធានការណ៍ «ដើម្បីធ្វើការផ្តន្ទាទោសឲ្យមានប្រសិទ្ធិភាព» ចំពោះជនទាំងឡាយណា ដែលរកឃើញថាមានទោសប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអំពើប្រល័យពូជសាសន៍នានាដូចដែល

មានចែងក្នុងមាត្រា៣ ។ ច្បាស់លាស់ជាងនេះទៅទៀតអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ តម្រូវឲ្យយកបុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើដែលអាចទទួលការផ្តន្ទាទោស មកជំនុំជម្រះក្តីដោយតុលាការ «របស់រដ្ឋនៅក្នុងដែនដីដែលអំពើនោះត្រូវបានប្រព្រឹត្ត» ឬដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ មេដឹកនាំដែលមានការទទួលខុសត្រូវស្របតាមរដ្ឋធម្មនុញ្ញ មន្ត្រីសាធារណៈ និងបុគ្គលម្នាក់ៗសុទ្ធតែអាចធ្វើការផ្តន្ទាទោសចំពោះបទល្មើសទាំងឡាយនៃអំពើប្រល័យពូជសាសន៍ដូចដែលបានចែងក្នុងមាត្រា៣ ។ ភាគីរដ្ឋទាំងឡាយដែលជាហត្ថលេខីនៃអនុសញ្ញានេះ ត្រូវអនុវត្តន៍កាតព្វកិច្ចនេះដើម្បីផ្តន្ទាទោស «សមស្របទៅនឹងរដ្ឋធម្មនុញ្ញនៃរដ្ឋរៀងៗខ្លួន» ។

ចំពោះការបង្ការ ឬ ទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺរដ្ឋទាំងអស់ត្រូវចងភ្ជាប់ដោយកាតព្វកិច្ចជាបទដ្ឋានដាច់ខាត (Jus cogens norm) ទោះបីរដ្ឋនោះមិនមែនជារដ្ឋហត្ថលេខីក៏ដោយ ។ តុលាការយុត្តិធម៌អន្តរជាតិ បានទទួលស្គាល់លក្ខណៈនៃបទដ្ឋានដាច់ខាតប្រឆាំងនឹងការប្រល័យពូជសាសន៍ ស្ថិតនៅក្នុង «ខ» រក្សាទុកទាំងឡាយក្នុងអនុសញ្ញាស្តីអំពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ ក្រោយមកតុលាការអន្តរជាតិបានអះអាងជាថ្មីនូវកាតព្វកិច្ចនេះក្នុងរឿងក្តី Barcelona Traction ។ នៅត្រង់នេះតុលាការយុត្តិធម៌អន្តរជាតិបានប្រកាសថាការទទួលខុសត្រូវរបស់រដ្ឋទាំងឡាយ ក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ គឺជាការកិច្ចមួយសម្រាប់រដ្ឋទាំងអស់ «ជាភាសាឡាតាំង Erga Omnes» ។ ការទទួលខុសត្រូវបែបនេះ «គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ដោយរដ្ឋទាំងអស់ ។ ដោយយល់អំពីសារៈសំខាន់នៃសិទ្ធិទាំងឡាយដែលពាក់ព័ន្ធរដ្ឋទាំងឡាយអាចត្រូវបានដាក់បន្ទុំឲ្យយកចិត្តទុកដាក់ផ្នែកច្បាប់ដើម្បីការពារសិទ្ធិទាំងនេះ ។ សិទ្ធិទាំងនេះគឺជាកាតព្វកិច្ចរបស់រដ្ឋទាំងអស់» ។

ដើម្បីប្រើប្រាស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បាន ដំបូងត្រូវរកឲ្យឃើញនូវក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាទាំងឡាយដែលជាជនរងគ្រោះ ។ ទី២ ចាំបាច់ត្រូវបង្ហាញពីចេតនាបំផ្លិចបំផ្លាញទាំងស្រុង ឬ ដោយផ្នែកនូវក្រុមដែលទទួលការការពារនោះ ។ ការប៉ុនប៉ងបំផ្លាញក្រុមដែលទទួលការការពារមួយ អាចញែកឲ្យដាច់នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត ។ ចេតនានៃការប្រព្រឹត្ត គឺជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលមានការលំបាកក្នុងការបង្ហាញភស្តុតាងបំផុត ពីព្រោះចាំបាច់ត្រូវញែកឲ្យដាច់ពីគ្នារវាងយុទ្ធជន និងជនស៊ីវិលទាំងឡាយដែលបានរងរបួស ឬបាត់បង់ជីវិត ឬជម្លៀសដោយសារសង្គ្រាមមួយដែលបានបង្កឡើង ប្រឆាំងនឹងភាគីសត្រូវរបស់រដ្ឋាភិបាល និងដោយសារសកម្មភាពនានាដែលសំដៅបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែកនូវក្រុមដែលទទួលការការពារ ។

ហេតុដូច្នេះហើយ ជារឿយៗការបង្ហាញអំពីអវត្តមាននៃ «ចេតនា» គឺជាការការពារជាវិជ្ជមានដ៏មានប្រសិទ្ធិភាពចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ ក៏ប៉ុន្តែនៅពេលដែលចេតនាប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍អាចត្រូវបង្ហាញច្បាស់ហើយនោះ តុលាការពុំចាំបាច់ព្យាយាមបង្ហាញឲ្យឃើញថា បុគ្គល ឬក្រុមនោះបានទទួលជោគជ័យក្នុងគោលបំណងរបស់ខ្លួនឡើយ ពីព្រោះទាំងការប៉ុនប៉ង និងការផ្សំគំនិតប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ អាចយកមកធ្វើការផ្តន្ទាទោសរួចទៅហើយ ។

មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ហើយអនុសញ្ញានេះចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ ។ រដ្ឋចំនួន៤៣ បានចុះហត្ថលេខាលើឯកសារច្បាប់ដើមនៃអនុសញ្ញានេះ ហើយក្រោយមកទៀតរដ្ឋចំនួន១០៤ បានឲ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។ ប្រទេសកម្ពុជាបានឲ្យសច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី ១៤ ខែតុលា ឆ្នាំ១៩៥០ ដោយពុំមានបង្ការធ្វើ «ខ» រក្សាទុក ហើយបានទទួលយកដែនសមត្ថកិច្ចដែលតម្រូវជាចាំបាច់នៃតុលាការយុត្តិធម៌អន្តរជាតិ ក្រោមអនុសញ្ញានេះក្នុងឆ្នាំ១៩៥៧ ។ ដូចដែលបាននិយាយពីមុនរួចមកហើយការបង្ការ ឬការទប់ស្កាត់អំពើប្រល័យពូជសាសន៍ត្រូវបានគេទទួលស្គាល់ថា ជាច្បាប់អន្តរជាតិ ជាទំ

នៀមទម្លាប់ ដោយពុំអនុញ្ញាតឲ្យធ្វើបដិបញ្ញត្តិ ឬការអនុវត្តន៍ប្រាសចាកពីអនុសញ្ញានេះឡើយ ។

ភស្តុតាងដើម្បីបង្ហាញធាតុផ្សំទាំងបី ដែលចែងក្នុងមាត្រា២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ៈ

**ធាតុផ្សំទី១ៈ អំពើនៃការប្រល័យពូជសាសន៍**

តើមានអំពើណាមួយក្នុងចំណោមអំពើទាំងប្រាំដែលបានរៀបរាប់ខាងលើកើតឡើងដែរឬទេ? សន្និសញ្ញាមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីចំណុចជាក់លាក់នៃអំពើដែលបានរៀបរាប់ដោយមាត្រា២នោះទេ ។ ក្នុងការកំណត់ថាតើ អំពើជាក់លាក់ណាមួយរំលោភលើមាត្រា ២នេះ ដែរឬយ៉ាងណានោះ ការផ្តោតយកចិត្តទុកដាក់ទៅលើសក្តានុពលដែលអំពើនោះបានបង្កឲ្យមានការបំផ្លិចបំផ្លាញផ្នែករាងកាយនៃក្រុមដែលទទួលការការពារមួយមានសារៈសំខាន់ជាចាំបាច់ ។ ឧទាហរណ៍នៃអំពើទាំងនេះមានដូចខាងក្រោមនេះ ÷

ក- ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម

ខ- ការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ការប្រព្រឹត្តបែបនេះរួមមានៈ ការដាក់ជាទាសករ ការបង្អត់អាហារ ការនិរទេស ការធ្វើទុក្ខបុកម្នេញ ការធ្វើទារុណកម្ម និងការឃុំឃាំងនៅក្នុងតំបន់ក្រខ្វត់ ជំរំបណ្តោះអាសន្ន ឬជំរំប្រមូលផ្តុំមនុស្សនៅក្នុងលក្ខខ័ណ្ឌរស់នៅ ដែលរៀបចំដើម្បីបង្កឲ្យធ្លាក់ក្នុងសភាពថោកទាប ការដកហូតនូវសិទ្ធិជាមនុស្សរបស់ជនរងគ្រោះ ឬគាបសង្កត់ និងបង្កឲ្យមានការឈឺចាប់យ៉ាងអមនុស្សធម៌ ។ ភាពមហន្តរាយនៃសតិបញ្ញា អាចត្រូវបានគេរាប់បញ្ចូលផងដែរនូវការបង្ខំឲ្យប្រើថ្នាំញៀន និងការអនុវត្តន៍បែបផ្សេងទៀតដែលបង្កមហន្តរាយខាងផ្នែកសតិបញ្ញា ។

គ- ការបង្កឡើងដោយចេតនានូវមហន្តរាយ ចំពោះស្ថានភាពរស់នៅរបស់ក្រុម សំដៅបំផ្លិចបំផ្លាញផ្នែករាងកាយដល់ក្រុមនោះទាំងមូល ឬដោយផ្នែក ។ ការប្រព្រឹត្តបែបនោះរួមមានៈ ការផ្តល់របបអាហារដល់ក្រុមមួយដើម្បីគ្រាន់តែមួយរស់ កាត់បន្ថយសេវាកម្មសុខាភិបាលឲ្យនៅតិចជាងកម្រិតអប្បបរមា និងពុំផ្តល់ទីស្នាក់អាស្រ័យគ្រប់គ្រាន់ ។

ឃ- ការដាក់វិធានការនានា ដោយមានចេតនាបង្ការមិនឲ្យមានកំណើតទារកនៅក្នុងក្រុម ។ វិធានការទាំងនោះរួមមានៈ ការប្រើមធ្យោបាយកុំឲ្យស្ត្រីមានកំណើតទារក ការបំបែកមនុស្សភេទខុសគ្នាឲ្យរស់នៅផ្សេងគ្នា ការបង្ខំឲ្យពន្លូតកូន និងការហាមឃាត់មិនឲ្យរៀបការ ។

ង- ការបញ្ជូនកូនក្មេង ដោយបង្ខិតបង្ខំចេញពីក្រុមមួយទៅក្រុមមួយទៀត ដែលកូនក្មេងទាំងនោះត្រូវបានបង្ខំឲ្យទទួលនូវការអប់រំខុសគ្នា អំពីការអប់រំរបស់ក្រុមរបស់កូនក្មេងទាំងនោះដើម្បីឲ្យកូនក្មេងទាំងនោះមានទំនៀមទម្លាប់ថ្មី សាសនាថ្មី និងប្រហែលជាឲ្យប្រើភាសាថ្មី តាមការជាក់ស្តែងអាចមានកម្រិតគ្រោះថ្នាក់បំផ្លិចបំផ្លាញក្រុមមួយដែលអនាគតរបស់ក្រុមនោះពឹងពាក់ជោគវាសនាទៅលើក្មេងជំនាន់នោះ ។

**ធាតុផ្សំទី២ៈ ក្រុមដែលត្រូវបានការពារ (ក្រុមដែលត្រូវបានការពារដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍)**

តើអំពើត្រូវបានប្រព្រឹត្តសំដៅបំផ្លិចបំផ្លាញក្រុម «ជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា» ដែរឬទេ? អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មិនបានពង្រីកការការពារទៅដល់ក្រុមនយោបាយ សេដ្ឋកិច្ច ឬក្រុមអាជីពទេ ។ នេះគឺដោយសារអ្នកព្រៀងអនុសញ្ញាយល់ថា អនុសញ្ញានេះគួរតែការពារតែបុគ្គលដែលជាសមាជិករបស់ក្រុមមួយពីកំណើត ដូច្នេះមិនអាចផ្លាស់ប្តូរលក្ខណៈពិសេសរបស់ក្រុមនោះបានទេ ។ ស្រដៀងគ្នានេះដែរ ក្រុមនយោបាយ សេដ្ឋកិច្ច និងក្រុមអាជីព ទំនងប្រែប្រួលគ្មានភាពស្ថិតស្ថេរជាអចិន្ត្រៃយ៍ ។

**ធាតុផ្សំទី៣ៈ ចេតនា**

តើអំពើត្រូវបានគេប្រព្រឹត្ត ដោយមានចេតនាបំផ្លិចបំផ្លាញទាំងមូល ឬដោយផ្នែកនៃក្រុមដែលត្រូវបានការពារដែរឬទេ?

អនុលោមទៅតាមការសិក្សារបស់អង្គការសហប្រជាជាតិស្តីពីអំពើប្រល័យពូជសាសន៍ «ដោយផ្នែក» ត្រូវបានគេយល់ថាជា «ចំនួនច្រើនសមហេតុផល ដោយប្រៀបធៀបទៅ

នឹងចំនួនសមាជិកសរុបនៃក្រុម ដូចជាសមាសភាពដឹកនាំរបស់ក្រុមនោះជាដើម» ។ ការសម្លាប់បុរសទាំងអស់ ឬស្ត្រីទាំងអស់នៃក្រុមមួយ ឬសមាជិកទាំងអស់នៃក្រុមមួយដែលមានទីលំនៅក្នុងប្រទេសណាមួយ ឬតំបន់នៃប្រទេសមួយ ក៏អាចជាភស្តុតាងនៃការបំផ្លិចបំផ្លាញ «ដោយផ្នែក» ដែលជាធាតុផ្សំទី៣នេះ ។ចេតនានៃអំពើប្រល័យពូជសាសន៍ ខុសប្លែកពីចេតនានៃអំពើឧក្រិដ្ឋធម្មតា ដូចជាមនុស្សឃាតជាដើម ហើយប្រសិនបើធាតុផ្សំ «ចេតនា» នេះគ្មានវត្តមានទេនោះ ទោះជាសកម្មភាពនោះសាហាវឃោរឃៅខ្លាំងប៉ុណ្ណាក៏ដោយ អំពើនោះពុំអាចជាអំពើប្រល័យពូជសាសន៍បានឡើយ ។ លទ្ធភាពពិតរបស់ជនដែលដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដើម្បីបំផ្លិចបំផ្លាញក្រុមជាគោលដៅគឺ មិនទាក់ទងទៅនឹងការកំណត់ថាតើសកម្មភាពទាំងនោះជាអំពើប្រល័យពូជសាសន៍នោះទេ ។ «ចេតនា» ត្រូវបានគេយល់ជាទូទៅថា ជាធាតុផ្សំដ៏ពិបាកបំផុតមួយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងការបង្ហាញភស្តុតាង ហើយជារឿយៗមានតែភស្តុតាងប្រយោល ឬ ភស្តុតាងបន្ទាប់បន្សំនៃធាតុផ្សំ «ចេតនា» កត្តានេះដែលអាចរកបាន ។ ឧទាហរណ៍នៃភស្តុតាងដែលអាចបង្ហាញនូវ «ចេតនា» រួមមាន ÷

- ការបញ្ជាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលនិយាយថាក្រុមដែលទទួលបានការពារត្រូវបោសសម្អាត ។
- ភស្តុតាងថា ក្រុមដែលត្រូវការពារ ត្រូវបានបំពាក់ផ្លាកជាសត្រូវរបស់រដ្ឋ ឬភស្តុតាងនៃសណ្ឋាននៃទង្វើបំផ្លិចបំផ្លាញ និងមានលក្ខណៈជាប្រព័ន្ធចំពោះក្រុមបែបនេះ ។
- ភស្តុតាងនៃចេតនា ប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់អង្គការមួយ ឬរដ្ឋមួយអាចដាក់ឲ្យបុគ្គលទាំងឡាយដែលពាក់ព័ន្ធជិតស្និទ្ធជាមួយអង្គការ ឬរដ្ឋខាងលើឲ្យទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ដែលអង្គការ ឬរដ្ឋខាងលើបានប្រព្រឹត្ត ។
- ប្រសិនបើផលវិបាកទាំងឡាយនៃអំពើមួយ អាចត្រូវបានប្រមើលមើលឃើញជាមុន ឬក៏ប្រហែលជាអាចដឹងមុនថានឹងនាំដល់ការបំផ្លិចបំផ្លាញក្រុមមួយ ។
- អនុលោមទៅតាមមាត្រាII(គ) នៃអនុសញ្ញានេះរបាយការណ៍មួយស្តីអំពីពង្រៀងនៃអនុសញ្ញា បានផ្តល់នូវការណែនាំដូចខាងក្រោមនេះ ដោយផ្អែកលើការបង្ហាញ ភស្តុតាង «ចេតនា» ប្រព្រឹត្តអំពើប្រល័យពូជសាសន៍÷

«ដាក់ស្តែង ប្រសិនបើសមាជិកនៃមនុស្សមួយក្រុមត្រូវបានគេដាក់នៅក្នុងជំរុំប្រមូលផ្តុំ ដែលជាកន្លែងដែលអត្រាមរណៈប្រចាំឆ្នាំ មានចំនួនចាប់ពី៣០ ទៅ៤០ភាគរយ បំណងក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺមិនអាចមន្ទិលសង្ស័យបានទេ ។ អាចមានករណីដែលពិបាកញែកឲ្យដាច់នៅត្រង់ថា អត្រាមរណៈខ្ពស់ធៀបទៅនឹងអត្រាខាងលើ អាចត្រូវបានចាត់ទុកថា មកពីមូលហេតុខ្វះការយកចិត្តទុកដាក់ ការធ្វេសប្រហែស ឬអំពីអមនុស្សធម៌ ដែលទោះបីជាគួរឲ្យស្អប់ខ្ពើមបែបណាក៏ដោយ អត្រាមរណៈនេះពុំអាចជាភស្តុតាងនៃ «ចេតនា» ប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ» ។

- «ចេតនា» អាចទាញបង្ហាញតាមរយៈ សកម្មភាពទាំងឡាយ ឬការខកខានមិនបានប្រតិបត្តិភារកិច្ចក្នុងលក្ខណៈធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់ក្នុងកម្រិតខ្លាំងជ្រុលពេកដែលចង្អុលបង្ហាញថាជនចុងចោទមានហេតុផលគ្រប់គ្រាន់ត្រូវតែដឹងអំពីផលវិបាកនានានៃទង្វើរបស់ខ្លួន ។
- អ្នកច្បាប់ជាច្រើនអះអាងថា ដរាបណាតម្រូវការចេតនាត្រូវបានបង្ហាញភស្តុតាងរួចហើយ មូលហេតុធំៗនានាពុំមានការទាក់ទងទៀតឡើយ ។ ដោយយោងទៅតាមសេចក្តីអះអាងនេះ សកម្មភាពមួយពុំត្រូវបានចាត់ទុកថាពុំមែនជាអំពើប្រល័យពូជសាសន៍ ដោយគ្រាន់តែថា អំពើនោះត្រូវបានជំរុញឲ្យប្រព្រឹត្តឡើងដោយហេតុផលនយោបាយ ។ (នៅមានត)





ការណែនាំអំពីតម្រូវការនៃធាតុផ្សំ "សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ" សម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់អន្តរជាតិ

សម្រាប់អ្នកអានដែលពុំមែនជាអ្នកច្បាប់ ហើយដែលពុំសូវស្គាល់អំពីចំណុចលម្អិតនៃច្បាប់ពាក់ព័ន្ធនឹង «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» និងអ្នកជំនាញជាន់ខ្ពស់ ហើយសូម្បីតែអ្នកច្បាប់ដែលពិភាក្សាអំពីបញ្ហាទាំងនេះ ជួនកាលអាចស្តាប់ទៅយល់ថាច្បាប់នេះចម្លែក ហាក់បីដូចជាយកច្បាប់នេះយកមកពីពិភពផ្សេងដូច្នោះ ។ ក៏ប៉ុន្តែដោយបានប្រឈមមុខនឹងការឈឺចាប់និងការស្លាប់បាត់បង់ជីវិតមនុស្សរាប់មិនអស់ អ្នកអានឆ្ងល់ថាតើអ្នកជំនាញច្បាប់ទាំងនេះឆ្លើយយ៉ាងដូចម្តេច ទើបដឹងច្បាស់បែបនេះថា អំពើឃោរឃៅទាំងឡាយត្រូវបានប្រព្រឹត្តឡើង ឬក៏ពុំត្រូវបានប្រព្រឹត្តឡើង «មានខ្សែសង្វាក់ ឬជាប់ពាក់ព័ន្ធ» ទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ? តើការសម្លាប់ និងធ្វើទារុណកម្មមនុស្សពុំអាចមានលក្ខណៈសាហាវឃោរឃៅស្មើគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេឬ ប្រសិនបើពុំគិតអំពីវត្តមាននៃសម្ព័ន្ធភាពសង្គ្រាម ដែលមើលទៅហាក់បីដូចជាពុំទាក់ទងគ្នាទៅនឹងឧក្រិដ្ឋកម្មនេះទាល់តែសោះ? ដើម្បីយល់បាននូវចម្លើយនានាចំពោះសំណួរដ៏សុក្រឹតតាមន័យច្បាប់ និងមានហេតុផលច្បាស់លាស់បែបនេះ យើងត្រូវទទួលស្គាល់ថា ច្បាប់នៃការដាក់ឲ្យទទួលខុសត្រូវជាអន្តរជាតិចំពោះអំពើឃោរឃៅព្រៃផ្សៃរំលោភលើសិទ្ធិមនុស្ស គឺច្បាប់នេះផ្ទុយមានទំនាស់ទៅនឹងគោលការណ៍សំខាន់មួយនៃច្បាប់អន្តរជាតិនោះ គឺអធិបតេយ្យភាពនៃប្រទេសមួយ ៗ ដើម្បីឲ្យសហគមន៍អន្តរជាតិ អាចលូកដៃចូលទៅក្នុងប្រទេសមួយដែលមានអធិបតេយ្យភាព ហើយដាក់មេដឹកនាំនៃប្រទេសនោះ ឲ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើអមនុស្សធម៌លើពលរដ្ឋរបស់ខ្លួន គឺជាគោលគំនិតមួយដែលពុំដែលធ្លាប់បានដឹងឮ ហើយទើបតែនឹងឮក្នុងពេលកន្លងមកនេះមិនយូរប៉ុន្មានឡើយ ។ ប្រការដែលគោលគំនិតនេះបានចាប់ផ្តើមយកមកអនុវត្តយ៉ាងយកចិត្តទុកដាក់ នៅក្នុងពេលមួយហៀបនឹងចូលសតវត្សរ៍ទី២១ គឺជាមរតកដែលសបញ្ជាក់យ៉ាងច្បាស់ នូវការស្អប់ខ្ពើមរបស់មនុស្សជាតិចំពោះអំពើប្រឡាក់ដោយឈាមក្នុងសតវត្សរ៍ទី២០ ។

គោលបំណងនៃអត្ថបទនេះ គឺដើម្បីពន្យល់ដោយសង្ខេបនូវអត្ថន័យនិងដើមកំណើតនៃតម្រូវការ «សម្ព័ន្ធភាពទៅ

នឹងជម្លោះប្រដាប់អាវុធ» ដើម្បីធ្វើការកាត់ទោសពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់អន្តរជាតិ ។ ការសម្រេចចិត្តរបស់តុលាការមួយថាតើ «តម្រូវការសម្ព័ន្ធភាព» នេះ នៅតែមានជាធរមាន នៅពេលដែលរបបខ្មែរក្រហមកាន់អំណាចដែរឬយ៉ាងណានោះ ហើយប្រសិនបើនៅជាធរមាន ថាតើតម្រូវការនេះអាចត្រូវបានចង្អុលបង្ហាញថា មានភស្តុតាងឆ្លើយតបពេញលេញចំពោះអំពើប្រព្រឹត្តដោយរបបខ្មែរក្រហម នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្លួនក្នុងប្រទេសកម្ពុជាដែរឬទេ? នោះនឹងជាបញ្ហាបឋម និងមានសារៈសំខាន់នៅក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពួកខ្មែរក្រហមត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។

បើកំណត់និយមន័យឲ្យខ្ចី «សម្ព័ន្ធភាពទៅនឹងជម្លោះប្រដាប់អាវុធ» សម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់អន្តរជាតិ ចាំបាច់តម្រូវឲ្យបង្ហាញពីខ្សែសង្វាក់ ឬការជាប់ពាក់ព័ន្ធរវាងអំពើទាំងឡាយ ដែលត្រូវបានចោទប្រកាន់ថា បំពេញលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលកំពុងកើតឡើងនាពេលនោះ ។ សារៈសំខាន់នៃការបង្ហាញអង្គហេតុទាំងពីរនេះចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺកើតឡើងទាំងស្រុងដោយការវិវត្តន៍ជាប្រវត្តិសាស្ត្រនៃច្បាប់អន្តរជាតិទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ខុសប្លែកពីករណីច្បាប់ជាតិភាគច្រើន ច្បាប់អន្តរជាតិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពុំមែនកើតឡើងដំបូងនៅក្នុងឯកសារសរសេរជាក់លាក់ណាមួយនោះឡើយ ។ ផ្ទុយទៅវិញអង្គច្បាប់នេះបានវិវត្តន៍ក្នុងរយៈពេលមួយ ដោយផ្អែកលើទំនៀមទម្លាប់ និង ការអនុវត្តន៍របស់បណ្តាប្រទេសនានា ។ ការកកើតដំបូងនៃច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺនៅក្នុងតុលាការនូរិមបឺកនៅប្រទេសអាល្លឺម៉ង់ ដែលក្នុងតុលាការនោះមេដឹកនាំនៃគណបក្សណាហ្ស៊ី អាល្លឺម៉ង់ ត្រូវបាននាំយកមកកាត់ទោសអំពីឧក្រិដ្ឋកម្មទាំងនេះ ដែលខ្លួនបានប្រព្រឹត្តនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ ជនស៊ីវិលរាប់លាននាក់ ត្រូវបានពួកណាហ្ស៊ីសម្លាប់នៅក្នុងអំឡុងសង្គ្រាមនោះ ។ ជនរងគ្រោះដែលបានស្លាប់ទាំងនោះរួមមានទាំងជនស៊ីវិលនៃបណ្តាប្រទេសដទៃទៀតដែលពួកណាហ្ស៊ីបានវាយដណ្តើមបាន ព្រមទាំងជនស៊ីវិលនៃប្រទេសអាល្លឺម៉ង់ខ្លួនឯង ដែលភាគច្រើនជាជនជាតិជ្វីហ្វ មិនតែប៉ុណ្ណោះថែមទាំងសមាជិកនៃក្រុមជនជាតិភាគតិចដទៃទៀត ។ បញ្ហាដែលតុលាការនូរិមបឺកប្រឈមមុខគឺថា ទោះបីជាការសម្លាប់ជនស៊ីវិលនៃបណ្តាប្រទេសដទៃទៀត ដោយពួកណាហ្ស៊ី ច្បាស់ណាស់ថា ជាការរំលោភបំពានលើច្បាប់សង្គ្រាមអន្តរជាតិក៏ដោយ ក៏ពេលនោះពុំទាន់មានច្បាប់អន្តរជាតិដែលចូលជាធរមានស្រាប់ ដែលដាក់ទោសព្រហ្មទណ្ឌចំពោះការសម្លាប់ពលរដ្ឋអាល្លឺម៉ង់រាប់លាននាក់ ដែលបានស្លាប់នៅក្នុងជំរំប្រមូលផ្តុំរបស់ពួកណាហ្ស៊ីនោះទេ ។ «នៅត្រង់ចំណុចនេះគួរតែបញ្ជាក់ឲ្យបានច្បាស់ថា សេចក្តីត្រូវការឲ្យមានតុលាការអន្តរជាតិមួយនៅក្នុងករណីដូចជា ការសម្លាប់រង្គាលរបស់ពួកណាហ្ស៊ី និងអំពើប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហមមានសន្ទុះពុះកញ្ជ្រោលឡើងពីព្រោះថា របបដឹកនាំដោយរដ្ឋាភិបាលនៃប្រទេសនេះផ្ទាល់ជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះមកលើពលរដ្ឋរបស់ខ្លួន ហើយបើពុំមានការនាំយកមកកាត់ទោសដោយសហគមន៍អន្តរជាតិ ពួកមេដឹកនាំទាំងនោះ នឹងរួចខ្លួនពីបទឧក្រិដ្ឋទាំងនោះ ។ ហេតុដូច្នេះតម្រូវចាំបាច់ឲ្យមានតុលាការលក្ខណៈអន្តរជាតិ ដែលប្រព្រឹត្តឡើងក្រោមច្បាប់អន្តរជាតិ» ។ ទោះបីជាអាជ្ញាធរជាក់លាក់ណាមួយ ពុំបានបញ្ជាក់ក្រោមច្បាប់អន្តរជាតិដើម្បីនាំយកមកកាត់ទោសពួកណាហ្ស៊ី អំពីបទសម្លាប់ពលរដ្ឋអាល្លឺម៉ង់ខ្លួនឯងក៏ដោយ ក៏តុលាការនូរិមបឺកបានធ្វើការសន្និដ្ឋានថា មនសិការនៃមនុស្សជាតិបានទទួចទាមទារឲ្យរកយុត្តិធម៌ឲ្យជនរងគ្រោះរាប់លាននាក់ ដែលត្រូវបានពួកណាហ្ស៊ីអាល្លឺម៉ង់សម្លាប់យ៉ាងព្រៃផ្សៃទាំងនោះ ។ បន្ទាប់ពីមានការជជែកវែកញែកជាច្រើនមកក៏បានឈានដល់ការសម្រុះសម្រួលគ្នាមួយរវាងអ្នកទាំងឡាយ ដែលបានទាញហេតុផលថា តុលាការនេះពុំមានសិទ្ធិអំណាចនៅក្រោមច្បាប់អន្តរជាតិដើម្បីធ្វើការកាត់ទោសពួកណាហ្ស៊ី ចំពោះការសម្លាប់

ជនជាតិអាល្លឺម៉ង់ដែលជាពលរដ្ឋរបស់ខ្លួន ហើយនឹងក្រុមមនុស្សម្នាងទៀតដែលទាញហេតុផលថា អំពើឃោរឃៅព្រៃផ្សៃបែបនេះមិនគួរអនុញ្ញាតឲ្យរួចខ្លួននោះទេ ។ ការសម្រុះសម្រួលនេះគឺថាការសម្លាប់ពលរដ្ឋអាល្លឺម៉ង់ ដោយពួកណាហ្ស៊ីអាល្លឺម៉ង់ អាចត្រូវបានបង្ហាញថា មានការពាក់ព័ន្ធក្នុងកម្រិតមួយទៅនឹងឧក្រិដ្ឋកម្មសង្គ្រាមរបស់របបណាហ្ស៊ីអាល្លឺម៉ង់ ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធជាមួយបណ្តាប្រទេសដទៃ «ដែលឧក្រិដ្ឋកម្មទាំងនេះអាចដាក់ទោសបានយ៉ាងច្បាស់ក្រឡែតក្រោមច្បាប់សង្គ្រាមអន្តរជាតិ» ។ បើដូច្នោះតុលាការអន្តរជាតិនូរ៉ឹមប៊ឺកនេះ មានសមត្ថកិច្ចអាចកាត់ទោសជនជាប់ចោទជាពួកណាហ្ស៊ីអាល្លឺម៉ង់ អំពីបទសម្លាប់ និងការប្រព្រឹត្តធ្វើបាបពលរដ្ឋរបស់ខ្លួនបាន ។ ការសម្រេចចិត្តមួយបែបនេះនៅតុលាការនូរ៉ឹមប៊ឺក គូសសម្គាល់នូវការចាប់កំណើតនៃទស្សនៈទំនើបនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយការសម្រុះសម្រួលដែលទើបតែនឹងរៀបរាប់ខាងលើ បានវិវត្តក្លាយទៅជាតម្រូវការ «សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ» ដើម្បីនាំយកមកកាត់ទោសនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់អន្តរជាតិ ។

ទោះបីជាបញ្ហានេះបើកទ្វារចំហឲ្យមានការពិភាក្សាវែកញែកក៏ដោយ អ្នកប្រាជ្ញជាច្រើនមានទស្សនៈថា នៅត្រឹមឆ្នាំ១៩៧៥ «សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ» នៅតែជាតម្រូវការមួយជាធរមានក្នុងច្បាប់អន្តរជាតិនៅឡើយ រីឯអ្នកប្រាជ្ញច្បាប់ភាគច្រើនបានឯកភាពថា ការវិវត្តន៍នៃច្បាប់អន្តរជាតិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចាប់តាំងពីចុងបញ្ចប់នៃរបបដឹកនាំដោយពួកខ្មែរក្រហម ពុំតម្រូវឲ្យមាន «សម្ព័ន្ធភាពសង្គ្រាម» នេះទៀតឡើយ ។ ហេតុដូច្នោះប្រសិនបើរដ្ឋាភិបាលមួយប្រព្រឹត្តការសម្លាប់រង្គាលទ្រង់ទ្រាយធំមួយមកលើពលរដ្ឋរបស់ខ្លួននាពេលបច្ចុប្បន្ននោះ ពុំចាំបាច់រកភស្តុតាងតម្រូវការបំពេញ «សម្ព័ន្ធភាពទៅនឹងជម្លោះប្រដាប់អាវុធ» ដើម្បីអាចកាត់ទោសមេដឹកនាំនៃរដ្ឋាភិបាលមួយនោះអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់អន្តរជាតិឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ តាមក្រមច្បាប់ព្រហ្មទណ្ឌជាមូលដ្ឋាន ជនជាប់ចោទមួយត្រូវជំនុំជម្រះក្តី ដោយអនុលោមទៅតាមច្បាប់ដែលនៅជាធរមាននាពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្ត ។ ហេតុដូច្នោះ ដើម្បីនាំយកមកកាត់ទោសមេដឹកនាំខ្មែរក្រហមអំពីបទសម្លាប់ និងប្រព្រឹត្តធ្វើបាបមកលើពលរដ្ឋរបស់ខ្លួននៅពេលដែលពួកខ្មែរក្រហមកាន់កាប់អំណាចនៅក្នុងប្រទេសកម្ពុជា តុលាការមួយអាចសន្និដ្ឋានថា ចាំបាច់ត្រូវតែបង្ហាញថា អំពើដែលពួកខ្មែរក្រហមបានប្រព្រឹត្ត «មានជាប់ពាក់ព័ន្ធទៅនឹង» ឧក្រិដ្ឋកម្មសង្គ្រាម ដែលប្រព្រឹត្តដោយរបបខ្មែរក្រហមនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលកំពុងកើតឡើងជាបន្តនៅក្នុងពេលនោះ ។ ទោះបីបញ្ហានេះ គឺច្បាស់ណាស់ថាជាបញ្ហាដែលត្រូវសម្រេចដោយអនុលោមទៅតាមច្បាប់របស់តុលាការដែលមានសមត្ថកិច្ចមួយក៏ដោយ ប៉ុន្តែចំពោះគំនិតរបស់ខ្ញុំផ្ទាល់ ខ្ញុំជឿថា មានភស្តុតាងគ្រប់គ្រាន់ដែលទំនងជាចង្អុលបង្ហាញថាៈ

១-របបខ្មែរក្រហម គឺស្ថិតក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម ចាប់តាំងពីឆ្នាំដំបូងបំផុតនៃការគ្រប់គ្រងអំណាចរបស់ខ្លួននៅកម្ពុជា ។

២-របបខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមដ៏ច្រើនសន្ធឹកសន្ធាប់ នៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធនោះ ។

៣-ពាក្យ «កម្ទេច» និងពាក្យ «បោសសម្អាត» នូវអ្វីដែលពួកខ្មែរក្រហមហៅថា «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» ដោយរបបខ្មែរក្រហម គឺមានការពាក់ព័ន្ធយ៉ាងច្បាស់ក្រឡែតទាំងទ្រឹស្តី និងការអនុវត្តន៍ជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលរបបខ្មែរក្រហមបានចូលប្រឡូក ។

ចំពោះតុលាការដែលរកឃើញស្របទៅនឹងការសន្និដ្ឋានទាំងនេះ នោះតម្រូវការនៃ «សម្ព័ន្ធភាពទៅនឹងជម្លោះប្រដាប់អាវុធ» នឹងមិនស្ថិតនៅជារនាំងចំពោះការនាំយកមេដឹកនាំខ្មែរក្រហម អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ ដែលពួកគេបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។

**រ៉ម៉ិន ចូរហាន់សាន់**

# "គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា និងរបបកម្ពុជាប្រជាធិបតេយ្យ"

គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា គឺជាគោលការណ៍មួយដែលចាក់គ្រឹះដ៏រឹងមាំនៅក្នុងច្បាប់អន្តរជាតិ ដែលដាក់មន្ត្រីយោធា និងមេដឹកនាំស៊ីវិលដែលជាអ្នកបញ្ជាឲ្យទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋជាក់លាក់មួយចំនួនដែលប្រព្រឹត្តដោយបុគ្គលនៅក្រោមបង្គាប់របស់ខ្លួន ។ នៅពេលដែលតម្រូវការផ្នែកច្បាប់ជាក់លាក់មួយចំនួនត្រូវបានឆ្លើយតបហើយនោះ គោលការណ៍ច្បាប់នេះ អាចជួយឲ្យតុលាការ ឬអង្គជំនុំជម្រះក្តីមួយរកឃើញថា ឧត្តមសេនីយ៍ម្នាក់មានទោសកំហុសពីបទមនុស្សឃាដជាច្រើនដែលប្រព្រឹត្តដោយពលទាហានធម្មតា ឬថានាយករដ្ឋមន្ត្រីម្នាក់មានកំហុសចំពោះការធ្វើទារុណកម្ម និងការប្រហារជីវិតដែលអនុវត្តនៅក្នុងពន្ធនាគាររបស់រដ្ឋមួយ ។

ការទាក់ទងនៃគោលការណ៍ នៃការទទួលខុសត្រូវលើការបញ្ជាទៅនឹងការជំនុំជម្រះក្តីខ្មែរក្រហមនាពេលអនាគតខាងមុខនេះ ស្តែងឲ្យឃើញយ៉ាងច្បាស់ក្រឡែត គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា ផ្តល់នូវមធ្យោបាយផ្នែកច្បាប់មួយ ដើម្បីដាក់អតីតមេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌជាច្រើន ដែលប្រព្រឹត្តដោយសមាជិកថ្នាក់ក្រោមនៃបក្សកុម្មុយនិស្តកម្ពុជា ។ យើងដឹងជាទូទៅថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាប្រព្រឹត្តបានតែមួយផ្នែកតូចនៃបទល្មើសដ៏ធ្ងន់ធ្ងរជាងគេបំផុតដោយផ្ទាល់ ក៏ប៉ុន្តែអំពើភាគច្រើននៃអំពើឧក្រិដ្ឋរាប់លានករណី ដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានអនុវត្តដោយទាហានថ្នាក់ក្រោម មន្ត្រីសន្តិសុខ និងឆ្មាំគុក ។ ហេតុដូច្នេះ គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជានឹងមានសារៈសំខាន់ចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ធាតុផ្សំជាមូលដ្ឋាននៃគោលការណ៍ នៃការទទួលខុសត្រូវលើការបញ្ជាមានបង្ហាញជូនដូចខាងក្រោមនេះ ។

## ១、 កាលប្រវត្តិ

ទោះបីជាគោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា គឺជាផ្នែកមួយនៃច្បាប់អន្តរជាតិ ជាទំនៀមទម្លាប់តាំងពីយូរយារមុនពួកខ្មែរក្រហមឡើងកាន់អំណាចទៅទៀតក៏ដោយ ក៏ការចងក្រងគោលការណ៍នេះជាច្បាប់ពិតប្រាកដជាលើកដំបូងទើបនឹងកើតមានឡើងនៅក្នុងពិធីសារបន្ថែម ឆ្នាំ១៩៧៧ ទៅនឹងអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ប៉ុណ្ណោះ ។ គោលការណ៍នេះត្រូវបានចែងក្នុងមាត្រា៨៦ និង៨៧ នៃពិធីសារបន្ថែមនេះ ហើយមានចែងច្បាប់ជាមូលដ្ឋាននៃគោលការណ៍នេះ ។ គោលការណ៍ច្បាប់នៃការទទួលខុសត្រូវលើការបញ្ជា ត្រូវបានបញ្ជាក់ច្បាស់ ហើយរៀបរាប់ជាសំខាន់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ តុលាការព្រហ្មទណ្ឌទាំង២នេះបានអនុវត្តគោលការណ៍នេះដោយគ្រាន់តែមានការលើកលែងបន្តិចបន្តួចប៉ុណ្ណោះ ហើយគោលការណ៍ច្បាប់នេះក៏អាចយកមកអនុវត្តនៅក្នុងការជំនុំជម្រះក្តីអតីតមេដឹកនាំរបបខ្មែរក្រហមនាពេលបច្ចុប្បន្ននេះដែរ ។

## ២、 ធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជា

និយាយតាមទ្រង់ទ្រាយជាគោល គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា អាចដាក់មន្ត្រី ឬមេដឹកនាំស៊ីវិលដែលជាអ្នកបញ្ជាឲ្យទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋនានា ដែលប្រព្រឹត្តដោយបុគ្គលនៅក្រោមបង្គាប់របស់ខ្លួន នៅពេលដែលលក្ខខណ្ឌដូចខាងក្រោមនេះត្រូវបានបំពេញៈ

### ក、 អំពើឧក្រិដ្ឋ

តម្រូវការធាតុផ្សំដំបូងនៃគោលការណ៍នៃការដាក់ឲ្យទទួលខុសត្រូវលើការបញ្ជា គឺមានលក្ខណៈច្បាស់ មានន័យថា ឧក្រិដ្ឋកម្មមួយត្រូវបានប្រព្រឹត្តឡើងរួចជាមុន ។ រាល់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរអាចនាំទៅដល់ការដាក់ឲ្យទទួលខុសត្រូវលើការបញ្ជា រួម

មានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការធ្វើទារុណកម្ម ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ហើយនិងបទល្មើសភាគច្រើនទៀតដែលបានចោទប្រកាន់ដោយពុំទាន់បានផ្តល់សំអាងភស្តុតាងមកលើពួកខ្មែរក្រហម ។ ឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្តដោយទាហាន ឬមន្ត្រីស៊ីវិលថ្នាក់ក្រោម ត្រូវមានភស្តុតាងគ្រប់គ្រាន់តាមច្បាប់ ដើម្បីបង្ហាញមុនពេលតុលាការឬអង្គជំនុំជម្រះក្តីមួយ អាចបន្តទៅដោះស្រាយការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ប្រធានឬមន្ត្រីថ្នាក់លើដែលត្រូវបានចោទប្រកាន់នោះ ។

## ខ. ទំនាក់ទំនងនៃការបញ្ជា

តម្រូវការទី២ នៃគោលការណ៍ទទួលខុសត្រូវលើការបញ្ជាគឺត្រូវបង្ហាញថា ទំនាក់ទំនងនៃការបញ្ជា ពិតជាមានវត្តមានរវាងមន្ត្រីថ្នាក់លើដែលត្រូវបានចោទប្រកាន់និងបុគ្គលនៅក្រោមបង្គាប់របស់មន្ត្រីនោះ នៅពេលដែលអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្ត ។ ទំនាក់ទំនងរវាងមន្ត្រីថ្នាក់លើ និងមន្ត្រីក្រោមបង្គាប់នេះអាចមានទ្រង់ទ្រាយជាទំនាក់ទំនងតាមច្បាប់ ឬទំនាក់ទំនងតាមហេតុការណ៍ ហើយមន្ត្រីថ្នាក់លើ ទាំងយោធា និងស៊ីវិល អាចដាក់ទោសក្រោមគោលការណ៍ច្បាប់នេះបាន ។ ដើម្បីបង្កើតបាននូវទំនាក់ទំនងលើការបញ្ជាដែលតម្រូវជាចាំបាច់នេះ មន្ត្រីថ្នាក់លើដែលត្រូវបានគេចោទប្រកាន់ ត្រូវមានអំណាចពិតប្រាកដដើម្បីគ្រប់គ្រងសកម្មភាពនានារបស់មន្ត្រីនៅក្រោមបង្គាប់របស់ខ្លួន ។ «អំណាចពិតប្រាកដ» មានន័យថា មន្ត្រីថ្នាក់លើមានសមត្ថភាព ១) ទប់ស្កាត់មន្ត្រីថ្នាក់ក្រោម កុំឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋនេះ ឬ ២) ដាក់ទណ្ឌកម្មមន្ត្រីថ្នាក់ក្រោម ចំពោះការប្រព្រឹត្តអំពើឧក្រិដ្ឋក្រោយការប្រព្រឹត្តអំពើនោះរួចហើយ ។ ជាការសំខាន់ណាស់ដែលត្រូវធ្វើការកត់ចំណាំថា មន្ត្រីថ្នាក់លើដែលត្រូវបានចោទប្រកាន់ អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវទោះបីជាមន្ត្រីនោះមានឋានៈអំណាចជាច្រើនថ្នាក់ខ្ពស់ដាច់ពីជនដៃដល់ដែលប្រព្រឹត្តអំពើឧក្រិដ្ឋក៏ដោយ ។

ហេតុដូច្នេះ មន្ត្រីយោធាជាន់ខ្ពស់អាចដាក់ឲ្យទទួលខុសត្រូវចំពោះអំពើរបស់កូនទាហានថ្នាក់ទាបបំផុតនៅក្រោមមន្ត្រីនោះបាន ប្រសិនបើខ្សែសង្វាក់នៃការបញ្ជាដែលពុំត្រូវបានកាត់ផ្តាច់មួយ ឬខ្សែបន្ទាត់នៃអាជ្ញាធរត្រូវបានគាំទ្រដោយភស្តុតាងត្រឹមត្រូវ ។

## គ. តម្រូវការនៃធាតុផ្សំ «ចេតនា»

តម្រូវការទី៣ សម្រាប់ដាក់ឲ្យមន្ត្រីថ្នាក់លើម្នាក់ឲ្យទទួលខុសត្រូវក្រោមគោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជាគឺ «ចេតនា» ប្រសិនបើមន្ត្រីថ្នាក់លើនោះ បានដឹងឮពិតប្រាកដដែលត្រូវបានគាំទ្រដោយភស្តុតាងផ្ទាល់ ឬភស្តុតាងប្រយោលថាបុគ្គលក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលកំពុងចោទសួរ ។ តុលាការ ឬអង្គជំនុំជម្រះក្តីមួយ នឹងមិនអាចធ្វើការសន្មតិដោយខ្លួនឯងថា មេបញ្ជាការនោះបានទទួលការដឹងឮពិតប្រាកដឡើយ ។ ការពិតនៃការដឹងឮរបស់មេបញ្ជាការ ត្រូវតែគាំទ្រដោយភស្តុតាងសមស្របទៅតាមស្តង់ដាភស្តុតាងជាក់លាក់មួយ ។ ព្រះរាជអាជ្ញាអាចបង្ហាញថា ថ្នាក់លើដែលត្រូវបានចោទប្រកាន់ បានដឹងឮពិតប្រាកដដោយផ្តល់ភស្តុតាងដូចជា ១) ចំនួន ប្រភេទ ទំហំនៃអំពើខុសច្បាប់ ពេលវេលា និងការផ្តល់ភស្តុភារដើម្បីប្រព្រឹត្តអំពើល្មើសទាំងនោះ ២) ចំនួន និងប្រភេទនៃទ័ពដែលពាក់ព័ន្ធ ៣) ទំហំភូមិសាស្ត្រ និងទីតាំងដែលអំពើទាំងនោះកើតឡើង និងល្បឿនដែលកិច្ចប្រតិបត្តិការទាំងនោះត្រូវបានអនុវត្ត ៤) មធ្យោបាយដទៃទៀតដែលឧក្រិដ្ឋកម្មស្រដៀងគ្នានេះ ត្រូវបានប្រព្រឹត្តឡើង ៥) អត្តសញ្ញាណកម្មរបស់មន្ត្រី និង បុគ្គលិកដែលពាក់ព័ន្ធ និង ៦) ទីតាំងឈរជើងរបស់មន្ត្រីថ្នាក់លើ នៅពេលដែលឧក្រិដ្ឋកម្មកើតឡើង ។

មិនតែប៉ុណ្ណោះតម្រូវការនៃធាតុផ្សំ «ចេតនា» ត្រូវបានឆ្លើយតប ប្រសិនបើមន្ត្រីថ្នាក់លើបានទទួលព័ត៌មានដែលសមល្មមនឹងធ្វើឲ្យមន្ត្រីថ្នាក់លើនោះ មានការចាប់អារម្មណ៍ថាមន្ត្រីថ្នាក់ក្រោមរបស់ខ្លួនអាចនឹងប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយគួរទទួលស្គាល់ពីតម្រូវការចាំបាច់ដើម្បីឲ្យមានការស៊ើបអង្កេតបន្ថែម ។

តាមធម្មតាមេបញ្ជាការម្នាក់ ពុំអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវបានទេ ប្រសិនបើគាត់គ្រាន់តែធ្វេសប្រហែស ។ មន្ត្រីថ្នាក់លើត្រូវតែបានដឹងឮច្បាស់ដូចដែលបានរៀបរាប់ខាងលើ ឬថាមន្ត្រីថ្នាក់លើនោះមានការធ្វេសប្រហែសខ្លាំងជ្រុលពេក ដែលអំពើរបស់មន្ត្រីនោះចង្អុលបង្ហាញអំពីការភ្ញាក់បានសភាពការណ៍ទាំងស្រុងចំពោះឧក្រិដ្ឋកម្មនោះ ឬបង្ហាញពីចេតនាចង់គាំទ្ររបស់មន្ត្រីនោះចំពោះជនរងគ្រោះ ។

### ឃ តម្រូវការនៃធាតុផ្សំ «អំពើ»

ដើម្បីដាក់មន្ត្រីថ្នាក់លើឲ្យទទួលខុសត្រូវក្រោមគោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា មន្ត្រីថ្នាក់លើត្រូវតែបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋមួយ ។ ទោះបីត្រូវបានហៅថាតម្រូវការឲ្យមានអំពើក៏ដោយ ទាំងអំពើគាំទ្រ ឬការខកខានពុំបានបំពេញភារកិច្ចមួយអាចបំពេញតម្រូវការនេះបានដែរ ។ មន្ត្រីថ្នាក់លើគឺទទួលខុសត្រូវ «ដោយផ្ទាល់» នៅពេលដែលមន្ត្រីនោះបានបញ្ជា ឬលើកទឹកចិត្តឲ្យបុគ្គលនៅក្រោមបង្គាប់ប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះ ។ ក៏ប៉ុន្តែការទទួលខុសត្រូវ «ប្រយោល» កើតឡើងនៅពេលដែលមន្ត្រីថ្នាក់លើនោះ ១) ខកខានពុំបានដាក់ទណ្ឌកម្មបុគ្គលថ្នាក់ក្រោម ចំពោះអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តឬ ២) ខកខានពុំបានចាត់វិធានការណ៍ទប់ស្កាត់ និងស៊ើបអង្កេតសមស្រប នៅពេលដែលមន្ត្រីថ្នាក់លើនោះបានដឹង ឬគួរតែបានដឹងថា មានគ្រោះថ្នាក់ខ្ពស់នៃការកើតឡើងនៃឧក្រិដ្ឋកម្ម ។ មន្ត្រីថ្នាក់លើអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវ «ជាប្រយោល» ប៉ុណ្ណោះ ប្រសិនបើមន្ត្រីនោះ មានសមត្ថភាពសមស្របដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះអំពើដែលកំពុងចោទសួរ ។

## ៣、ការទទួលខុសត្រូវ

នៅពេលដែលគ្រប់តម្រូវការទាំងអស់នៃគោលការណ៍នៃការទទួលខុសត្រូវលើបទបញ្ជាត្រូវបានឆ្លើយតប មន្ត្រីថ្នាក់លើដែលមានទោសកំហុសត្រូវប្រឈមមុខនឹងការទទួលខុសត្រូវដូចគ្នាទៅនឹងបុគ្គលក្រោមបង្គាប់ ដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះដោយផ្ទាល់ដែរ ។ ហេតុដូច្នេះគោលការណ៍នៃការទទួលខុសត្រូវលើបទបញ្ជា អាចដាក់អតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាឲ្យទទួលខុសត្រូវ និងប្រឈមមុខនឹងយុត្តិធម៌តាមច្បាប់ ។ នៅក្នុងករណីរបបកម្ពុជាប្រជាធិបតេយ្យ ការរកឲ្យឃើញឧក្រិដ្ឋកម្មធំៗរាប់រយពាន់ពុំជាការលំបាកអ្វីឡើយ ហើយការបង្ហាញថាបទល្មើសជាច្រើននៃបទល្មើសដ៏សាហាវឃោរឃៅបំផុត ត្រូវបានលើកទឹកចិត្ត ឬយ៉ាងហោចណាស់ពុំត្រូវបានដាក់ទណ្ឌកម្មពីថ្នាក់លើ ក៏ពុំមែនជារឿងលំបាកដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ លេខាធិការនៃអង្គការបក្សកុម្មុយនិស្តកម្ពុជា «ប៉ុលពត» បានធ្វើឲ្យមានការលំបាក ដើម្បីនឹងបង្ហាញទំនាក់ទំនងចំពោះការបញ្ជាដែលមានលក្ខណៈចាំបាច់ក្នុងការដាក់ទោសក្រោមគោលការណ៍ច្បាប់នេះ ។

ដោយការកាត់ទោសមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់ ហៀបនឹងកើតឡើងហើយនោះ ព្រះរាជអាជ្ញានឹងចាំបាច់ត្រូវបញ្ជាក់ឲ្យច្បាស់ពីខ្សែសង្វាក់នៃការបញ្ជាដែលមានវត្តមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រចាំបាច់បញ្ចូលគ្នានូវភស្តុតាង ឯកសារកសិណផ្ទាល់មាត់ និង របាយការណ៍អ្នកប្រាជ្ញដ៏ជំនាញទាំងឡាយដើម្បីចង្អុលបង្ហាញពីទំនាក់ទំនងលើបទបញ្ជាដែលតម្រូវការជាចាំបាច់ ។ លើសពីនេះទៅទៀតភស្តុតាងដែលបង្ហាញថា ជនចុងចោទពិតជាមានការដឹងឮដែលនាំឲ្យមានទោស ហើយតម្រូវការនៃធាតុផ្សំ «ចេតនា» ត្រូវបានបំពេញនឹងមានសារៈសំខាន់បំផុតចំពោះគោលការណ៍ច្បាប់នេះ ។ ជាថ្មីម្តងទៀត ការផ្គុំប្រភពពត៌មានទាំងនេះនឹងផ្តល់នូវរូបភាពដ៏ពេញលេញបំផុតមួយ ហើយជួយដល់តុលាការ ឬអង្គជំនុំជម្រះក្តីមួយនូវក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌដ៏សមស្រប ។ មានតែតាមរយៈការយល់ដឹង និង ការអនុវត្តន៍គោលការណ៍នៃការទទួលខុសត្រូវលើបទបញ្ជា ទើបអាចរកយុត្តិធម៌ពិតប្រាកដសម្រាប់ប្រទេសកម្ពុជា និងសម្រាប់ជនរងគ្រោះច្រើនរាប់មិនអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**ចន ឆរធីអារី**



# អ្វីទៅជាការពិត?

«អ្វីទៅជាការពិត?»ហាក់បីដូចជាសំណួរមួយដ៏គួរឲ្យអស់សំណើច ។ ចំពោះមនុស្សភាគច្រើនអ្វីទៅជាការពិត? ជាធម្មតាហាក់បីដូចជាច្បាស់ក្រឡែត ដូចជាគ្មានអ្វីគួរឲ្យលំបាកយល់ទាល់តែសោះ ប្រសិនបើនរណាម្នាក់យកសត្វឆ្មាពណ៌ខ្មៅមួយក្បាលបង្ហាញយើង ហើយប្រាប់ថា «ជាឆ្មាពណ៌ស» នៅពេលនោះយើងអាចដឹងភ្លាមថា នោះមិនមែនជាការពិតទេ ។ ផ្ទុយមកវិញប្រសិនបើគេយកសត្វឆ្មាខ្មៅមួយ ហើយប្រាប់យើងថាជាឆ្មាខ្មៅនោះ យើងអាចមានអារម្មណ៍ដឹងច្បាស់ថា នេះជាការពិត ។ ដូច្នេះ «ការពិត» ហាក់បីដូចជារឿងដ៏សាមញ្ញមួយក៏ប៉ុន្តែក្នុងភាពជាក់ស្តែងក្នុងសង្គមមនុស្ស «ការពិត» ពុំមែនជារឿងសាមញ្ញមួយនោះទេ ។ បញ្ហាមួយក្នុងរង្វង់ចំណោទបញ្ហាទស្សនវិជ្ជាដ៏ធំធេងបំផុត សម្រាប់មនុស្សគ្រប់ជំនាន់នោះ គឺធ្វើយ៉ាងដូចម្តេចទើបដឹងថា អ្វីជាការពិតនេះឯង ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ក៏បានទទួលស្គាល់យ៉ាងច្បាស់នូវបញ្ហានេះ ។ ព្រះពុទ្ធមានពុទ្ធដីកាប្រៀនប្រដៅថា អ្វីៗដែលមើលនឹងភ្នែកឃើញច្បាស់ក្រឡែតបំផុតក្នុងលោកជាច្រើនដែលមនុស្សលោកបានជួបប្រទះក្នុងជីវិត ហើយតាមធម្មតាយើងមានអារម្មណ៍ថា «មែនទែន» ឬ «ពិត» នោះគឺសុទ្ធសឹងតែជាការស្រមើស្រមៃទាំងអស់ ដែលនាំឲ្យយើងទាំងអស់គ្នាភ័ន្តច្រឡំអំពី «ការពិត» ។

ប្រសិនបើលោកអ្នកឃ្លានអាហារ ឬក៏ប្រសិនបើលោកអ្នកស្រឡាញ់នរណាម្នាក់ ឬប្រសិនបើលោកអ្នកបានជួបប្រទះការខឹងក្រេវក្រោធ ឬការស្អប់ខ្ពើមចំពោះ «សត្រូវ» ណាមួយនោះជារឿយៗ លោកអ្នកយល់ឃើញថា អារម្មណ៍ទាំងអស់នេះគឺ «ពិត» ព្រោះថាអារម្មណ៍ទាំងនេះ ឆ្លុះបញ្ចាំងអ្វីមួយដែលពិត

ហើយមានការពិតក្នុងលោក ពីព្រោះមនុស្សគ្រប់រូបសុទ្ធតែមានអារម្មណ៍បែបនេះ ។ ក៏ប៉ុន្តែនេះពុំមែនអ្វីដែលព្រះពុទ្ធជាម្ចាស់ព្រះប្រៀនប្រដៅនោះទេ ។ ព្រះពុទ្ធបានបង្រៀនថាអារម្មណ៍បែបនេះបានត្រឹមតែនាំមុខឲ្យមនុស្សឃ្លាតឆ្ងាយពីការយល់ដឹងពិតតែប៉ុណ្ណោះ ។ យោងទៅតាមព្រះពុទ្ធជាម្ចាស់ ផ្លូវអារម្មណ៍ និងការស្រេកឃ្លានរបស់មនុស្សលោក គឺពុំមែនជាផ្លូវនាំទៅរកការពិតឡើយ ។ នេះបង្ហាញថា ព្រះពុទ្ធជាម្ចាស់បានយល់ច្បាស់អំពីខ្លឹមសារនៃបញ្ហាថា «អ្វីជាការពិត?» នេះ ។

ទស្សនវិទូក្នុងលោក បានស៊ិតស្វាញស្វែងរកចម្លើយទៅនឹងបញ្ហានេះ តាមរយៈការស្រាវជ្រាវពីប្រវត្តិសាស្ត្រពិភពលោកទាំងមូលដែលបានកត់ត្រាទុក ហើយគួរឲ្យភ្ញាក់ផ្អើលណាស់ អស់រយៈពេលរាប់ពាន់ឆ្នាំ នៃការគិតពិចារណាយ៉ាងហ្មត់ចត់ដោយអ្នកប្រាជ្ញដ៏ឈ្លាសវៃបំផុតក្នុងលោក មកទល់នឹងពេលនេះនៅតែពុំមានការឯកភាពគ្នា ដែលមានមូលដ្ឋានរឹងមាំ និងអាចទទួលយកបានជាសកលថា តើអ្វីប្រាកដដែលជាសារជាតិនៃការពិតនៅឡើយ ។ មានសាខាប្រវត្តិវិទ្យាមួយហៅថា «ទ្រឹស្តីនៃចំណេះដឹង» ដែលផ្តោតទៅលើការជជែកវែកញែកពីអ្វីដែលជាការពិត ហើយថាតើធ្វើដូចម្តេចទើបយើងអាចដឹងថា អ្វីមួយជាការពិត នៅពេលដែលយើងឃើញ ឬជួបប្រទះ ។ មានផ្នែកស៊ើបអង្កេតវិទ្យាសាស្ត្រមួយទៀតហៅថា ទស្សនវិជ្ជានៃវិទ្យាសាស្ត្រ ពីព្រោះអ្នកវិទ្យាសាស្ត្រជាច្រើនជឿថា គោលបំណងនៃវិស័យវិទ្យាសាស្ត្រទាំងមូលគឺពិតជាគ្មានអ្វីក្រៅពីស្វែងរកការពិតនោះទេ ។ ទោះជាយ៉ាងនេះក្តី ក៏នៅតែមានការវិភាគវែកញែកដ៏ក្តៅគគុកមួយអំពីការពិតនៅឡើយ ក្នុងចំណោមអ្នកទស្សនវិទូផ្នែកវិទ្យាសាស្ត្រទាំងនោះ ។ ហើយបញ្ហានេះនៅតែជាការពិភាក្សាដ៏សែនស្មុគស្មាញមួយ ។

ជនជាតិក្រិចកាលពីសម័យបុរាណ បានប្តេជ្ញាយកចិត្តទុកដាក់ដ៏ច្រើនសន្ធឹកសន្ធាប់ទៅលើចំណោទបញ្ហាថាអ្វីទៅជាការពិត? ហើយអរិយធម៌របស់ជនជាតិក្រិច គឺជាអរិយធម៌ដំបូងគេបង្អស់ក្នុងលោកនេះដែលបានកត់ត្រាយ៉ាងប្រុងប្រយ័ត្ន និងល្អិតល្អន់នូវរាល់គំនិត និងការពិភាក្សារបស់ខ្លួនអំពីបញ្ហានៃការពិតនេះ ។ អ្នកទស្សនវិទូជនជាតិក្រិចដ៏ល្បីល្បាញបំផុត គឺលោក អារីស្តូត ដែលបានប៉ុនប៉ងចាប់យកផ្នែកមួយនៃចំណោទបញ្ហានៃការពិតមកដោះស្រាយបង្ហាញ ។

លោក អារីស្តូត បានរិះរកឃើញប្រព័ន្ធ «តក្កវិជ្ជា» មួយ ។ គាត់បានចាប់ផ្តើមដោយសំណើដែលបង្ហាញភស្តុតាងច្បាស់បំផុតដោយខ្លួនឯងគឺ «វត្ថុមួយមានតម្លៃស្មើនឹងខ្លួនឯង» ។ ទំនាក់ទំនងនេះត្រូវបានហៅថា «អត្តសញ្ញាណ» ហើយអាចត្រូវបានឆ្លុះបញ្ចាំងក្នុងទម្រង់ជានិមិត្តសញ្ញា «ក ស្មើនឹង ក» ។ ចេញពីការអង្កេតដ៏ងាយស្រួលបំផុតនេះ អារីស្តូត បានបន្តរិះរកបង្កើតប្រព័ន្ធតក្កវិជ្ជានេះ ជាឧទាហរណ៍ យើងអាចបង្កើតសមភាព «តក្កភាព» ឬ «ទំនាក់ទំនងតក្ក» ។

ឧទាហរណ៍នៃតក្កភាព ដែលមានជាយូរលង់ណាស់មកហើយនោះគឺ «មនុស្សទាំងអស់ស្លាប់ ។ សូក្រាត គឺជាមនុស្ស ។ នាំឲ្យសូក្រាតត្រូវតែស្លាប់ ។» ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយើងផ្លាស់ប្តូរសមភាពនេះតែបន្តិច ហើយជំនួសវិញដោយ «សំណើថា មនុស្សទាំងអស់ស្លាប់ សូក្រាតគឺជាមនុស្ស ដូច្នេះសូក្រាតត្រូវតែស្លាប់ជាការពិត» នៅពេលនោះ យើងនឹងឃើញមានបញ្ហា ។ សំណើទី២នេះ បើនិយាយឲ្យលម្អិតទៅលើន័យគឺជាការដាក់ឈ្មោះឲ្យខុស ដែលជាមូលហេតុនាំឲ្យមានការភ័ន្តច្រឡំ ។ បើនិយាយឲ្យត្រឹមត្រូវប្រាកដ តក្កភាពអំពីការស្លាប់របស់សូក្រាត គឺមិនមែនមានឈ្មោះថាជា «ការពិតTruth» ទេ ប៉ុន្តែមានឈ្មោះថា «មានន័យ Valid» ។ សំណើដែលមានន័យ គឺជាសំណើដែលក្នុងនោះពុំមានភាពមិនត្រូវគ្នាលើតក្កភាព ឬភាពផ្ទុយគ្នាខាងក្នុងសំណើនោះ ។

ភាពខុសប្លែកគ្នារវាង «ការពិត» និង «មានន័យ» បានបង្កើតឲ្យមានបញ្ហាជាច្រើន ក្នុងចំណោមប្រភេទមនុស្សដ៏ឆ្លាតវៀងវៃជាច្រើន អស់រយៈពេលដ៏យូរលង់ណាស់មកហើយ ។ ភាពខុសប្លែកគ្នានេះ អាចត្រូវបានប្រទះឃើញនៅក្នុងប្រវត្តិនៃសាខាគណិតវិទ្យា ហៅថាធរណីមាត្រ ។ ទស្សនវិទូជនជាតិក្រិច

នាសម័យបុរាណម្នាក់ទៀត ឈ្មោះ អ៊ីគ្លីត បានបង្កើតប្រព័ន្ធគណិតវិទ្យាមួយពាក់ព័ន្ធទៅនឹង បន្ទាត់មុំកម្ពស់ ចន្លោះបន្ទាត់ពីលក្ខណៈពិសេស និង រាង ដែលកើតចេញពីការផ្គុំបន្ទាត់ ។ ប្រព័ន្ធធរណីមាត្រនេះត្រូវបានដាក់ឈ្មោះថា «ធរណីមាត្រអ៊ីគ្លីត» ហើយសព្វថ្ងៃនេះ ប្រព័ន្ធធរណីមាត្រនៅតែជាផ្នែកដ៏សំខាន់មួយសម្រាប់ការបង្រៀននៅតាមសាលាគ្រប់ទីកន្លែង ទូទាំងពិភពលោកអស់រយៈពេល២៣០០ឆ្នាំ បន្ទាប់ពីគាត់បានច្នៃប្រឌិតប្រព័ន្ធនេះ ។ អ៊ីគ្លីត គឺជាអ្នកប្រាជ្ញដើរតាមគន្លងរបស់អារីស្តូត ហេតុដូច្នេះហើយ គោលការណ៍ធរណីមាត្ររបស់អ៊ីគ្លីត ត្រូវបានបង្កើតឡើង ហើយអនុវត្តទៅតាមក្បួនច្បាប់នៃតក្កភាពរបស់អារីស្តូត ។ ជាឧទាហរណ៍សំណើថា «នៅក្នុងត្រីកោណប្រភេទណាក៏ដោយ មុំពីរបូកចូលគ្នាត្រូវតែតិចជាងមុំកែងពីរ» ពីព្រោះថាសំណើនេះ ដែលជាការពិតតាមតក្កវិជ្ជាឥតខ្ចោះបានដើរតាមក្បួនច្បាប់នៃតក្កភាពរបស់អារីស្តូត ។ អ៊ីគ្លីតជឿថា ប្រព័ន្ធនេះបានពិពណ៌នាអំពីការពិតរបស់ធម្មជាតិ ដែលគ្មាននរណាអាចផ្លាស់ប្តូរបាន ។ ក៏ប៉ុន្តែជំនឿរបស់អ៊ីគ្លីតប្រែជាពុំសូវត្រឹមត្រូវឡើយ ។

ជាច្រើនសតវត្សរ៍ក្រោយមក អ្នកប្រាជ្ញគណិតវិទ្យាមួយក្រុមរួមបញ្ចូលទាំង ឡាបាឆេវស្គី Labachevsky បូលីយ៉ៃ Bolyai ហ្គោស Gauss និង រៀម៉ាន់ Riemann បានបង្កើតផ្នែកមួយនៃគណិតវិទ្យា ដែលឥឡូវនេះហៅថា ធរណីមាត្រមិនអ៊ីគ្លីត ។ នៅក្នុងប្រព័ន្ធធរណីមាត្រទាំងនេះ សំណើរបស់អ៊ីគ្លីតមួយចំនួនពុំពិតទាំងអស់ទេ! បើធ្វើការប្រៀបធៀបទៅនឹងទ្រឹស្តីអារីស្តូត នៅក្នុងធរណីមាត្រមិនអេគ្លីតអាចទាញថា «ក មិនស្មើនឹង ក» ទេក្នុងករណីមួយចំនួន ។ ការអះអាងបែបនេះនាំឲ្យមានការពិភាក្សាដែលពិបាកនឹងរកដំណោះស្រាយថា តើធរណីមាត្រមួយណា «ពិត» ធរណីមាត្រអ៊ីគ្លីត ឬ ធរណីមាត្រមិនអ៊ីគ្លីត? ដោយហេតុថា បញ្ហាបែបនេះលេចឡើងជាញឹកញាប់ទៅលំបាកនេះ បណ្តាលឲ្យមានការភ័ន្តច្រឡំណាស់ ពីព្រោះថាសំណួរខាងលើនេះជាសំណួរដែលមិនត្រឹមត្រូវ ។ ចម្លើយគឺថាពុំមានធរណីមាត្រណា «ពិត» នោះទេ ។ ប៉ុន្តែចំពោះប្រព័ន្ធតក្កនិងប្រព័ន្ធធរណីមាត្រត្រូវបានហៅថា «មានន័យ» ពីព្រោះថាក្បួនច្បាប់របស់ប្រព័ន្ធធរណីមាត្រនេះ គឺមានភាពសមភាពត្រូវគ្នាទាំងអស់ ។ «មានន័យ» គឺសំដៅតែទៅលើភាពត្រូវគ្នាខាងក្នុងនៃទំនាក់ទំនងតក្ក ក្នុងចំណោម ឬរវាងសំណើទាំងឡាយ ។ ផ្ទុយទៅវិញ «ការពិត» សំដៅទៅលើទំនាក់ទំនងមួយរវាងអំណះអំណាងជាភាសាមួយទៅនឹងភាពជាក់ស្តែងតាមការអង្កេត និងការពិសោធន៍ជាសត្យានុម័ត ។

ទោះបីជាយ៉ាងដូច្នោះក៏ដោយ ជនជាតិក្រិចនាសម័យបុរាណប្រើពាក្យ២ខុសពីគ្នា ។ ពាក្យទាំង២នោះ បកប្រែទៅជាភាសាអង់គ្លេសថា "Truth" ហើយជាភាសាខ្មែរថា «ការពិត» ។ ពាក្យទី១ ជាភាសាក្រិច ដែលមានន័យថា «ការពិត» គឺ «Episteme» ។ ការពិតនេះ ឈរលើគោលការណ៍នៃចំណេះដឹងពិត ដែលមានតែព្រះ «អាចជាព្រះមួយ ឬច្រើន អាស្រ័យទៅលើជំនឿសាសនារបស់មនុស្ស» ជាអ្នកបង្កើតចក្រវាឡ ។ ពាក្យក្រិច Episteme មានន័យថា ការដឹងពិតទាំងស្រុងអំពីចក្រវាឡ ដែលមនុស្សគ្មានជីវិតអមតៈ ដូចជារូបយើងទាំងអស់គ្នាមិនអាចយល់បាន ។ នេះមានន័យថា មានតែព្រះទ្រង់ត្រាស់ដឹងអ្វីៗទាំងអស់ក្នុងចក្រវាឡ ។ ពាក្យទី២ ដែលជនជាតិក្រិចនាសម័យបុរាណ ប្រើសម្រាប់ពាក្យថា «ការពិត» នោះគឺ Noesis ។ ក្នុងន័យនៃពាក្យនេះ ការពិតឆ្លុះបញ្ចាំងតាមពិភពនៃបទពិសោធន៍និងការយល់ឃើញតាមបញ្ញាធម្មតារបស់មនុស្សទូទៅ ។ និយាយម្យ៉ាងទៀតពាក្យថា Noesis គឺស្ថិតនៅក្នុងកម្រិតនៃសមត្ថភាពការយល់ដឹងរបស់មនុស្សទូទៅ ។ ការពិតប្រភេទនេះ គឺជាការពិតដែលអ្នកវិទ្យាសាស្ត្របានស្វែងរក ។ តាមពិតអត្ថន័យនៃការពិតនេះ គឺជាការពិតដែលត្រូវបានគ្រប់គ្រងមួយកម្រិតដោយមនុស្សលោក ដែលបានស្រាវជ្រាវរកបានជោគជ័យ ។ អ្នកប្រាជ្ញទស្សនវិជ្ជាដ៏ល្បីល្បាញជាងគេបំផុត ឈ្មោះ អាល់បឺត អេនស្តែន Albert Einstein នៅពេលដែលគាត់បានធ្វើសេចក្តីអត្ថាធិប្បាយមួយអំពីទ្រឹស្តីការពិត Noesis ថា «អ្វីដែលពិបាកយល់បំផុតអំពីចក្រវាឡគឺថា ចក្រវាឡអាចយល់បាន» ។

នៅក្នុងសេចក្ដីអត្ថាធិប្បាយនោះលោក អេនស្តេន បានវេចខ្ចប់អាថ៌កំបាំងមួយ ក្នុងចំណោមអាថ៌កំបាំងដែលស្ថិតក្នុងភាពងងឹតជាយូរយារណាស់មកហើយនៅក្នុងទស្សនវិជ្ជាវិទ្យាសាស្ត្រ ។ ហេតុអ្វីបានជាគណិតវិទ្យា «ផ្ដល់ផលប្រយោជន៍?» ហេតុអ្វីបានជាទ្រឹស្តីវិទ្យាសាស្ត្រជាច្រើន អនុញ្ញាតឲ្យយើងអាចទស្សន៍ទាយបានយ៉ាងត្រឹមត្រូវខ្លាំងម្ល៉េះ អំពីអ្វីៗជាច្រើននៅពិភពខាងក្រៅ? អ្វីទៅជាទំនាក់ទំនងរវាងទ្រឹស្តីវិទ្យាសាស្ត្រទាំងនោះទៅនឹងពិភពលោកដែលអនុញ្ញាតឲ្យយើងបានយល់អំពីអ្វីដែលកំពុងប្រព្រឹត្តទៅជុំវិញខ្លួនយើង? និយាយម្យ៉ាងទៀត អ្វីគឺជាលក្ខណៈនៃ «ការពិត»? បញ្ហានេះចាប់ផ្ដើមចូលទៅក្នុងបញ្ហាទស្សនវិជ្ជាដែលសិក្សាអំពីសារជាតិនៃការពិត និងអត្ថិភាពនៃការពិតហើយត្រង់ហ្នឹងហើយដែលបញ្ហានៃការពិតចាប់ផ្ដើមកាន់តែស្មុគស្មាញ ។

ទស្សនវិទូផ្នែកវិទ្យាសាស្ត្រ ឈ្មោះ កាល ប៉ុបព័រ Karl Popper ព្យាយាមទំលុះអាថ៌កំបាំងទាំងនេះ គឺមូលហេតុអ្វីបានជាទ្រឹស្តីវិទ្យាសាស្ត្រ ហាក់បីដូចជា «ត្រឹមត្រូវ» យ៉ាងខ្លាំងទៅនឹងពិភពលោក ។ ប៉ុបព័រ បានសន្និដ្ឋានការពិតថា មានពិភពផ្សេងៗជាច្រើន ។ ពិភពមួយ គឺពិភពខាងក្រៅ «សត្យានុម័ត» គឺពិភពខាងក្រៅខ្លួនយើង ដែលពាសពេញទៅដោយពិភពផ្កាយ រុក្ខជាតិ និងសត្វនានា និងអ្វីៗផ្សេងទៀតផងទាំងពួង ។ ពិភពមួយទៀតគឺពិភព «អត្តនោម័ត» នោះមានន័យថា ពិភពដែលមាននៅក្នុងចិត្តរបស់យើងគ្រប់ៗគ្នា ។ ប៉ុបព័រ បានប៉ុនប៉ងពិពណ៌នាប្រព័ន្ធមួយដើម្បីឲ្យយើងជាមនុស្សលោក ដែលងប់ងុលនឹងពិភពអត្តនោម័តទាំងនោះ អាចយល់ដឹងពីវត្ថុផ្សេងៗក្នុងពិភពសត្យានុម័តខាងក្រៅ ។ គាត់បានហៅប្រព័ន្ធនេះថា «តក្កភាពនៃរបកគំហើញវិទ្យាសាស្ត្រ» ។ យោងទៅតាម ប៉ុបព័រ របៀបដែលតក្កភាពនៃរបកគំហើញវិទ្យាសាស្ត្រ ដំណើរការគឺពិតជាសាមញ្ញល្មមអាចយល់បាន ។

លោក ប៉ុបព័រ បានពិពណ៌នាវិទ្យាសាស្ត្រថា ជាដំណើរការនៃការបង្កើតអំណះអំណាង ដែលអាចយកមកសាកល្បងបញ្ជាក់ភាពពិតត្រឹមត្រូវ ។

អ្នកវិទ្យាសាស្ត្រទាំងឡាយបានប៉ុនប៉ងបង្ហាញភស្តុតាងថា អំណះអំណាង ឬសមត្ថកម្មមួយចំនួន ពុំមានការពិតឡើយ ។ ប្រសិនបើអ្នកវិទ្យាសាស្ត្រទាំងនោះពុំអាចបង្ហាញឲ្យឃើញថា អំណះអំណាងណាមួយខុស អំណះអំណាងនោះរមែងជាការ «ត្រឹមត្រូវ» ។ មធ្យោបាយនេះត្រូវបានហៅថា «ធ្វើកោសល្យវិច័យលើកំហុស» ពីព្រោះថាគោលដៅចម្បង គឺបង្ហាញភស្តុតាងថាអ្វីមួយខុស ហើយទទួលយកអ្វីដែលពុំអាចបង្ហាញថាខុសជាការ «ត្រឹមត្រូវ» តាមលក្ខណៈវិទ្យាសាស្ត្រ ។ យ៉ាងហោចណាស់បង្ហាញភស្តុតាងថាអំណះអំណាងមួយ «ត្រឹមត្រូវ» សមហេតុផលបំផុតល្មមនឹងអាចទទួលយកបាន ប្រសិនបើយើងពុំទាន់បានជួបប្រទះការពន្យល់មួយថ្មីប្រសើរជាង ដែលពិពណ៌នាពីបាតុភូតនេះឲ្យបានពេញលេញ និងថែមទាំងពុំអាចបង្ហាញថា ខុសសូម្បីតែបន្តិច ។ ប៉ុបព័រ បានទាញហេតុផលថា ឆ្លងកាត់មករាប់សិបសតវត្សរ៍នៃការជឿទុកចិត្តលើការសាកល្បងអំណះអំណាងនានាតាមរបៀបនេះ ទ្រឹស្តីវិទ្យាសាស្ត្របែបទំនើបត្រូវបានច្នៃកែតម្រូវដែលជួយឲ្យយើងយល់បានយ៉ាងច្បាស់ អំពីរបៀបដែលពិភពលោកយើងនេះប្រព្រឹត្តទៅ ឧទាហរណ៍ ទ្រឹស្តីមេរោគនៃជំងឺ ឬតារាងធាតុបន្សំនៃគីមី ។ នេះជារបៀបដែលវិទ្យាសាស្ត្រស្វែងរកប្រភេទនៃ «ការពិត» មួយ ។

ក៏ប៉ុន្តែប្រភេទនៃការពិត ដែលរកឃើញនៅក្នុងវិទ្យាសាស្ត្រ គឺគ្រាន់តែជាប្រភេទមួយក្នុងចំណោមប្រភពនៃការពិតទាំងអស់ ដែលមនុស្សជាតិទាំងមូលបានដឹង ។ មិនតែប៉ុណ្ណោះនៅមានការពិតផ្នែកសាសនា ការពិតផ្នែកអក្សរសាស្ត្រ និងអ្វីដែលយើងហៅថាការពិត «ផ្នែកនយោបាយ» ។ អ្នកគោរពសាសនាធំដែលជឿថា មានព្រះតែមួយ ដូចជាសាសនាជ្វីហ្វ សាសនាគ្រឹស្ត សាសនា អ៊ីស្លាម ជាដើម ។ល។ ជឿថាការពិតគឺព្រះជាអ្នកមើលឃើញ និងប្រទានឲ្យ ដែលជំនឿបែបនេះត្រូវបានបកស្រាយបង្ហាញនៅក្នុងអក្សរចារឹក ឬ ក្នុងគម្ពីរសាសនានានា ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា សាសនាទាំង៣នេះ

សុទ្ធតែបាន «ឆ្លុះបញ្ចាំង» ដូចគ្នាច្រើនជាទីបំផុតអំពី «ការពិត ឬភាសាបាលីហៅថា សច្ចភាព» ដូចជា «យើងមិនត្រូវសម្លាប់អ្នកដទៃ» «យើងមិនត្រូវប្រព្រឹត្តអំពើផិតក្បត់» ជាដើម ។ល។ ទាំងនេះគឺជាគោលការណ៍សីលធម៌ និងចរិយាធម៌ ឬក្បួនច្បាប់ ដែលតាមរបៀបនេះមនុស្សទាំងឡាយត្រូវបានរំពឹងទុកថា នឹងយកមកអនុវត្តក្នុងការរស់នៅក្នុងសង្គម ហើយបើមនុស្សគ្រប់រូបប្រតិបត្តិតាមការពិតទាំងនេះ នោះពិភពលោកគឺប្រហែលជាកន្លែងមួយដ៏ប្រសើរ ។ យ៉ាងហោចណាស់ ពិភពលោកពិតជាសន្តិភាព នៅពេលដែលមនុស្សទាំងឡាយគោរពតាមក្បួនច្បាប់ទាំងនោះជាជាងការកាប់សម្លាប់គ្នា នៅក្នុងការប្រកែកអំពីបញ្ហាថាតើក្បួនច្បាប់របស់អ្នកណាមួយដែលពិត! ស្រដៀងគ្នានេះដែរ «សាសនា» ដែលពុំជឿថាមានព្រះជាអ្នកបង្កើតលោក ដូចជាសាសនាព្រះពុទ្ធ និងសាសនាដែលជឿថាមានព្រះច្រើន ដូចជាសាសនាហិណ្ឌូ ក៏បានផ្ដល់នូវក្បួនច្បាប់ ឬ «សច្ចភាព» ដែលមនុស្សលោកអាចបញ្ឈរដំណើរជីវិតរបស់ខ្លួនតាមគន្លងនោះ ហើយអាចយល់ពីទំនាក់ទំនងរបស់ខ្លួនទៅនឹងចក្រវាឡ ។

រឿងនិទានមួយចំនួនដែលយើងអាចប្រទះឃើញនៅក្នុងអក្សរសាស្ត្រ ក៏មានប្រភេទនៃការពិតមួយផ្សេងទៅទៀត ។ រឿងនិទានទាំងនោះ ត្រូវបាននិយាយតៗគ្នាពីមាត់មួយទៅមាត់មួយពីជំនាន់មួយទៅជំនាន់មួយ តាមទំនៀមទម្លាប់នៅក្នុងសង្គមមួយចំនួនដូចជារឿងព្រេងដែលបានកត់ត្រាទុកជាឯកសារ ដែលអាចរក្សាបានគង់វង្សមកទល់សព្វថ្ងៃនេះ និងរឿងប្រឌិតដ៏ល្បីល្បាញផ្សេងទៀត ។ តាមរយៈរឿងទាំងនោះ អ្នកនិពន្ធ ជារឿយៗបានឆ្លុះបញ្ចាំងពីភាពឆ្លាតវៀងវៃក្នុងផ្នត់គំនិតមនុស្ស នាយុគសម័យនោះគឺភាពឆ្លាតវៀងវៃដែលរាប់ថា ជាប្រភេទមួយទៀតនៃការពិត ។ ជាឧទាហរណ៍រឿងស្ដេចអូឌីប៉ុស (Oedipus the King) ដែលសរសេរដោយអ្នកនិពន្ធកំណាព្យ ជនជាតិក្រិច សូផូកូល Sophocoles កាលពីជាង ២៤០០ឆ្នាំមុន គឺពុំមែនជាការពិតឡើយនៅក្នុងន័យអក្សរសាស្ត្រ ។ ទោះបីជាយ៉ាងណាក៏ដោយ រឿងនេះមានបង្កប់នូវការអត្ថន័យស៊ីជម្រៅលើ «ការពិតជាច្រើន» អំពីសារជាតិនៃទំនាក់ទំនងរបស់មនុស្សនៃមោទនភាព ភាពលោភលន់ និងសោកនាដកម្ម ។ ការយល់ឃើញទាំងនេះ គឺជាហេតុផលមួយក្នុងហេតុផលទាំងឡាយ ដែលធ្វើឲ្យរឿងនេះរស់រានមានជីវិតបន្តមកទល់សព្វថ្ងៃនេះ ហើយរឿងនេះនៅតែយកមកសម្ដែងនៅលើឆាក និងបញ្ចាំងតាមកញ្ចក់ទូរទស្សន៍ជានិច្ចកាល ។ យើងអាចរៀនអំពីការពិតសំខាន់ៗដោយសិក្សាអំពីការពិតនោះ ទោះបីជាវាផ្អែកទៅលើព្រឹត្តិការណ៍ដែលប្រឌិតឡើងទាំងស្រុងក៏ដោយ ។

«ការពិត» ផ្នែកនយោបាយ ក៏ជាបញ្ហាមួយទៀតដែរ ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក ឯកសារមួយក្នុងចំណោមឯកសារសំខាន់បំផុតនៃលទ្ធិប្រជាធិបតេយ្យ អាមេរិកចាប់ផ្ដើមដោយប្រើឃ្លាថា «យើងទុកឲ្យការពិតទាំងនេះបង្ហាញភស្តុតាងដោយខ្លួនឯងផ្ទាល់ថា មនុស្សទាំងអស់កើតមកស្មើៗគ្នា...» «ការពិតផ្នែកនយោបាយ» នេះ គឺជាគោលការណ៍គ្រឹះនៃការរៀបចំមួយក្នុងចំណោមគោលការណ៍ដទៃទៀត សម្រាប់រៀបចំរដ្ឋាភិបាល និងនយោបាយនៅក្នុងសហរដ្ឋអាមេរិក ។ ចំណែកឯនៅក្នុងប្រទេសកម្ពុជាវិញ មតិជាច្រើនចាត់ទុកគោលការណ៍ «ព្រះមហាក្សត្រ គឺជាព្រះបិតាជាតិ ហើយជាព្រះបិតាការពារសាសនា» ថាជា «ការពិត» ។ ការពិតនេះ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងបាវចនាជាតិ ក្នុងមាត្រាទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា «ជាតិ សាសនា ព្រះមហាក្សត្រ» ហេតុដូច្នេះ នេះគឺជាគោលការណ៍គ្រឹះនៃការរៀបចំរដ្ឋាភិបាល និង នយោបាយនៅក្នុងប្រទេសកម្ពុជា ទោះបីជាញឹកញាប់លក្ខណៈជាក់លាក់នៃការប្រព្រឹត្តទៅនៃគោលការណ៍នេះ អាចមានការលំបាកនឹងយល់បានក៏ដោយ ហើយជួនកាលក៏មានការលំបាកប្រហាក់ប្រហែលគ្នានេះដែរ ក្នុងការមើលឲ្យឃើញថា តើគោលការណ៍ «មនុស្សទាំងអស់កើតមកស្មើៗគ្នាជាមនុស្ស» តែងតែយកមកអនុវត្តតាមរបៀបណានៅក្នុងសហរដ្ឋអាមេរិក ។ លោក ហិនរី អាដាម Henry Adam ដែលជាអ្នកនិពន្ធ សញ្ជាតិអាមេរិក ដ៏ឆ្នើមម្នាក់ ត្រូវបានមនុស្សជាច្រើនលើកយកមកនិយាយយ៉ាងល្បីខ្ទរខ្ទារថា មានពេលមួយនោះគាត់បានសរសេរ

ថា «គាត់ពុំខ្វល់ថាតើការពិត គឺពិត ឬមិនពិតនោះទេ។» សម្ដីរបស់គាត់ប្រហែលជាជួយឲ្យយើងអាចចែកឲ្យបានដាច់រវាងការពិតផ្នែកនយោបាយ និងប្រភេទនៃការពិតផ្សេងទៀត ។

មិត្តភក្ដិរបស់ខ្ញុំម្នាក់ បានប្រាប់ខ្ញុំកាលពីពេលថ្មីៗនេះនូវរឿងកំប្លែងមួយ ។ រឿងកំប្លែងនោះ មានដូចតទៅនេះ ÷ ពាណិជ្ជករម្នាក់កំពុងស្វែងរកជួលគណនេយ្យករម្នាក់ឲ្យមកធ្វើការនៅក្រុមហ៊ុនរបស់គាត់ ។ បេក្ខជន៣នាក់ បង្ហាញខ្លួនដើម្បីចូលសម្ភាសន៍ ។ ពាណិជ្ជករនោះហៅបេក្ខជនទី១ ឲ្យចូលមកក្នុងការិយាល័យរបស់គាត់ ហើយគាត់សួរបេក្ខជនទី១ថា «២បូកនឹង២ស្មើប៉ុន្មាន?» បេក្ខជននោះឆ្លើយថា ស្មើនឹង៤ ។ ពាណិជ្ជករនោះ ថ្លែងអំណរគុណដល់បេក្ខជនទី១ ហើយចង្អុលបង្ហាញទ្វារចេញ ។ នៅពេលដែលបេក្ខជនទី២ចូលមកសម្ភាសន៍ពាណិជ្ជករបានសួរម្ដងទៀតថា «តើ២ បូកនឹង២ ស្មើប៉ុន្មាន?» បេក្ខជនទី២ ក៏បានឆ្លើយដែរថា ស្មើនឹង៤ ។ បេក្ខជនទី២នេះក៏ត្រូវបានសុំឲ្យចេញទៅក្រៅបន្ទប់ដូចបេក្ខជនទី១ដែរ ។ បន្ទាប់មកទៀត បេក្ខជនទី៣



ក៏ចូលមកក្នុងបន្ទប់ការិយាល័យរបស់ពាណិជ្ជករ ហើយគាត់ត្រូវបានសួរសំណួរដដែលថាតើ «២ បូកនឹង២ស្មើប៉ុន្មាន?» បេក្ខជនទី៣បានងើបពីកៅអី ហើយក្រោកឈរឡើងចាក់សោទ្វារបន្ទប់ការិយាល័យ បិទវាំងននរួចហើយខ្សឹប ដាក់ត្រចៀកពាណិជ្ជករនោះថា «តើលោកឯងចង់ឲ្យ២បូកនឹង២ស្មើប៉ុន្មាន?» នៅពេលនោះស្រាប់តែបេក្ខជនទី៣ ត្រូវបានជ្រើសរើសឲ្យធ្វើការភ្លាម ។ រឿងបែបនេះទោះបីជារឿងកំប្លែង ប៉ុន្តែធ្លាប់កើតឡើងពិតចំពោះមនុស្សមួយចំនួននៅក្នុងប្រទេសជាច្រើន។ បន្ទាប់មកសួរថាតើធ្វើយ៉ាងដូចម្ដេចទើបយើងអាចរកឃើញការពិតអំពីនយោ-បាយ? នៅពេលដែលមានកំហឹងនឹងអ្នកនយោបាយ ឬមិនជឿថាអ្វីដែលអ្នកនយោបាយនិយាយជាការពិតនោះមានមតិមហាជនកម្ពុជាខ្លះយល់ច្រឡំថា «នយោបាយ» គឺ «នយោបោក» ឬ «ការបោកប្រាស់» ។ មតិនេះបានក្លាយទៅជាវប្បធម៌មួយដែលចាត់ទុកនយោបាយជាពាក្យផ្ទុយទៅនឹងអ្វីដែលពិតតាមការបកស្រាយផ្សេងៗ ។ ក៏ប៉ុន្តែធាតុពិតនៃពាក្យ «នយោបាយ» ពុំ

ដូច្នោះទេ យើងអាចរកឃើញការពិតអំពីនយោបាយបានដោយអនុវត្តមធ្យោបាយ វិទ្យាសាស្ត្រជាច្រើន ។ នេះគឺជាមុខវិជ្ជាសិក្សាមួយ ដែលនៅក្នុងបណ្តាបស្ចិមប្រទេស ហៅថា «វិទ្យាសាស្ត្រនយោបាយ Political Science» ដែលជាមុខវិជ្ជាមួយដែលគួរឲ្យចង់ដឹង ហើយដែលពុំត្រូវបានបង្រៀន នៅតាមសាលា នៅប្រទេសកម្ពុជាឡើយ ។ ប៉ុន្តែមុខវិជ្ជានេះគួរតែយកមកបង្រៀន ពីព្រោះតាមមធ្យោបាយនេះ យើងអាចយល់បានកាន់តែប្រសើរនូវការពិតនានា ដែលបង្កប់ពីក្រោយពាក្យ «នយោបាយ» និងគោលជំហររបស់អ្នកនយោបាយនានា ។ ជាឧទាហរណ៍មួយដែលអាចយកមកពិចារណាតាមវិទ្យាសាស្ត្រនយោបាយ គឺថាពាណិជ្ជករម្នាក់ត្រូវបានរដ្ឋាភិបាលប្រគល់កិច្ចសន្យាដ៏ធំមួយឲ្យប្រតិបត្តិការងារសាធារណៈ ដូចជាសាងសង់ផ្លូវថ្មីមួយ ។ យើងអាចសួរសំណួរថាតើកិច្ចសន្យានោះត្រូវបានផ្តល់ឲ្យទៅពាណិជ្ជករនោះតាមរបៀបណា? តើពាណិជ្ជករនោះសូកសំណូក ឬ «ប្រាក់រត់ការ» ឬដែលហៅថា «ទឹកតែ» ទៅឲ្យឥស្សរជននយោបាយដែលចំណារផ្តល់កិច្ចសន្យានោះដែរឬទេ? ថាតើអ្នកតាក់តែងច្បាប់ដែលបានបោះឆ្នោតគាំទ្រការប្រគល់កិច្ចសន្យានោះទទួលគុណបំណាច់អ្វីខ្លះពីពាណិជ្ជករដែរឬទេ? ថាតើអ្នកនយោបាយសម្រេចដូច្នេះ ដោយសារខ្លួនមានដីចម្ការដែលនៅតាមដងផ្លូវថ្មីនេះដែរឬទេ? តើមានភស្តុតាងអ្វីខ្លះដើម្បីបង្ហាញថាផ្លូវថ្មីនេះពិតជាផ្តល់ផលប្រយោជន៍ដល់តំបន់ទាំងនោះ ដែលអ្នកនយោបាយបានលើកឡើងក្នុងការទាញហេតុផលដើម្បីគាំទ្រការផ្តល់កិច្ចសន្យានោះ? តើអ្នកទទួលផលប្រយោជន៍ដ៏ធំពីកិច្ចសន្យានេះតាមពិតគឺជានរណា? តើអាចមានក្រុមហ៊ុនដទៃទៀតដែលអាចសង់ផ្លូវមានគុណភាពល្អជាង ហើយចំណាយតិចជាងដែរឬទេ? តើការសម្រេចចិត្តនោះធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈសុទ្ធសាធ ឬក៏ដើម្បីផលប្រយោជន៍ឯកជនដែរឬយ៉ាងណា? តើមានឯកសារ ឬកំណត់ហេតុនៃការចរចាគ្នាដែលអាចជួយជាពន្លឺមកលើសំណួរណាមួយ ក្នុងចំណោមសំណួរទាំងនេះដែរឬទេ? តាមរបៀបនេះ យើងអាចចាប់ផ្តើមស្រាយសំបុកផលប្រយោជន៍ដែលជំពាក់ជំពិននៅពីក្រោយការសម្រេចចិត្តបែបនេះ ហើយចាប់ផ្តើមយល់ពី «ការពិត» នៃនយោបាយ ។

ជាគោលដៅសំខាន់បំផុត ការពិតប្រភេទនេះហើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាព្យាយាមរកឲ្យបាន ។ បាវចនារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ «ស្វែងរកការពិត» ។ ប្រភេទនៃការពិត ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរក គឺជាអ្វីដែលជនជាតិក្រិចនាសម័យបុរាណ ហៅថា "Noesis" ដែលជាប្រភេទនៃការពិត ដែលអ្នកវិទ្យាសាស្ត្រស្វែងរកដោយប្រើប្រាស់តក្កភាពនៃការរុករកតាមបែបវិទ្យាសាស្ត្រ ដែលពិពណ៌នាដោយទស្សនវិទូ កាល ប៉ុបព័រ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិតអំពីនយោបាយនៃរបបខ្មែរក្រហម ឬច្បាស់ជាងនេះអំពីការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ ថាតើប្រជាជនកម្ពុជាជាច្រើនស្លាប់យ៉ាងដូចម្តេច? តើប្រជាជនទាំងនោះស្លាប់ដោយសារអ្វី? តើប៉ុន្មាននាក់ស្លាប់ដោយអត់អាហារ? តើប៉ុន្មាននាក់ស្លាប់ដោយសារជំងឺ? ប៉ុន្មាននាក់ត្រូវបានសម្លាប់ដោយការប្រហារជីវិត? តើការប្រហារជីវិតទាំងនោះត្រូវបានរៀបចំ និងអនុវត្តឡើងយ៉ាងដូចម្តេច? តើនរណាជាអ្នកបញ្ជា? នៅពេលណា? នៅទីកន្លែងណា? ហើយថាតើបទបញ្ជាទាំងនោះបញ្ជូនពីថ្នាក់លើមកកម្មាភិបាលថ្នាក់ក្រោម ដែលជាអ្នកអនុវត្តន៍បទបញ្ជាយ៉ាងដូចម្តេច? តើអ្វីទៅជាអង្គការ? នរណាជាអ្នកបញ្ជាកងកម្លាំងសន្តិសុខនៃរបបខ្មែរក្រហម? តើការសម្លាប់រង្គាលត្រូវអនុវត្តន៍នៅទីណាខ្លះក្នុងប្រទេសកម្ពុជា? នរណាជាជនរងគ្រោះ ហើយនរណាជាឃាតករ? ទាំងនេះគឺជាចង្កោមសំណួរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងស្វែងរកចម្លើយ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើមធ្យោបាយវិទ្យាសាស្ត្រ ។ អ្នកវិទ្យាសាស្ត្រនយោបាយ និងអ្នកប្រាជ្ញវិទ្យាសាស្ត្រសង្គមជាច្រើនមកពីទ្វីបអ៊ឺរ៉ុប អូស្ត្រាលី និងសហរដ្ឋអាមេរិក ដែលបានផ្តល់ដំបូន្មានជាប្រចាំដល់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីរបៀបរៀបចំការស្វែងរកការពិត នៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់បច្ចេកទេសវិទ្យាសាស្ត្រទំនើប និងមាន

លក្ខណៈស្មុគស្មាញបែបនេះ ។ មធ្យោបាយទាំងនេះរួមមាន ឧបករណ៍ ដូចជាប្រើប្រាស់ប្រព័ន្ធផ្កាយរណបនៅក្នុងលំហអាកាស ដើម្បីជួយបង្កើតទិន្នន័យផែនទីរណ្តៅសាកសព ប្រើប្រាស់បច្ចេកវិទ្យាពត៌មានដទៃទៀត ដើម្បីថែរក្សា តម្កល់ទុក និងផលិតឡើងវិញនូវទិន្នន័យដើមជាច្រើនសណ្ឋាន តាមរយៈទិន្នន័យឯកសារខ្មែរក្រហមដែលប្រមូលបាននៅក្នុងដំណើរការស្រាវជ្រាវនេះ ។ សំខាន់បំផុតនោះគឺការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពឹងផ្អែកទៅលើការរកឃើញឯកសារការិយាធិបតេយ្យ ដែលចងក្រងដោយយន្តការសម្លាប់របស់របបខ្មែរក្រហម ។ ឯកសារទាំងនោះរួមមានដូចជា អនុសារណៈ កំណត់ហេតុ បទបញ្ជា បញ្ជីសម្លាប់ កំណត់ហេតុអង្គប្រជុំជាដើម ។ល ។

ឯកសារទាំងនេះពិពណ៌នាអំពីរបៀបដែលការប្រល័យពូជសាសន៍នៅកម្ពុជា ត្រូវបានរៀបចំឡើង ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញឯកសាររាប់រយពាន់សន្លឹក ដែលជាឯកសារបែបនេះ ។ ការបើកទូលាយ និងការវិភាគពត៌មាននៅក្នុងឯកសារទាំងនេះ នឹងប្រាប់រឿងរ៉ាវនៃការប្រល័យពូជសាសន៍នៅកម្ពុជាបានយ៉ាងទូលំទូលាយ ជាពិសេសរឿងរ៉ាវពីជនរងគ្រោះ និងជនដៃដល់នៃអំពើប្រល័យពូជសាសន៍ ។ ទាំងនេះគឺជាសាច់រឿងប្រវត្តិសាស្ត្រ ដែលប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន និងពេលអនាគតមានសិទ្ធិត្រូវដឹង ។

ការស្វែងរកការពិតអំពីសំណួរទាំងនេះ គឺជាបេសកកម្មដ៏សំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលខ្ញុំបានបញ្ជាក់ខាងលើរួចមកហើយថា ការរកឃើញការពិត និងបានដឹងការពិតពុំមែនជាភារកិច្ចដ៏សាមញ្ញមួយនោះទេ ។ ប៉ុន្តែពុំទាន់ហួសពេលនៅឡើយទេសម្រាប់ប្រទេសកម្ពុជា លទ្ធភាពរកការពិតចំពោះបញ្ហានេះនៅតែមាន ហើយសម្រាប់ប្រទេសកម្ពុជាការពិតនេះគឺមានសារៈសំខាន់មិនអាចវាស់ស្ទានបានឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបន្តបូជាកិច្ចខិតខំប្រឹងប្រែងចំពោះភារកិច្ចស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយមានការប្តេជ្ញាចិត្តធ្វើឲ្យបានជោគជ័យនូវភារកិច្ចនេះ ។

**យុគ ឆាង**



# មរតកខ្មែរក្រហម

ដោយមានការបាក់បែកនៃអង្គការចាត់តាំងនយោបាយ និងការដួលរលំនៃអំណាចយោធារបស់ខ្មែរក្រហមនោះ ប្រទេសកម្ពុជាកំពុងតែខិតជិតដល់គ្រឡាអុកចុងក្រោយនៃរឿងរ៉ាវសោកនាដកម្មរបស់ពួកខ្មែរក្រហម ។ ប៉ុន្តែខ្ញុំសង្កេតឃើញ និងមានការបារម្ភថា អ្នកដែលរស់នៅបរទេសដែលទើបមកដល់និងជាពិសេសអ្នកដែលមកស្នាក់នៅក្នុងស្រុកខ្មែរជាយូរយារណាស់មកហើយដែរនោះ មិនបានដឹងពីសោកនាដកម្មដ៏ធ្ងន់ធ្ងរ ដែលពួកខ្មែរក្រហមបានប្រព្រឹត្តចំពោះសង្គម ក៏ដូចជាប្រជាជនកម្ពុជាស្លូតត្រង់នោះឡើយ ។



ការវិភាគដេញដោលថ្មីៗនេះអំពីថាតើត្រូវដោះស្រាយដោយរបៀបណាចំពោះមេដឹកនាំខ្មែរក្រហមឈ្មោះ តាម៉ុក ដែលកំពុងត្រូវបានឃុំឃាំង វាហាក់ដូចជារបត់ដ៏សមគួរមួយក្នុងការពិភាក្សាដើម្បីអនាគតរបស់កម្ពុជាអំពីអ្វីៗដែលបន្សល់ទុកដោយពួកខ្មែរក្រហម ហើយនិងការពាក់ព័ន្ធរបស់ខ្មែរក្រហម ។

វាគឺជាការបន្សល់ទុកមួយ ដែលមានលក្ខណៈស្មុគស្មាញ ហើយដែលកាន់តែច្បាស់ទៅទៀតគឺបន្សល់ នូវឥទ្ធិពលដ៏ធ្ងន់ធ្ងរដែលកើតមានចំពោះគ្រប់ការពិតជាក់ស្តែងទាំងឡាយ វិស័យសេដ្ឋកិច្ច វិស័យយោធា សង្គម នយោបាយ និងវិស័យ ច្បាប់របស់ប្រទេសកម្ពុជា ។

ឥឡូវយើងនាំគ្នាគិតអំពីមរតកសេដ្ឋកិច្ចរបស់ខ្មែរក្រហមវិញ ។ ចំពោះការវិវត្តន៍សព្វថ្ងៃ វាហាក់ដូចជាលំបាកណាស់ក្នុងការរំលឹកឡើងវិញ នូវអ្វីដែលកើតមានឡើងក្នុងកំឡុង៣០ឆ្នាំមុនដែលកាលនោះសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈល្អប្រសើរប្រសិនបើធ្វើការប្រៀបធៀបទៅនឹងប្រទេសជិតខាងដូចជាវៀតណាម និងថៃ។ ខ្មែរក្រហមបានបំផ្លាញទាំងស្រុងនូវសេដ្ឋកិច្ចកម្ពុជាក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលជាផលវិបាកមួយនៃសេដ្ឋកិច្ចមិនចាយក្រដាសប្រាក់ និងសេដ្ឋកិច្ចដែលពឹងផ្អែកទៅលើវិស័យកសិកម្មសម្រាប់ដោះដូររបស់ និងសម្រាប់តែមួយគេៗ ឬមួយក្រពះ ថ្វីដ្បិតតែមានផ្អែកទំនើបៗនៅតាម តំបន់ខ្លះៗ ឬជាយក្រុង ។ ទោះបីជាក្រោយពេលដែលពួកខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចក្នុងឆ្នាំ១៩៧៩ក៏ដោយ ក៏ការគំរាមកំហែងនៃការ «វិលត្រឡប់សាជាថ្មី» របស់ពួកខ្មែរក្រហមនៅតែតាមលងប្រទេសកម្ពុជារហូតក្នុងទម្រង់ជាសង្គ្រាមរ៉ាំរ៉ៃ ជិត២ទសវត្សរ៍កន្លងមកនេះ ។ ក្នុងកំឡុងពេលជាងពីរទសវត្សរ៍កន្លងមក មួយភាគធំនៃថវិកាជាតិត្រូវបានចំណាយទៅលើការការពារទប់ស្កាត់នៃការវិលត្រឡប់មកកាន់អំណាចរបស់ពួកខ្មែរក្រហម ពោលគឺមានន័យថា ធនធានសេដ្ឋកិច្ចទាំងអស់មិនបានជួយដល់ការស្តារនិតិសម្បទា និងការអភិវឌ្ឍន៍ប្រទេសឡើយ ។ គេរដិណែលទាំងនេះ បានឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។

លើសពីនេះទៅទៀត ដើម្បីគាំទ្រនូវសង្គ្រាមដ៏គួរឲ្យធុញទ្រាន់គ្រប់ភាគីទាំងអស់ បានងាកមករកការប្លន់យកនិងការបំផ្លាញនូវធនធានធម្មជាតិមានជាអាទិ៍ ដូចជា ត្បូង ព្រៃឈើ និងផលិតផលផ្អែកនេសាទជាដើម ដែលការរុញច្រានប្រទេស

កម្ពុជាឲ្យខិតជិតដល់មហន្តរាយផ្នែកបរិស្ថាន ហើយប្រហែលជារុញហួសបាត់ទៅហើយក៏មិនដឹង ។ ពេលវេលានឹងបើកកកាយអំពីរឿងរ៉ាវទាំងឡាយ ប៉ុន្តែការរំលោភលើបរិស្ថាននៅតែបន្តទៅទៀត ទោះបីជាសង្គ្រាមបានបញ្ចប់ទៅហើយក៏ដោយ ។ រដ្ឋាភិបាលបច្ចុប្បន្នបានសន្យាថា នឹងបញ្ចប់នូវនយោបាយប្រកបដោយហាយនភាព ហើយបានបោះជំហានទៅមុខខ្លះ ហើយក្នុងទិសដៅនេះ ។ ប៉ុន្តែបញ្ហានេះបានពាក់ព័ន្ធយ៉ាងខ្លាំងទៅដល់វចនាសម្ព័ន្ធនយោបាយសង្គម ។ កងទ័ពរាជរដ្ឋាភិបាលក៏ពាក់ព័ន្ធក្នុងការកាប់បំផ្លាញព្រៃឈើនេះដែរ ។

ថ្មីៗនេះអតីតខ្មែរក្រហមភូមិភាគពាយ័ព្យបានស្នើគម្រោងអភិវឌ្ឍន៍ដ៏សម្បើមមួយចំនួន ប៉ុន្តែគម្រោងទាំងអស់នៅមិនទាន់សម្រេច ហើយស្ថិតនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅភ្នំពេញនៅឡើយទេ ។ មនុស្សដែលជាកូនចៅរបស់ អៀង សារី ប្រាថ្នាចង់ទាក់ទាញអ្នកវិនិយោគទុនបរទេស តាមរយៈគម្រោងអភិវឌ្ឍន៍រចនាសម្ព័ន្ធ ដូចជាទំនប់វារីអគ្គីសនីធំៗនិងប្រព័ន្ធ ប្រឡាយទឹកសម្រាប់វិស័យកសិកម្ម ហើយទាក់ទាញនូវជំនួយមនុស្សធម៌ក្នុងគម្រោងអភិវឌ្ឍន៍សង្គមដូចជាសាលារៀន មន្ទីរ ព្យាបាលជំងឺ និងការដោះមីនជាដើម ៗល ។ ហើយថ្មីៗនេះដែរ សហគមន៍អឺរ៉ុបបានប្រកាសជំនួយចំពោះគម្រោងទី២នេះ ដល់ភូមិភាគពាយ័ព្យ ។ ក្នុងស្ថានការណ៍ណាក៏ដោយ ក៏សំណើគម្រោងអភិវឌ្ឍន៍របស់ពួកខ្មែរក្រហមបានបង្ហាញយ៉ាងគ្រប់គ្រាន់ថាតើ គំនិតសេដ្ឋកិច្ចរបស់ខ្មែរក្រហមដែលមានសារជាតិម៉ៅនិយមប្រឡោងខាមនោះ នឹងចេញដល់កម្រិតណា ហើយអ្វីដែលជាការបង្ហាញច្បាស់នោះ គឺការបង្កើតកាស៊ីណូ និងបនស្រីពេស្យាក្នុងក្រុងប៉ៃលិន ។



នៅអតីតភូមិភាគឧត្តររបស់ខ្មែរក្រហម ការគិតតាមផ្លូវចាស់នៅតែបន្តក្នុងការឱបក្តាប់អំណាច ។ ការកាប់ព្រៃឈើ និងលួចវត្ថុបុរាណនៃប្រាសាទនានាក៏នៅតែបន្តកើតមានឡើងជាទម្រង់សកម្មភាពសេដ្ឋកិច្ច ។ ជាការសន្មតិសកម្មភាពនឹងផ្លាស់ប្តូរទៅ នៅពេលដែលប្រាសាទ និងព្រៃឈើក្លាយជាប្រភពនៃប្រាក់ចំណូល ហើយនៅពេលដែលពួកខ្មែរក្រហមនៅភូមិភាគឧត្តរ ចាប់ផ្តើមយល់ដឹងអំពីសក្តានុពលភាពរបស់តំបន់នៅក្បែរៗប្រទេសថៃ ដែលស្ថិតនៅជិតតំបន់ប្រវត្តិសាស្ត្រ

ជាច្រើនដងទៀត ដែលគ្មានអ្នកទេសចរណ៍ណាម្នាក់ធ្លាប់ទៅដល់ជាច្រើនទសវត្សរ៍មកហើយ ។

ឥឡូវយើងនាំគ្នាគិតអំពីមរតកផ្នែកយោធារបស់ខ្មែរក្រហម ។ ការគំរាមកំហែងផ្នែកយោធារបស់ខ្មែរក្រហមលែងមានតទៅទៀតហើយ ។ ភាពឯកោផ្នែកនយោបាយពីអន្តរជាតិ ដែលបណ្ដាលមកពីដំណើរការសន្តិភាព នៅទីក្រុងប៉ារីស និងនយោបាយមុខពីរ ពីរទសវត្សរ៍របស់រដ្ឋាភិបាល «ការបង្រួបបង្រួមជាតិ និងការគាបសង្កត់ផ្នែកនយោបាយ» បាននាំទៅដល់ការរលំរលាយនៃអំណាចយោធារបស់ខ្មែរក្រហម ។ ការរលំរលាយចុងក្រោយ ត្រូវបានកត់សម្គាល់ តាមរយៈការចាប់មេទ័ពក្បាលរឹង ក្នុងខែមេសាឈ្មោះ «តាម៉ុក» ដែលប្រជាជន កម្ពុជាមានការភ័យខ្លាចជាទូទៅ ។



ជាសារវន្តនយោបាយរបស់រដ្ឋាភិបាលក្រុងភ្នំពេញ ចំពោះខ្មែរក្រហមមានអត្ថិភាពរហូតក្នុងកំឡុងពេល ២០ឆ្នាំចុងក្រោយនេះ ។ នៅខែមករា ឆ្នាំ១៩៧៩ ហេង សំរិន បានប្រកាស ក្នុងនាមជារណសិរ្សសង្គ្រោះជាតិបដិវត្តន៍ដែលចូលមកជំនួសរបបខ្មែរក្រហមនោះថា «បងប្អូនណាបានប្រព្រឹត្តបទឧក្រិដ្ឋកម្ម ហើយសារភាពនូវទោសកំហុសខ្លួន និងវិលត្រឡប់មករួមរស់ជាមួយបដិវត្តន៍វិញ បដិវត្តន៍នឹងមិនយកទោសពៃរ៍អ្វីឡើយ» ។

ចំពោះអ្នកដែលមិនបានធ្វើតាមសេចក្ដីប្រកាសនឹងត្រូវកម្ទេច ។ ប៉ុន្តែនយោបាយនេះមានសុពលភាពអស់រយៈពេល ២ទសវត្សរ៍ ដោយមានតែករណីលើកលែងតែ២ប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៧៩ របបថ្មីមួយដែលជាដូវការតែងតែបន្ទោសអ្វីៗគ្រប់យ៉ាងចំពោះ «បន ប៉ុល ពត, អៀងសារី» បានកាត់ទោសជនទាំងពីររូបនេះប្រហារជីវិតដោយកំបាំងមុខ ហើយបានកាត់ទោសពួកកម្មាភិបាលខ្មែរក្រហមមួយចំនួនតូចរបស់ ប៉ុល ពត ឲ្យជាប់ទោសតាមច្បាប់កំណត់ដោយឲ្យរៀនសូត្រនយោបាយ ។ ករណីលើកលែងទី១ ត្រូវបានធ្វើឡើងចាប់ពីពេលចាប់ផ្ដើមនៃការរលត់រលាយនៃរបបខ្មែរក្រហមមកម៉្លេះ ។ ករណីលើកលែងទី២ គឺកំពុងតែចូលមកដល់ចុងបញ្ចប់នៃការរលំរលាយរបស់របស់ខ្មែរក្រហម ហើយក្នុងការដាក់ខទានសញ្ញាប្រវត្តិសាស្ត្រនៅចុងបញ្ចប់នៃសុបិនអាក្រក់ខ្មែរក្រហមពោលគឺ នៅពេលដែលកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមដែលគ្មានសុច្ចន្ទៈមួយចំនួន ត្រូវនាំយកការកាត់ទោសជាយថាហេតុបន្តបន្ទាប់ និងទទួលនូវការដាក់ទោសពៃរ៍ ។

ពួកកូនចៅរបស់ អៀង សារី នៅប៉ៃលិនជារឿយៗ បានគំរាមថា នឹងត្រឡប់ទៅធ្វើសង្គ្រាមវិញ ប្រសិនបើមេដឹកនាំចាស់ៗរបស់ខ្លួនត្រូវបាននាំយកមកកាត់ទោស ។ ការគំរាមទាំងនេះគ្មានការពិតជាមូលដ្ឋានទាល់តែសោះ ។ កូនទាហានជាច្រើនត្រូវបានរំសាយអស់ទៅហើយ ហើយអ្នកនៅសល់ទាំងអម្បាលមាណគឺ កំពុងស្ថិតក្នុងដំណើរការនៃសមាហរណកម្មចូលទៅក្នុងកងទ័ពជាតិ ។ ពួកកូនទាហានទាំងនោះដឹងថា ការត្រឡប់ទៅធ្វើសង្គ្រាមវិញមានន័យថា ការវិលត្រឡប់ទៅរកការសម្លាប់រង្គាលខ្មែរ និងខ្មែរគ្នាឯង ការរស់នៅដោយស៊ីស្លឹកឈើ និងសត្វល្អិតជាអាហារ ដេកឲ្យមូសខាំ ហាលភ្លៀង និងការស្លាប់ដោយគ្រាប់មីន ដូចសត្វធាតុប៉ុណ្ណោះ ។ ពួកទាហានទាំងអស់នោះ ពិតជាមិនស្ម័គ្រចិត្តធ្វើដូច្នេះឡើយ ។ ចំពោះមនុស្សភាគច្រើនយល់ថា បំណងប្រាថ្នាដ៏ធំរបស់ពួកទាហានទាំងនោះ គឺប្រហែលជាចង់បានការងារធ្វើនៅកាស៊ីណូប៉ៃលិនឯណោះទៅវិញទេ ។ កូនទាហានទាំងនោះចង់មានអាហារសម្រាប់ចម្អែតក្រពះ និងសាលារៀនសម្រាប់កូនចៅរបស់ខ្លួន ។ សង្គ្រាមបានបញ្ចប់ទៅហើយ ប៉ុន្តែ

ការគំរាមគំហែងឥតឈប់ឈរបានបង្ហាញថា ប្រហែលជាមេដឹកនាំចាស់ៗដែលធ្វើជាអ្នកចំបាំងពេញមួយជីវិតយុវវ័យទៅហើយនោះ អាចក្លាយជាមនុស្សអសមត្ថភាពផ្នែកខួរក្បាល ពិបាកសម្រួលខ្លួនរស់នៅក្នុងសុខសន្តិភាពជាមួយសង្គមជាតិ ។

អំពើឆក់ប្លន់ពិតជានៅតែជាបញ្ហាពុំរ៉ាំរ៉ៃនៅឡើយ តែវាកើតឡើងតែនៅជាយៗស្រុកតែប៉ុណ្ណោះ ។ នេះជាផលវិបាកដែលមិនអាចជៀសផុតនៃវិធីសាស្រ្តជាប្រពៃណីក្នុងការដឹកនាំប្រទេសកម្ពុជា ។ ប៉ុន្តែវាក៏ជាបញ្ហាអាចដោះស្រាយបានដែរ ទោះបីជាមានឬមិនមានការកាត់ទោសខ្មែរក្រហម ដែលមានលក្ខណៈទ្រង់ទ្រាយធំក៏ដោយ ។

ការរំសាយកងទ័ពដ៏ច្រើនសន្ធឹកសន្ធាប់ ឥឡូវគឺជាបញ្ហាយោធាប្រទាញប្រទង់ និងក្តៅគគុកមួយ ។ វានឹងមានការរំជើបរំជួលក្នុងសង្គម និងការកើនឡើងនៃអំពើឆក់ប្លន់ ដែលបណ្តាលមកពីការគ្មានការងារធ្វើរបស់ពលទាហានខ្មែរក្រហម ឬពលទាហានផ្សេងៗទៀត ប្រសិនបើការរំសាយទ័ពមិនត្រូវបានដោះស្រាយឲ្យបានត្រឹមត្រូវ ហើយនិងផ្តល់ប្រាក់ឥណទានឲ្យបានសមរម្យ ។ ជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីធានាការកាត់រំសាយទ័ព ដែលមានទ្រង់ទ្រាយធំ ពិតជាមិនអាចរ៉ាប់រងដំណើរការទាំងស្រុងបានឡើយ ។ គំរូទំនាក់ទំនងស៊ីវិល និងយោធារបស់ប្រទេសចិន គឺមិនមានលក្ខណៈសមស្របទេចំពោះប្រទេសកម្ពុជាដែលមានបំណងកសាងនូវប្រព័ន្ធប្រជាធិបតេយ្យសេរី ។ សន្និសីទកាសែតរបស់ធនាគារពិភពលោកស្តីអំពីការកាត់រំសាយទ័ពក្នុងខែឧសភា ឆ្នាំ១៩៩៩ មានការខកខានក្នុងការលើកយកមកពិភាក្សា សូម្បីតែបញ្ហាសំខាន់ៗដែលរួមមានការដកអាវុធពីអតីតពលទាហានអ្នករំសាយ ។ល។ ការនេះវានឹងមានការលំបាកជាងអ្វីដែលជាការមើលពីខាងក្រៅទៅទៀត ។

មរតកដ៏យូរអង្វែងមួយទៀតរបស់ខ្មែរក្រហមគឺគ្រាប់មីន ។ ទុក្ខទោសនេះនឹងបន្តលងប្រជាជនកម្ពុជា ហើយបន្តការអូសបន្លាយការរអាក់រអួល ផ្នែកផលិតកម្មដល់ជំនាន់ក្រោយៗទៀត ។ ថ្វីបើមានរឿងអាស្រូវផ្នែកហិរញ្ញវត្ថុនៅមជ្ឈមណ្ឌលកំចាត់គ្រាប់មីនកម្ពុជាថ្មីៗនេះក៏ដោយ ក៏ការដោះមីនសង្គ្រោះមនុស្សជាតិ និងការពង្រឹងសមត្ថភាពក្នុងការដោះមីន គួរតែជាបញ្ហាព្រួយបារម្ភដ៏ចម្បងសម្រាប់សហគមន៍អន្តរជាតិ ។

មរតកសង្គមរបស់ខ្មែរក្រហម គឺមានលក្ខណៈស្មុគស្មាញហើយនិយាយដោយចំ គឺពិបាកយល់ណាស់ ។ ពេទ្យវិកលចរិតនិងអ្នកចិត្តសាស្រ្តសង្គមកំពុងតែសិក្សាអំពីឥទ្ធិពលនៃសង្គ្រាមនិងអំពើប្រល័យពូជសាសន៍មកលើប្រជាជនកម្ពុជាទូទៅ ដែលកើតមានរយៈពេលជាច្រើនទសវត្សរ៍ហើយនោះ ។ មកដល់សព្វថ្ងៃនេះមិនទាន់មានការយល់ស្របមតិ គ្នាជាទូទៅនៅឡើយទេ ក្រោយពីមានឧប្បត្តិហេតុនៃភាពចលាចលដ៏គួរឲ្យរន្ធត់ និងជំងឺផ្នែកចិត្តសាស្រ្តដែលកើតឡើងតាមរយៈជម្លោះជាងមួយភាគបួននៃសតវត្សរ៍ ។ ប៉ុន្តែក្នុងរយៈពេលដ៏ខ្លី ក្រោយពីបុគ្គលម្នាក់មកដល់កម្ពុជា និងចាប់ផ្តើមមានទំនាក់ទំនងជាមួយប្រជាជនសាមញ្ញនោះ បុគ្គលនោះនឹងសង្កេតឃើញថា មរតកចិត្តសាស្រ្តខ្មែរក្រហមពិតជានៅតែមានសុពលភាពនៅឡើយ នៅក្នុងចំណោមប្រជាជនកម្ពុជា ។

សង្គមប្រពៃណីរបស់កម្ពុជា ត្រូវបានរៀបចំឡើងជាសមូហភាពនៅតាមភូមិ និងតាមរយៈកុលសម្ព័ន្ធ ។ ថ្វីត្បិតតែមានពាក្យវោហាសព្ទថា «សាមគ្គី» ក៏ដោយ ក៏ខ្មែរក្រហមបានធ្វើឲ្យបែកខ្ញែកនូវទម្រង់គ្រប់គ្រងសង្គមឲ្យមានលក្ខណៈតូចៗដោយបានបង្ខំឲ្យជនគ្រប់ៗរូបការពារខ្លួនដោយខ្លួនឯង ។ មរតកនៃនយោបាយដ៏ឆ្គួតលីលានេះ គឺជាតិមួយដែលមានសុទ្ធតែមនុស្សចម្លែកៗ ហើយជាកន្លែងដែលគំនិតនៃកាតព្វកិច្ចជួយគ្នាទៅវិញទៅមកត្រូវបានសឹករេចរិលអស់ ។ វាហាក់ដូចជាថាការលោតផ្លោះពីសង្គមប្រពៃណីទៅកាន់សង្គមដែលមានទំនើបភាវូបនីយកម្មត្រូវបានធ្វើឡើងដោយប្រើពេលជិតពីរបីជំនាន់ ប៉ុន្តែត្រូវរលំរលាយតែមួយរំពេច គឺគ្រាន់តែដោយការប្រើកម្លាំងបង្ខំតែពីរថ្ងៃ ដោយពួកខ្មែរក្រហមប៉ុណ្ណោះ ។

ជាការចម្លែក នយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាលបច្ចុប្បន្ន ហាក់បីដូចជាត្រូវបានបង្កើតឡើងដោយខិតខំប្រឹងធ្វើ

ឲ្យខុសស្រឡះពីអ្វីដែល ប៉ុល ពត បានធ្វើយ៉ាងច្បាស់ក្រឡែត ។ ប៉ុល ពត បានខិតខំអភិវឌ្ឍន៍សង្គម តាមរយៈប្រព័ន្ធសេដ្ឋកិច្ច "Autarky" «ប្រព័ន្ធសេដ្ឋកិច្ចដែលផលិត និងប្រើប្រាស់ផលិតផលក្នុងស្រុក ហើយប្រឆាំងការនាំចូលផលិតផលមកពីបរទេស» ដែលធ្វើឲ្យទំនាក់ទំនងសេដ្ឋកិច្ចខាងក្រៅប្រទេស កាន់តែមានលក្ខណៈធ្លាក់ចុះ ធ្វើឲ្យឯកោផ្នែកក្នុងរវាងតំបន់មួយទៅតំបន់មួយ ដោយជំរុញឲ្យមាន «ភាពម្ចាស់ការ» និងដោយថាហេតុធ្វើឲ្យបុគ្គលម្នាក់ៗមានភាពឯកោ ។ ប៉ុល ពត បានប្រកាសថា អង្គការអនុញ្ញាតឲ្យមានតែរបស់ជាប់ខ្លួនតែប៉ុណ្ណោះ ។ របបដឹកនាំបច្ចុប្បន្ន បានធ្វើបញ្ច្រាសពីការពិតទាំងអស់ខាងលើនេះ ។ រដ្ឋាភិបាលបច្ចុប្បន្ន បានខិតខំរិះរកមធ្យោបាយកសាងនូវសំណាញ់នៃទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសជិតឆ្ងាយ ដើម្បីជំរុញឲ្យមានពាណិជ្ជកម្មក្នុងស្រុក ដោយភ្ជាប់ផ្នែកក្នុងពីតំបន់មួយទៅតំបន់មួយនៅក្នុងប្រទេស តាមរយៈបណ្តាញអភិវឌ្ឍន៍នៃផ្នែកទំនាក់ទំនង និងគមនាគមន៍ដឹកជញ្ជូន និងដោយផ្តល់នូវវិធានការណ៍ជាក់ស្តែងប្រកបដោយសេរីភាព និងស្វ័យភាពទៅដល់បុគ្គលគ្រប់ៗរូប ។ សេរីភាពតាមពិតមានន័យថា មនុស្សគ្មានការប៉ុនប៉ងក្នុងការរំលោភទៅលើអ្វីដែលអ្នកដឹកនាំយល់ថា ជាបុព្វសិទ្ធិរបស់ខ្លួន ។



យុទ្ធសាស្ត្រនេះគឺមានសារៈសំខាន់ដោយឡែកមួយពេលនិយាយដល់អតីតតំបន់ខ្មែរក្រហមនោះ ។ លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ឃែនែត គ្វីន ដែលទើបតែបញ្ចប់អាណត្តិថ្មីៗនេះធ្លាប់បានប្រាប់ខ្ញុំថា កាលពី១០ឆ្នាំមុន មធ្យោបាយក្នុងការកម្ចាត់ខ្មែរក្រហម គឺការកសាងផ្លូវថ្នល់ឲ្យចូលទៅដល់តំបន់ខ្មែរក្រហម ។ ចំពោះបញ្ហានេះលោកបានវែកញែកថា នឹងអាចធ្វើឲ្យមានឥទ្ធិពលមិនល្អ ចំពោះពួកខ្មែរក្រហមតាមរយៈគំនិត និងពាណិជ្ជកម្មបរទេស ដែលនាំឲ្យមានការបែកបាក់បណ្តុំគំនិតមនោគមន៍វិជ្ជា និងកម្លាំងទ័ពរបស់ពួកខ្មែរក្រហមទាំងនោះទៀតផង ។ ពេលនោះខ្ញុំគិតថា វាគឺជាគំនិតហួសហេតុមួយតែប៉ុណ្ណោះ ប៉ុន្តែនៅទីបញ្ចប់អ្វីៗដែលកើតឡើងមានលក្ខណៈដូចបេះបិទទៅនឹងគំនិតនោះ ។ ខ្ញុំដឹងថា វាជាការពិត ប៉ុន្តែខ្ញុំហ៊ាននិយាយថា លោកឯកអគ្គរដ្ឋទូតអាមេរិក គ្វីន បានវែកញែកប្រាប់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយលោក គ្វីន ហាក់ដូចជាជោគជ័យក្នុងការធ្វើឲ្យលោកនាយករដ្ឋមន្ត្រី ជឿជាក់ចំពោះគំនិតនេះ ។

ផលវិបាកសង្គមយូរអង្វែងទៅមុខនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រដ្ឋាភិបាល អាចមានលក្ខណៈកាន់តែធ្ងន់ជាងឥទ្ធិពលរបស់វាចំពោះមរតកខ្មែរក្រហមទៅទៀត នៅពេលដែលជីវិតជនបទកាន់តែខិតជិតទៅនឹងជីវិតទីក្រុង តាមរបៀបដែលមិនដែលធ្លាប់មានពីមុនមកនៅក្នុងប្រទេសកម្ពុជានោះ ។

មរតកខ្មែរក្រហមដែលមានលក្ខណៈសាំញ៉ាំបំផុតនោះគឺប្រហែលជា «មរតកនយោបាយ» ។ ឥឡូវចូរយើងក្រឡេកទៅក្រោយមើលព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧ ។

តាមគំនិតរបស់ខ្ញុំ ផ្កាភ្លើង ដែលឆេះនៅ ខែកក្កដា ឆ្នាំ១៩៩៧ នោះគឺជាព្រឹត្តិការណ៍ដែលស្ទើរតែមិននឹកស្មានដល់មួយ ។ ដោយស្ថិតនៅក្រោមឥទ្ធិពលនៃយុទ្ធវិធីភ័ន្តច្រឡំនោះ កងកម្លាំងរាជានិយមនៃរដ្ឋាភិបាលចំរុះបានប៉ុនប៉ងទាំងងងើលក្នុងការចងសម្ព័ន្ធជាមួយពួកខ្មែរក្រហម ដើម្បីឲ្យមានប្រៀបខាងកម្លាំងលើគណបក្សប្រជាជន ។

ដូចដែលបានទាយទុកមុនអ៊ីចឹង អំពើនេះត្រូវបានគណបក្សប្រជាជនចាត់ទុកថា មិនត្រឹមតែជារដ្ឋប្រហារទេ តែ

ថែមទាំងយល់ថា ជាការវិលត្រឡប់សារជាថ្មីនៃរបបខ្មែរក្រហមទៀតផង ។ ដូច្នេះគណបក្សប្រជាជន បានឆ្លើយតបទៅនឹងអំពើនេះតាមរបៀបទាំងពីរនេះឯង ។ ឥទ្ធិពលមួយនៃរដ្ឋប្រហារក្នុងឆ្នាំ១៩៩៧ គឺថា គណបក្សប្រជាជនបានកម្ទេច និងកម្ចាត់ខ្សែបញ្ជារបស់កម្លាំងរាជានិយមស្ទើរតែអស់រលីង ។

ថ្វីត្បិតតែវាជាភាពឃោរឃៅមិនសមហេតុផលក៏ដោយ ក៏សកម្មភាពនេះមានប្រយោជន៍ល្អ ដល់ការបំបាក់នូវបង្គោលដ៏រឹងមាំនៃអស្ថេរភាពមួយក្នុងប្រទេសកម្ពុជា«ការប្រកាប់ប្រចាក់គ្នាផ្នែកកម្លាំងទ័ព» ។ ដូច្នេះសម្តេច ហ៊ុន សែន បានសម្រេចនូវការធ្វើសមាហរណកម្មកម្លាំងទ័ព ដែលជាចំណុចប្រហោងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។ វាជាការពិតណាស់ ដែលថាការធ្វើរបៀបនេះពិតជាមានការបង្ហូរឈាមខ្លះៗជាមិនខាន ។ លើសពីនេះទៀត ការបង្រួបបង្រួមដោយកម្លាំងនៃកងទ័ពជាតិ ក្រោមការបាត់បែងរបស់គណបក្សប្រជាជន បានធ្វើឲ្យលទ្ធភាពក្រុមខ្មែរក្រហមដែលចង់ឲ្យកងកម្លាំងរាជានិយម និងកម្លាំងរបស់គណបក្សប្រជាជនប្រខាំគ្នា ត្រូវបរាជ័យទាំងស្រុង ។

ប៉ុន្តែនៅពេលទន្ទឹមនឹងគ្នានេះដែរ ក៏មានការបែកបាក់យ៉ាងស្រួចស្រាវក្នុងជួរគណបក្សប្រជាជនដែរ ។ ពីរខែកន្លងទៅ គឺនៅថ្ងៃទី២៨ ខែមិថុនា នៅពេលសមាជពេញអង្គបក្សសម្តេច ជា ស៊ីម បានមានប្រសាសន៍ថា «ពួកអ្នកប្រឆាំងគណបក្សប្រជាជនបានព្យាយាមពេញទំហឹងក្នុងការបំបែកបំបាក់សាមគ្គីភាព និងឯកភាពក្នុងជួរដឹកនាំរបស់បក្សក្នុងគោលគំនិតកម្ទេចបក្សរបស់យើង ។ ប៉ុន្តែពួកទាំងនោះមិនដែលបានសម្រេចម្តងណាឡើយ ។ សូមអរគុណចំពោះការដែលយើងដឹងអំពីរបៀបរួបរួម និងប្រមូលកម្លាំងគ្នា ដែលជាហេតុនាំឲ្យយើងអាចទទួលបានជោគជ័យក្នុងការដោះស្រាយរាល់បញ្ហាទាំងអស់នោះ» ។

ថ្វីដ្បិតតែពាក្យដ៏មានខ្លឹមសារនេះហូរចេញពីមាត់របស់ប្រធានបក្សប្រជាជនកម្ពុជាយ៉ាងនេះក៏ដោយ តែប្រសិនបើការរួបរួមបក្សពិតជាគ្មានបញ្ហាមែននោះ ម៉្លេះវានឹងគ្មានការកើតឡើងនូវបញ្ហាខាងដើមឡើយ ។ ច្បាប់ផ្ទៃក្នុងរបស់បក្សដែលមានបុសគល់ឡើនីនក្លែងក្លាយដែលហៅថា «ប្រជាធិបតេយ្យប្រមូលផ្តុំ» នោះបានបិទបាំងនូវបន្ទោះ ឬចន្លោះក្រហូងយ៉ាងជិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ក្រហែងប្រេះស្រាំ វាស្ថិតនៅទីនោះនៅឡើយទេ ហើយប្រហែលវាអាចបង្កជាការគំរាមកំហែងដល់ស្ថេរភាពផ្ទៃក្នុងរបស់ប្រទេសកម្ពុជាសព្វថ្ងៃទៀតផង ។

នៅដើមឆ្នាំ១៩៩៩ មានការរំដើបរំជួលដ៏ធ្ងន់ធ្ងរក្នុងជួរបក្សស្តីអំពីបញ្ហាថាតើត្រូវដាក់ទណ្ឌកម្មចំពោះមេដឹកនាំកំពូលខ្មែរក្រហមតាមវិធីណាមួយឲ្យសមស្រប ។ ការលើកលែងស្រាអបអរសាទរនៅដើមឆ្នាំ១៩៩៩ គឺគ្រាន់តែជាពិធីដ៏អឺកធឹកមួយដើម្បីបង្ហាញពីការចុះចូលរបស់ ខៀវ សំផន និង នួន ជា ជាមួយសម្តេច ហ៊ុន សែន តែប៉ុណ្ណោះ ប៉ុន្តែទិដ្ឋភាពនេះបានធ្វើឲ្យមានការវិលវល់ចំពោះមនុស្សជាច្រើនដែលបានប្រយុទ្ធប្រឆាំងទល់នឹងពួកខ្មែរក្រហមអស់ជាច្រើនសតវត្សរ៍ មកហើយនោះ ។ ចំពោះបញ្ហានេះខ្ញុំសង្ស័យថា វាគឺជាអ្វីដែលបានបង្វែរសម្តេច ហ៊ុន សែន ចេញពីសេចក្តីប្រកាសដែលថា «គួរតែកប់ចោលនូវអតីតកាល» ។

នៅជាប់ជាមួយនឹងខ្មែរក្រហមតែងតែងមាននយោបាយនៃការស្មោះត្រង់អស់ពីចិត្តពីថ្លើមចំពោះបក្សក្នុងខ្លួនមេដឹកនាំធំៗ ។ ប៉ុន្តែនៅមុនពេលមរណភាពរបស់ ប៉ុល ពត កម្លាំងខ្មែរក្រហមបានចាប់ផ្តើមធ្វើសមាហរណកម្មចូលទៅក្នុងបក្សពួកតូចៗ ដែលមានការសង្ស័យគ្នាទៅវិញទៅមក ដោយពឹងផ្អែកទៅលើភក្តីភាពផ្ទាល់ខ្លួនចំពោះមេបញ្ជាការយោធាមូលដ្ឋាន ។ បើនិយាយដល់ប្រវត្តិនៃវិសុទ្ធកម្មដោយគ្មានមេត្តាវិញនោះ ព្រឹត្តិការណ៍នេះកើតឡើងដោយសារតែគ្មានមូលដ្ឋាននៃការទុកចិត្តគ្នាទៅវិញទៅមកឬកម្លាំងស្អិតរមួត ដែលជាហេតុនាំឲ្យមានការឃ្លាតឆ្ងាយពីគ្នាជាមួយនឹងមតិទូទៅមួយដែលថា មានការសម្លាប់កម្មាភិបាលដ៏ច្រើនឥតគណនា ។ ដោយមានការរំលោភទៅលើមតិទូទៅ ដែលមិនបានពោល បានបង្ហាញយ៉ាងច្បាស់ពីការធ្លាក់ខ្លួនយ៉ាងឆាប់រហ័សរបស់ ប៉ុល ពត ហើយបន្ទាប់មកគឺ តាម៉ុក ។

ពួកអតីតមេដឹកនាំខ្មែរក្រហមមិនទុកចិត្តគ្នាឡើយ ។ ដូច្នេះ

ថ្មីត្បិតតែគណបក្សប្រជាជនមានការប្រេះស្រាំយ៉ាងណាក៏ដោយ ក៏គណបក្សនេះនៅតែមានប្រៀបដែរ ក្នុងការប្រើល្បិចបែងចែក និងកាន់កាប់ ។ ពួកអតីតខ្មែរក្រហមទាំងអស់បានទទួលស្គាល់ថា សម្តេច ហ៊ុន សែន គ្មានមនុស្សណាអាចមានសមត្ថភាពប្រកួតប្រជែងជាមួយបានឡើយ ។ ប៉ុន្តែទោះបីជាពួកខ្មែរក្រហមគោរពនូវភាពគ្មានមេត្តា និងសមត្ថភាពរបស់សម្តេចក៏ដោយ ក៏ពួកខ្មែរក្រហមទាំងអស់មិនទាន់បានឯកភាពគ្នាក្នុងការយកសេចក្តីបង្អាប់ថ្មីមកបង្កើតជាបទបញ្ហាផ្ទៃក្នុងនៅឡើយទេ ។

ការនេះនាំឲ្យយើងទៅដល់មរតកមួយទៀតគឺ មរតកច្បាប់ខ្មែរក្រហម ដែលជាបញ្ហាចំពោះអនាគតជាជាងចំពោះអតីតកាល ។ អនុលោមទៅតាមនយោបាយកម្ពុជា ដែលមានអាយុកាល២០ឆ្នាំទៅហើយ ចំពោះអ្នកដែលស្ថិតនៅថ្នាក់ដឹកនាំទី២ និងទី៣ របស់អតីតខ្មែរក្រហមទាំងក្មេង ទាំងចាស់ ដែលនឹងត្រូវពាក់ពន្ធ័ពីបទប្រល័យពូជសាសន៍ និងពួកដែលមិនត្រូវការយកចិត្តទុកដាក់ពីតុលាការ នឹងត្រូវបានលើកលែងទោស និងបន្តធ្វើសមាហរណកម្មជាបន្តបន្ទាប់ទៀត ចូលទៅក្នុងជីវភាពនយោបាយក្នុងប្រទេសកម្ពុជា ។

ទស្សនវិស័យរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមិនអាចជាក្តីសង្ឃឹមឡើយ ។ អៀង សារី បានផ្ញើសារលិខិតមួយទៅឲ្យសម្តេច ហ៊ុន សែន ពេលដែលសន្លឹកឆ្នោតលើសលុបក្នុងតំបន់របស់គាត់ត្រូវបានបោះគាំទ្រលោក សម រង្ស៊ី ក្នុងកំឡុងពេលនៃការបោះឆ្នោតកាលពីឆ្នាំ១៩៩៨ ។ សម្តេច ហ៊ុន សែន ក៏អាចនឹងផ្ញើសារមួយតបវិញផងដែរ ហើយអ្នកជំនាន់ក្រោយៗ បានដឹងច្បាស់ពីសារនោះតាមរយៈការច្បិចយកមួយម្តងៗនូវមេធំៗជាច្រើន ដែលជាមនុស្សរមិលគុណនោះ ។ អាវុធដែលសម្តេច ហ៊ុន សែន បានជ្រើសរើសមានតែមួយទេគឺ «ច្បាប់» ។

ម៉ុក និង ឌុច ត្រូវបានចាប់ខ្លួនពីប៉ៃលិន តែវាគ្មានការភ្ញាក់ផ្អើលឡើយ ដោយសារតែពួកទាំងពីរត្រូវបានពួកខ្មែរក្រហមដេរប្រមាថ ។ ចំពោះ នួន ប៉ែត ត្រូវបានកាត់ទោសប្រហារជីវិតនៅខណៈដែលឧត្តមសេនីយ សំ ប៊ិត និង វរសេនីយឯក ឈូក រិន ត្រូវបានចោទប្រកាន់ ហើយយើងគ្រាន់តែបានឮរសៀកៗពីការចាប់ខ្លួន តាមរយៈអតីតកូនចៅរបស់ពួកទាំងពីរនាក់នោះប៉ុណ្ណោះ ។ ឥឡូវយើងនឹងដឹងទៀតថា មនុស្សជាច្រើនទៀតនឹងត្រូវចាប់ខ្លួន ក្នុងករណីនៅពីក្រោយខ្នងអ្នកចាប់ពង្រត់ទាំងអម្បាលមាណ ។



ក្នុងដំណើរត្រឡប់មកពីការចូលរួមពិធី ទទួលសញ្ញាប័ត្ររបស់កូនប្រុសនៅបណ្ឌិតសភា យោធាវេសភ័ញ West Point នៅសហរដ្ឋអាមេរិក កាលពីប៉ុន្មានខែកន្លងទៅនេះ សម្តេច ហ៊ុន សែន បានឆៀងចូលទីក្រុងប៉ារីស ហើយបានឲ្យពួកអ្នកកាសែតបារាំង ចូលធ្វើកិច្ចសម្ភាសន៍មួយ ។នៅទីនោះ សម្តេច ហ៊ុន សែន បានប្រកាសថា ការស៊ើបអង្កេតក្នុងករណីតាម៉ុកបានបង្ហាញថា អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងដោយ «របបទាំងមូល» និង «ចលនានយោបាយ» ដូច្នេះ ការកាត់ទោសតាម៉ុក និងឌុច គឺអាចមានលក្ខណៈគ្រប់គ្រាន់ហើយសម្រាប់ការ «សម្រេចយុត្តិធម៌» ឲ្យប្រជាជនកម្ពុជា ។ ការនេះពិតជាមិនមែនជាការលាតត្រដាងសម្រាប់នរណាម្នាក់ដែលសូម្បីតែប្រវត្តិសាស្ត្រទំនើបកម្ពុជាក៏ដឹងស្រពេចស្រពិលដែរ ។ ប៉ុន្តែតើនេះជាការចន្លុះបង្ហាញនូវបំណងសំខាន់យូរអង្វែងរបស់សម្តេច ហ៊ុន សែន ឬ? សម្តេច ហ៊ុន សែន បានមានប្រសាសន៍ យ៉ាងស៊ីជម្រៅថា «មនុស្សម្នាក់ត្រូវតែចាប់ត្រីឲ្យបានសិន មុនពេលដែលខ្លួនសម្រេច

ចិត្តក្នុងការឆាវាតាមរបៀបណា» ។ ខ្ទះឆារបស់សម្តេច ហ៊ុន សែន ឥឡូវកំពុងតែក្តៅហើយ ហើយគាត់នឹងអាចដាក់ត្រីម្តងមួយៗ ចូលទៅក្នុងប្រេងឆាដែលកំពុងតែពុះ ។ ក៏ប៉ុន្តែគាត់នឹងឆាត្រី នៅពេលដែលគាត់ទំនេរ ហើយនឹងធ្វើទៅតាមតារាងកាលវិភាគរបស់គាត់ ជាជាងតាមកាលវិភាគដែលសហគមន៍អន្តរជាតិមានបំណងនឹងដាក់ឲ្យ ។ តើមានការផ្តាច់ប្រព័ន្ធដ៏សំខាន់ណាមួយរវាងសហគមន៍អន្តរជាតិ និងគំនិតរបស់រដ្ឋាភិបាលកម្ពុជាដែរឬទេ ស្តីអំពីថាតើ ត្រូវបន្តដំណើរការអំពីបញ្ហាខ្មែរក្រហមឲ្យលឿនប៉ុណ្ណា ។

ចិនបានមានប្រតិកម្មយ៉ាងខ្លាំងក្លា ចំពោះលទ្ធភាពនៃការរកយុត្តិធម៌ចំពោះបញ្ហាខ្មែរក្រហម ដោយបានចេញមុខចំហក្នុងការការពារសម្ព័ន្ធមិត្តរបស់ខ្លួន ។ មន្ត្រីចិនបាននឹងកំពុងបញ្ចុះបញ្ចូលទាំងសភាជាតិ និងរដ្ឋាភិបាលកម្ពុជាឲ្យជួយគាំទ្រដល់ខ្លួនក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីកុំឲ្យមានតួនាទីរបស់អន្តរជាតិក្នុងតុលាការខ្មែរក្រហម ដែលជាការគាំទ្រដល់ទស្សនៈ «តម្លៃនៃអាស៊ី» របស់ចិន ដែលថាមហាឃាតកម្មមនុស្សជាតិក្នុងស្រុក មិនមែនជាកិច្ចការរបស់នរណាម្នាក់ឡើយ ។

តើប្រទេសកម្ពុជានឹងគោរព និងធ្វើតាមជ្រុលហួសហេតុតាមឥទ្ធិពលរបស់ប្រទេសចិន ឬក៏បន្តដំណើរទៅមុខឆ្ពោះទៅរកសង្គមមួយដែលយកច្បាប់ជាមូលដ្ឋានឬយ៉ាងណា?

ប្រទេសបារាំងបានបញ្ជូនក្រុមអ្នកច្បាប់កំពូលៗមួយក្រុមមកជួយផ្តល់ជាយោបល់ដល់រដ្ឋាភិបាលកម្ពុជា ស្តីអំពីរបៀបដោះស្រាយរឿងរ៉ាវតុលាការខ្មែរក្រហម ។ បុគ្គលម្នាក់គ្រាន់តែអាចសង្ឃឹមថា ក្រុមនេះនឹងមិនរួមបញ្ចូលបុគ្គលិកក្រសួងការបរទេសបារាំង ដែលបានបន្តដឹកជញ្ជូនអាវុធទៅឲ្យពួកប្រល័យពូជសាសន៍នៅហ៊ូទូ នៃប្រទេសរ៉ាន់ដា Rwanda ក្នុងអំឡុងពេលនៃការសម្លាប់ ជនជាតិ ភាគតិចទុតស៊ី Tutsi នៅក្នុងប្រទេសក្រោយឆ្នាំ១៩៩៤ នោះឡើយ ។ តើការព្រួយបារម្ភរបស់ប្រទេសបារាំង ចំពោះបញ្ហាយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា អាចចាកឆ្ងាយពីការប៉ុនប៉ងប្រើភាសាខ្មែរនិងបារាំងជាផ្លូវការក្នុងតុលាការដែរឬទេ?

នៅស្របពេលគ្នានេះដែរសហរដ្ឋអាមេរិក ដែលធ្លាប់តែបានលះបង់ធនធានសំខាន់ៗ ព្រមទាំងវោហាសាស្ត្រដើម្បីស្វែងរកយុត្តិធម៌កាលពីឆ្នាំថ្មីៗកន្លងទៅនេះ បានបាត់មុខនិងត្រូវវិវក់ដោយសារតែសង្គ្រាមនៅកូសូវ៉ូ ក៏ដូចជាដោយការព្រួយបារម្ភចំពោះនយោបាយក្នុងប្រទេសរបស់ខ្លួន ។ ដោយក្តីសង្ឃឹមជាមួយនឹងឯកអគ្គរដ្ឋទូតអាមេរិកថ្មី និងឯកអគ្គរដ្ឋទូតថ្មីនិងខ្លាំងប្រចាំនៅអង្គការសហប្រជាជាតិនោះ ការដឹកនាំដែលគ្មានអ្វីគួរឲ្យចាប់អារម្មណ៍ និងគ្មានឥទ្ធិពលរបស់សហរដ្ឋអាមេរិកចំពោះបញ្ហានេះនឹងទទួលបាននូវការលើកស្ទួយ ដែលជាការចាំបាច់យ៉ាងខ្លាំងនោះជាមិនខានឡើយ ។

ប៉ុន្តែ តើទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាអាចជៀសផុតពីការបរាជ័យ ក្នុងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិដែរឬទេ ក្នុងការនាំយកពួកខ្មែរក្រហមមកវិនិច្ឆ័យទោស? ការដឹកនាំដែលខ្លាំង មានលក្ខណៈច្នៃប្រឌិតនិងមានគោលការណ៍ច្បាស់លាស់របស់សហគមន៍អន្តរជាតិ គឺពិតជាតម្រូវការយ៉ាងបន្ទាន់ចំពោះបញ្ហាយុត្តិធម៌ក្នុងប្រទេសកម្ពុជាពីព្រោះថ្នាក់ដឹកនាំកម្ពុជា ហាក់បីដូចជាគ្មានសមត្ថភាពទាំងក្នុងការទប់ទល់និង ការដេញដោលស្តីអំពីបញ្ហាក្នុងប្រទេសរបស់ខ្លួនឬក្នុងការពន្យល់ឲ្យពិភពលោកបានដឹងអំពីមូលហេតុដែលពួកខ្លួននៅតែបន្តការស្ទាក់ស្ទើរតទៅទៀត ។ សម្តេច ហ៊ុន សែន មានប្រតិកម្មគួរឲ្យសរសើរខាងវោហាសាស្ត្រ នៅពេលដែលមានបញ្ហាយុត្តិធម៌ខ្មែរក្រហម ។ ប៉ុន្តែកាលពីពេលថ្មីៗនេះ បើយោងទៅតាមមតិទូទៅមួយក្នុងសហគមន៍អន្តរជាតិបានឲ្យដឹងថាសម្តេច ហ៊ុន សែន ហាក់បីដូចជាបាត់បង់នូវគុណធម៌ចំពោះបញ្ហានេះទៅវិញ ។

ឥឡូវនេះ ដោយសារតែពេលវេលានៃចំណាត់ការរឿងយុត្តិធម៌អំពើប្រល័យពូជសាសន៍បានមកដល់ អៀង សារី បែរជាប្រឆាំងតបទាំងមិនគួរឲ្យជឿទៅវិញ ដោយយកអាវុធដែលកូនចៅខ្មែរក្រហមរបស់ខ្លួនប៉ុនប៉ងលុបបំបាត់មកប្រើគឺ

«លុយ» នេះឯង ។ ហើយការវាយបកត្រឡប់មកវិញដ៏គួរឲ្យភ្ញាក់ផ្អើលដោយទឹកប្រាក់របស់ខ្មែរក្រហមនោះ ហាក់ដូចជាបានធ្វើឲ្យរដ្ឋាភិបាលភ្លេចខ្លួនលែងយកចិត្តទុកដាក់ទៅលើរឿងនេះទៅហើយ ។ វាដូចដែលកម្មាភិបាលគណបក្សប្រជាជនកម្ពុជាដើមចាស់ធ្លាប់បានប្រាប់ខ្ញុំទាំងមិនសប្បាយចិត្តដូច្នោះដែរអំពីរឿងនេះ នៅពេលដែលខ្ញុំបានសួរពីមូលហេតុនៃការមិនបានដើរតាមដំណើរជាប្រវត្តិសាស្ត្រ ចំពោះយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ ។ វាអាចជាបញ្ហា «នៃការដះទឹកលុយ» ។ តើសម្តេច ហ៊ុន សែន អាចមានលទ្ធភាពដកខ្លួនចេញពីសំណាញ់នៃសិទ្ធិអំណាចបញ្ញាដែលចងរឹតរបបរបស់គាត់កាន់តែតឹង ទៅនឹងអតីតស្ថានការណ៍នៅប៉ៃលិនដែរឬទេ?

ទាំងនេះគឺជាសំណួរស្តីអំពីមរតកខ្មែរក្រហម ដែលកំពុងតែត្រូវបានសួរសព្វថ្ងៃ ។ ប្រជាជនកម្ពុជាព្រមទាំងសហគមន៍អន្តរជាតិ ទន្ទឹងរង់ចាំចម្លើយទាំងនេះដោយអន្ទះសាបំផុត ។

**ក្រេក អ៊ិចខេសាន់**

---

# បងស្រីខ្ញុំ

ជានិច្ចកាលជាពិសេស នៅថ្ងៃប្រារព្ធបុណ្យភ្ជុំបិណ្ឌជារៀងរាល់ឆ្នាំចូលមកដល់ ខ្ញុំតែងតែនឹកឃើញបងស្រីបង្អស់របស់ខ្ញុំ ដែលបានស្លាប់ដោយអត់អាហារក្នុងរបបខ្មែរក្រហម ។ ប្តី



របស់បងស្រីខ្ញុំម្នាក់នេះត្រូវបានកម្មាភិបាលខ្មែរក្រហមយកទៅសម្លាប់ចោល ដោយសារតែគាត់ធ្លាប់ធ្វើជាគ្រូបង្រៀន ។ មិនតែប៉ុណ្ណោះកូនស្រីតូច និងកូនប្រុសពៅរបស់បងស្រីខ្ញុំក៏ស្លាប់ដោយអត់អាហារក្នុងរបបនេះដែរ ។

ប្រជាជនខ្មែរមានជំនឿថា បុណ្យភ្ជុំបិណ្ឌ គឺជាពេលដែលព្រលឹងរបស់អ្នកដែលបានស្លាប់ទៅ ត្រូវបានយមរាជ ឬទេវតា ដោះលែងឲ្យមានសេរីភាពឲ្យមកសាកសួរសុខទុក្ខជួបជុំបងប្អូន ។ រីឯបងប្អូនសាច់ញាតិត្រូវធ្វើម្ហូបអាហារ និងតង្វាយគ្រឿងសក្ការបូជាផ្សេងៗដល់ព្រលឹងបុព្វបុរសដូនតាទាំងអស់នេះដើម្បីបានទទួលអាហារឲ្យបានគ្រប់គ្រាន់ ។ ជំនឿទៀតថាព្រលឹងទាំងនោះនឹងដើរវិលវល់ ចំនួនប្រាំពីរវត្តស្វែងរកម្ហូបអាហារ ។

ខ្ញុំតែងតែគិតថា ព្រលឹងបងស្រីរបស់ខ្ញុំបានមកជ្រកនៅយ៉ាងសុខសាន្តជាមួយគ្រួសាររបស់ខ្ញុំ នៅក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌ ។ ហើយខ្ញុំនៅតែមានអារម្មណ៍ថា បងស្រីរបស់ខ្ញុំ គាត់នៅតែស្រេកឃ្លានអាហារខ្លាំងណាស់ ។ ខ្ញុំចង់ឲ្យបាយគាត់ទទួលទានឲ្យបានឆ្អែត ។ អារម្មណ៍ខ្ញុំតែងតែរំជួលយ៉ាងខ្លាំង នៅពេលដែលឃើញមនុស្សម្នាទៅវត្តមានចានស្រាក់ ដាក់ម្ហូប ផ្លែឈើនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ ហើយខ្ញុំតែងមានអារម្មណ៍ខ្សឹកខ្សួលក្នុងជម្រៅចិត្ត ដោយសារការអាណិតអាសូរដែលខ្ញុំមានចំពោះបងស្រីរបស់ខ្ញុំ និងអ្នកក្រីក្រ ។ អ្វីដែលធ្វើឲ្យខ្ញុំកាន់តែសោកសង្រេងជាងនេះទៅទៀតនោះគឺថាកូនស្រីច្បងរបស់បងស្រីខ្ញុំ ដែលរស់នៅមកទល់សព្វថ្ងៃនេះ ត្រូវកំព្រា គ្មានឪពុកម្តាយតាំងពីកុមារភាព ។ ក្មួយស្រីរបស់ខ្ញុំនេះមានឈ្មោះថា អ៊ុង ធារី ។ ក្មួយស្រីរបស់ខ្ញុំឥឡូវមានអាយុ ២៩ឆ្នាំ ហើយមានប្តី និងកូន២នាក់ទៀតផង ។ ក្មួយស្រីរបស់ខ្ញុំតែងតែសួរខ្ញុំថា ហេតុអ្វីបានជាពួកខ្មែរក្រហមសាហាវខ្លាំងម្ល៉េះ រហូតដល់ទៅបង្អត់អាហារសូម្បីតែល្មមគ្រប់គ្រាន់ម្តាយរបស់វាអាចរស់បាន ។ សំណួររបស់ក្មួយស្រីរបស់ខ្ញុំក៏មិនខុសគ្នាទៅនឹងសំណួរដែលបងប្អូនជនរួមជាតិកម្ពុជារាប់ពាន់នាក់ដែលធ្លាប់សួរខ្ញុំជាទូទៅនោះទេ ជាពិសេសនៅពេលដែលខ្ញុំចុះទៅបំពេញបេសកកម្មនៅតាមស្រុកភូមិដើម្បីធ្វើការស្រាវជ្រាវប្រមូលភស្តុតាង និងសម្ភាសន៍សាក្សីនានាទាក់ទងនឹងឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហមដែលបានលេបត្របាក់យកជីវិតប្រជាជនកម្ពុជាអស់ជិត២លាននាក់ ។ នៅតាមភូមិស្រុក អ្នកភូមិចេះតែបន្តដំណើរជីវិតរបស់ខ្លួនជាធម្មតា ក៏ប៉ុន្តែអតីតកាលដ៏ជូរចត់ក្នុងរបបខ្មែរក្រហមនៅជិតជាប់ក្នុងខ្លួនអ្នកភូមិនៅឡើយ ។ ជនរងគ្រោះកម្ពុជាក៏ដូចជារូបខ្ញុំផ្ទាល់ត្រូវការចម្លើយមួយចំពោះអ្វីដែលបានកើតឡើងចំពោះបងប្អូនសាច់សារលោហិតរបស់ខ្លួននៅក្នុងរបបខ្មែរក្រហម ។

តុលាការឯករាជ្យត្រឹមត្រូវ និង យុត្តិធម៌មួយត្រូវតែបង្កើតឡើងដើម្បីផ្តល់ចម្លើយនេះ ដល់បងប្អូនមាមីងនៅតាមបណ្តាភូមិស្រុក ។ ការផ្តល់ចម្លើយនេះ សំខាន់មិនត្រឹមតែជាការផ្សះផ្សាជាតិ និងរបួសផ្លូវចិត្តរបស់បងប្អូនមីងមាទាំងនោះឲ្យបានស្រាកស្រាន្តពីអតីតកាលដ៏ជូរចត់របស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការជួយប្រែក្លាយសង្គមកម្ពុជាឲ្យក្លាយទៅជានីតិរដ្ឋពិតប្រាកដមួយទៀតផង ។ ប្រទេសកម្ពុជាពិតជាពុំអាចទទួលបាននូវស្ថេរភាព សុភមង្គល និងការអភិវឌ្ឍន៍ពិតប្រាកដ លុះត្រាតែគោលដៅនៃតុលាការមួយអាចសម្រេចបានដោយជោគជ័យលើបញ្ហាយុត្តិធម៌ប្រល័យពូជសាសន៍ ។

ព្រលឹងរបស់បងស្រីរបស់ខ្ញុំ និងបងប្អូនរបស់ខ្ញុំជាច្រើនទៀត ព្រមទាំងប្រជាជនខ្មែររាប់លាននាក់ដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហមបានរង់ចាំអស់រយៈពេលជាង២០ឆ្នាំមកហើយមកទល់នឹងថ្ងៃនេះ ដើម្បីឲ្យមានតុលាការត្រឹមត្រូវមួយ ។

បុណ្យភ្ជុំបិណ្ឌនៃចុងសតវត្សរ៍ទី២០កន្លងទៅនេះមានលក្ខណៈពិសេសបំផុត ដោយសារថាពិធីបុណ្យនេះកត់សម្គាល់ពីសក្ខីកម្មនៃការប្រែក្លាយកម្ពុជាមួយឆ្ពោះទៅរកការបង្រួបបង្រួមជាតិ និងការស្វែងរកយុត្តិធម៌ពិតប្រាកដចំពោះជនរងគ្រោះនៃរបបខ្មែរក្រហមនៅក្នុងសហស្សវត្សរ៍ថ្មី ។ ការខកខានពុំបានផ្តល់តុលាការមួយដែលមានសមត្ថភាព និងមិនលម្អៀងដល់ជនរងគ្រោះដើម្បីរកយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍ គឺពុំមានលក្ខណៈខុសប្លែកគ្នាពីការប្រគេនចានស្រាក់ទទេដែលគ្មានម្ហូប

ដល់ព្រះសង្ឃឡើយ ។ នោះគឺជាការក្បត់នឹងច្បាប់ទម្លាប់របស់ប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាស្ទើរតែទាំងអស់នៅក្នុងប្រទេស ក៏ដូចជានៅក្រៅប្រទេស គឺជាជនរងគ្រោះនៃរបបខ្មែរក្រហម ហើយចាំបាច់ត្រូវធ្វើការរួមគ្នាជាធ្លុងមួយក្នុងការជួយរកយុត្តិធម៌ជូនកម្ពុជា និងមនុស្សជាតិទូទៅ ។ **ឆាំង យុ**

---

# ផ្ញើមកពូរបស់ខ្ញុំ

ជាអកុសល ការគិតគូររបស់ខ្ញុំចំពោះរឿងខ្មែរក្រហម ពេលខ្លះដូចជាស្រពេចស្រពិល ហើយជួនកាលទៀតដូចជាច្បាស់ជ្រលពេកតាមរបៀបដែលខ្ញុំសម្លឹងមើលបញ្ហាផ្សេងៗដែលកើតឡើងក្នុងពិភពលោកយើងនេះ ។ ខ្ញុំជឿថា ប្រទេសនីមួយៗមានប្រវត្តិសោកនាដកម្មដ៏ឈឺចាប់របស់ខ្លួន ។ ជាឧទាហរណ៍ សហរដ្ឋអាមេរិកមានអំពើទាសភាពពីអតីតកាល ជនជាតិជ្វីហ្វ ជួបប្រទះនូវការសម្លាប់បំផុតពូជ ហើយយើងជាប្រជាជនកម្ពុជាក៏ជួបប្រទះនូវរឿងដូច្នេះដែរ ។ ខ្ញុំជឿថា អំពើដែលពួកខ្មែរក្រហមធ្វើគឺដូចគ្នាទៅនឹងការសម្លាប់បំផុតពូជ ដែលជនជាតិជ្វីហ្វបានទទួលរងកាលពីអំឡុងសង្គ្រាមលោកលើកទី២ ។ ដូច្នេះប្រហែលជាកង់ប្រវត្តិសាស្ត្រពិតជាវិលកើតម្តងហើយម្តងទៀត ។ ទោះបីជាយើងរស់នៅទីណាមួយក៏ដោយក្នុងពិភពលោកនេះ ព្រឹត្តិការណ៍បែបនេះអាចកើតឡើងគ្រប់ពេលវេលា ។ យើងសាកស្រមៃមើលឃើញថា ប្រសិនបើមនុស្សគ្រប់គ្នាមានការឯកភាពគ្នាទាំងអស់លើពិភពលោក យើងមិនដឹងជាមានមនុស្សណែនណាន់តាន់តាប់ប៉ុនណានោះទេ ។ ជួនកាលខ្ញុំឆ្ងល់ថាប្រសិនបើពុំមានសង្គ្រាម មិនដឹងជាពិភពលោកយើងទៅជាបែបណា ហើយប្រសិនបើឪពុក-ម្តាយរបស់ខ្ញុំនៅរស់ ព្រមទាំងប្អូនប្រុស ប្អូនស្រីរបស់ខ្ញុំទៀតផងនោះ មិនដឹងជាជីវិតខ្ញុំខុសប្លែកពីពេលនេះប៉ុណ្ណានោះទេ ។ កូនស្រីរបស់ខ្ញុំឈ្មោះ ចឌីន (Jordyn) ជួនកាលបានសួរខ្ញុំថាហេតុអ្វីក៏ខ្ញុំគ្មានឪពុក-ម្តាយ ដូចឪពុក-ម្តាយរបស់មិត្តភក្តិរបស់វា ។ នៅពេលកូនស្រីខ្ញុំសួរដូច្នេះ ខ្ញុំបានព្យាយាមពន្យល់វា អំពីអ្វីដែលបានកើតឡើងចំពោះជីដូន-ជីតារបស់វា ប៉ុន្តែខ្ញុំមានការពិបាកនឹងពន្យល់វាណាស់ ។ ចំពោះខ្ញុំៗសោកស្តាយណាស់ដោយដឹងថា កូនប្រុស-ស្រីរបស់ខ្ញុំពុំមានឱកាសនឹងបានជួបមុខឪពុក-ម្តាយរបស់ខ្ញុំជារៀងរហូត ។ ពូពិតជាដឹងថារឿងដ៏សោកសង្រេងបំផុតចំពោះខ្ញុំនោះគឺជាអ្វីហើយ ។ តើមែនដែរឬទេ? ខ្ញុំនៅចាំបានអំពីឪពុក-ម្តាយរបស់ខ្ញុំព្រាលៗដោយខ្លួនឯង ។ នៅពេលដែលឪពុក-ម្តាយរបស់ខ្ញុំស្លាប់ ខ្ញុំអាយុប្រហែល៥ឆ្នាំ ។ ខ្ញុំបានគិតរឿងរ៉ាវដ៏ចម្លែកមួយ នៅពេលដែលខ្ញុំនឹកឃើញពេលដែលឪពុក-ម្តាយរបស់ខ្ញុំ ត្រូវបានអ្នកស្រុកយកទៅកប់ ។ ខ្ញុំចេះតែគិត ឬប្រហែលជាការស្រមើស្រមៃក៏មិនដឹងថា ឪពុក-ម្តាយរបស់ខ្ញុំ កំពុងធ្វើពុតជាស្លាប់ដើម្បីឲ្យអ្នកស្រុកកប់ពួកគាត់ ហើយបន្ទាប់មកឪពុក-ម្តាយរបស់ខ្ញុំនឹងជីករូងក្រោមដីដែលអាចនាំពួកគាត់ឲ្យទៅដល់ពិភពមួយទៀតហើយ ពួកគាត់នឹងត្រឡប់មកយកខ្ញុំ និងប្អូនស្រីរបស់ខ្ញុំទៅតាមក្រោយ ។ ចម្លែកណាស់មែនទេ?

ចំពោះខ្ញុំៗជឿថា ការរកយុត្តិធម៌ គឺមិនគ្រប់គ្រាន់សម្រាប់សងនូវអ្វីដែលបានកើតឡើងចំពោះគ្រួសាររបស់ខ្ញុំបានឡើយ ។ ក្នុងពិភពលោកនេះ ពុំមានយុត្តិធម៌ណាមួយអាចនាំឪពុក-ម្តាយ បងប្អូនរបស់ខ្ញុំត្រឡប់មកវិញបានទេ ។ យើងគួរតែសួរខ្លួនឯងថា តើធ្វើយ៉ាងដូចម្តេច ក្នុងនាមជាមនុស្សជាតិដើម្បីទប់ស្កាត់សោកនាដកម្មបែបនេះ កុំឲ្យកើតឡើងជាថ្មីម្តងទៀត ។ **ពីក្មួយសម្លាញ់របស់ពូ អ៊ុង ធាវី**

**សេចក្តីជូនដំណឹងចំពោះមិត្តអ្នកអាន**

ប្រសិនបើអស់លោកអ្នកត្រូវការផ្សាយពត៌មានស្វែងរកក្រុមគ្រួសារ ឬមិត្តភក្តិដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហមសូមមេត្តាផ្ញើលិខិត និងរូបថតប្រសិនបើមានមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ ។

# ឆ្នាំថ្មីស្រែថ្មី "បទបាសក្ស" (បាសាក់)

ដំនោរត្រជាក់ធ្លាក់ពីជើង
លឿងប្រាលដូចមាសគ្មានស្មោកស្មៅ
ផ្លែញឹកហើយថ្លោសក្អួរវែងៗ
ល្អស្មើយ៉ាងនេះគ្រប់ប្រកល្ហក

មិត្តអើយស្រូវយើងទុំផ្អិនផ្អោ
ឃើញភ្ញាមកក់ក្តៅគ្មានខានខក ។
ឱនទានហើយវែងរឹតគ្មានស្អក
ហើយការស្ទូងដកបានច្រើនណាស់ ។

យើងប្រូតបោកបែនឲ្យរួចឆាប់
មិនឲ្យទុំជ្រុះប្រែប្តូរផ្លាស់
កម្លាំងរាប់រយពាន់យើងប្រមូល
សម្ភារៈចាំបាច់ត្រៀមគ្រប់គ្រាន់

ប្រញាប់កើបផលឲ្យរហ័ស
ក្រឡាស់ខ្ទូចខាតប្រូតមិនទាន់ ។
បញ្ចូលរួមរួតយ៉ាងរួសរាន់
បោកបែនបញ្ជូនដឹកទុកដាក់ ។

លែងចោទរឿងសើមរឿងទុំញួស
កណ្តៀវខានកោរទោះភ្លៀងធ្លាក់
ចំណាំងកាត់វែងក្អួរសំយ៉ុង
បោករួចគ្រាប់ជ្រុះគ្មានសល់អី

រឿងហួសប្រូតកាត់ទាំងស៊ើរស្ទុះ
មិនឲ្យអួលអាក់យើងលៃលក ។
ស្មើចុងកណ្តាប់មិនខ្ទេចខ្ទី
បោសដីបាតលានអស់ហ្មត់ហ្មង ។

ខ្ញុំប្រូតមិត្តបោកមីងរោយបក់
ប្អូនៗកុមារហាលត្រសង
គ្រប់ផ្នែកសម្រុកព្រមៗគ្នា
តែក្នុង១វគ្គចប់សព្វមុខ

ពូឆក់ឱកាសដឹកតែម្តង
បងស្រ្តីកើបយករាប់ទុក ។
ជំរុញការងារក្តៅគគុក
ដោកក្រុងជង្រុកពេញហូរហៀរ ។

យើងខ្ញុំមកផ្តើមត្រៀមរៀបចំ
ទំនប់ប្រឡាយស្រះនានា
ត្រៀមធ្វើចំការថែហែកដី
ខ្វាត់ខ្វែងពាសពេញល្អត្រចង់

បង្ហុំបន្ថែមជីពូជធារ
ការងារស្រែប្រាំងគ្មានបង្អង់ ។
ហើយលើកភ្លឺថ្មីធំខ្ពស់ត្រង់
តម្រង់តាមទិសតម្លើងផល ។

៣តោនមធ្យម១ហិកតា
យើងប្រូតរួចឆាប់មិនស្ងួវខ្វល់
លៃឲ្យឆ្នាំថ្មីលេចស្រែថ្មី
កម្ពុជាសំបូរចំរើនសប្បាយ

វស្សាខាងមុខនេះត្រូវផ្តល់
ត្រៀមគ្មានសល់សព្វសុសសាយ ។
ទិដ្ឋភាពប្រិមប្រិយធានាឆាយ
ប្រទេសទាំងឡាយយកគំរូ ។

**កត់ត្រាចងក្រងជាឯកសារ**

**សើ សាយ្យាណា**

